# រាជបណ្ឌិត្យសភាកម្ពុជា

## អបអរសាទរ

## ពិធីថ្វាយនិងប្រគេនគោរមងារកិត្តិឧទ្ទេសបណ្ឌិត និងសញ្ញាបត្រកិត្តិបណ្ឌិតនៃរាជបណ្ឌិត្យសភាកម្ពុជា



## ដល់មន្ត្រីសង្ឃជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជា

*រាជបណ្ឌិត្យសភាកម្ពុជា ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៣*



## បុព្វកថា

ក្រុមបណ្ឌិតសភាចារ្យនៃរាជបណ្ឌិត្យសភាកម្ពុជា បានពិនិត្យមើលលើស្នាព្រះហស្ត និងស្នាដៃដ៏ច្រើនសន្ធឹកសន្ធាប់ របស់ជយលាភីទាំង៩អង្គ ក៏ដូចឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត គាត ឈន់ ដែរដែលលោកទាំងអស់សុទ្ធតែបានចូលរួមចំណែកយ៉ាងសកម្មក្នុងការកសាង អភិវឌ្ឍន៍ និងទ្រទ្រង់នូវសមិទ្ធផលធំៗ ទាំងក្នុងវិស័យព្រះពុទ្ធសាសនា និងក្នុងវិស័យសេដ្ឋកិច្ច-សង្គម ក្រោមមាគ៌ាដឹកនាំដ៏ឈ្លាសវៃរបស់ សម្តេចអគ្គមហាសេនាបតីតេជោបណ្ឌិតសភាចារ្យ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាប្រធានកិត្តិយសនៃក្រុម បណ្ឌិតសភាចារ្យ ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រីនិង រដ្ឋមន្ត្រីនៃទីស្តីការគណៈរដ្ឋមន្ត្រី ជាប្រធាន ក្រុមបណ្ឌិតសភាចារ្យ ខ្ញុំជាអនុប្រធានអចិន្ត្រៃយ៍ ហេតុដូចនេះហើយទើប សម្រេចប្រគល់គោរមងារកិត្តិឧទ្ទេសបណ្ឌិត ថ្វាយសម្តេចអគ្គមហាសង្ឃរាជាធិបតី **ទេព វង្ស** ក្រោមព្រះរាជក្រឹត្យ នស/រកត/០៩១២/៨៣៥ សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី **បួរ គ្រី** ក្រោមព្រះរាជក្រឹត្យ នស/រកត/០៩១២/៨៣៦ និងសម្តេចព្រះមហាសុមេធាធិបតី**នន្ទ ង៉ែត** ក្រោមព្រះរាជក្រឹត្យ នស/រកត/០៩១២/៨៣៧ សញ្ញាបត្រកិត្តិបណ្ឌិតប្រគេនសម្តេចព្រះធម្មលិខិត **លាស់ ឡាយ** ប្រធានថេរសភាព្រះពុទ្ធសាសនា និងសញ្ញាបត្រកិត្តិបណ្ឌិតប្រគេនសម្តេចព្រះពោធិវង្ស **អ៊ំ លីមហេង**, សម្តេចព្រះវន្ន័ត **ណយ ច្រឹក**, សម្តេចព្រះឧត្តមបញ្ញា **ដួង ផង់**, សម្តេចឧត្តមវង្សា **មួង រ៉ា** និងព្រះមុនីកោសល **ហ៊ុល សុវណ្ណ**។

គោរមងារកិត្តិឧទ្ទេសបណ្ឌិត កិត្តិសេដ្ឋាបណ្ឌិតព្រមទាំងសញ្ញាបត្រកិត្តិបណ្ឌិត ជាសញ្ញាបត្រកិត្តិយសដ៏ ឧត្តុង្គឧត្តមរបស់រាជបណ្ឌិត្យ

សភាកម្ពុជា។ គោរមងារនិងសញ្ញាបត្រនេះស្នើប្រគល់ ជូនឥស្សរជនឬបញ្ញជន ដែលមានគុណបំណាច់ និងមានស្នាដៃជាប្រយោជន៍ចំពោះជាតិមាតុភូមិក្នុង ការអភិវឌ្ឍន៍នូវសង្គម វប្បធម៌ សាសនា និងសេដ្ឋកិច្ចជាតិព្រមទាំងជាបុគ្គលដែលបានការទទួលស្គាល់ពីមហាជនថែមទៀត។

រាជបណ្ឌិត្យសភាកម្ពុជា ក្នុងរយៈពេលអណត្តិរបស់ខ្លួនមកទល់ពេលនេះគឺពីឆ្នាំ១៩៩៩ ដល់ ឆ្នាំ២០១៣ បាន និងជូន ថ្វាយ ប្រគេនគោរមងារបានចំនួន ៣៤ រូបហើយត្រឹមថ្ងៃនេះ ៖ (១)គោរមងារជាបណ្ឌិតសភាចារ្យ(Academician) ចំនួន ២២ នាក់ មរណភាពអស់ ៤ នាក់(២)គោរមងារជា កិត្តិព្រឹទ្ធបណ្ឌិត ចំនួន ៣ នាក់ (៣)គោរមងារជា កិត្តិឧទ្ទេសបណ្ឌិត ចំនួន៣ អង្គ (៤)គោរមងារជា កិត្តិសេដ្ឋាបណ្ឌិតចំនួន ១ នាក់ (៥) សញ្ញាបត្រកិត្តិបណ្ឌិត ចំនួន ៥ នាក់ បរទេស ៣ នាក់ ខ្មែរ ២ នាក់។

កម្រងអត្ថបទនៅក្នុងដៃឯកឧត្តម លោកជំទាវ និងអស់លោក-លោកស្រីកំពុងអាននេះរៀបចំឡើងដើម្បីអបអរសាទរពិធីមហោឡារិកដែលត្រូវបានចែកជាពីរផ្នែកធំៗ ៖

I-គោរមងារ កិត្តិឧទ្ទេសបណ្ឌិត និងសញ្ញាបត្រកិត្តិបណ្ឌិត នៃរាជបណ្ឌិត្យសភាកម្ពុជាមាន ៥ ចំណុច៖

១-សារតារសង្ខេបនៃរាជបណ្ឌិត្យសភាកម្ពុជា, ២-សមាជិកពេញសិទ្ធិនៃរាជបណ្ឌិត្យសភាកម្ពុជា, ៣-ឯកសណ្ឋានកិត្តិសេដ្ឋាបណ្ឌិត, ៤-ស្វែងយល់អំពីបណ្ឌិតកិត្តិយសលើសកលលោក, ៥-ឯកសណ្ឋាននៅប្រទេសមួយចំនួន លើសកលលោក។

II-ពិធីប្រគល់គោរមងារ កិត្តិឧទ្ទេសបណ្ឌិត និងសញ្ញាបត្រកិត្តិបណ្ឌិត នៃរាជបណ្ឌិត្យសភាកម្ពុជាថ្វាយអរិយសង្ឃឆ្នើម នៃព្រះរាជាណាចក្រកម្ពុជាមាន៤ ចំណុច ៖



១-សុន្ទរកថា ប្រធានរាជបណ្ឌិត្យសភាកម្ពុជា , ២-គុណកថានិងជីវប្រវត្តិសង្ខេបរបស់ **ជយលាភីគ្រប់រូប**, ៣-ជីវប្រវត្តិពិស្តារ , ៤-សុន្ទរកថា តំណាងជយលាភី ។

ប៉ុន្តែអាស្រ័យដោយព្រះរាជសុខភាព រាជបណ្ឌិត្យសភាកម្ពុជាបានរៀបចំពិធីអបអរសាទរថ្វាយសញ្ញាបត្រ កិត្តិបណ្ឌិតចំពោះ សម្តេចព្រះធម្មលិខិត **លាស់ ឡាយ** ប្រធានថេរសភា ព្រះពុទ្ធសាសនាកាលពីថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១១ និងនៅថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៣ កន្លងទៅនេះ ក៏បានរៀបចំពិធីអបអរសាទរថ្វាយគោរមងារកិត្តិឧទ្ទេសបណ្ឌិតចំពោះ សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី **ទេព វង្ស** សម្តេចព្រះមហាសង្ឃរាជនៃគណៈមហានិកាយ និងសម្តេចព្រះមហាសុមេធាធិបតី **នន្ទ ង៉ែត** សម្តេចព្រះសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជារួចហើយដែរ។

ជាមួយគ្នានេះ ខ្ញុំសូមជម្រាបជូនផងដែរថា សៀវភៅស្តីពីពិធីអបអរសាទរឧបនាយករដ្ឋមន្ត្រី **គាត ឈន់** ជាកិត្តិសេដ្ឋាបណ្ឌិតនៃរាជបណ្ឌិត្យសភាកម្ពុជានាពេលនេះ មាននៅក្នុងសៀវភៅមួយទៀតដែលមានទម្រង់ដូចគ្នា។

សៀវភៅតូចនេះ គឺរៀបចំឡើងដើម្បីអបអរសាទរពិធីដ៏មានអត្ថន័យជាប្រវត្តិសាស្ត្រនាពេលនេះ។

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៣

**ប្រធានរាជបណ្ឌិត្យសភាកម្ពុជា**

**បណ្ឌិតសភាចារ្យ ខ្លូត ធីតា**

## អារម្ភកថា

បន្ទាប់ពីបានឆ្លងកាត់ព្យុះភ្លៀងនៃមហាវិនាសកម្ម ដោយសារសង្គ្រាមរបបប្រល័យពូជសាសន៍ ទុរគតភាពគ្រប់បែបយ៉ាង ដែលបានយាយីដល់ការរស់នៅរបស់ប្រជាជនកម្ពុជា អស់ជាច្រើនទសវត្សរ៍មកហើយនោះ ពេលនេះកម្ពុជាកំពុងតែប្រែមុខមាត់ ថ្មីហើយកាន់តែប្រសើរឡើង ទាំងផ្នែកសម្ភារៈ ស្មារតីនិងចំណេះដឹង។

ជាការពិតណាស់សព្វថ្ងៃនេះ កម្ពុជាក្រោមការដឹកនាំរបស់សម្តេចអគ្គមហាសេនាបតីតេជោបណ្ឌិតសភាចារ្យ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ពីសំណាក់សម្តេចធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា និងសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា បានធ្វើឱ្យសង្គមជាតិកម្ពុជាកាន់តែពង្រឹងភាពជាប្រទេសស៊ីវិល័យមួយនៅលើសកលលោក។

មានន័យថា ប្រជាជនកម្ពុជាកំពុងតែត្រូវបានពង្រឹងលើគ្រប់វិស័យ រស់នៅដោយភាពថ្លៃថ្នូរ ស័ក្តិសមជាពលរដ្ឋនៃប្រទេសជាតិមួយដែលមានវប្បធម៌ អរិយធម៌ខ្ពង់ខ្ពស់។ នេះហើយជាការវិវត្តមួយដែលបញ្ចៀសសោកនាដកម្មក្នុងអតីតកាល កុំឱ្យកើតឡើងជាថ្មីម្តងទៀត។ ប៉ុន្តែយើងត្រូវតែទទួលស្គាល់ដែរថា យើងកំពុងស្ថិតនៅក្នុងស្ថានភាពមួយ មិនទាន់រឹងមាំនៅឡើយទេ ទាមទារឱ្យយើងទាំងអស់គ្នាជាពលរដ្ឋខ្មែរគ្រប់រូប ត្រូវតែប្រឹងប្រែងឱ្យបានខ្លាំងក្លាថែមទៀត ដើម្បីលើកស្ទួយប្រទេសជាតិយើងឱ្យរីកចម្រើនបន្ថែមទៀតលើគ្រប់វិស័យ ឈានឆ្ពោះទៅរកភាពរឹងមាំដូចអារ្យប្រទេសលើសកលលោក។



មូលអត្ថន័យនៃខ្លឹមសារក្នុងសៀវភៅនេះ គឺខ្ញុំចង់បង្ហាញអំពីកម្រិតជោគជ័យរបស់ជយលាភី ព្រះកិត្តិនាម ព្រះកិត្តិយស ក៏ដូចជាប្រវត្តិខ្លះៗនៃរាជបណ្ឌិត្យសភាកម្ពុជាផងដែររួមមាន ៖

១-សាវតារសង្ខេបនៃរាជបណ្ឌិត្យសភាកម្ពុជា

២-សមាជិកបណ្ឌិតសភាពេញសិទ្ធិ(បណ្ឌិតសភាចារ្យ) នៃរាជបណ្ឌិត្យសភាកម្ពុជា

៣-ឯកសណ្ឋានអាវកិត្តិបណ្ឌិតនៃរាជបណ្ឌិត្យសភាកម្ពុជា

៤-កម្រិតបណ្ឌិតកិត្តិយសលើសកលលោក

៥-ឯកសណ្ឋាននៅប្រទេសមួយចំនួនលើសកលលោក

គោរមងារកិត្តិឧទ្ទេសបណ្ឌិត និង កិត្តិសេដ្ឋាបណ្ឌិត ព្រមទាំងសញ្ញាបត្រកិត្តិបណ្ឌិត ជាគោរមងារនិងសញ្ញាបត្រកិត្តិយសដ៏ឧត្តុង្គឧត្តមរបស់រាជបណ្ឌិត្យសភាកម្ពុជា។ គោរមងារនិងសញ្ញាបត្រនេះស្នើប្រគល់ជូនឥស្សរជន ឬ បញ្ញជនដែលមានគុណបំណាច់និងស្នាដៃជាប្រយោជន៍ចំពោះជាតិមាតុភូមិ ក្នុងការអភិវឌ្ឍនូវសង្គមវប្បធម៌ សាសនានិងសេដ្ឋកិច្ចជាតិ ព្រមទាំងជាបុគ្គលដែលបានការទទួលស្គាល់ជាពីមហាជនថែមទៀត។ គោរមងារនិងសញ្ញាបត្រនេះ ត្រូវបានសម្រេច អនុម័តដោយក្រុមបណ្ឌិតសភាចារ្យនៃរាជបណ្ឌិត្យសភាកម្ពុជាដែលមានសម្តេចតេជោបណ្ឌិតសភាចារ្យ **ហ៊ុន សែន** ជាប្រធានកិត្តិយស ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ជាប្រធាន និងនាងខ្ញុំប្រធានរាជបណ្ឌិត្យសភាកម្ពុជា ជាអនុប្រធានអចិន្ត្រៃយ៍ តាមការស្នើសុំរបស់ប្រធានរាជបណ្ឌិត្យសភាកម្ពុជា ដោយមានការឯកភាពពាក្យពេចន៍ពីក្រុមប្រឹក្សាជាតិភាសាខ្មែរផងដែរ។

រាជបណ្ឌិត្យសភាកម្ពុជា បានចុះកិច្ចសហប្រតិបត្តិការជាមួយប្រទេសអាស៊ានជាច្រើន និងប្រទេសអឺរ៉ុបមួយចំនួនទៀត។ រាជបណ្ឌិត្យសភាកម្ពុជាអាស៊ាននៅចុងឆ្នាំ២០១២ គឺចុះនៅទីក្រុងហ្សាកាតាប្រទេសឥណ្ឌូណេស៊ី។ ចំណែប្រទេសភូមានិងឡាវមិនទាន់បង្កើតបណ្ឌិតសភាវិទ្យាសាស្ត្រនេះទេ ហើយក៏មិនទាន់ចុះកិច្ចសហប្រតិបត្តិការបណ្ឌិតសភាវិទ្យាសាស្ត្រដែរ។ រាជបណ្ឌិត្យសភាកម្ពុជា បានចុះកិច្ចសហប្រតិបត្តិ-ការចំនួន៣ បណ្ឌិតសភាប្រទេសចិន គឺទី១ នៅទីក្រុងប៉េងកាំង ទី២ នៅទីក្រុងសៀងហៃ ទី៣ នៅខេត្តជាំងស៊ីសាកលវិទ្យាល័យជីជាំង ទី៤ នៅបណ្ឌិតសភាប្រទេសវៀតណាមខាងជើង ទី៥ នៅបណ្ឌិតសភា-ប្រទេសវៀតណាមខាងត្បូង ទី៦ នៅបណ្ឌិតសភាកូរ៉េខាងត្បូង ទី៧ បណ្ឌិតសភាម៉ាឡេស៊ី ទី៨ បណ្ឌិតសភាសូវៀត ទី៩ នៅបណ្ឌិតសភាឥណ្ឌូណេស៊ី ហើយត្រៀមចុះជាមួយឡាវនៅខែខាងមុខនេះ ជាងនេះទៅទៀតក៏បានធ្វើសមាគមវប្បធម៌ជាមួយថៃនិងត្រៀមចុះជាមួយប្រទេសដទៃទៀតជាបន្តបន្ទាប់។ ទាំងនេះគឺត្រូវបានទទួលសិទ្ធិប្រទានពីរាជរដ្ឋាភិបាលទាំងអស់។

ជាងនេះទៅទៀត ការបង្កើតរាជបណ្ឌិត្យសភាកម្ពុជាឡើងវិញនេះជាការសម្រេចចិត្តខាងនយោបាយ និង ចក្ខុវិស័យដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាល យើងដែលមានសម្តេចអគ្គមហាសេនាបតីតេជោបណ្ឌិតសភាចារ្យ **ហ៊ុន សែន** ជាប្រមុខដឹកនាំ ក្នុងការប្រមូលផ្តុំធនធានបញ្ញាញាណជាន់ខ្ពស់របស់ជាតិនិងប្រើប្រាស់ធនធានទាំងនោះសម្រាប់ការកសាងនិងការអភិវឌ្ឍប្រទេសជាតិ។ ក្នុងឋានៈជាស្ថាប័នស្រាវជ្រាវជាន់ខ្ពស់របស់ជាតិ រាជបណ្ឌិត្យសភាកម្ពុជាត្រូវបានរាជរដ្ឋាភិបាល



ប្រគល់បេសកកម្មឱ្យអភិវឌ្ឍកម្លាំងបញ្ញាញាណនៃប្រជាជាតិកម្ពុជា ព្រមទាំងលើកទឹកចិត្តណែនាំគ្រប់គ្រង ពង្រីកការស្រាវជ្រាវគ្រប់មុខជំនាញនៅក្នុងប្រទេសនិងស្ថាបនាទំនាក់ទំនងសហប្រតិបត្តិការផ្នែកស្រាវជ្រាវជាមួយស្ថាប័នជាតិនិងអន្តរជាតិ ដែលមានគោលបំណងដូចគ្នា។ ក្នុងនោះ ក៏មានភារកិច្ចមួយក្នុងកិច្ចការផ្តល់គោរមងារសញ្ញាបត្រនិងគ្រឿងឥស្សរិយយសជូនដល់ឥស្សរជនឆ្នើមផងដែរ។

ខ្ញុំសូមបញ្ជាក់ថា សៀវភៅនេះបានបោះពុម្ពលើកទីមួយ នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៣ លុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៣ ខ្ញុំបានកែសម្រួលនូវចំណុចខ្វះខាត បញ្ចូលព្រះឆាយល័ក្ខ (រូបថត) ព្រមទាំងសម្រិតសម្រាំងដើម្បី បោះពុម្ពលើកទី២ ។

គោលបំណងរបស់ខ្ញុំ គឺជាការរួមចំណែកមួយយ៉ាងសំខាន់ក្នុងការលើកកម្ពស់ធនធានមនុស្សនៅក្នុងប្រទេសកម្ពុជារបស់យើង ដែលយើងកំពុងត្រូវការ ដើម្បីរួមចំណែកកសាងនិងការពារមាតុភូមិរបស់យើងឱ្យបានថ្កុំថ្កើងជារៀងរហូត។

“អ្វីៗទាំងអស់ដើម្បី ជាតិ សាសនា ព្រះមហាក្សត្រ ជាទីស្នេហារបស់យើង!”

“អ្វីៗទាំងអស់ដើម្បីវឌ្ឍនភាពមាតុភូមិកម្ពុជាជាទីស្នេហានៃយើង!”

ភ្នំពេញថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៣

ហត្ថលេខា



បណ្ឌិតសភាចារ្យ **ខ្លួត ធីតា**

# មាតិកា

**ផ្នែកទី១ ៖ គោរមងារកិត្តិឧទ្ទេសបណ្ឌិត និងសញ្ញាបត្រកិត្តិបណ្ឌិត នៃរាជបណ្ឌិត្យសភាកម្ពុជា»**

១- សាវតារសង្ខេបនៃរាជបណ្ឌិត្យសភាកម្ពុជា
២- សមាជិកពេញសិទ្ធិនៃរាជបណ្ឌិត្យសភាកម្ពុជា
៣-ឯកសណ្ឋានកិត្តិបណ្ឌិត
៤- បណ្ឌិតកិត្តិយសលើសកលលោក
៥- ឯកសណ្ឋាននៅប្រទេសមួយចំនួនលើសកលលោក

**ផ្នែកទី២ ៖ ពិធីថ្វាយគោរមងារកិត្តិឧទ្ទេសបណ្ឌិត និងសញ្ញាបត្រកិត្តិបណ្ឌិត នៃរាជបណ្ឌិត្យសភាកម្ពុជា ថ្វាយ ប្រគេនចំពោះព្រះអរិយសង្ឃជាន់ខ្ពស់ ៩ អង្គ នៃព្រះរាជាណាចក្រកម្ពុជា**

១-សុន្ទរកថាលោកជំទាវបណ្ឌិតសភាចារ្យ ខ្លួត ធីតា ប្រធានរាជបណ្ឌិត្យសភាកម្ពុជា
២-គុណកថា និងជីវប្រវត្តិសង្ខេប
៣-ជីវប្រវត្តិពិស្តារ
៤- សុន្ទរកថាតំណាងជយលាភី

*រៀបចំចងក្រងឯកសារដោយខុទ្ទកាល័យរាជបណ្ឌិត្យសភាកម្ពុជា*

ទូរស័ព្ទ ៖ ០៩៧ ៩៨០ ០០០០/០១៧ ៦០១ ៦៦៦/០៩៧ ៦៧៦ ០១៦៨
បោះពុម្ពលើកទី២ ចំនួន ៥.០០០ក្បាល



# កម្មវិធី

## អបអរសាទរ ពិធីថ្វាយគោរមងារកិត្តិឧទ្ទេសបណ្ឌិត និងសញ្ញាបត្រកិត្តិបណ្ឌិត នៃរាជបណ្ឌិត្យសភាកម្ពុជា ថ្វាយ ប្រគេនចំពោះព្រះអរិយសង្ឃជាន់ខ្ពស់ ៩ អង្គ នៃព្រះរាជាណាចក្រកម្ពុជា

វិមានសន្តិភាព ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៣

ម៉ោង ៧:៣០ ព្រឹក ភ្ញៀវកិត្តិយស អញ្ជើញដល់
ម៉ោង ៨:០០ ព្រឹក ជយលាភី យាង និមន្ត និង អញ្ជើញដល់
ម៉ោង ៨:២៥ ព្រឹក សម្តេចអគ្គមហាសេនាបតីតេជោបណ្ឌិតសភាចារ្យ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានីហ៊ុនសែន** អញ្ជើញដល់
ម៉ោង ៨:៣០ ព្រឹក ចាប់ផ្តើមកម្មវិធី

-គោរពភ្លេងជាតិនៃព្រះរាជាណាចក្រកម្ពុជា និង បទសរភញ្ញ
-សុន្ទរកថាស្វាគមន៍របស់លោកជំទាវបណ្ឌិតសភាចារ្យ **ខ្លួត ធីតា** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា
-ការអានគុណកថានិងជីវប្រវត្តិសង្ខេបរបស់ជយលាភី ដោយឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ីង ច័ន**
-ការអានព្រះរាជក្រឹត្យតែងតាំងគោរមងារថ្វាយ និងជូនជយលាភីជាកិត្តិឧទ្ទេសបណ្ឌិតនិងកិត្តិសេដ្ឋាបណ្ឌិតនៃរាជបណ្ឌិត្យសភាកម្ពុជា ដោយឯកឧត្តមបណ្ឌិតសភាចារ្យ **សំ សោភាន់**
-ស្មូតកំណាព្យៈសមិទ្ធគុណសម្តេចតេជោលើកស្ទួយបញ្ញវន្តខ្មែរ

-ពិធីថ្វាយស្លាកឈ្មោះ សញ្ញារាជបណ្ឌិត្យសភាកម្ពុជា ព្រះរាជក្រឹត្យតែងតាំងគោរមងារកិត្តិឧទ្ទេសបណ្ឌិត និងសញ្ញាបត្រកិត្តិបណ្ឌិតនៃរាជបណ្ឌិត្យសភាកម្ពុជាចំពោះ៖

.សម្តេចព្រះអភិសិរីសុគន្ធាធិបតីមហាសង្ឃរាជាធិបតី **នូន ង៉ែត** សម្តេចព្រះមហាសង្ឃរាជនៃ គណៈធម្មយុត្តិកនិកាយនៃព្រះរាជាណាចក្រកម្ពុជា

.សម្តេចព្រះពោធិវង្ស **អ៊ំ លឹមហេង** សម្តេច ព្រះសង្ឃនាយករងទី២ នៃព្រះរាជាណាចក្រកម្ពុជា

.សម្តេចព្រះវនរ័ត **ណយ ជ្រឹក** សម្តេចព្រះសង្ឃនាយករងទី៣នៃព្រះរាជាណាចក្រកម្ពុជា

.សម្តេចព្រះឧត្តមបញ្ញា **ដួង ផង់** សមាជិកថេរសភាព្រះពុទ្ធសាសនានៃព្រះរាជាណាចក្រកម្ពុជា

.សម្តេចព្រះឧត្តមវង្សា **មួង រ៉ា** លេខាថេរសភាព្រះពុទ្ធសាសនានៃព្រះរាជាណាចក្រកម្ពុជា

.ព្រះមុនីកោសល **ហ៊ុល សុវណ្ណ** សមាជិកថេរសភាព្រះពុទ្ធសាសនានៃព្រះរាជាណាចក្រកម្ពុជា

-ពិធីបំពាក់ឯកសណ្ឋានកិត្តិសេដ្ឋាបណ្ឌិត ស្លាកឈ្មោះ សញ្ញារាជបណ្ឌិត្យសភាកម្ពុជា និង ព្រះរាជក្រឹត្យតែងតាំងគោរមងារកិត្តិសេដ្ឋាបណ្ឌិតនៃរាជបណ្ឌិត្យសភាកម្ពុជា ជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់** ពិធីនេះថ្វាយ ប្រគេន និងជូនដោយ៖

.សម្តេចអគ្គមហាសេនាបតីតេជោបណ្ឌិតសភាចារ្យ **ហ៊ុន សែន**



.ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **សុខ អាន**

.លោកជំទាវបណ្ឌិតសភាចារ្យ **ខ្លូត ធីតា**

-សុន្ទរកថា ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិតឧបនាយករដ្ឋមន្ត្រី **គាត ឈន់** តំណាងជ័យលាភី៧អង្គ/នាក់

-ថតរូបអនុស្សាវរីយ៍

## ជយលាភីថវិការទទួលនាក់ ក្នុងពិធី
## ថ្វាយគោរមងារកិត្តិឧទ្ទេសបណ្ឌិត ប្រគេនសញ្ញាបត្រ
## កិត្តិបណ្ឌិត និង ជូនគោរមងារកិត្តិសេដ្ឋាបណ្ឌិត
## នៃរាជបណ្ឌិត្យសភាកម្ពុជា ចំពោះមន្ត្រីសង្ឃជាន់ខ្ពស់ និង
## ឥស្សរជនឆ្នើមនៃព្រះរាជាណាចក្រកម្ពុជា

វិមានសន្តិភាព ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៣

- ✓ **គោរមងារកិត្តិឧទ្ទេសបណ្ឌិត ៖**

  នៅថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៣ កន្លងទៅនេះរាជបណ្ឌិត្យសភាកម្ពុជា ក៏បានរៀបចំពិធីអបអរសាទរ ថ្វាយគោរមងារកិត្តិឧទ្ទេសបណ្ឌិត ចំពោះសម្តេចព្រះអគ្គមហាសង្ឃ រាជាធិបតី **នេព ទេព្យ** សម្តេចព្រះមហាសង្ឃរាជនៃគណៈមហានិកាយ និងសម្តេចព្រះមហាសុមេធាធិបតី **នន្ទ ង៉ែត** សម្តេចព្រះសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជាផងដែរ ដោយសម្តេចទាំងពីរកំពុងរក្សាព្រះរាជសុខភាពជាប្រចាំ។

  សម្តេចព្រះអភិសិរីសុគន្ធាធិបតីមហាសង្ឃរាជាធិបតី **បួរ គ្រី** សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយនៃព្រះរាជាណាចក្រកម្ពុជា

- ✓ **សញ្ញាបត្រកិត្តិបណ្ឌិត ៖**

  .កាលពីថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១១ រាជបណ្ឌិត្យសភាកម្ពុជា បានរៀបចំពិធីអបអរសាទរថ្វាយសញ្ញាបត្រ កិត្តិបណ្ឌិតចំពោះសម្តេចព្រះធម្មលិខិត **លាស់ ឡាយ** ប្រធានថេរសភាព្រះពុទ្ធសាសនា

  .សម្តេចព្រះពោធិវង្ស **អ៊ំ លឹមហេង** សម្តេចព្រះសង្ឃនាយករងទី២ នៃព្រះរាជាណាចក្រកម្ពុជា

  .សម្តេចព្រះវនរ័ត **ណយ ច្រឹក** សម្តេចព្រះសង្ឃនាយករងទី៣ នៃព្រះរាជាណាចក្រកម្ពុជា

  .សម្តេចព្រះឧត្តមបញ្ញា **ដួង ផង់** សមាជិកថេរសភាព្រះពុទ្ធសាសនានៃព្រះរាជាណាចក្រកម្ពុជា

  .សម្តេចព្រះឧត្តមវង្សា **មួង រ៉ា** លេខាថេរសភាព្រះពុទ្ធសាសនានៃព្រះរាជាណាចក្រកម្ពុជា

  .ព្រះមុនីកោសល **ហ៊ីល សុវណ្ណ** សមាជិកថេរសភាព្រះពុទ្ធសាសនានៃព្រះរាជាណាចក្រកម្ពុជា

- ✓ **គោរមងារកិត្តិសេដ្ឋាបណ្ឌិត ៖**

  ឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

# ផ្នែកទី១
# គោរមងារកិត្តិឧទ្ទេសបណ្ឌិត និង
# សញ្ញាបត្រកិត្តិបណ្ឌិតនៃរាជបណ្ឌិត្យសភាកម្ពុជា

## ១-សាវតារសង្ខេបនៃរាជបណ្ឌិត្យសភាកម្ពុជា

នៅឆ្នាំ១៩៦៥ រាជបណ្ឌិត្យសភាបានចាប់បដិសន្ធិឡើងតាមព្រះរាជក្រម លេខ ២៦១ ប.រ និងព្រះរាជក្រឹត្យលេខ ៤៩៩ ប.រ. ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ១៩៦៥ ប៉ុន្តែមិនទាន់មានដំណើរការនៅឡើយទេ ដោយសារសង្គ្រាមស៊ីវិលចាប់ពី ឆ្នាំ១៩៧០ មកក៏បានកាត់ផ្តាច់ការខិតខំទាំងនោះទៅវិញ។ នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៩៩ រាជបណ្ឌិត្យសភាបានបង្កើតឡើងវិញដោយព្រះរាជក្រឹត្យលេខ នស/រកត/០៥៩៩/៩៧ គឺនៅដើមអាណត្តិទី២នៃរាជរដ្ឋាភិបាល ដែលដឹកនាំដោយសម្តេចអគ្គមហាសេនាបតីតេជោបណ្ឌិតសភាចារ្យ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី និង ក្រោមការដឹកនាំផ្ទាល់របស់ឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី **សុខ អាន**។ រាជបណ្ឌិត្យសភាកម្ពុជា ជាស្ថាប័នស្រាវជ្រាវនិងបណ្តុះបណ្តាលជាន់ខ្ពស់ដ៏ធំមួយរបស់ជាតិ ដែលត្រូវបានបង្កើតឡើងវិញក្នុងដំណាក់កាល ដែលកម្ពុជាចាកផុតពីសង្គ្រាមស៊ីវិលនិងទទួលបាននូវសន្តិភាពពេញលេញ តាមរយៈនយោបាយឈ្នះ-ឈ្នះរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ដែលឡាយព្រះហស្តលេខាដោយព្រះមហាក្សត្រ នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្ថាប័ននេះមានឈ្មោះថា "រាជបណ្ឌិត្យសភាកម្ពុជា" ចាប់ពីពេលនោះ



មក។ ក្រោយមកព្រះរាជក្រឹត្យនេះត្រូវបានកែសម្រួល ដោយព្រះរាជក្រឹត្យលេខ នស/រកត/ ០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ដើម្បីឲ្យសមស្របទៅនឹងសំណូមពរការងារបច្ចុប្បន្ន និងការរីកចម្រើនរបស់ស្ថាប័ន។

បច្ចុប្បន្នរាជបណ្ឌិត្យសភាកម្ពុជា មានវិទ្យាស្ថានចំនួន០៦ ជាស្ថាប័នស្រាវជ្រាវ ដែលក្នុងនោះមាន (១)វិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ មាន៥ផ្នែក (២)វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមមាន៨ផ្នែក (៣)វិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រ និង កសិកម្ម មាន៤ផ្នែក(៤) វិទ្យាស្ថានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា មាន៥ផ្នែក (៥)វិទ្យាស្ថានភាសាជាតិ មាន៤ផ្នែក និង (៦)វិទ្យាស្ថានទំនាក់ទំនងអន្តរជាតិមាន៦ផ្នែក ជារួមមាន៣២ ផ្នែក(នាយកដ្ឋាន) ផ្នែកនីមួយៗមាន២មុខជំនាញ ព្រមទាំងមានមជ្ឈមណ្ឌលចំនួន៥គឺ មជ្ឈមណ្ឌលស្រាវជ្រាវអាស៊ី(កូរ៉េ) មជ្ឈមណ្ឌលបណ្តុះបណ្តាលភាសាអង់គ្លេសកម្ពុជា-ឥណ្ឌា មជ្ឈមណ្ឌលគ្រប់គ្រងប្រធានបទ វិទ្យាស្ថានខុងជឺ(ចិន) និងមជ្ឈ-មណ្ឌលព័ត៌មានវិទ្យា ដែលទាំងអស់សុទ្ធតែបាននិងកំពុងបំពេញភារកិច្ចទាំងក្នុងនិងក្រៅប្រទេសទៅតាមជំនាញរបស់ខ្លួន។ ទន្ទឹមនឹងនោះ រាជបណ្ឌិត្យសភាកម្ពុជា មានបណ្ណាល័យអេឡិចត្រូនិកមួយ ដែលមានឈ្មោះថា បណ្ណាល័យអេឡិចត្រូនិកសម្តេចអគ្គមហាសេនាបតីតេជោបណ្ឌិតសភាចារ្យ **ហ៊ុន សែន** និង លោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី** នាថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១១ ក្រោមចំណារឯកភាពដ៏ ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោបណ្ឌិតសភាចារ្យ **ហ៊ុន សែន**។ បច្ចុប្បន្នបណ្ណាល័យអេឡិចត្រូនិកនេះ មានឯកសារជាភាសាជាតិចំនួន ៣០០ក្បាល ភាសាបរទេសចំនួន៤លានក្បាល ៧០% ជា ភាសាចិន និងមានឯកសារសិក្សាក្រាស់ៗចំនួន ១៧២.៥០០ក្បាល ដែលក្នុងនោះ

ឯកសារចំនួន១៥០.០០០ ក្បាលជាភាសាចិន។ ឯកសារទាំងនោះភាគច្រើនបានទទួលពីសាកលវិទ្យាល័យ **ជីវ ជាំង** ប្រទេសចិន ក្រោមកិច្ចសហប្រតិបត្តិការរវាងរាជបណ្ឌិត្យសភាកម្ពុជា និង សាកលវិទ្យាល័យជីវជាំងប្រទេសចិន ក្នុងបំណងបម្រើដល់ការសិក្សាស្រាវជ្រាវរវាងប្រទេសទាំងពីរ ក៏ដូចជាបណ្តាប្រទេសនានាលើសកលលោកផងដែរ។

តាមរយៈអនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០០ រាជរដ្ឋាភិបាលកម្ពុជា បានកំណត់មុខងារនិងភារកិច្ចដល់រាជបណ្ឌិត្យសភាកម្ពុជាដូចខាងក្រោម ÷

១- គ្រប់គ្រងនិងពង្រីកការស្រាវជ្រាវខេមរវិទ្យា និង គ្រប់មុខជំនាញនៅក្នុងនិងក្រៅប្រទេស។

២- ស្ថាបនាទំនាក់ទំនងសហប្រតិបត្តិការផ្នែកស្រាវជ្រាវជាមួយក្រសួង ស្ថាប័ន អង្គការជាតិ និងអន្តរជាតិ ដែលមានគោលបំណងដូចគ្នា។

៣- រៀបចំវេទិកាវិទ្យាសាស្ត្រ និងអប់រំ ដើម្បីជួយអភិវឌ្ឍប្រទេសលើគ្រប់វិស័យ។

៤- បណ្តុះបណ្តាលថ្នាក់បរិញ្ញាជាន់ខ្ពស់និងថ្នាក់បណ្ឌិត

៥- បោះពុម្ពផ្សាយឯកសារ និងស្នាដៃស្រាវជ្រាវជាភាសាជាតិឱ្យបានទូលំទូលាយដល់មហាជននៅក្នុងប្រទេស និង ជាភាសាបរទេស ដើម្បីផ្សព្វផ្សាយខេមរវិទ្យានៅលើវេទិកាអន្តរជាតិ។

៦- ប្រមូលនិងតម្កល់ឯកសារស្រាវជ្រាវ អំពីប្រទេសកម្ពុជា អំពីបណ្តាប្រទេសនៅក្នុងតំបន់ និងលើពិភពលោក។



៧- ប្រមូលកម្លាំងបញ្ញាញាណរបស់ជាតិ ដើម្បីជំរុញការអភិវឌ្ឍប្រទេសឱ្យបានឆាប់រហ័ស។

៨- លើកសំណើជូនគោរមងារ និង គ្រឿងឥស្សរិយយសវិទ្យាសាស្ត្រ ដល់ឥស្សរជនឆ្នើមជាតិនិងអន្តរជាតិ។

៩- សហការពិនិត្យ និងវាយតម្លៃសញ្ញាបត្របរិញ្ញាបត្រ និងក្រោយបរិញ្ញាបត្រ។

១០- រួមចំណែក និងធ្វើសហប្រតិបត្តិការក្នុងការការពារកម្មសិទ្ធិផ្នែកវិទ្យាសាស្ត្រ គ្រប់វិស័យទាំងក្នុង និងក្រៅប្រទេស បច្ចុប្បន្នបានសហការជាមួយនឹងសាកលវិទ្យាល័យនានា និងបណ្ឌិត្យសភាលើសកលលោកផងដែរ។

១១- ពិនិត្យនិងវាយតម្លៃស្នាដៃស្រាវជ្រាវវិទ្យាសាស្ត្រនានា។

១២- ពិនិត្យនិងវាយតម្លៃការវិវត្តសង្គមនិងរួមវិភាគទានជំរុញការអភិវឌ្ឍទាំងភាសាជាតិ ប្រវត្តិសាស្ត្រ វិទ្យាសាស្ត្រ និង ចំណីអាហារ។ល។

១៣- សហការរួមចំណែកទំនាក់ទំនង ជាមួយក្រសួងនានា ទៅតាមជំនាញនៃផ្នែករបស់វិទ្យាស្ថាននីមួយៗ។

១៤- ត្រៀមបង្កើត និងគ្រប់គ្រងសាខានៃរាជបណ្ឌិត្យសភាកម្ពុជានៅតាមភូមិភាគនានាលើផ្ទៃប្រទេស។

១៥- សហការជាមួយក្រសួង ដែលពាក់ព័ន្ធដើម្បីជួយបង្កើតនិងណែនាំការគ្រប់គ្រងសារមន្ទីរបុរេប្រវត្តិសាស្ត្រនៅតាមខេត្ត/ក្រុងនានា។

ដើម្បីជាកិច្ចឆ្លើយតបទៅនឹងកំណើតរាជបណ្ឌិត្យសភាកម្ពុជា កាលពីថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៩៩ ក្នុងឱកាសសម្ពោធរាជបណ្ឌិត្យសភាកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោបណ្ឌិតសភាចារ្យ **ហ៊ុន សែន** បានគូសបញ្ជាក់ថា ៖

«...ខ្ញុំជឿថា ពិធីសម្ពោធរាជបណ្ឌិត្យសភានៅថ្ងៃនេះ គឺជាការបើកសករាជថ្មីមួយទៀតនៃការអភិវឌ្ឍធនធានមនុស្សរបស់កម្ពុជា... បទពិសោធន៍នៃប្រទេសជិតខាងជាច្រើនបានបង្ហាញឱ្យឃើញថា ការអភិវឌ្ឍធនធានមនុស្ស គឺជាគន្លឹះដ៏សំខាន់នៅក្នុងការកាត់បន្ថយភាពក្រីក្រ និងការលើកតម្កើងជីវភាពរបស់ប្រជាជន ហើយកិច្ចការនេះ វារឹតតែមានសារសំខាន់ពិសេសខ្លាំងណាស់ទៅទៀតសម្រាប់កម្ពុជា ដោយសារថា ប្រទេសជាតិយើងកំពុងតែខិតខំតស៊ូ ដើម្បីជម្នះនូវមត៌កប្រវត្តិសាស្ត្រដ៏ឈឺចាប់ ដែលបន្សល់ទុកដោយរបបប្រល័យពូជសាសន៍ និងសង្គ្រាម អូសបន្លាយនៅក្នុងអតីតកាលថ្មីៗរបស់ខ្លួន។

...នៅចំពោះមុខអរុណោទ័យនៃសហស្សវត្សថ្មី ពិភពលោកកំពុងតែធ្វើដំណើរយ៉ាងលឿនទៅមុខនៅក្នុងចរន្តសាកលូបនីយកម្មឆ្ពោះទៅកាន់ប្រព័ន្ធសេដ្ឋកិច្ចថ្មីមួយ ដែលគ្មានព្រំដែននិងគ្មាន ឧបសគ្គសម្រាប់ចរាចរនៃទំនិញ សេវាមូលធន និងកម្លាំងពលកម្ម ដែលមានចរិតជាសេដ្ឋកិច្ចឌេខូបនីយកម្ម (Digitalized Economy) ដោយពឹងផ្អែកលើចំណេះដឹង(Knowledge-basedeconomy)។ នៅក្នុងប្រព័ន្ធសេដ្ឋកិច្ចថ្មីនេះ មូលធនបញ្ញានឹងដើរតួនាទីគន្លឹះក្នុងការកំណត់សមត្ថភាពដណ្តើមឈ្នះរបស់ជាតិនីមួយៗ។



...ខ្ញុំមានមហិច្ឆតាចង់ប្រែក្លាយទសវត្សរ៍ទីមួយនៃសហស្សវត្សថ្មីឱ្យទៅជាទសវត្សរ៍នៃកំណើនសេដ្ឋកិច្ច ទសវត្សរ៍នៃការប្រយុទ្ធនឹងភាពក្រីក្រតោកយ៉ាក ដើម្បីវឌ្ឍនភាពសង្គមនិងវិបុលភាព សម្រាប់កម្ពុជានោះ គឺសង្គ្រាមនៃការពង្រឹងវប្បធម៌សន្តិភាព និងការប្រយុទ្ធដើម្បី ការអភិវឌ្ឍដោយចីរភាព និងសមធម៌ដែលខ្ញុំជឿថា នឹងជួយឱ្យយើងអាចលើកស្ទួយឡើងវិញបាននូវព្រលឹងនិងអត្តសញ្ញាណជាតិ និងទ្រទ្រង់ នូវប្រជាជាតិមួយដែលធ្លាប់តែរឹងមាំនិងមានមោទកភាព ឱ្យងើបមកកាន់សភាពដើមរបស់ខ្លួនឡើងវិញ។ នៅក្នុងរយៈពេលពី២០ ទៅ ៣០ ឆ្នាំខាងមុខ ខ្ញុំចង់ឃើញប្រទេសកម្ពុជាក្លាយទៅជាប្រទេសមួយ ដែលមានកម្រិតរីកចម្រើនប្រហាក់ប្រហែល នឹងបណ្តាប្រទេសជឿនលឿននានាដែលនៅជិតខាងនៅក្នុងតំបន់ ហើយប្រជាជនកម្ពុជាគ្រប់រូប នឹងមានជីវភាពរស់នៅសមរម្យ ថ្លៃថ្នូរស្ថិតនៅក្នុងវឌ្ឍនភាព វិបុលភាព និងសុភមង្គល។

ខ្ញុំយល់ថា យើងមានមូលហេតុគ្រប់គ្រាន់សម្រាប់ស្មារតីសុទិដ្ឋិនិយម និងក្តីសង្ឃឹមថា យើងនឹងបានទទួលជ័យជម្នះ នៅក្នុងសង្គ្រាមដ៏លំបាកនេះ។ ក្នុងរយៈពេលដ៏ខ្លីប៉ុណ្ណោះ យើងសម្រេចបាននូវសមិទ្ធផលដ៏ច្រើនបើប្រៀបធៀប នឹងប្រទេសឯទៀតដែលត្រូវចំណាយពេលវេលាអស់រាប់ទសវត្សរ៍ ដើម្បីឈានពីស្ថានភាព ដែលយើងបានជួប ប្រទះកាលពីប៉ុន្មានឆ្នាំ ឬប៉ុន្មានខែ មុននឹងមកដល់ស្ថានភាពនាពេលបច្ចុប្បន្ននេះ។ ជាការពិតណាស់ យើងនឹងត្រូវជួបប្រទះជាមួយបញ្ហាប្រឈមនិងឧបសគ្គជាច្រើនទៀតនាពេលខាងមុខ ហើយត្រូវធ្វើដំណើរទៅមុខឱ្យបានឆាប់រហ័ស ដោយត្រូវលោតផ្លោះដំណាក់កាលជាច្រើនថែមទៀត។

ក៏ប៉ុន្តែ សមិទ្ធផលដែលយើងទទួលបានធ្វើឱ្យខ្ញុំមានជំនឿថា កម្ពុជានឹងឆ្លងកាត់រាល់ឧបសគ្គ និងការលំបាកទាំងឡាយនាពេលអនាគត។ ផ្លូវដែលកម្ពុជាត្រូវដើរនៅវែងអន្លាយ ហើយលំបាកណាស់។ តែអស់លោកអ្នកប្រាកដជាយល់ស្របនឹងខ្ញុំថា សង្គមមួយដែលបានរស់ឡើងវិញពីអន្លង់មហន្តរាយហើយធ្វើដំណើរឆ្លងកាត់កំណាត់ផ្លូវដ៏វែងក្នុងរយៈពេលខ្លីបែបនេះ គឺមិនមែនជាការសាមញ្ញធម្មតានោះទេ។ នេះគឺជាសញ្ញាដែលបង្ហាញឱ្យឃើញ ពីសក្តានុពលភាពដ៏ធំធេងសម្រាប់អនាគតនៃកម្ពុជាយើង។

ទោះជាយ៉ាងណាក៏ដោយក៏ខ្ញុំដឹងយ៉ាងច្បាស់ថា នេះគឺជាសមរភូមិប្រយុទ្ធធំណាស់សម្រាប់យើងទាំងអស់គ្នា។គន្លឹះសំខាន់បំផុតសម្រាប់ជ័យជម្នះក្នុងរយៈពេលវែងនៅក្នុងសង្គ្រាមនេះ គឺការអភិវឌ្ឍធនធានមនុស្សប្រកបទៅដោយចីរភាព ពិសេសរាជបណ្ឌិត្យសភាត្រូវ ដើរតួនាទីស្នូលយ៉ាងសំខាន់នៅក្នុងកិច្ចការនេះ។

ខ្ញុំសង្ឃឹមថាក្រោយពីសម្ពោធជាផ្លូវការនៅថ្ងៃនេះ រាជបណ្ឌិត្យសភា នឹងរៀបចំបានរចនាសម្ព័ន្ធគ្រឹះសម្រាប់ប្រែក្លាយខ្លួន ឱ្យទៅជាមជ្ឈមណ្ឌលសម្រាប់យុទ្ធសាស្ត្រនៃការអភិវឌ្ឍធនធានមនុស្ស ជាឃ្លាំងនៃចំណេះវិជ្ជាជាន់ខ្ពស់ ជាទីកន្លែងប្រមូលផ្តុំនូវបញ្ញាញាណរបស់ជាតិនិងជាស្ថាប័ននៃការបណ្តុះបណ្តាលជាន់ខ្ពស់ក្នុងកម្រិតជាតិ និងអន្តរជាតិសម្រាប់ប្រទេសកម្ពុជានិងសម្រាប់បណ្តាប្រទេសក្នុងតំបន់ក៏ ដូចជាលើសកលលោកផងដែរ។

ក្នុងន័យនេះ ខ្ញុំសូមអំពាវនាវដល់គ្រប់ស្ថាប័នជាតិ និងដៃគូអន្តរជាតិទាំងអស់សូមឱ្យជួយផ្តល់ការឧបត្ថម្ភគាំទ្រ ដល់រាជបណ្ឌិត្យ-



សភាកម្ពុជា ដើម្បីឱ្យស្ថាប័ននេះអាចសម្រេចបានដោយជោគជ័យនូវបេសកកម្មដ៏ឧត្តុង្គឧត្តមក្នុងការរួមចំណែកអភិវឌ្ឍន៍មូលធនបញ្ញា និងការ ប្រមូលផ្តុំកម្លាំងបញ្ញាញាណរបស់ជាតិ ដើម្បីបុព្វហេតុនៃអនាគតដ៏ភ្លឺស្វាងរបស់កម្ពុជា»។

## ២- សមាជិកបណ្ឌិតសភាពេញសិទ្ធិ(បណ្ឌិតសភាចារ្យ) នៃរាជបណ្ឌិត្យសភាកម្ពុជា

| | |
|---|---|
|  | សម្តេចអគ្គមហាសេនាបតីតេជោបណ្ឌិតសភាចារ្យ<br>**ហ៊ុន សែន** |
|  | ឯកឧត្តមបណ្ឌិតសភាចារ្យ<br>**សុខ អាន** |
|  | លោកជំទាវបណ្ឌិតសភាចារ្យ<br>**ខ្លូត ធីតា** |
|  | ឯកឧត្តមបណ្ឌិតសភាចារ្យ<br>**ស៊ន សំណាង** |
|  | ឯកឧត្តមបណ្ឌិតសភាចារ្យ<br>**ព្រុំ ម៉ល់** |
|  | ឯកឧត្តមបណ្ឌិតសភាចារ្យ<br>**រស់ ចន្ទ្រាបុត្រ** |
|  | ឯកឧត្តមបណ្ឌិតសភាចារ្យ<br>**ជា ណោង** |

| | |
|---|---|
|  | ឯកឧត្តមបណ្ឌិតសភាចារ្យ<br>**សំ សោភាន់** |
|  | ឯកឧត្តមបណ្ឌិតសភាចារ្យ<br>**តិច សំណាង** |
|  | ឯកឧត្តមបណ្ឌិតសភាចារ្យ<br>**ស៊ុំ ឈុំប៊ុន** |
|  | ឯកឧត្តមបណ្ឌិតសភាចារ្យ<br>**អ៊ីច ច័ន** |
|  | ឯកឧត្តមបណ្ឌិតសភាចារ្យ<br>**សោម សុមុនី** |
|  | ឯកឧត្តមបណ្ឌិតសភាចារ្យ<br>**ខៀវ ថវិកា** |
|  | ឯកឧត្តមបណ្ឌិតសភាចារ្យ<br>**ឆយ អូន** |

បណ្ឌិតសភាចារ្យចំនួន ០៤ រូបគឺ បណ្ឌិតសភាចារ្យ **ចាន់ ពន** បណ្ឌិតសភាចារ្យ **ឡុង សៀម**, បណ្ឌិតសភាចារ្យ **ឆយ យីហ៊ាន** បណ្ឌិតសភាចារ្យ **ឃីន សុខ** បានទទួលមរណភាព កាលពីឆ្នាំ២០០៨ ២០០៩, ២០១០ និង ២០១២ កន្លងទៅ ដោយរោគាពាធ។



## ៣-ឯកសណ្ឋានអាវកិត្តិបណ្ឌិតនៃរាជបណ្ឌិត្យសភាកម្ពុជា

### ៣.១-អំពីទម្រង់អាវកិត្តិបណ្ឌិត

អាវកិត្តិបណ្ឌិតនៃរាជបណ្ឌិត្យសភាកម្ពុជា គឺជានិមិត្តកម្មមួយសម្រាប់សម្គាល់និងផ្តល់ជូនចំពោះអ្នកវិទ្យាសាស្រ្តជាន់ខ្ពស់ថ្នាក់បណ្ឌិត ឬចំពោះឥស្សរជនជាតិនិងបរទេស ដែលមានគុណបំណាច់ខ្ពស់ចំពោះជាតិមាតុភូមិកម្ពុជា ហើយមានសញ្ញាបត្រវិទ្យាសាស្រ្ត ចាប់ពីកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ឡើងទៅផងដែរ។

អាវកិត្តិបណ្ឌិតមានទម្រង់ជាប្រភេទ**អាវវែង កតាំង** មានសម្រុងមួយជំហរគ្របពីលើអាវក្នុង ហើយមានលក្ខណៈទូលាយ ភ្ជាប់ដោយឡេវខាងមុខពណ៌មាស **ចំនួនប្រាំគ្រាប់** ដែលរចនារូបសញ្ញារាជបណ្ឌិត្យសភាកម្ពុជា និងមានរចនាប៉ាក់ក្បាច់អង្គរពណ៌មាសយ៉ាងប្រណិតនៅលើផ្នែកនៃតួដងខ្លួននិងដៃអាវ។ អាវនេះធ្វើពីសំពត់សូត្រខ្មែរដែលជាផលិតផលរបស់ខ្មែរ( សូត្រខ្មែរ )ដោយប្រើប្រាស់រចនាលម្អដោយក្បាច់សិល្បៈខ្មែរជាពិសេស ប្រើក្បាច់មេ ជាក្បាច់អង្គរ ដែលបង្ហាញពីស្នាដៃសិល្បៈខ្មែរនាសម័យមហាអង្គរដ៏រុងរឿងនៃយើងកាលពីអតីតកាល។

សូមបញ្ជាក់ជូនថា រាជបណ្ឌិត្យសភាកម្ពុជា មិនថ្វាយឬប្រគេនអាវ ឬ មួកដល់ព្រះសង្ឃទេ គឺថ្វាយតែព្រះរាជក្រឹត្យ និង សញ្ញាបត្រតែប៉ុណ្ណោះ។

ចំណែកព្រះសង្ឃ ព្រះអង្គគ្រាន់តែបន្ថែមផ្លាកព្រះនាម (ឈ្មោះ) និងផ្លាកសញ្ញារាជបណ្ឌិត្យសភាកម្ពុជា មិនមានសម្លៀកបំពាក់អ្វីផ្សេងទេ។



ឯកសណ្ឋានអាវ កិត្តិបណ្ឌិត

## ៣.២-ខ្លឹមសារអាវកិត្តិបណ្ឌិត

### ក.អំពីអត្ថន័យនៃក្បាច់

ក្បាច់ដែលភ្ជាប់នឹងអាវកិត្តិបណ្ឌិតនេះជាក្បាច់ខ្មែរដែលតំណាងអត្តសញ្ញាណថ្កុំថ្កើងនៃវប្បធម៌ជាតិខ្មែរសុទ្ធសាធ។ ក្បាច់ខ្មែរមាន បួនគឺ ក្បាច់អង្គរ ក្បាច់ភ្ញីទេស ក្បាច់ភ្ញីវល្លិ និងក្បាច់ភ្ញីភ្លើង។ ក្បាច់ខ្មែរប្រើសម្រាប់នៅតាមទីកន្លែងផ្សេងៗ គឺលើគ្រឿងសង្ហារិម លើគ្រឿង



អលង្ការ លើសម្លៀកបំពាក់ និងលើសម្ភារ ប្រើប្រាស់។ ចំណែកក្បាច់អង្គរមានទម្រង់បីសំខាន់គឺ ក្បាច់អង្គរទម្រង់ត្របកឈូក ចំពីមុខ ក្បាច់អង្គរទម្រង់ត្របកឈូកចំហៀង ឬកន្ទុយហង្ស និងក្បាច់អង្គរទម្រង់ផ្កាច័ន (ក្បាច់ដកច័នអង្គរ)។ ក្បាច់អង្គរច្រើនប្រើសម្រាប់លម្អលើសំណង់ធុនធ្ងន់ដែលសាងឡើងពីថ្ម ស៊ីម៉ង់ត៍ ឬឈើ ដូចជា ប្រាសាទបុរាណ វាំង វត្ត មន្ទីររាជការធំៗ។ អាវកិត្តិបណ្ឌិតប្រើក្បាច់ខ្មែរមួយចំនួន មកលម្អមាន ៖

- ក្បាច់អង្គរទម្រង់ផ្កាច័ន (ក្បាច់ដកច័នអង្គរ) គឺជាមេក្បាច់រចនាលើតួ ដងខ្លួននិងចុងដៃនៃអាវ។ ក្បាច់នេះបំបែកចេញពីក្បាច់អង្គរទម្រង់ត្របកឈូកចំពីមុខ និងក្បាច់ផ្សេងៗមានក្បាច់កេសរ ឬក្បាច់ផ្ចេញក្របីឬក្បាច់ពងត្រី។

-ក្បាច់អង្គរទម្រង់ត្របកឈូកចំពីមុខគឺជាមេក្បាច់យ៉ាងសំខាន់ដែលអាចបំបែកឱ្យល្អិតល្អន់បានច្រើន។មេក្បាច់នេះរចនានៅដើមដៃ។

- ក្បាច់ពងត្រី គឺជាក្បាច់លម្អ ដែលមានរាងមូលប្រៀបដូចជាលេខ១ខ្មែរឬគូទខ្យង នៅអមសងខាងក្បាច់រចនាលើតួដងខ្លួន ដើមដៃ និងចុងដៃនៃអាវ។

### ខ.អំពីការប្រើក្បាច់

ក្បាច់ខ្មែរពណ៌មាសមានទំហំទទឹង៦ សង់ទីម៉ែត្រ ប្រើស្របតាមដងខ្លួននៅអមសងខាងឡេវអាវពីលើដល់ក្រោម និងចុងដៃនៃអាវ មានរចនាដោយក្បាច់អង្គរទម្រង់ផ្កាច័ន ភ្ជាប់ដោយក្បាច់អង្គរក្នុងទម្រង់ត្របកឈូកឬទម្រង់ស្លឹកពោធិ៍ ជាមួយក្បាច់ភ្ញីទេសចង្វាយភ្ជាប់ចេញជា

លម្អហើយអមដោយខ្សែតូចឆ្មាល់មួយនិងខ្សែក្រាស់ មួយនៅស្របគ្នា។ នៅចន្លោះខ្សែទាំងពីរមានក្បាច់ពងត្រីបន្តគ្នារដឹកយ៉ាងប្រណីត។

ក្បាច់ប្រើលើដើមដៃអាវ មានលម្អដោយក្បាច់អង្គរពណ៌មាស ហ៊ុំព័ទ្ធវង្វង់ដៃអាវទាំងស្រុង ដែលមានពីរសង្កាត់គឺ សង្កាត់ដើមដៃ និង សង្កាត់ចុងដៃ។ សង្កាត់ដើមដៃគឺ សម្រាប់សម្គាល់ស័ក្តិកិត្តិបណ្ឌិត មាន ទំហំក្បាច់ទទឹង ៦សង់ទីម៉ែត្រ ជាក្បាច់អង្គរទម្រង់ត្របកឈូកចំពីមុខ ដាក់តម្រៀបជួរបន្តគ្នា និងអមដោយក្បាច់ ពងត្រីពីរជួរ តម្រៀបបន្តគ្នា ស្របនឹងក្បាច់មេកណ្ដាលនៅចន្លោះខ្សែពណ៌មាស ដោយមានលក្ខណៈ ស៊ីមេទ្រីគ្នាទៅនឹងក្បាច់ជួរកណ្ដាល។ ចំណែកសង្កាត់ចុងដៃគឺយកដូច ទម្រង់ក្បាច់តាមដងខ្លួន។

## គ-អំពីខ្លឹមសារនៃពណ៌អាវកិត្តិបណ្ឌិត

អាវកិត្តិបណ្ឌិតនៃរាជបណ្ឌិត្យសភាកម្ពុជាកំណត់យក *ពណ៌ខៀវចាស់* ជា មូលដ្ឋាននៃអត្តសញ្ញាណកិត្តិយស។ ពណ៌ខៀវ គឺជាមេពណ៌ មួយក្នុងចំណោម មេពណ៌ទាំងបី( ក្រហម ខៀវ និង ស ) ដែលតំណាង ភាពប្រុងប្រយ័ត្ន សេចក្ដី ខ្ជាប់ខ្ជួន និង ភាពយុត្តិធម៌។ អត្ថន័យពណ៌ ខៀវត្រូវបានកំណត់ទៅតាមជំនឿរបស់ជាតិសាសន៍ផ្សេងៗគ្នា ដែល ក្នុងន័យវិជ្ជមាន ហើយជាទូទៅពណ៌ខៀវស្គាល់ សំណាងល្អ ការទំនាក់ ទំនងល្អ មានគតិបណ្ឌិត មានការការពារ ការជំរុញចិត្ត ការទុកចិត្ត ភាពស្ងប់ស្ងៀម ភាពទន់ភ្លន់ ប្រឱតញ្ញាណ សេរីភាព មនុស្សធម៌ សេចក្ដីស្រឡាញ់ ភាពស្មោះត្រង់ ភាពឆ្លាតវៃ សិល្បៈ សេចក្ដីមេត្តា និងសាមគ្គីភាព។ រីឯពណ៌ខៀវចាស់ សម្គាល់កម្រិតខ្ពស់ជាងខៀវ ធម្មតា គឺមានភាពស៊ីជម្រៅ មានជំនាញ មានស្ថិរភាព ភាពដែលអាច ជឿទុកចិត្តបាន ភាពជាបញ្ញវន្តមានចំណេះដឹងជ្រៅជ្រះ មានគតិបណ្ឌិត



មានអំណាច មានការបង្រួបបង្រួម មានភាពហ្មត់ចត់ មានសុខភាព ល្អហ៊ានសម្រេចចិត្ត មានច្បាប់ទម្លាប់ មានសណ្ដាប់ធ្នាប់ ភាពសម ហេតុផលនិងភាពឱ្យជាទីពឹងបាន។

ចំណែកការយកពណ៌មាសមករចនាលើមេក្បាច់អង្គរគឺតំណាង អត្តសញ្ញាណថ្កុំថ្កើងនៃវប្បធម៌ សិល្បៈជាតិខ្មែរ។

## ឃ.អំពីការរចនាលើឡេវអាវកិត្តិបណ្ឌិត

អាវកិត្តិបណ្ឌិត ប្រើឡេវជារូបសញ្ញានៃរាជបណ្ឌិត្យសភាកម្ពុជា ចំនួន ៥ គ្រាប់។

អត្ថន័យនិងខ្លឹមសារសំខាន់ៗនៃចំនួន៥ មាន ៖

-លេខ៥ ជាលេខគោលធំនៃលំដាប់ចំនួនរៀបរបស់ខ្មែរ ( ចំនួន រៀបមានមួយ ពីរ បី បួន និង ប្រាំ )

- ញាណទាំង៥របស់មនុស្សគឺ ចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ កាយវិញ្ញាណ និងជិវ្ហាវិញ្ញាណ

- ប្រាសាទអង្គរវត្តមានកំពូលចំនួន ៥ តំណាងគឺភ្នំព្រះសុមេរុ ចំកណ្ដាល និង ទិសធំទាំងបួន នៃទ្វីបចក្រវាឡ( ឧត្តរករោទ្វីប បុព្វទ្វីប ជម្ពូទ្វីបនិងអមរគោយានីទ្វីប )

- ប្រើក្នុងប្រពៃណីខ្មែរស្ដីពីការសំពះមាន៥គឺ ដៃបន្ទូល ដៃបង្គំ ដៃសំពះ ដៃខមាទោស និងដៃប្រណម្យ

- ប្រើក្នុងទំនៀមប្រណិធាន ដែលចេញមកពីពាក្យប្រាំធាន នៃ ការតាំងសេចក្ដីប្រាថ្នា។

- ចំនួនប្រាំមានប្រើក្នុងទំនៀម ប្រពៃណី និងជំនឿសាសនា របស់យើងច្រើនទៀត។

## ខ-អត្ថន័យនៃខ្លឹមសារនៃរូបសញ្ញារាជបណ្ឌិត្យសភាកម្ពុជា

យោងតាមសេចក្ដីសម្រេចលេខ១០សសរ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១០ ស្ដីពីសញ្ញារាជបណ្ឌិត្យសភាកម្ពុជារបស់ទីស្ដីការគណៈរដ្ឋមន្ត្រី បានបង្ហាញថា សញ្ញារបស់រាជបណ្ឌិត្យសភាកម្ពុជា មានទម្រង់ជារង្វង់មូលមានខ្សែពីរជាន់ និងរូបខាងក្នុងមានទម្រង់ជាត្រីកោណ ដែលមាន ៖

- **រូបជើងពានមាស** ដែលទ្រូប **សាស្ត្រា** ដោយមានចារឹក អក្សរកាត់ឈ្មោះ រាជបណ្ឌិត្យសភាកម្ពុជាគឺ **“រ ប ស ក”**
- **រូបសារ** នៅចន្លោះរូបសាស្ត្រានិងរូបចុងស្លាបប៉ាកកា ហើយនៅក្នុងរូបសារមានរូបសញ្ញា **ឱម**។
- នៅខាងលើរូបសារមានរូបសញ្ញា **ចុងស្លាបប៉ាកកា** និង **អដ្ឋង្គិកមគ្គ(ត្រាសានិស)** ដែលហ៊ុំព័ទ្ធដោយរូបពន្លឺ ឆព្វណ្ណរង្សី មានចំនួន១៦។
- នៅក្នុងរង្វង់អមរូបខាងក្នុងដែលមានទម្រង់ជាត្រីកោណមានរូបជើងពាន សាស្ត្រា សារ ឱម ចុងស្លាបប៉ាកា អដ្ឋង្គិកមគ្គ និងឆព្វណ្ណរង្សី មានរូប **ចង្វាយក្បាច់អង្គរ** ដែលតភ្ជាប់គ្នាពី ទម្រជើងពាន។
- នៅក្រោមរូបចង្វាយក្បាច់អង្គរមានចារឹកអក្សរខ្មែរថា “**រាជបណ្ឌិត្យសភាកម្ពុជា**”។







*ឡេវអាវកិត្តិសេដ្ឋាបណ្ឌិត  សញ្ញារាជបណ្ឌិត្យសភាកម្ពុជា*

*រីឯខ្លឹមសាររបស់រាជបណ្ឌិត្យសភាកម្ពុជាមានដូចខាងក្រោម៖*

- ទម្រង់ **រង្វង់មូល** ក្នុងន័យទូទៅ តំណាងពិភពលោក ឬ ចក្រវាឡ ព្រះអាទិត្យ និងវិទ្យាសាស្ត្រ។
- ទម្រង់ **ត្រីកោណ** នៃរូបខាងក្នុង ក្នុងន័យសមាធិ លំនឹង និងអំណាច។
- រូប **ជើងពានមាស** ជាទម្រ ក្នុងន័យការផ្ដល់នូវកិត្តិយស។
- រូប **សាស្ត្រា** ជាឃ្លាំងវិជ្ជា គឺជាគម្ពីរឯកសារដែលកត់ត្រានូវព្រឹត្តិការណ៍ ប្រវត្តិ ប្រពៃណី ទំនៀមទម្លាប់ ជំនឿ សាសនា និងខ្លឹមសារនៃការស្រាវជ្រាវ។ ខ្មែរនិយមតម្កល់សាស្ត្រានៅតាមវត្តអារាម ដោយតំណាងព្រះត្រៃបិដកចំនួន ១១០ ក្បាល រួមមានអរិយសច្ចៈទាំង៤គឺ ៖ អរិយសច្ចៈ ទី១៖ -**ទុក្ខអរិយសច្ចៈ** គឺទុក្ខមានពិត ដែលកើតមានដល់មនុស្សគ្រប់រូប ហើយពុំអាចជៀសផុតបានឡើយ តែខុសគ្នាត្រង់ អ្នកខ្លះមាន ទុក្ខ

តិច អ្នកខ្លះមានទុក្ខច្រើន។ អរិយសច្ចៈទី២៖ -**សមុទយអរិយសច្ចៈ** គឺទុក្ខ ដែលកើតឡើងមកពីហេតុ ហេតុដែលនាំ ឲ្យមានទុក្ខគឺ តណ្ហា និងអវិជ្ជា។ អរិយសច្ចៈ ទី៣-**និរោធអរិយសច្ចៈ** ការរួចស្រឡះការរំលត់ទុក្ខ គឺពិតជាមានពិត។ អរិយសច្ចៈ ទី៤-**មគ្គអរិយសច្ចៈ** គឺជាផ្លូវ ឬមធ្យោបាយ ឬមាគ៌ានាំឲ្យផុតទុក្ខ។ **មគ្គអរិយសច្ចៈ** ឬ **អដ្ឋង្គិកមគ្គ** មាន៨ ជាអាទិ៍គឺ ៖ ១-**សម្មាទិដ្ឋិ** សេចក្តីយល់ឃើញត្រូវ, ២-**សម្មាសង្កប្ប** ការត្រិះរិះត្រូវ, តម្រិះត្រូវ, ៣-**សម្មាវាចា** សម្តីត្រូវ, ៤-**សម្មាកម្មន្ត** ការងារត្រូវ, ៥-**សម្មាអាជីវ** ការចិញ្ចឹមជីវិតត្រូវ, ៦-**សម្មាវាយាម** ការព្យាយាមត្រូវ, ៧-**សម្មាសតិ** ស្មារតីត្រូវ, ការរឭកត្រូវ ៨-**សម្មាសមាធិ** សមាធិត្រូវ។

- រូប **សារ** ជាដងខ្លួន និងព័ត៌មាន ដែលជាឯកសារផ្សព្វផ្សាយនូវច្បាប់គតិយុត្តិ ឬដំណឹងផ្សេងៗ។
- រូប **ឱម** ក្នុងន័យជា វិញ្ញាណ ព្រលឹង កំណើត។ ក្នុងន័យទី១ គឺ **ឱម** ជាពាក្យសង្ខេប ជាបទសន្ធិនៃអក្សរ ៣ តួ គឺ **អ ឧ ម** ដែលជាត្រៃសរណៈរបស់ពួកព្រាហ្មណិកមានន័យថា **អ** គឺព្រះវិស្ណុ **ឧ** គឺព្រះឥសូរនិង **ម** គឺព្រះព្រហ្ម។ ចំពោះពុទ្ធសាសនិកជារតនត្រ័យសង្ខេបមានន័យថា **អ** គឺអរហំសម្មាសម្ពុទ្ធ, **ឧ** គឺឧត្តមធម៌ និង **ម** គឺមហាសង្ឃ (ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ) នៅកម្ពុជា។ ពួកពុទ្ធសាសនិកនិកាយមហាយាន ចាត់ទុក **ឱម** ជាស្រទាប់ផ្កាឈូក។ នៅប្រទេស នេប៉ាល់ គេថា ឱម ជាតំណាងផែនដី និង តំណក់ទឹក។
- រូប **ស្លាបប៉ាកកា** ជាក្បាលគំនិត និងសំណេរ សម្រាប់ គូសវាសខាងគំនិតកត់ត្រានូវខ្លឹមសារព្រឹត្តិការណ៍ ឬហេតុការណ៍នានាដែលកើតឡើង។
- រូប **ពន្លឺពណ៌ឆព្វណ្ណរង្សី** ជារស្មីពន្លឺ ៦ពណ៌ គឺខៀវ, លឿង, ក្រហម, ស, ហង្សបាទ,ផ្លេក (ពន្លឺពេជ្រ) ចេញពីចុង ស្លាបប៉ាកកា ដោយមានកាំរស្មីចំនួន១៦ ដែលតំណាងចំណេះដឹងនៃព្រះសិរៈ ជាថាមពល និងសមត្ថភាព។
- រូប**ចង្វាយក្បាច់អង្គរ** ដែលតភ្ជាប់គ្នាទ្រដើងពាន គឺតំណាងអត្តសញ្ញាណថ្កុំថ្កើងនៃវប្បធម៌សិល្បៈរបស់ខ្មែរ ដែលតំណាងអត្តសញ្ញាណ ជាតិខ្មែរ។

ក្នុងន័យរួម រាជបណ្ឌិត្យសភាកម្ពុជា ជាធនាគារខួរក្បាល ដែលប្រមូលផ្តុំដោយបញ្ញវន្តជាន់ខ្ពស់ ផ្តល់នូវកិត្តិយសលើការងារស្រាវជ្រាវការចងក្រង និង ការបោះពុម្ពផ្សាយប្រកបដោយគតិបណ្ឌិត ក្នុងការត្រិះរិះពិចារណាគ្រប់ជ្រុងជ្រោយ មានចំណេះដឹង និងសមត្ថភាពខាងជំនាញវិទ្យាសាស្ត្រ ហើយរក្សានូវតម្លៃខាងវប្បធម៌ សិល្បៈ សាសនា និងភាសារបស់ខ្លួន ដែលជាព្រលឹងនៃអត្តសញ្ញាណជាតិខ្មែរ។ ជាងនេះទៅទៀត រាជបណ្ឌិត្យសភាកម្ពុជាលើកទឹកចិត្ត និងផ្តល់កិត្តិយស ដល់បណ្ឌាឥស្សរជនជាតិនិងអន្តរជាតិ ដែលមានគុណបំណាច់ចំពោះជាតិមាតុភូមិកម្ពុជាយើង និងមានចំណេះដឹងផ្នែកវិទ្យាសាស្ត្រ ចាប់ពីថ្នាក់បរិញ្ញាជាន់ខ្ពស់ ( Master’s Degree ) ឡើងទៅ។

## ៣.៣ លក្ខណៈសម្គាល់ខ្លះៗអំពីមួកនៅក្នុងសង្គមខ្មែរ សម័យបុរាណ

*រៀបរៀងដោយបណ្ឌិតសភាចារ្យ **ខ្លួត ធីតា** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា, ជំនួយការស្រាវជ្រាវ ដោយលោក **សួត្រ សំណាង** លោក **ឈឹម សុខាន់ដារា** និងលោក ហៀង លាងហុង*

**មួក** មានលក្ខណៈច្រើនប្រភេទ និងជានិមិត្តរូបនៃអត្តសញ្ញាណវប្បធម៌របស់ជាតិនីមួយៗ។ តាមវចនានុក្រមខ្មែរសម្ដេចព្រះសង្ឃរាជជួនណាត (១៩៦៧) ពន្យល់ថា ៖

*មួក* ន. ប្រដាប់មានរូបផ្សេងៗច្រើនបែបសម្រាប់ពាក់លើសីសៈ ជាគ្រឿងការពារព្រះអាទិត្យ ធូលីជាដើម។ បើជារាជស័ព្ទហៅថា ព្រះ មាលា និងតាមពាក្យបុរាណ ហៅថា សិរតោណ ឬ សិរត្រោណ។

នៅក្នុងសង្គមខ្មែរសម័យបុរាណ ការប្រើប្រាស់មួកក៏ដូចជាការស្លៀកសម្លៀកបំពាក់និងការតុបតែងខ្លួនដែរ គឺសុទ្ធតែបង្ហាញពីឋានៈនិងតួនាទីក្នុងសង្គម។ ការតុបតែងខ្លួន និងការពាក់មួក ឬព្រះមាលា ឬមកុដ បានបង្ហាញ ពីការបែងចែកឋានៈរបស់បុគ្គល ដូចជា ព្រះមហាក្សត្រ ព្រះមហេសី ព្រះគ្រូ មហាមន្ត្រី មេទ័ព ...ជាដើម។ នៅក្នុងសិលាចារឹក K. ៩១០ មានប្រើពាក្យថា makuta មានន័យថា មកុដ ឬ ក្បាំង។ ចំណែកនៅក្នុងសិលាចារឹក K.១១៥ មានប្រើពាក្យថា mala (មាលា) មានន័យថា កម្រងផ្កា ឬ មកុដ ។ សិលាចារឹក K. ២៣៥ គេឃើញមានប្រើពាក្យថា mukutaveni (មុកុតវេនិ) មានន័យថា មកុដ (ទាប) មានសក់ក្រងលក្ខណៈជាក្បាំងទម្លាក់ពីក្រោយ ក្បាល។ លក្ខណៈមួក ឬ



សិរតោណ សម័យបុរេអង្គរ (ស.វ.ទី៦ ដល់ចុងស.វ.ទី ៨) មើលតាមចម្លាក់បដិមាភេទប្រុស គេឃើញការប្រើប្រាស់មួកមានរាងជា បំពង់វែង ឬរាងស៊ីឡាំង ពាក់គ្របពីលើក្បាល ដោយសំយាករមូរសក់ធ្លាក់គ្របលើកញ្ចឹងក។





លក្ខណៈមួកទេវរូបភេទប្រុសនៅស.វ.ទី៧
មួកទេវរូបភេទប្រុសដើមស.វ.ទី៩





ទម្រង់មួក ឬ មកុដ នៅសម័យគូលែន
ស្ថិតក្នុងរាជ្យព្រះបាទ ជ័យវរ្ម័នទី២ (គ.ស. ៨០២ ដល់ ៨៥០)

ចំពោះមួក ឬមកុដ របស់បដិមាស្ត្រីវិញ គឺមានរាងជាបំពង់ខ្ពស់ពាក់គ្របពីលើក្បាល កំពូលមួកចងភ្ជាប់ជាមួយកម្រងសក់រាងផ្តេកៗ ៣ ជាន់ ដោយទម្លាក់របុំសក់មកក្រោមសងខាងវិញ។



គំរូមួក ឬ មកុដ បដិមាទេវីជាទេវរូប

ភេទស្រី រកឃើញនៅកោះគ្រៀង
ស្រុកសម្បូណ៌ ខេត្តក្រចេះ

ស.វ.ទី៨ (សម័យចេនឡា)



## លក្ខណៈមួកសម័យអង្គរ (ស.វ.ទី៩ ដល់ស.វ.ទី១៤)

នៅសម័យអង្គរ គេឃើញមានការវិវត្តនូវលក្ខណៈមួក ឬព្រះមាលាជាច្រើនបែបច្រើនយ៉ាង ទៅតាមនិន្នាការសិល្បៈនៃរជ្ជកាលរបស់ព្រះមហាក្សត្រអង្គនីមួយៗ។ ការប្រើមួកត្រូវបានបែងចែកទៅតាមឋានៈ និងតួនាទីរបស់បុគ្គល។

### ព្រះមហាក្សត្រ

ព្រះមហាក្សត្រលម្អព្រះកេសដោយសិរតាណ ឬមកុដធ្វើពីមាសដាំដោយត្បូងពេជ្រ ជួនកាលទ្រង់ពាក់កម្រងផ្កាម្យ៉ាងដូចផ្កាម្លិះ។ បើសិក្សាតាមទេវរូបវិញ ឃើញថា លម្អព្រះមាលា គឺមានក្បាំង និងក្នួងសក់លើកឡើងខ្ពស់ មានរាងរីកខាងលើមានរាងជាកង់ៗ។ គ្រប់មកុដទាំងអស់មានក្បាំងធ្លាក់សំយាកគ្របលើកញ្ចឹងក ហើយលម្អរបស់ក្បាំងមានរាងចតុកោណស្មើ អមទៅដោយបន្ទះស្តើងតូចៗសំប៉ែត និងក្បាច់ធ្មេញរណារ និងត្របកឈូក។





គំរូមួក ឬ មកុដ សម័យអង្គរ

## ព្រាហ្មណ៍ ព្រះគ្រូ ឬ ព្រះរាជគ្រូ

នៅសម័យអង្គរ អ្នកប្រតិបត្តិសាសនាបានតុបតែងខ្លួនខុសៗ គ្នាទៅតាមនិកាយសាសនា ដែលគេគោរព។ បព្វជិតខាងព្រហ្មញ្ញសាសនាត្រូវបានចាត់ទុកជាអ្នកមានចំណេះដឹងខ្ពង់ខ្ពស់ ដែលខ្មែរសម័យបុរាណច្រើនតែចាត់ទុកពួកព្រាហ្មណ៍ជា*បណ្ឌិត*គឺសំដៅចំពោះអ្នកមានចំណេះខ្ពង់ខ្ពស់។ពួកព្រាហ្មណ៍ស្លៀកពាក់ដូចអ្នកស្រុកទូទៅដែរ ប៉ុន្តែប្លែកបន្តិចត្រង់មានអំបោះពណ៌សពាក់នៅនឹង-ក និងមានពនាក្រណាត់ខ្វែងលើស្មាដើម្បីសម្គាល់ថា ជាអ្នកមានចំណេះដឹងជ្រៅជ្រះ។ នៅលើចម្លាក់តាមជញ្ជាំងប្រាសាទអង្គរវត្ត គេឃើញពួកព្រាហ្មណ៍តុប តែងព្រះកេសដោយបួងសក់ឡើងលើហើយចងរឹតក្នុងសក់ដោយខ្សែអង្កាំមានតម្លៃ។







គំរូមួក ឬការលម្អក្បាលរបស់ពួកព្រាហ្មណ៍ នៅសម័យអង្គរ



( ក្នុងរង្វង់ ) – មួក ឬ មកុដរបស់ពួកព្រាហ្មណ៍ ឬ ព្រះគ្រូ
នៅសម័យអង្គរ



គំរូមួក ឬមាលារបស់ពួកតាបស តាមចម្លាក់នៅប្រាសាទអង្គរវត្ត



គំរូតុបតែងព្រះកេសរបស់ព្រាហ្មណ៍ព្រះគ្រូតាមចម្លាក់នៅប្រាសាទអង្គរវត្ត



គំរូម្ជូករបស់ពួកព្រាហ្មណ៍ព្រះគ្រូ តាមចម្លាក់នៅប្រាសាទបាយ័ន





ព្រះវិស្ណុ និងតាឥសី ជាតួអង្គតំណាងព្រះគ្រូ។ នៅក្នុងពិធីសំពះគ្រូទាំងនៅក្នុងផ្នែកតន្ត្រីនិងនាដសាស្ត្រគេតែងតាំងរូបឥសីនៅចំកណ្តាលអាសនៈ។ រីឯក្នុងផ្នែកសូនរូបនិងស្ថាបត្យកម្មវិញ គេយកព្រះវិស្ណុជា តួអង្គព្រះគ្រូ។ ព្រះវិស្ណុជាព្រះគ្រូមានគ្រឿងលម្អការពារក្បាល គឺម្ជូក ឬសិរត្រាណជាមកុដកំពូលមួយ។ ចំណែកឯតាឥសីវិញ មានគ្រឿងលម្អការពារក្បាលជា មកុដរាងកន្ទុយត្រី។

## សោភណភាព នៃមកុដតួអង្គផ្សេងៗក្នុងគំនូបុរាណខ្មែរ ឆ្នាំ២០០៥







ប្រភព៖ វ៉េន សុន និង ប៊ី ច័ន្ទា



## ៤- កម្រិតបណ្ឌិតកិត្តិយសលើសកលលោក

(ស្រាវជ្រាវដោយលោកជំទាវបណ្ឌិតសភាចារ្យ ខ្លូត ធីតា)

បណ្ឌិតកិត្តិយស គឺកម្រិតសិក្សាកិត្តិយសជាន់ខ្ពស់។ សាកលវិទ្យាល័យមួយផ្តល់សញ្ញាបត្រកិត្តិយសទៅនរណាម្នាក់ នឹងលើកលែងចំពោះលក្ខន្តិកៈនានា សម្រាប់កម្រិតសិក្សាណាមួយ។ សញ្ញាបត្រត្រូវបានគេប្រគល់ឱ្យដើម្បីផ្តល់កិត្តិយសដល់អ្នកទទួល និង ដើម្បីផលប្រយោជន៍សាកលវិទ្យាល័យ។ កម្រិតវប្បធម៌របស់អ្នកទទួលនឹងអាចកើនឡើងយ៉ាងខ្ពស់។ អ្នកទាំងនោះអាចមិនមានទំនាក់ទំនងជាមួយសាលា មិនមានទទួលសញ្ញាបត្រពីសាលានោះពីមុនមក និងមិនមានការអប់រំខ្ពស់នៅក្នុងសាលារៀន ឬពួកគេអាចមានការអប់រំត្រឹមត្រូវ និងបណ្ឌិតកិត្តិយសផ្សេងទៀត។ សញ្ញាបត្រកិត្តិយសតែងតែជាប្រភេទបណ្ឌិតកិត្តិយស ប៉ុន្តែ ក៏អាចជាអនុបណ្ឌិតកិត្តិយសផងដែរ។

នៅក្នុងប្រទេសជាច្រើន បណ្ឌិត គឺជាកម្រិតខ្ពស់ជាងគេបំផុតនៃកម្រិតសិក្សា។ បណ្ឌិតកិត្តិយស អាចត្រូវបានប្រគល់ឱ្យដោយសារមូលហេតុជាច្រើន ដែលត្រូវបានធ្វើសេចក្តីសម្រេចដោយសាកលវិទ្យាល័យ។ អ្នកទទួលបានបណ្ឌិតកិត្តិយសមុនគេបង្អស់ក្នុងកំណត់ត្រា គឺត្រូវបានគេប្រគល់ជូនលោក Billy Graham ដោយសាកលវិទ្យាល័យ Oxford ក្នុងទសវត្សរ៍ឆ្នាំ១៤៧០។ ការអនុវត្តនេះបានក្លាយទៅជាធម្មតា ប៉ុន្តែក្នុងទសវត្សរ៍ឆ្នាំ១៦០០ ក្នុងប្រទេសអង់គ្លេស ខ្សែរាជវង្សនឹងចុះសួរសុខទុក្ខនៅតាមសាកលវិទ្យាល័យនានា។

អ្នកទទួលបណ្ឌិតកិត្តិយស អាចប្រើប្រាស់សញ្ញាបត្រនេះដូចសញ្ញាបត្រពិតដែរលើកលែងតែករណីមួយចំនួនដែលប្រវត្តិសិក្សាផ្លូវការគឺត្រូវបានគេទាមទារ។ អ្នកទទួលនឹងមិនទាន់ចាប់ប្រើប្រាស់ងារបណ្ឌិតនេះ ទោះបីជាមិនមានច្បាប់ណា ប្រឆាំងវាឡើយ។ អ្នកទទួលបណ្ឌិតកិត្តិយស លោក Benjamin Franklin, Maya Angelou, និង Billy Graham ក្នុងចំណោមអ្នកទាំងនោះ បានប្រើងារនេះមុន ឬ ក្រោយជា Nominally។ សាកលវិទ្យាល័យជាច្រើនដែលប្រគល់បណ្ឌិតកិត្តិយសបានហៅអ្នកទាំងនោះជាបណ្ឌិត"។ ទោះបីជាងារនេះត្រូវបានគេ ប្រើប្រាស់មុន(Prenominal)ឬក្រោយ(Postnominal) បណ្ឌិតកិត្តិយសនេះគួរតែត្រូវបានគេប្រើដោយបន្ថែមលើងារសញ្ញាបត្រ។

គេច្រើនសង្កេតឃើញថា សាកលវិទ្យាល័យជាញឹកញាប់ផ្តល់រង្វាន់ជាមួយសុន្ទរកថា នៅក្នុងពិធីប្រគល់សញ្ញាបត្របញ្ចប់ការសិក្សា។ តួយ៉ាងមនុស្សមួយចំនួនត្រូវបានគេផ្តល់សញ្ញាបត្រ ហើយក្រុមអ្នកវាយតម្លៃរបស់សាកលវិទ្យាល័យសម្រេចលើអ្នក ដែលអាចទទួលសញ្ញាបត្រនេះបាន។ ទោះបីជាយ៉ាងណានៅកន្លែងមួយចំនួន អាចត្រូវបានគេដាក់ពាក្យស្នើសុំ។ វាជាបញ្ហាសាមញ្ញមួយនៅក្នុងចក្រភពអង់គ្លេស អូស្ត្រាលី ញ៉ូវស៊ឺលែន និងអៀកឡង់ដែលការទទួលបានងារនេះ អ្នកទទួលត្រូវមានទំនាក់ទំនងជាមួយសាកលវិទ្យាល័យ។ អ្នកទទួលបណ្ឌិតកិត្តិយសជាទូទៅមានពិន្ទុសិក្សាត្រឹមត្រូវនិងជាបុគ្គលិក នៅក្នុងសាកលវិទ្យាល័យនោះ។



ការផ្តល់សញ្ញាបត្របណ្ឌិតកិត្តិយសអាចធ្វើឱ្យមានការវែកញែកផ្សេងៗគ្នានៅក្នុងសាកលវិទ្យាល័យ ជាពិសេសបើអ្នកទទួល ជាអ្នកនយោបាយ។ អតីត ប្រធានាធិបតីអាមេរិក លោក George W. Bush បានទទួលបណ្ឌិតកិត្តិយស ពីសាកលវិទ្យា Yale ជាអតីតសាកលវិទ្យាល័យដែលគាត់បានទទួលសញ្ញាបត្រកាលពីឆ្នាំ១៩៦៨ បានធ្វើឱ្យមានការរំជើបរំជួលទាំងសាស្ត្រាចារ្យ និងនិស្សិតធ្វើពហិការមិនចូលរៀនក្នុងឆ្នាំ២០០១។ ដូចគ្នានេះដែរ ក្នុងឆ្នាំ២០០៧ មានការតវ៉ាប្រឆាំងការផ្តល់បណ្ឌិតកិត្តិយសរបស់សាកលវិទ្យាល័យOxford ជូនលោក Robert Mugabe មេដឹកនាំកំពូលរបស់ប្រទេស Zimbabway នៅក្នុងឆ្នាំ១៩៨៤។

តើយើងអាចទទួលសញ្ញាបត្របណ្ឌិតកិត្តិយសដោយរបៀបណា?

សាកលវិទ្យាល័យមួយផ្តល់សញ្ញាបត្របណ្ឌិតកិត្តិយស ដល់អ្នកដែលបានចូលរួមចំណែកដែលមានសារប្រយោជន៍សម្រាប់សាកលវិទ្យាល័យ ឬជាការថ្លែង អំណរគុណសម្រាប់ការជួយជ្រោមជ្រែង និងគាំទ្រ។ សញ្ញាបត្រប្រភេទនេះមិន ត្រូវបានគេប្រគល់ឱ្យតាមរយៈការជោគជ័យក្នុងការសិក្សា និងមិនបង្ហាញថា អ្នកទទួលបានសិក្សាជា ផ្លូវការនៅសាលា ដែលផ្តល់បណ្ឌិតកិត្តិយសនេះដែរ។សាធារណជននិងម្ចាស់ជំនួយភាគច្រើនត្រូវបានគេផ្តល់បណ្ឌិតកិត្តិយស។ អ្នកដែល ចង់ទទួលសញ្ញាបត្របណ្ឌិតកិត្តិយស គួរតែប្រឹងប្រែងធ្វើការក្នុងវិស័យ ឬតស៊ូដើម្បីក្លាយជាអ្នកជួយសាលាមួយ។

អត្ថន័យយ៉ាងជ្រាលជ្រៅនៃបណ្ឌិតកិត្តិយស មានភាពខុសគ្នាពីអ្នកទទួលម្នាក់ទៅម្នាក់។ ជាច្រើនករណី សញ្ញាបត្រនេះ ត្រូវបានគេគោរព ប៉ុន្តែមិនមែនជាជោគជ័យនៃការសិក្សាទេ។ អ្នកទទួលមួយចំនួន ត្រូវបានគេប្រគល់បណ្ឌិតកិត្តិយសដោយសារតែការងារទាក់ទិននឹងការសិក្សានិងការងារវិទ្យាសាស្ត្រដែលអ្នកទាំងនោះបានធ្វើកន្លងមក។ ឧទាហរណ៍ អ្នកនិពន្ធអាចទទួលសញ្ញាបត្របណ្ឌិតកិត្តិយស ផ្នែកអក្សរសាស្ត្រ។

បណ្ឌិតកិត្តិយសត្រូវបានគេចេញឱ្យដើម្បីផ្តល់តួនាទីឱ្យអ្នកទទួល និងដើម្បីរឹតចំណងទំនាក់ទំនងរវាងសាលា និងជាមួយសាធារណជនដែលទទួលសញ្ញាបត្រនេះ។ តារាសម្តែងក៏អាចទទួលសញ្ញាបត្រនេះផងដែរ ដោយជំនួសមក វិញនូវការប្រើឈ្មោះរបស់ ពួកគេដើម្បីបង្កើនប្រជាប្រិយភាពសាលានៅក្នុងពេលមានកម្មវិធីអ្វីមួយដូចជាបើកបវេសនកាលជាដើម។

សាលាផ្តល់បណ្ឌិតកិត្តិយសសម្រាប់ ការសម្រេចជោគជ័យ ឬដើម្បីរឹតចំណងទាក់ទងជាមួយសាធារណជនដែលបំពេញការងារនិងសម្រេចលទ្ធផលស្របនឹងគោលដៅសិក្សានិងសង្គមរបស់សាលា។

សាកលវិទ្យាល័យក៏ប្រើសញ្ញាបត្របណ្ឌិតកិត្តិយស ដើម្បីផ្តល់កិត្តិយសដល់អ្នកផ្តល់ជំនួយសំខាន់ៗផងដែរ។ បណ្ឌិតកិត្តិយសគឺជាមធ្យោបាយមួយ ដែលសាលាមួយអាចបង្ហាញការគាំទ្ររបស់ សប្បុរសជនឬអ្នកដែលខិតខំគាំទ្រខាងផ្នែកច្បាប់របស់សាលា។នៅពេលប្រគល់សញ្ញាបត្រប្រភេទនេះ សាលានឹងខិតខំជ្រើសរើសយកផ្នែកមួយណាដែលស័ក្តិសមនឹងការខិតខិប្រឹងប្រែងរបស់អ្នកទទួល ដែលទទួលបានជោគជ័យ ប៉ុន្តែវាមិនអាចត្រឹមត្រូវទាំងស្រុងនោះទេ។ ការរួមចំណែកនិងការគាំទ្រសម្រាប់សាលាណាមួយ មិនអាចធានាថានឹងមានការផ្តល់ឱ្យនូវបណ្ឌិតកិត្តិយសនេះទេ ប៉ុន្តែពួកគេអាចធ្វើឱ្យវាកើតមានឡើង។

កាលពី២៥០ ឆ្នាំមុន សាកលវិទ្យាល័យមួយចំនួនបាន ចាប់ផ្តើមផ្តល់ សញ្ញាបត្រដែលឱ្យឈ្មោះថា «បណ្ឌិតកិត្តិយស» ទៅអ្នកដែលគេចង់ឱ្យដើម្បីជាកិត្តិយសនិងទទួលស្គាល់។ ទោះបីជាយ៉ាងណា ទាំងសាកលវិទ្យាល័យ និងអ្នកទទួលជឿជាក់ថា បណ្ឌិតកិត្តិយសនេះ ដូចកម្រិតបណ្ឌិតទូទៅដែរ។គោលបំណងនៃការផ្តល់កិត្តិយសនេះគឺ ដើម្បីបង្ហាញថាមិនមែនជាការអនុញ្ញាតឱ្យការអប់រំភ្លាមៗទេ។ ជាញឹកញាប់កិត្តិយសនេះត្រូវបានប្រគល់ឱ្យនរណាម្នាក់ ដែលមានបណ្ឌិតរួចហើយក៏ថាបាន។

អ្នកប្រកាន់យកគោលការខ្ជាប់ខ្ជួនគិតថា បណ្ឌិតកិត្តិយសគឺជាសញ្ញាបត្របណ្ឌិតពិត ដោយសារការយល់ឃើញស្រដៀងគ្នាក្នុងវិស័យអប់រំដែរ។ ពួកគេនិយាយថា មនុស្សម្នាក់មិនអាចមានចំណេះដឹង ពិតប្រាកដដោយមិនមានការ អនុញ្ញាត និងទទួលស្គាល់ឡើយ។

បណ្ឌិតកិត្តិយសអាចទទួលបានគ្រប់ផ្នែកទាំងអស់ ដូចបណ្ឌិតសិក្សាដែរ គ្រាន់តែខុសគ្នាត្រង់ប្រើ ឈ្មោះសញ្ញាបត្រហាក់ទូលាយជាងបន្តិច។ អ្នកមានសញ្ញាបត្របណ្ឌិតសិក្សា និងអត់សញ្ញាបត្របណ្ឌិតសិក្សាអាចទទួលបណ្ឌិតកិត្តិយសបានដូចគ្នា។

## ៥-ឯកសណ្ឋាននៅប្រទេសមួយចំនួនលើសកលលោក

**សម្លៀកបំពាក់សិក្សា** ( FromWikipedia, the free encyclopedia )

( ស្រាវជ្រាវដោយលោកជំទាវបណ្ឌិតសភាចារ្យ ខ្លួត ធីតា និង លោកស្រីបណ្ឌិត ឌួង សុខឃឿន )

សម្លៀកបំពាក់សិក្សា គឺជាប្រពៃណីនៃការស្លៀកពាក់សម្រាប់ ពិធីទាក់ទិននឹងការសិក្សាជាបឋមដូចជា ការសិក្សានៅកម្រិតទី៣ និងកម្រិត២ ដែលប្រើប្រាស់ដោយ អ្នកដែលអនុញ្ញាតឱ្យចូលរៀនកម្រិតមហាវិទ្យាល័យឬអ្នកដែលមានឋានៈ (និស្សិតមិនទាន់ទទួលសញ្ញាបត្រនៅមហាវិទ្យាល័យចំណាស់ៗ) មាន ៖

១- សម្លៀកបំពាក់ទទួលសញ្ញាបត្ររបស់ប្រទេសអង់គ្លេស
២- សម្លៀកបំពាក់ទទួលសញ្ញាបត្ររបស់ប្រទេសអាមេរិក
៣- សម្លៀកបំពាក់ទទួលសញ្ញាបត្ររបស់ប្រទេសបារាំង
៤- សម្លៀកបំពាក់ទទួលសញ្ញាបត្ររបស់ប្រទេសអាល្លឺម៉ង់
៥- សម្លៀកបំពាក់ទទួលសញ្ញាបត្ររបស់ប្រទេសប៉ូឡូញ
៦- សម្លៀកបំពាក់ទទួលសញ្ញាបត្ររបស់ប្រទេសស៊ុយអែត

សម្លៀកបំពាក់ទទួលសញ្ញាបត្រ បានរកឃើញនៅតាមមហាវិទ្យាល័យជាច្រើននៅក្នុងចក្រភពអង់គ្លេសនិងសហរដ្ឋអាមេរិក ដែលត្រូវបានគេយកមកពីសាកលវិទ្យាល័យ Cambridge និងសាលកវិទ្យាល័យ Oxford ដែលមានប្រវត្តិនៃការរីកចម្រើនខាងសម្លៀកបំពាក់ទទួល



សញ្ញាបត្រ និងសម្រាប់បព្វជិតក្នុងមជ្ឈិមសម័យនៅសាកលវិទ្យាល័យទ្វីបអឺរ៉ុប។

សម្លៀកបំពាក់ក្នុងពិធីនានា គឺជាទូទៅត្រូវបានគេពាក់ពីក្នុងអាវវែង។ឧទាហរណ៍បុរសពាក់ឈុតពណ៌ខ្មៅជាមួយអាវសនិងក្រវ៉ាត់ក ឬសម្លៀកបំពាក់ បព្វជិត កងទ័ពឬសម្លៀកបំពាក់ស៊ីវិល ឬសម្លៀកបំពាក់ជាតិហើយស្ត្រីពាក់ដូចគ្នាដែរ។ សាកលវិទ្យាល័យចំណាស់ៗមួយចំនួនដូចជាសាកលវិទ្យាល័យ Cambridge និង Oxford បានចែងនូវការស្លៀកពាក់ (ដែលត្រូវបានគេស្គាល់ថា Subfusc) ដែលគេពាក់ពីខាងក្រៅអាវវែង។ ទោះបីជាមានសាកលវិទ្យាល័យមួយចំនួន មិនខ្វល់ខ្វាយពីសម្លៀកបំពាក់ដែលគេពាក់ខាងក្នុងអាវវែងក៏ដោយ ក៏វាត្រូវបានគេចាត់ទុកថាជាទម្រង់នៃការស្លៀកពាក់មិនសមរម្យសម្រាប់សម្លៀកបំពាក់ធម្មតា ឬដូចការស្លៀកពាក់នៅក្នុងពិធីបញ្ចប់ការសិក្សា ហើយមានសាកលវិទ្យាល័យមួយចំនួនទៀត មិនអនុញ្ញាតឱ្យនិស្សិតចូលរួមនៅក្នុងពិធីទៀតផង ប្រសិនបើពួកគេមិនបានស្លៀកពាក់ត្រឹមត្រូវទេនោះ។

### ៥.១-សម្លៀកបំពាក់ទទួលសញ្ញាបត្ររបស់ប្រទេសអង់គ្លេស

វាមានការបែងចែកដាច់ពីគ្នានៃប្រភេទសម្លៀកបំពាក់ទទួលសញ្ញាបត្រ។ ថ្មីៗនេះអាវធំវែង ក្រណាត់គ្រប និងមួកត្រូវបានគេបែងចែកទៅតាមប្រភេទទៅតាមរូបរាង និងគំរូដែលត្រូវបានគេស្គាល់ថា Groves Classification of Academic Dress ដែលយកតាមឯកសារ Nicholas Groves' មានចំណងជើងថា *Hood and Gown Patterns*។ ក្នុងតារាងនោះមានម៉ូដឬគំរូសម្លៀកបំពាក់ទទួលសញ្ញាបត្រជាច្រើនហើយដាក់ជាលេខសម្គាល់ឬ Groves Classification Number។ ឧទាហរណ៍ ម៉ូដ

សម្លៀកបំពាក់សម្រាប់ថ្នាក់បរិញ្ញានៅសាកលវិទ្យាល័យ Cambridge ត្រូវបានគេជ្រើសរើសយក [b2] ហើយមួកដែលមានរូបរាងពេញលេញ គឺចូលក្នុងប្រភេទ[f1]។

ចាប់តាំងពីមជ្ឈិមសម័យ សម្លៀកបំពាក់បណ្ឌិតដូចជា Bishop និង Cardinal ត្រូវបានគេអនុញ្ញាតឱ្យពាក់ក្រណាត់ពណ៌ជិត ដូចជាពណ៌ក្រហមច្រាល ពណ៌ស្វាយ ឬពណ៌ក្រហម។ នៅក្នុងសាកលវិទ្យាល័យចំណាស់ៗ មួយចំនួនបណ្ឌិត ពាក់អាវវែង ឬអាវបំពង់រលុង (ពេលខ្លះគេហៅថា “festal robes”) ដែលវាត្រូវ បានគេពាក់ក្នុងឱកាសសំខាន់ៗ។ វាមានរាងពីរបែបខុសពីគ្នាដែលប្រើនៅក្នុងប្រទេសអង់គ្លេសសម្រាប់អាវវែងរបស់បណ្ឌិត។ អាវបណ្ឌិតរបស់សាកលវិទ្យាល័យ Cambridge និងសាកលវិទ្យាល័យ Oxford ពីមុនវាមានដៃអាវរាងប៉ោង បន្ទាប់មកគឺ អាវដៃវែងហើយបើកដៃ។ ម៉ូដដែលកម្រ ឃើញមួយទៀតគឺ អាវប្រភេទ Cambridge MusD ដែលមានរូបរាងជា បន្សំរវាងម៉ូដទាំងពីរ។

ប្រភេទផ្សេងទៀតនៃអាវបណ្ឌិតគឺអាវ Undress ។ វាគឺជាអាវវែងពណ៌ខ្មៅ (ដែលវាអាចឬមិនអាចចែកឱ្យដាច់ជាមួយអាវរបស់អនុបណ្ឌិត (បរិញ្ញាប័ត្រជាន់ខ្ពស់) អាស្រ័យលើសាកល វិទ្យាល័យនីមួយៗ។ វាតុបតែងដោយខ្សែ កម្រង ឬ បញ្ជាក់ច្បាស់ពីកម្រិត) ដែលត្រូវបានគេពាក់នៅពិធីមិនសូវផ្លូវការ ដូចជាការបង្រៀនជាដើម។ អាវវែងប្រភេទនេះមិនសូវឃើញមានពាក់ឡើយ នៅក្នុងសម័យបច្ចុប្បន្ននេះគេប្រើអាវឈុតជំនួសវិញ។ ការប្រើប្រាស់អាវ undress កាន់តែតិចទៅនៅក្នុងជីវិត



មហាវិទ្យាល័យ។ ប៉ុន្តែអាវ undress នៅតែដើរតួនាទីយ៉ាងសំខាន់នៅក្នុងមហាវិទ្យាល័យចំណាស់ៗ ដែលសម្លៀកបំពាក់ទទួល សញ្ញាបត្រត្រូវបានគេប្រើប្រាស់ជាញឹកញាប់។ នៅសាកលវិទ្យាល័យCambridge បណ្ឌិត ម្នាក់ៗមានសម្លៀកបំពាក់ undress របស់ខ្លួន ហើយមានការតុបតែងផ្សេងៗគ្នា ដែលមានអត្ថន័យអាចកត់សម្គាល់ពីកម្រិត របស់អ្នកប្រើប្រាស់ដោយមិនចាំបាច់មានមួក។

សម្លៀកបំពាក់មួយបែបផ្សេងទៀត ដែលមិនសូវប្រើប្រាស់នៅពេលបច្ចុប្បន្ននេះ គឺពាក់នៅពីលើអាវវែងពណ៌ខ្មៅ។ មានតែសាកលវិទ្យាល័យ Cambridge និង សាកលវិទ្យាល័យ Oxford ទេដែលប្រើសម្លៀកបំពាក់ប្រភេទ នេះសម្រាប់ ក្នុងពិធីផ្លូវការបំផុត និងសម្រាប់ក្រុមបណ្ឌិតសភាចារ្យ ឬ ក្រុម មន្ត្រី[1]។

ទម្លាប់នៃការចែកសញ្ញាបត្រនៅសាកលវិទ្យាល័យ Oxford គឺក្រណាត់ ដៃអាវពណ៌ក្រហមច្រាលពាក់នៅពីលើអាវវែងពណ៌ខ្មៅ ដែលដៃអាវវែងមូរចូលតាមប្រហោងដៃ ។វាស្រដៀងនឹង Chimere របស់ Bishop លើកលែងតែនៅពេល ដែលគេពាក់វា គឺបិទតែឡេវពីរធំៗប៉ុណ្ណោះ។ វាត្រូវបានគេប្រើប្រាស់នៅពេលប្រជុំសាកលវិទ្យាល័យ ឬការជួបជុំធំៗដោយអ្នកដែលបង្ហាញបណ្ឌិត។

ភាពកម្រ និងភាពបុរាណជាងនេះទៅទៀតគឺ CappaClausa ឬ Cope គឺអាវដណ្តប់ធំពណ៌ក្រហមជិត រួមនឹងមានរោមសត្វនៅផ្នែកខាងលើស្មា ដែលពាក់ដោយអធិការបតីរងនៃសាកលវិទ្យាល័យ Cambridge

---

១ www.newadwadvent.org/cathen/05072b.htm

នៅពេលប្រគល់សញ្ញាបត្រ និង សម្រាប់អ្នកដែលទទួលបានបណ្ឌិតជាន់ខ្ពស់។

### ៥.១.១-អំពីមួក

មួក បានក្លាយជានិមិត្តរូបនៃសម្លៀកបំពាក់ទទួលសញ្ញាបត្រ។ នៅក្នុងសាកលវិទ្យាល័យមួយចំនួនមួកនេះអាចពាក់បានទាំងអ្នកបញ្ចប់ការសិក្សានិងអ្នកមិនទាន់បញ្ចប់ការសិក្សា។ វាមានរាងជ្រុងនៅផ្នែកខាងលើជាមួយ និងរំយោលដែលភ្ជាប់ពីឡេវនៅកណ្ដាលផ្ទៃនៃមួក។ ជាទូទៅគេប្រើប្រាស់វាស្របទៅ នឹងអាវវែងធំ តែមនុស្សមួយចំនួនជាពិសេសស្ត្រីពាក់វាឆៀងទៅខាងក្រោយ។

នៅក្នុងសាកលវិទ្យាល័យមួយចំនួន បណ្ឌិតពាក់មួកមូលទន់ៗ ដែលត្រូវបានគេស្គាល់ថាជា មួក Tudor ជាជាង មួក Trencher។ មួកប្រភេទផ្សេងទៀត ដែលត្រូវបានគេប្រើប្រាស់នៅក្នុងសាកលវិទ្យាល័យមួយចំនួននៅក្នុងចក្រភព អង់គ្លេសគឺ មួក John Knox (ភាគច្រើនគឺនៅសាកលវិទ្យាល័យនៅប្រទេស Scottish) មួក Bishop Andrewes (ការបង្កើតថ្មីនៃមួកបុរាណ ដែលពាក់ដោយ Cambridge DDs) និង មួក Pileus (នៅ Sussex)។ នៅសាកលវិទ្យាល័យមួយចំនួន ដូចជាសាកលវិទ្យាល័យ Oxford ស្ត្រីអាចពាក់មួក Oxford ដែរ។

ប្រភេទផ្សេងទៀតនៃមួកនៅក្នុងចក្រភពអង់គ្លេស គឺមិនត្រូវបានគេពាក់នៅក្នុងកន្លែងពិធីទេ គឺជាទូទៅគេកាន់វា។ នៅក្នុងពិធីបញ្ចប់ការសិក្សាមួយចំនួនមួកមិនត្រូវបានចែកឱ្យបុរសទេគឺវាត្រូវបានគេធ្វើសម្រាប់តែស្ត្រីទេ ដែលជាអ្នកពាក់វានៅខាងក្នុងកន្លែងពិធី ឬអត់ពាក់ទាំងអស់



គ្នា។ការប្រតិបត្តិនេះបានធ្វើឱ្យសាកលវិទ្យាល័យមួយចំនួន នៅក្នុងចក្រភពអង់គ្លេស និងប្រទេសអៀកឡង់បង្កើតជាគំនិតថា ការពាក់មួកនេះត្រូវបានគេលុបបំបាត់នៅពេល ប្រឆាំងតវ៉ានឹងការមិនឱ្យស្ត្រីចូលរៀនមហាវិទ្យាល័យ។

ការយល់ខុសនៃច្បាប់ទម្លាប់មួយចំនួនបានក្លាយជាការយល់ច្រឡំ ដែលសាកលវិទ្យាល័យមួយចំនួនមិនប្រកាន់យកការពាក់មួក ហើយសាកលវិទ្យាល័យមួយចំនួនទៀត បានបោះបង់ការប្រើប្រាស់មួក ដោយសារមូលហេតុនយោបាយសង្គមក្នុងនោះគឺមានសាកលវិទ្យាល័យOpen។

សាកលវិទ្យាល័យ East Anglia គឺខូចកេរ្តិ៍ឈ្មោះខាងការរចនាម៉ូដមួកថ្មី ពីរដោយ Cecil Beaton ។ ទី១ គឺ Dan Dare ឬ Mickey Mouse ដែលវាគឺជាមួកលលាដ៍ក្បាលមានជាយតូចជុំវិញខាងលើសម្រាប់កម្រិតបរិញ្ញាបត្រ ហើយមួយទៀតគឺ tricon ដែលក្រឡាប់ ដោយមានរាងត្រីកោណជំនួសរាងការេនៅផ្នែកខាងលើគឺសម្រាប់ថ្នាក់អនុបណ្ឌិត។

### ៥.១.២-សម្លៀកបំពាក់សម្រាប់មន្ត្រីនៅក្នុងសាកលវិទ្យាល័យ

មន្ត្រីសាកលវិទ្យាល័យ ជាទូទៅប្រើប្រាស់សម្លៀកបំពាក់ខុសៗគ្នា និងយ៉ាងល្អិតល្អន់បំផុត។អធិការបតីនិងអនុអធិការបតីអាចនឹងប្រើប្រាស់អាវវែង ពណ៌ខ្មៅប្រភេទ damask (ពេលខ្លះមានកន្ទុយវែង) ដែលលម្អដោយខ្សែ និងឡេវពណ៌មាស ឬពណ៌ប្រាក់។ ទម្រង់សម្លៀក បំពាក់នេះមិនមែនជាសម្លៀកបំពាក់សម្រាប់តែបណ្ឌិតសភាចារ្យនោះទេ គឺសម្រាប់អ្នកមានឋានៈខ្ពស់ផងដែរ។ ក្រៅពីសម្លៀកបំពាក់នេះវាអាចមានសម្លៀកបំពាក់ទម្រង់ផ្សេងៗ ទៀតដូចជា Cappaclausa ឬ cope ដែលត្រូវបាន

ប្រើប្រាស់ដោយអនុអធិការបតីនៃសាកលវិទ្យាល័យ Cambridge នៅក្នុងពិធីមួយចំនួនឬប្រើប្រាស់ដោយ តំណាងរបស់គាត់ និងសម្រាប់បណ្ឌិតដែលបង្ហាញពីបេក្ខភាពទទួលសញ្ញាបត្រដែលត្រូវបានប្រើប្រាស់ម្តងដោយបណ្ឌិតខាងសាសនា។

### ៥.១.៣-ទំនៀមទម្លាប់ចក្រភពអង់គ្លេស

នៅក្នុងពិធីទទួលសញ្ញាបត្រ អ្នកទទួលសញ្ញាបត្រតែងតែ ស្លៀកពាក់ អាវធំវែងទៅតាមកម្រិតសញ្ញាបត្រដែលពួកគេទទួលមុនថ្ងៃបញ្ចប់ការសិក្សា។ នេះមិនត្រូវបានគេសង្កេតឃើញ នៅតាមបណ្តាមហាវិទ្យាល័យចំណាស់ៗនៅក្នុងចក្រភពអង់គ្លេសទេ ដូចជាសាកលវិទ្យាល័យ Oxford និង សាកលវិទ្យាល័យ St Andrews ជាដើម ដែលសាកលវិទ្យាល័យទាំងនោះមានសម្លៀកបំពាក់របស់ពួកគេរៀងៗខ្លួន។

សាកលវិទ្យាល័យ Oxford : នៅមុនពេលប្រគល់សញ្ញាបត្រ និស្សិតនឹងជាទូទៅពាក់ឯកសណ្ឋានជានិស្សិតមិនទាន់បញ្ចប់ការសិក្សា ឬ អាវនិស្សិត (ប្រសិនបើ ពួកគេនឹងទទួលសញ្ញាបត្របរិញ្ញាបត្រ) ឬ សម្លៀកបំពាក់និស្សិតបញ្ចប់ការសិក្សា ឬក៏សម្លៀកបំពាក់កម្រិត ដែលពួកគេទទួលចុងក្រោយគេ(ប្រសិនបើពួកគេនឹងទទួលសញ្ញាបត្រកម្រិតជាន់ខ្ពស់)។ បន្ទាប់ពីទទួលបានសញ្ញាបត្រហើយ ពួកគេចេញពីកន្លែងពិធីហើយប្រើសម្លៀកបំពាក់កម្រិត សញ្ញាបត្រថ្មីរបស់ពួកគេ បន្ទាប់មកទើប ត្រឡប់មកកន្លែងពិធីវិញ។ សម្រាប់កម្រិតបណ្ឌិតជាន់ខ្ពស់ និង អនុបណ្ឌិត ប្រសិនបើនិស្សិតកាន់សាសនាគ្រិស្ត អ្នកទាំងនោះ នឹងលុតជង្គង់នៅមុខអធិការបតី ឬអនុអធិការបតី (ក្នុងនាមជា លោកឪពុក) ហើយយកគម្ពីរ Bible មកគោះក្បាល។



សាកលវិទ្យាល័យ Cambridge: នៅមុនពេលទទួលសញ្ញាបត្រ និស្សិត មិនទាន់បញ្ចប់ការសិក្សាស្លៀកពាក់ឯកសណ្ឋានកម្រិត ដែលពួកគេមិនទាន់បញ្ចប់ការសិក្សាដែលពួកគេនឹងទទួល។ បន្ទាប់ពីថ្ងៃបញ្ចប់ ការសិក្សាពួកគេនឹងពាក់ឯកសណ្ឋានត្រឹមត្រូវទៅតាមសញ្ញាបត្រដែលពួកគេទទួល។ នៅក្នុងពិធីទទួលសញ្ញាបត្រ ពួកគេនឹងលុតជង្គង់ ឱបដៃនៅមុខអនុអធិការបតី ឬ អ្នកតំណាង ដោយគាត់យកដៃទាំងពីរទៅចាប់ឱបដៃរបស់អ្នកទទួល ហើយសូត្រភាសាឡាតាំង។

សាកលវិទ្យាល័យ St Andrews : មុនពេលទទួល អ្នកទទួលពាក់តែអាវកម្រិតសញ្ញាបត្រដែលគេនឹងទទួល។ នៅពេលប្រារព្ធពិធីពួកគេលុតជង្គង់នៅ មុខអធិការបតី ឬអនុអធិការបតី ដែលជាអ្នកប្រគល់សញ្ញាបត្រ ហើយគោះ ក្បាល របស់ពួកគេនឹងមួកមូលរ មួខណ: ដែលម្នាក់ផ្សេងទៀតបំពាក់មួកកម្រិតសញ្ញាបត្រថ្មីដែលពួកគេនឹងទទួល។

### ៥.២-សម្លៀកបំពាក់ទទួលសញ្ញាបត្ររបស់ប្រទេសអាមេរិក

សម្លៀកបំពាក់ទទួលសញ្ញាបត្រ នៅសហរដ្ឋអាមេរិក ទទួលឥទ្ធិពលមកពី អឺរ៉ុប។ មានច្បាប់អន្តរមហាវិទ្យាល័យដែលត្រូវបានបង្កើតឡើង អំពីឯកសណ្ឋានសម្រាប់ការទទួលសញ្ញាបត្រ ដែលភាគច្រើនត្រូវបានគេយកមកប្រើប្រាស់ បើទោះបីជាស្ថាប័នមួយចំនួនមិនប្រកាន់ខ្ជាប់ទាំងស្រុងក៏ដោយ ហើយមួយភាគតិចបានបោះបង់វាទៅហើយ។

ការអនុវត្តប្រើប្រាស់សម្លៀកបំពាក់ទទួលសញ្ញាបត្រដែលបង្ហាញនៅសាកលវិទ្យាល័យអាមេរិក ក្នុងអំឡុងពេលអាណានិគមនោះគឺទទួលឥទ្ធិពលពីអឺរ៉ុប។ និស្សិតភាគច្រើនដែលសិក្សានៅសាកលវិទ្យាល័យ

ហើយដែលទទួលរងអាណានិគមគឺតម្រូវឱ្យពាក់សម្លៀកបំពាក់ «ទំនៀមទម្លាប់សាកលវិទ្យាល័យ» គ្រប់ពេល។ វាគឺជាការអនុវត្តមួយដែលនៅសេសសល់រហូតដល់សម័យសង្គ្រាមស៊ីវិល នៅក្នុងប្រទេសអាមេរិក នៅវិទ្យាស្ថានជាន់ខ្ពស់ជាច្រើន។នៅតំបន់ខ្លះការស្លៀកពាក់បែបនេះ នៅតែមានការប្រើប្រាស់ ដូចជានៅ Sewance ដែល និស្សិតនៅក្នុងសមាគមនៅតែបន្តប្រើសម្លៀកបំពាក់នោះនៅក្នុងថ្នាក់រៀន។ បន្ទាប់ពីសង្គ្រាមស៊ីវិលបញ្ចប់ សម្លៀកបំពាក់នេះត្រូវបានគេប្រើប្រាស់សម្រាប់តែនៅពេលមានពិធីតែប៉ុណ្ណោះ។ វាមិនមានស្តង់ដារជាក់លាក់ណាមួយស្តីពីអត្ថន័យនៃសម្លៀកបំពាក់ទាំងនោះទេ។ នៅក្នុងឆ្នាំ១៩៨៣ គណៈកម្មការអន្តរសាកលវិទ្យាល័យដែលមានតំណាងមកពីសាកលវិទ្យាល័យល្បីៗត្រូវបានបង្កើតឡើង ដើម្បីបង្កើតប្រព័ន្ធទទួលស្គាល់សម្លៀកបំពាក់ទទួលសញ្ញាបត្រមួយ។ គណៈកម្មការបានជួបប្រជុំគ្នានៅសាកលវិទ្យាល័យ Columbia នៅក្នុងឆ្នាំ១៨៩៥ ហើយ បានប្រកាសប្រើប្រាស់ច្បាប់សម្រាប់ សម្លៀកបំពាក់ទទួលសញ្ញាបត្រ ដែលមានចែងពីការឆ្នៃម៉ូដនិងប្រភេទវត្ថុធាតុដើមដែលត្រូវប្រើប្រាស់សម្រាប់អាវវែងនិងកំណត់ពីពណ៌ដែលបញ្ជាក់ពីមុខជំនាញ ដែលពួកគេសិក្សា។ នៅឆ្នាំ១៩៣២ ក្រុមប្រឹក្សាអាមេរិកសម្រាប់ការអប់រំ (American Council on Education, ACE) បានទទួលសិទ្ធិពី គណៈកម្មការ ដើម្បីកំណត់ថាតើការផ្លាស់ប្តូរនេះត្រូវបានអនុវត្តដោយ សាកលវិទ្យាល័យ និងមហាវិទ្យាល័យដែលចូលរួមប្រជុំក្នុងឆ្នាំ ១៨៩៥ ប្រសិនបើមិនដូច្នោះទេ ត្រូវពង្រាងច្បាប់កែប្រែថ្មី ហើយប្រគល់មក គណៈកម្មការដើម្បីពិចារណា



លើចំណុចទាំងនោះ។ គណៈកម្មការត្រូវពិនិត្យលើពេលវេលា ហើយសម្រេចលើច្បាប់សម្រាប់សម្លៀកបំពាក់ ដែលមានប្រសិទ្ធភាពចាប់ពីឆ្នាំដែលអនុវត្តនោះមក។គណៈកម្មការសម្លៀកបំពាក់សិក្សា និងពិធីការ (Committee on Academic Costumes and Ceremonies) ត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាអាមេរិក សម្រាប់ការអប់រំនៅក្នុងឆ្នាំ១៩៥៩។

ទោះបីជាសំលៀកបំពាក់សិក្សា មិនត្រូវបានគេប្រើប្រាស់ក្រៅពីពិធីទទួលសញ្ញាបត្រក៏ដោយ ក៏វានៅតែទទួលបានប្រជាប្រិយភាពនិង បានរីកសាយភាយស្តីពី ការប្រើប្រាស់សម្លៀកបំពាក់នេះ ក្នុងពិធីបញ្ចប់ការសិក្សា ថ្នាក់វិទ្យាល័យ អនុវិទ្យាល័យ បឋមសិក្សា និង ថ្នាក់មត្តេយ្យ។

### ៥.២.១-សម្លៀកបំពាក់ទទួលសញ្ញាបត្រ

សម្លៀកបំពាក់បណ្ឌិតជាទូទៅគឺពណ៌ខ្មៅ ទោះបីជាសាលាមួយចំនួនប្រើសម្លៀកបំពាក់តាមពណ៌សាលារបស់ពួកគេក៏ដោយ។ ជាទូទៅសម្លៀកបំពាក់បណ្ឌិត ស្រដៀងនឹងសម្លៀកបំពាក់របស់និស្សិតបញ្ចប់ថ្នាក់បរិញ្ញាដែរ គ្រាន់តែបន្ថែមឆ្នូត ក្រណាត់កម្មីរ បន្ទះនៅលើដៃអាវនិងផ្នែកខាងមុខនៃអាវ។ ចំពោះពណ៌ខ្មៅ ឬពណ៌ផ្សេងទៀតនៃការតុបតែងបញ្ជាក់ពីជំនាញ ដែលពួកគេសិក្សា។ ប៉ុន្តែសម្រាប់ Ph.D. ទោះបីជាសញ្ញាបត្រ ដែលប្រគល់ឱ្យស្ថិតក្នុងវិស័យផ្សេងគ្នាក៏ដោយ ក៏ពណ៌ដែលគេប្រើគឺ មានតែពណ៌ខៀវក្រមៅទេដែលគេប្រើ បើទោះបីជាក្នុងផ្នែកអ្វីក៏ដោយ។ ឧទាហរណ៍ ប្រសិនបើមិនប្រើពណ៌ខ្មៅទេ Ph.D. ផ្នែកសាសនា(Ph.D. in Theology) នឹងប្រើអាវកម្មីពណ៌ខៀវ ឬប្រើពណ៌ក្រហម។ អាវវែងមានដៃវែងពេញ មិនមែនដៃរាងប៉ោងដូចអាវរបស់

បរិញ្ញាបត្រទេ។ អាវមួយចំនួនមានបន្ថែមក្រវាត់ក ឬ បូនៅពេលបិទ។ វាត្រូវបានគេរចនាពាក់បិទ ឬបើកខាងមុខ។

### ៥.២.២-ក្រណាត់គ្រប

សម្រាប់ Ph.D. គឺក្រណាត់គ្របមានបណ្ដោយ៥ អ៊ីញ (ពណ៌ខៀវក្រម៉ៅ) ក្រណាត់កម្មី ដែលបញ្ជាក់ពីថ្នាក់បណ្ឌិតនិងនៅក្នុងផ្នែកទស្សនវិជ្ជា។ យើងអាចកត់សម្គាល់ថា តើមកពីសាកលវិទ្យាល័យណា និងកម្រិតអ្វីតាមរយៈពណ៌ និងគំរូឆ្នូតខ្សែនៅលើក្រណាត់គ្រប។ ចំពោះអាវដែលរចនាក្រណាត់កម្មីពណ៌ខ្មៅខាងមុខ និងដៃអាវដែល Inter-collegiate Academic Code បានចែង គឺសម្រាប់ថ្នាក់បណ្ឌិតនិងសម្រាប់ក្រុមប្រឹក្សាភិបាលមហាវិទ្យាល័យ ឬសាកលវិទ្យាល័យ។

នៅក្នុងមហាវិទ្យាល័យនិងសាកលវិទ្យាល័យជាច្រើន នៅក្នុងប្រទេសអាមេរិកពណ៌ថ្មេររបស់ក្រណាត់គ្របកម្មី គឺមានលក្ខណៈផ្សេងគ្នា អាស្រ័យលើជំនាញសិក្សា និងកម្រិតសញ្ញាបត្រដែលត្រូវទទួល។ ឧទាហរណ៍ អនុបណ្ឌិតសិល្បៈ(Master of Arts)ផ្នែកសារព័ត៌មានពាក់ពណ៌ក្រហមជាំ ដែលតំណាងអ្នកសារព័ត៌មាន ជាជាងការពាក់ពណ៌ សដែលបញ្ជាក់ពីផ្នែកសិល្បៈ។

ច្បាប់បានចែងថា "វាមានលក្ខណៈសមស្របសម្រាប់សម្លៀកបំពាក់កម្រិតបរិញ្ញាដោយមិនចាំបាច់មានក្រណាត់គ្រប"។ វិទ្យាស្ថាន ជាច្រើន ជាពិសេសវិទ្យាស្ថានធំៗបានឈប់ប្រើប្រាស់ក្រណាត់គ្រប សម្រាប់ថ្នាក់បរិញ្ញាបត្រនៅក្នុងពិធីចែកសញ្ញាបត្រទាំងអស់ ថ្វីបើអ្នកបញ្ចប់ការសិក្សានៅតែត្រូវបានគេតម្រូវឱ្យពាក់ នៅពេលដែលសញ្ញាបត្រ ត្រូវបានគេ



ប្រគល់ឱ្យ។ បណ្ឌិតកិត្តិយស ឬបណ្ឌិត ជាញឹកញាប់ត្រូវបាន គេប្រគល់ឱ្យដោយអ្នកសិក្សា ដែលមានឋានៈខ្ពស់នៃវិទ្យាស្ថានមួយនូវ ក្រណាត់គ្របនៅឯវេទិកា។

ក្រណាត់គ្របតែមួយទេ ដែលនឹងត្រូវពាក់នៅពេលប្រគល់ម្ដងៗ។ ពណ៌ថ្មេរមិនបានបញ្ចូល ឬ បង្ហាញរួមគ្នាដើម្បីបញ្ជាក់ថា មានជំនាញច្រើនលើសពីមួយ។ អ្នកដែលមានសញ្ញាបត្រ ច្រើនតែកម្រិតដូចគ្នាអាចពាក់សម្លៀកបំពាក់ជំនាញណាមួយក៏បាន។ ច្បាប់បានចែងមិនអនុញ្ញាតឱ្យលាយនិងផ្គូផ្គងគ្នាឡើយ។ អាវផាយដែលប្រើប្រាស់ដោយវិទ្យាស្ថានសិក្សាមួយ និងសញ្ញា បត្រដែលគេប្រគល់ឱ្យដោយ វិទ្យាស្ថាននោះទៅអ្នកពាក់ (ដែលវាមានបញ្ជាក់ ពីពណ៌ថ្មេរ ប្រវែង ក្រណាត់គ្រប និងម៉ូដអាវ) ត្រូវតែស្របគ្នា។ មានករណី លើកលែងមួយ សម្រាប់មន្ត្រីរបស់វិទ្យាស្ថានដែលនៅពេលកំពុងស្លៀកសម្លៀកបំពាក់ថ្នាក់បណ្ឌិតអាចបង្ហាញក្រណាត់គ្របសម្រាប់សញ្ញាបត្រណាមួយ ក៏បានដែលទទួលបានពីវិទ្យាស្ថាន។

### ៥.២.៣-មួក

មួកត្រូវបានគេតម្រូវឱ្យប្រើដូចមានចែងក្នុងច្បាប់។ វត្ថុធាតុដើមគឺត្រូវតែដូចនឹងអាវ។ ករណីលើកលែងគឺ កម្មី ដែលត្រូវបានប្រើសម្រាប់តែថ្នាក់បណ្ឌិតប៉ុណ្ណោះ ដែលឃើញមានពហុជ្រុង(៤ ៦ឬ៨) ប៉ុន្តែមួកមានបួនជ្រុង គឺតម្រូវឱ្យប្រើប្រាស់ ហើយមានតែពណ៌ខ្មៅមួយគត់។

### ៥.២.៤-ខ្សែរំយោល

ខ្សែរំយោលពាក់នៅលើមួក គឺពណ៌ខ្មៅ ដែលបញ្ជាក់ពីពណ៌របស់មហាវិទ្យាល័យ ឬសាកលវិទ្យាល័យណាមួយ។ ខ្សែរំយោលត្រូវបានគេ

ប្រើសម្រាប់បង្ហាញពីសមាជិកភាពនៅក្នុងសង្គមកិត្តិយសជាតិ (National Honor Societies) ឬរង្វាន់ផ្សេងៗ។ ប៉ុន្តែយោងតាម ACE បានចែងថា "ខ្សែរំយោល គួរតែមានពណ៌ខ្មៅ ឬពណ៌សមរម្យណាមួយ អាស្រ័យលើជំនាញ" ហើយលើកលែងតែពណ៌មាសមួយទេ។ ចំពោះមួកកម្មី និងខ្សែពណ៌មាសគឺប្រើប្រាស់សម្រាប់ថ្នាក់បណ្ឌិត។ មានមហាវិទ្យាល័យ និងសាកលវិទ្យាល័យមួយចំនួន អនុវត្តការដាក់ខ្សែ រំយោលទៅម្ខាង នៅថ្ងៃទទួលសញ្ញាបត្រ ប៉ុន្តែក្នុងសម័យទំនើបការ អនុវត្តនេះពុំត្រឹមត្រូវទេ ដោយសារខ្យល់បក់។ឧទាហរណ៍ដូចជា សាកលវិទ្យាល័យ Oxford សម្រាប់អ្នកមិនទាន់ទទួលសញ្ញាបត្រចាប់ផ្តើមពិធីដោយដាក់ខ្សែរំយោល នៅខាងស្តាំបន្ទាប់មកបង្វែរទៅខាងឆ្វេង។សម្រាប់អនុបណ្ឌិតនិងបណ្ឌិត ខ្សែរំយោលជាទូទៅគឺគេបែរទៅខាងឆ្វេងជានិច្ច។

### ៥.២.៥-ពណ៌សម្រាប់អន្តរសាកលវិទ្យាល័យ

ពណ៌ត្រូវបានគេប្រើប្រាស់សម្រាប់ផ្នែកផ្សេងៗពីគ្នានៃជំនាញសិក្សា ដែលវាបានក្លាយជា ស្តង់ដាមួយសម្រាប់សហរដ្ឋអាមេរិក បង្កើតឡើងដោយ ការិយាល័យអន្តរសាកលវិទ្យាល័យនៃសម្លៀកបំពាក់សិក្សា និងត្រូវបានទទួលស្គាល់ដោយក្រុមប្រឹក្សាអាមេរិកសម្រាប់ការអប់រំ (ACE) លើច្បាប់សម្លៀកបំពាក់សិក្សា Academic Costume Codes។

ខាងក្រោមនេះជា តារាងពណ៌ដែលគេប្រើទៅតាមមហាវិទ្យាល័យ និងឯកទេសខុសៗគ្នា ៖



| ល.រ | មហាវិទ្យាល័យ/ជំនាញ | ពណ៌ |
|---|---|---|
| ០១ | កសិកម្ម | ពណ៌ពោតទុំ |
| ០២ | សិល្បៈ អក្សរសាស្ត្រ និង មនុស្សសាស្ត្រ | ពណ៌ស |
| ០៣ | ពាណិជ្ជកម្ម គណនេយ្យ និង អាជីវកម្ម | ពណ៌ប្រផេះ |
| ០៤ | ទន្តសាស្ត្រ | ពណ៌ស្វាយ( ខ្ចី ) |
| ០៥ | សេដ្ឋកិច្ច | ពណ៌ប្រាក់ |
| ០៦ | អប់រំ | ពណ៌ខៀវស្រាល |
| ០៧ | វិស្វកម្ម | ពណ៌ទឹកក្រូច |
| ០៨ | វិចិត្រសិល្បៈ ស្ថាបត្យកម្ម | ពណ៌ត្នោត |
| ០៩ | រុក្ខាប្រមាញ់ បរិស្ថាន | ពណ៌ឈាមជ្រូក |
| ១០ | សារព័ត៌មាន | ពណ៌ក្រហមដាំ |
| ១១ | ច្បាប់ | ពណ៌ស្វាយ |
| ១២ | វិទ្យាសាស្ត្របណ្ណាល័យ គ្រប់គ្រងព័ត៌មាន | ពណ៌លឿងខ្ចី |
| ១៣ | វេជ្ជសាស្ត្រ | ពណ៌បៃតង |
| ១៤ | តន្ត្រី | ពណ៌ផ្កាឈូក |
| ១៥ | គិលានុបដ្ឋាយិកា | ពណ៌ទឹកក្រូច( ស្រាល ) |
| ១៦ | វាគ្មិន សុន្ទរកថា ទំនាក់ទំនង | ពណ៌ទឹកប្រាក់ប្រផេះ |
| ១៧ | ឱសថសាស្ត្រ | ពណ៌ទឹកសណ្តែកខៀវ |

| | | |
|---|---|---|
| ១៨ | ទស្សនវិជ្ជា | ពណ៌ខៀវចាស់ |
| ១៩ | រូបវាងកាយសាស្ត្រ<br>ការព្យាបាលដោយដៃ<br>ការព្យាបាលដោយចលនា | ពណ៌ស្លែ(ខ្ចី) |
| ២០ | រដ្ឋបាលសាធារណៈ<br>ច្បាប់សាធារណៈ សេវា អន្តរជាតិ | ពណ៌ផ្ទៃមេឃ |
| ២១ | សុខភាពសាធារណៈ | ពណ៌ផ្កាឈូក(ខ្ចី) |
| ២២ | វិទ្យាសាស្ត្រ សង្គម និងធម្មជាតិ | ពណ៌លឿង(មាស) |
| ២៣ | កិច្ចការសង្គម | ពណ៌បៃតងខ្ចី |
| ២៤ | វិទ្យាសាស្ត្រខាងសាសនា | ពណ៌ក្រហម |
| ២៥ | បសុពេទ្យ | ពណ៌ប្រផេះ |

ក្នុងឆ្នាំ១៩៨៦ក្រុមប្រឹក្សាអាមេរិកសម្រាប់ការអប់រំបានធ្វើបច្ចុប្បន្នភាពច្បាប់ និងបន្ថែមឃ្លាខាងក្រោមបញ្ជាក់ពីការប្រើប្រាស់ពណ៌ខៀវក្រមៅ សម្រាប់បណ្ឌិតខាងទស្សនវិជ្ជា (Ph.D.) ដែលទទួលបានតាមជំនាញនីមួយៗ។

## ៥.២.៦-គ្រឿងលម្អ

គ្រឿងមួយចំនួនទៀតដូចជា ខ្សែបំពាក់ក ក្រណាត់បង់ក ខ្សែបំពាក់ស្មា ជាដើមបង្ហាញពីការជោគជ័យក្នុងការសិក្សា ឬ កិត្តិយសត្រូវបានគេប្រើដោយឡែកក្នុងវិទ្យាស្ថានមួយចំនួន។ ទោះបីជាយ៉ាងណា ACE មិនអនុញ្ញាតឱ្យប្រើគ្រឿងទាំងនោះលើ ឬលើសពីច្បាប់ដែលបានចែងទេ។



សម្លៀកបំពាក់ទទួលសញ្ញាបត្ររបស់ប្រទេសអាមេរិក ជាទូទៅគឺបិទ ខាងមុខ និង ពាក់ជាមួយមួក ព្រមទាំងក្រណាត់គ្រប។ នៅលើសម្លៀកបំពាក់បរិញ្ញាបត្រ(Baccalaureate)គេសង្កេតឃើញមាន ក្រមាបង់ក ខ្សែពាក់ស្មា ឬ ខ្សែពាក់ក។

## ៥.៣-សម្លៀកបំពាក់ទទួលសញ្ញាបត្រប្រទេសបារាំង

សម្លៀកបំពាក់ទទួលសញ្ញាបត្រនៅក្នុងប្រទេសបារាំង ត្រូវបានគេហៅថា Toge ដែលវាស្រដៀងនឹងសម្លៀកបំពាក់ចៅក្រមក្នុង ប្រទេសបារាំងលើកលែងតែពណ៌ប៉ុណ្ណោះដែលខុសគ្នាទៅតាមជំនាញអ្នកបញ្ចប់ការសិក្សា។ សព្វថ្ងៃនេះវាត្រូវបានគេប្រើតិចតួចលើកលែង តែបណ្ឌិតក្នុងកម្មវិធីបើកបវេសន កាលឆ្នាំសិក្សាថ្មី ឬ ពីធីប្រគល់សញ្ញាបត្រថ្នាក់បណ្ឌិត។ សម្រាប់ថ្នាក់បណ្ឌិតមានដូចខាងក្រោម ៖

-អាវវែងដែលមានជួរឡេវវែង (ជាប្រពៃណីវាមានចំនួន ៣៣ ប៉ុន្តែបច្ចុប្បន្ននេះអាចមានតិចជាង)នៅផ្នែកខាងមុខនិងកន្ទុយនៅផ្នែក ខាងក្រោយ (ដែលសម្លៀកបំពាក់បច្ចុប្បន្នមិនអាចមើលឃើញទេ ប៉ុន្តែវាត្រូវបានគេភ្ជាប់ នឹងឡេវមួយនៅផ្នែកខាងក្នុងនៃអាវវែងនោះ)។ អាវវែង គឺមានពីរពណ៌គឺពណ៌ខ្មៅ និងពណ៌ស្តង់ដានៃជំនាញសិក្សារបស់អ្នកទទួលសញ្ញាបត្រជាមួយ និង Simarras (បន្ទះតូចបញ្ឈរវាងវែងពីរនៅពីមុខអាវ)។

-Epitoge (Epitoga) : ជាក្រណាត់មួយផ្ទាំងដែលមានធ្នូតរោមសំឡី ពណ៌ស (ធ្នូតបីសម្រាប់ថ្នាក់បណ្ឌិត) ភ្ជាប់ដោយឡេវមួយនៅស្មាខាងស្តាំ ជាមួយកន្ទុយរាងត្រីកោណវែងស្មើងនៅខាងមុខ និងកន្ទុយ

រាងត្រីកោណខ្លីធំនៅខាងក្រោយ (កន្ទុយទាំងពីរគឺមានធ្នូតរោមសត្វ) ហើយពណ៌របស់វាគឺ អាស្រ័យលើជំនាញសិក្សា។ Epitoga នេះបាន វិវត្តមកពីក្រណាត់គ្រប ម្ល៉ោះហើយបានជាសម្លៀកបំពាក់បារាំងមិនមាន ក្រណាត់គ្រប។

-ខ្សែក្រវាត់វែងមួយពណ៌ខ្មៅឬពណ៌ស ទៅតាមជំនាញសិក្សាមាន ជាយខាងចុង (អាចជាពណ៌មាស ឬដូចពណ៌ខ្សែក្រវាត់) ហើយភ្ជាប់ នឹងផ្នែកក្បាល។

-មួកដែលមានពណ៌អាស្រ័យលើជំនាញសិក្សា រចនាមានធ្នូត ពណ៌មាស គឺសម្រាប់តែបុរសទេ ហើយវាមិនត្រូវបានគេពាក់ទេ គឺគេ កាន់វា (ដោយសារតែសម្លៀកបំពាក់ទទួលសញ្ញាបត្រនៅប្រទេសបារាំង គឺ មិនដែលពាក់នៅទីខាងក្រៅទេ ហើយបុរសគឺគេមិនតម្រូវឱ្យពាក់ មួកនៅខាងក្នុងទេ) ហើយជាញឹកញាប់ត្រូវបានគេលុបចោល។

-ស្រោមដៃពណ៌សមិនត្រូវបានគេពាក់ទៀតឡើយ។

សាកលវិទ្យាធិការ អធិការបតី ឬ ប្រធាន ប្រើសម្លៀកបំពាក់ជាក់លាក់ ដែរគឺពណ៌ស្វាយ។

តារាងខាងក្រោមនេះនឹងបង្ហាញពីពណ៌ ដែលគេប្រើប្រាស់ទៅ តាមជំនាញសិក្សាផ្សេងៗគ្នា៖

| ល.រ | មុខជំនាញសិក្សា | ពណ៌ |
|---|---|---|
| ០១ | វិទ្យាសាស្ត្រខាងសាសនា | ពណ៌ស្វាយ |
| ០២ | ច្បាប់ | ពណ៌ក្រហមប្រាល |
| ០៣ | វេជ្ជសាស្ត្រ (និង ផ្នែកដែលទាក់ទងនឹង សុខភាព) | ពណ៌ក្រហមខ្ចី |
| ០៤ | វិទ្យាសាស្ត្រ (ពិត និង ពិសោធ) | ពណ៌ក្រហមស្រាល |
| ០៥ | សិល្បៈ អក្សរសាស្ត្រ ទស្សនវិទ្យាមនុស្សសាស្ត្រ | ពណ៌គគី(ដី) |



សម្លៀកបំពាក់នេះមានពីរប្រភេទគឺ ប្រភេទទំហំតូចនិងទំហំធំ។ ប្រភេទនីមួយៗមានចំណុចកត់សម្គាល់ និងទម្រង់ខុសប្លែកគ្នាត្រង់ វត្តមាន ឬអវត្តមានរបស់ មួកនិងការបែងចែកពណ៌នៅលើអាវ។

១-ទំហំតូច ៖ អាវមានពណ៌ខ្មៅសុទ្ធ លើកលែងតែ Simarras ដែល ពណ៌របស់វាអាស្រ័យលើមុខជំនាញសិក្សា ឡេវពណ៌ខ្មៅ ខ្សែ ឆៀងពណ៌ខ្មៅ។

២-ទំហំធំ ៖ អាវមានពណ៌ខ្មៅចន្លោះ Simarrasពណ៌ខ្មៅ និង ពណ៌ទៅតាមមុខជំនាញសិក្សានៅចំហៀងនិងនៅលើដៃអាវ។ពណ៌របស់ ឡេវអាវនិងខ្សែឆៀងគឺ យកតាមពណ៌របស់មុខជំនាញសិក្សា ចំណែក ជាយមានពណ៌ដូច គ្នា ឬពណ៌មាស។

នៅក្នុងឱកាសសំខាន់ៗសម្លៀកបំពាក់ទំហំធំគឺប្រើជាមួយក្រវាត់ក ពណ៌ ស ហើយទំហំតូចប្រើជាមួយក្រវាត់កពណ៌ខ្មៅ។

### ៥.៤-សម្លៀកបំពាក់ទទួលសញ្ញាបត្រប្រទេសអាល្លឺម៉ង់

សម្លៀកបំពាក់ទទួលសញ្ញាបត្ររបស់ប្រទេសអាល្លឺម៉ង់ត្រូវបានគេ ឱ្យឈ្មោះថា «Talar» គឺវាមានដូចជា អាវវែងពណ៌ខ្មៅដៃធំស្រដៀងនឹង នៅអឺរ៉ុប និងអាមេរិកដែរ។ វាបង្ហាញពីសម្លៀកបំពាក់សាមញ្ញរបស់ អ្នកសិក្សានៅសម័យកណ្ដាល។

នៅក្នុងប្រទេសអាល្លឺម៉ង់ មានតែសាកលវិទ្យាធិការនាយកសាស្ត្រាចារ្យនិងគ្រូបង្រៀនទេដែលប្រើប្រាស់សម្លៀកបំពាក់នេះមិនមែនសម្រាប់និស្សិតឬអ្នកបញ្ចប់ការសិក្សាទេ។សាកលវិទ្យាល័យក្នុងប្រទេសអាល្លឺម៉ង់នីមួយៗមានប្រព័ន្ធនៃការប្រើប្រាស់ពណ៌ និងក្រណាត់រៀងៗខ្លួន ដែលខុសពីសាកល វិទ្យាល័យនៅចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក។ បន្ទាប់ពីបដិវត្តិន៍ដ៏អស្ចារ្យ របស់និស្សិតឆ្នាំ១៩៦៧ មកសាកលវិទ្យាល័យក្នុងប្រទេសអាល្លឺម៉ង់ទាំងអស់បានបោះបង់សម្លៀកបំពាក់ទាំងនោះចោលពីព្រោះពួកគេគិតថា វាជាគំនិត អភិរក្ស និយម ដែលរងឥទ្ធិពលពីពួកសង្គមនិយម កាលពីសម័យនោះ។

វាមិនមែនរហូតមកដល់សម័យកាលនេះទេ ដែលសាកលវិទ្យា-ល័យមួយចំនួនបានចាប់ផ្ដើមអនុវត្តប្រពៃណីសម្លៀកបំពាក់ម្ដងទៀត។ ឧទាហរណ៍ សាកលវិទ្យាល័យ Bonn បានអនុវត្តប្រពៃណីនេះ ឡើងវិញនៅក្នុងឆ្នាំ២០០៥ ជាលើកដំបូងចាប់តាំងពីឆ្នាំ១៩៦៩។

សព្វថ្ងៃនេះសាកលវិទ្យាល័យថ្មីៗ ជាច្រើនកំពុងប្រើប្រាស់សម្លៀកបំពាក់នេះ។ ឧទាហរណ៍ Anglo របស់អាមេរិក ដោយមិនយកតាមប្រពៃណីចាស់ទេ។

### ៥.៥-សម្លៀកបំពាក់ទទួលសញ្ញាបត្រនៅប្រទេសព័រទុយហ្គាល់

ការប្រើប្រាស់សម្លៀកបំពាក់ទទួលសញ្ញាបត្រ សម្រាប់និស្សិតមិនទាន់បញ្ចប់ការសិក្សានៅសាកលវិទ្យាល័យ ភាគច្រើននៅប្រទេសព័រទុយហ្គាល់និងបណ្ឌាវិទ្យាស្ថានអប់រំជាន់ខ្ពស់នានា នៅតែរីកសាយភាយ



និងទទួលបានការគាំទ្រក្នុងទស្សវត្សរ៍ថ្មីៗកន្លងមកនេះ។ សម្លៀកបំពាក់ (Traje) មានខោពណ៌ខ្មៅ (ឬសំពត់សម្រាប់និស្សិតនារី) អាវពណ៌សក្រវាត់កពណ៌ខ្មៅ អាវធំក្រៅពណ៌ខ្មៅ (ហៅថា batina) និង អាវវែងពណ៌ខ្មៅ។បណ្ឌាវិទ្យាស្ថានអប់រំជាន់ខ្ពស់មួយចំនួនរបស់ប្រទេសព័រទុយហ្គាល់ មានសម្លៀកបំពាក់ខុសប្លែកពីសម្លៀកបំពាក់ ដែលមានដើមកំណើតពីសាកលវិទ្យាល័យ Coimbra។

### ៥.៦-សម្លៀកបំពាក់ទទួលសញ្ញាបត្រនៅប្រទេសស៊ុយអែដ និងហ្វាំងឡង់

ប្រទេសស៊ុយអែដនិងហ្វាំងឡង់ មានប្រពៃណីប្រហាក់ប្រហែលគ្នាចំពោះសម្លៀកបំពាក់ទទួលសញ្ញាបត្រ។ សម្រាប់ខណៈដែលការសិក្សាល្អក្រវាត់កពណ៌សត្រូវបានគេប្រើប្រាស់ ប៉ុន្តែរួមនឹងមួកពិសេសមួយផ្សេងទៀត។

និស្សិតបច្ចេកវិទ្យាក្នុងប្រទេសស្វីដឺននិងហ្វាំងឡង់ ពាក់មួកពិសេសម៉្យាងហៅថា Student-mossa។ វាស្រដៀងនឹងមួកដែកពាក់ដោយសិស្សបញ្ចប់ការសិក្សានៅវិទ្យាល័យក្នុងប្រទេសទាំងពីរ ប៉ុន្តែទ្រង់ទ្រាយនិងសញ្ញានៅលើមួកបញ្ជាក់ថា និស្សិតនោះមកពីសាកលវិទ្យាល័យណា។ ទោះបីជាសាកលវិទ្យាល័យខុសគ្នា មានវិន័យខុសៗគ្នាចំពោះការប្រើប្រាស់មួកក៏ដោយ តែដោយវាមិនត្រូវបានគេផ្ដល់ឱ្យឡើយមុនពេលនិស្សិតនោះបញ្ចប់ការសិក្សាឆ្នាំទី១។

នៅក្នុងប្រទេសទាំងពីរ សាកលវិទ្យាល័យជាច្រើនមានមួកបណ្ឌិតសម្រាប់អ្នក ដែលបានបញ្ចប់ Ph.D. ឬ សញ្ញាបត្រស្មើ។ នៅសាកលវិទ្យាល័យមួយចំនួន កង(ring)ត្រូវបានគេប្រគល់ឱ្យជាមួយនឹងមួក។

ជាទូទៅ វត្ថុធាតុប្រើសម្រាប់កាត់សម្លៀកបំពាក់ទទួលសញ្ញាបត្រ គឺ ទទួលរងឥទ្ធិពលមកពីធាតុអាកាសរបស់ទីតាំងគ្រឹះស្ថាន ឬ ទីកន្លែងដែលអ្នកបញ្ចប់ការសិក្សានឹងពាក់វា។ ក្នុងករណីមួយណាក៏ដោយ ACE អនុញ្ញាតឱ្យមានផាសុកភាពដល់អ្នកពាក់ និងសុខចិត្តប្រើវត្ថុធាតុស្រាលសម្រាប់តំបន់អាកាសធាតុត្រូពិច។

កាលពីសម័យមុន រោមសត្វត្រូវបានគេប្រើប្រាស់ដើម្បីធ្វើខ្សែបន្ទាត់នៅលើក្រណាត់គ្រប (ជាពិសេសនៅចក្រភពអង់គ្លេស) គេប្រើរោមទន្សាយនិងរោមចៀម។

អាវរបស់បណ្ឌិត ជាធម្មតាប្រើឡែនរោមចៀម Panama សំពត់ព្រៃ (damask) សំពត់ចរបាប់ (brocade) ហើយវាមានព៌ណខ្លាំងដើម្បីចែកឱ្យដាច់ពីកម្រិតថ្នាក់ទាប[២]។

[២] www.newadwadvent.org/cathen/05072b.htm



## ផ្នែកទី២
## ពិធីថ្វាយគោរមងារកិត្តិឧត្តមបណ្ឌិត និងសញ្ញាបត្រកិត្តិបណ្ឌិត នៃរាជបណ្ឌិត្យសភាកម្ពុជា ថ្វាយ ប្រគេនចំពោះព្រះអរិយសង្ឃជាន់ខ្ពស់ ៩ អង្គ នៃព្រះរាជាណាចក្រកម្ពុជា

## សុន្ទរកថា
## លោកជំទាវបណ្ឌិតសភាចារ្យ ខ្លួត ធីតា
## ប្រធានរាជបណ្ឌិត្យសភាកម្ពុជា
### វិមានសន្តិភាព ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៣

-សូមក្រាបថ្វាយបង្គំ សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី **បួរ គ្រី** សម្តេចព្រះមហាសង្ឃ រាជនៃគណៈធម្មយុត្តិកនិកាយនៃព្រះរាជាណាចក្រកម្ពុជាជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់!

- សូមក្រាបថ្វាយបង្គំសម្តេចព្រះសង្ឃព្រះអរិយសង្ឃទាំង៨ អង្គដែលជាជយលាភី ជាទីគោរពសក្ការៈ ដ៏ខ្ពង់ខ្ពស់ !

- សូមក្រាបថ្វាយបង្គំសម្តេចព្រះសង្ឃនាយករង ព្រះថេរានុថេរៈគ្រប់ព្រះអង្គ ជាទីគោរពសក្ការៈ!

- សូមគោរព សម្តេចអគ្គមហាសេនាបតីតេជោបណ្ឌិតសភាចារ្យ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!

- សូមគោរព ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ជាទីគោរពដ៏ខ្ពង់ខ្ពស់!

-សូមគោរពឯកឧត្តម ឧបនាយករដ្ឋមន្ត្រី លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ ព្រឹទ្ធសភា រដ្ឋសភា ឯកឧត្តម លោកជំទាវ រដ្ឋមន្ត្រី អនុរដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ាជាទីគោរពរាប់អាន !



- ឯកឧត្តមបណ្ឌិតសភាចារ្យ សាស្ត្រាចារ្យ បណ្ឌិត ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីនិងប្អូនៗនិស្សិត ភ្ញៀវជាតិ និងអន្តរជាតិ ជាទីមេត្រី!

ថ្ងៃនេះថ្នាក់ដឹកនាំមន្ត្រីរាជការរាជបណ្ឌិត្យសភាកម្ពុជាទាំងមូល និងខ្ញុំព្រះករុណា នាងខ្ញុំផ្ទាល់មានកិត្តិយស និងមោទនភាពយ៉ាងក្រៃលែង ដែលបានរៀបចំពិធីប្រគល់គោរមងារកិត្តិឧទ្ទេសបណ្ឌិតថ្វាយសម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី **បួរ គ្រី** និង គោរមងារកិត្តិសេដ្ឋាបណ្ឌិតជូនឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, និងសញ្ញាបត្រកិត្តិបណ្ឌិតប្រគេនសម្តេចព្រះពោធិវង្ស **អ៊ំ លឹមហេង**, សម្តេចព្រះវនរ័ត **ណយ ច្រឹក**, សម្តេចព្រះឧត្តមបញ្ញា **ដួង ផង់**, សម្តេចឧត្តមវង្សា **មួង រ៉ា** និងព្រះមុនីកោសល **ហ៊ុល សុវណ្ណ** នាពេលនេះ។ ពិធីដ៏មានអត្ថន័យនាថ្ងៃនេះ នឹងត្រូវចារឹកទុកក្នុងក្រាំងប្រវត្តិសាស្ត្រ របស់រាជបណ្ឌិត្យសភាកម្ពុជាជារៀងរហូត។ ជាមួយគ្នានេះផងដែរ នាងខ្ញុំសូមទូលថ្វាយ ប្រគេន និងជម្រាបជូនដល់អង្គពិធីទាំងមូលមេត្តាជ្រាបថា កាលពីថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១១ រាជបណ្ឌិត្យសភាកម្ពុជា បានរៀបចំពិធីអបអរសាទរថ្វាយសញ្ញាបត្រកិត្តិបណ្ឌិតចំពោះសម្តេច ព្រះធម្មលិខិត លាស់ ឡាយ ប្រធានថេរសភាព្រះពុទ្ធសាសនាដែលសម្តេចមានព្រះជន្មាយុ ច្រើនព្រះវស្សា ហើយនិងមានព្រះរាជជរាពាធផង។ ហើយនៅថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៣ កន្លងទៅនេះ រាជបណ្ឌិត្យសភាកម្ពុជា ក៏បានរៀបចំពិធីអបអរសាទរថ្វាយគោរមងារកិត្តិឧទ្ទេសបណ្ឌិត ចំពោះសម្តេចចព្រះអគ្គមហាសង្ឃ

រាជាធិបតី ទេព វង្ស សម្តេចព្រះមហាសង្ឃរាជនៃគណៈមហានិកាយ និង សម្តេចព្រះមហាសុមេធាធិបតី នន្ទ ង៉ែត សម្តេចព្រះសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជាដែរផង ដោយសម្តេចទាំងពីរកំពុងរក្សាព្រះរាជសុខភាពជាប្រចាំ។

មន្ត្រីសង្ឃជាន់ខ្ពស់និងឥស្សរជនឆ្នើមខាងលើ សុទ្ធតែបានចូលរួមចំណែកយ៉ាងសកម្មក្នុងការ កសាងនូវសមិទ្ធផលធំៗ ទាំងក្នុងវិស័យព្រះពុទ្ធសាសនា និងក្នុងសេដ្ឋកិច្ចសង្គម ក្រោមមាគ៌ាដឹកនាំដ៏ ឈ្លាសវៃរបស់សម្តេចអគ្គមហាសេនាបតីតេជោបណ្ឌិតសភាចារ្យ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

គោរមងារកិត្តិឧទ្ទេសបណ្ឌិត និងកិត្តិសេដ្ឋាបណ្ឌិត ព្រមទាំងសញ្ញាបត្រកិត្តិបណ្ឌិតជាគោរមងារ និងសញ្ញាបត្រកិត្តិយសដ៏ឧត្តុង្គឧត្តមរបស់រាជបណ្ឌិត្យសភាកម្ពុជា។ គោរមងារ និងសញ្ញាបត្រនេះស្នើប្រគល់ជូនឥស្សរជន ឬបញ្ញជន ដែលមានគុណបំណាច់ និងស្នាដៃជាប្រយោជន៍ចំពោះជាតិមាតុភូមិ ក្នុងការអភិវឌ្ឍនូវសង្គមវប្បធម៌ សាសនា និងសេដ្ឋកិច្ចជាតិ ព្រមទាំងជាបុគ្គល ដែលបានការទទួលស្គាល់ ជាពីមហាជនថែមទៀត។ គោរមងារនិងសញ្ញាបត្រនេះ ត្រូវបានសម្រេចអនុម័តដោយក្រុមបណ្ឌិតសភាចារ្យនៃរាជបណ្ឌិត្យសភាកម្ពុជា ដែលមានសម្តេចតេជោបណ្ឌិតសភាចារ្យ ហ៊ុន សែន ជាប្រធានកិត្តិយស ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន ជាប្រធាន និងនាងខ្ញុំប្រធានរាជបណ្ឌិត្យសភាកម្ពុជា ជាអនុប្រធានអចិន្ត្រៃយ៍ តាមការស្នើសុំរបស់ប្រធានរាជបណ្ឌិត្យ



សភាកម្ពុជា ដោយមានការឯកភាពពាក្យពេចន៍ពីក្រុមប្រឹក្សាជាតិភាសាខ្មែរផងដែរ។

ឆ្លៀតឱកាសដ៏ថ្លៃថ្លានេះ ទូលថ្វាយ ប្រគេន និង ជម្រាបជូនដល់អង្គពិធីទាំងមូលមេត្តាជ្រាបថា រាជបណ្ឌិត្យសភាកម្ពុជាជាស្ថាប័នស្រាវជ្រាវដ៏សំខាន់មួយរបស់ជាតិ ដែលបានចាប់បដិសន្ធិឡើងដំបូងនៅខែសីហា ឆ្នាំ១៩៦៥ ប៉ុន្តែមិនទាន់បានដំណើរការផងសង្គ្រាមក៏ធ្វើឱ្យវិនាសទៅ។ ទើបតែនៅថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៩៩ ស្ថាប័នមួយនេះបានកើតឡើងវិញស្របពេលដែលប្រទេសកម្ពុជាចាកផុតពីសង្គ្រាម និងទទួលបាននូវសុខសន្តិភាពពេញផ្ទៃប្រទេស ក្រោមនយោបាយឈ្នះ-ឈ្នះ ដែលជាទស្សន វិជ្ជារបស់សម្តេចតេជោបណ្ឌិតសភាចារ្យ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ ពេលនោះជាកាលានុវត្តភាពមួយដ៏ត្រចះត្រចង់ ដែលរាជបណ្ឌិត្យសភាកម្ពុជាត្រូវបានបង្កើតឡើង និងមានដំណើរ ការជារៀងរហូតមក។ រាជបណ្ឌិត្យសភាកម្ពុជាមាន ៦ វិទ្យាស្ថានធំៗ ដែលមាន ៣២ ផ្នែកស្មើ ៣២ នាយកដ្ឋាន ផ្នែកនីមួយៗមាន ២ មុខវិជ្ជា និង វិទ្យាស្ថានថ្មីមួយទៀតគឺ វិទ្យាស្ថានខុន ជី ព្រមទាំង ៤មជ្ឈមណ្ឌលទៀត (មជ្ឈមណ្ឌលកូរ៉េ ឥណ្ឌា ព័ត៌មាន និងប្រធានបទ)។ រាជបណ្ឌិត្យសភាកម្ពុជាមាន មន្ត្រី និងបុគ្គលចំនួន ២៤៥ នាក់ បណ្ឌិតសភាចារ្យ ២២ នាក់ មរណភាពអស់ ៤ នាក់ នៅសល់ ១៨ នាក់ មានកម្រិតបណ្ឌិត ៧២ នាក់ កំពុងសិក្សា និងការពារថ្នាក់ បណ្ឌិតទាំងអាហារូបករណ៍ ៣ វគ្គ ចំនួន ១៦២ នាក់ និងថ្នាក់បង់វិភាគទានចំនួន១២៧ នាក់ ក្នុងនោះបញ្ចប់បណ្តើរៗចំនួន៥២ នាក់។

រាជបណ្ឌិត្យសភាកម្ពុជាមាននារី៤០នាក់ ថ្នាក់បណ្ឌិតសភាចារ្យ ១ នាក់ ថ្នាក់បណ្ឌិត៤ នាក់ បេក្ខជនបណ្ឌិតចំនួន ១៥ នាក់ បរិញ្ញាបត្រជាន់ខ្ពស់ ១៤ នាក់ កម្មករ ៦ នាក់។

រាជបណ្ឌិត្យសភាកម្ពុជា បានចុះកិច្ចសហប្រតិបត្តិការជាមួយប្រទេសអាស៊ានជាច្រើន និងប្រទេសអឺរ៉ុបមួយចំនួនទៀត។រាជបណ្ឌិត្យសភាកម្ពុជាអាស៊ាននៅចុងឆ្នាំ២០១២គឺចុះនៅទីក្រុងហ្សាកាតាប្រទេសឥណ្ឌូណេស៊ី ។ចំណែប្រទេសភូមានិងឡាវ មិនទាន់បង្កើតបណ្ឌិតសភាវិទ្យាសាស្ត្រនេះទេ ហើយក៏មិនទាន់ចុះកិច្ចសហប្រតិបត្តិការ បណ្ឌិតសភាវិទ្យាសាស្ត្រដែរ។ រាជបណ្ឌិត្យសភាកម្ពុជាបានចុះកិច្ចសហប្រតិបត្តិការណ៍ចំនួន ៣ បណ្ឌិតសភាប្រទេសចិន គឺមួយនៅទីក្រុងប៉េងកាំងពីរនៅទីក្រុងសៀងហៃ បីនៅខេត្តជាំងស៊ី សាកលវិទ្យល័យជីជាំង ទី៤ នៅបណ្ឌិតសភាប្រទេសវៀតណាមខាងជើង ទី៥នៅបណ្ឌិតសភាប្រទេសវៀតណាមខាងត្បូង ទី៦ នៅបណ្ឌិតសភាកូរ៉េខាងត្បូង ទី៧បណ្ឌិតសភាម៉ាឡេស៊ី ទី៨បណ្ឌិតសភាសូវៀត ទី៩នៅបណ្ឌិតសភាឥណ្ឌូណេស៊ីត្រៀមចុះជាមួយឡាវនៅខែខាងមុខនេះ ជាងនេះទៅទៀតក៏បានធ្វើសមាគមវប្បធម៌ជាមួយថៃ និងត្រៀមចុះជាមួយប្រទេសដទៃទៀត ជាបន្តបន្ទាប់។ ទាំងនេះគឺត្រូវបានទទួលសិទ្ធិប្រទាន ពីរាជរដ្ឋាភិបាលទាំងអស់។

ជាងនេះទៅទៀត ការបង្កើតរាជបណ្ឌិត្យកម្ពុជាឡើងវិញនេះ ជាការសម្រេចចិត្តខាងនយោបាយនិងចក្ខុវិស័យដ៏ ត្រឹមត្រូវរបស់រាជរដ្ឋាភិបាលយើង ដែលមានសម្តេចអគ្គមហាសេនាបតីតេជោបណ្ឌិតសភាចារ្យ **ហ៊ុន**



**សែន** ជាប្រមុខដឹកនាំ ក្នុងការប្រមូលផ្តុំធនធានបញ្ញាញាណ ជាន់ខ្ពស់របស់ជាតិ និងប្រើប្រាស់ធនធានទាំងនោះ សម្រាប់ការកសាង និងការអភិវឌ្ឍប្រទេសជាតិ។ ក្នុងឋានៈជាស្ថាប័នស្រាវជ្រាវជាន់ខ្ពស់របស់ជាតិ រាជបណ្ឌិត្យសភាកម្ពុជា ត្រូវបានរាជរដ្ឋាភិបាលប្រគល់បេសកកម្មឱ្យអភិវឌ្ឍកម្លាំងបញ្ញាញាណនៃប្រជាជាតិកម្ពុជា ព្រមទាំងលើកទឹកចិត្តណែនាំគ្រប់គ្រង ពង្រីកការស្រាវជ្រាវគ្រប់មុខជំនាញនៅ ក្នុងប្រទេសនិងស្ថាបនាទំនាក់ទំនងសហប្រតិបត្តិការ ផ្នែកស្រាវជ្រាវជាមួយស្ថាប័នជាតិ និងអន្តរជាតិ ដែលមានគោលបំណងដូចគ្នា។ ក្នុងនោះក៏មានភារកិច្ចមួយក្នុងកិច្ចការផ្តល់គោរមងារសញ្ញាបត្រ និងគ្រឿងឥស្សរិយយសជូនដល់ឥស្សរជនឆ្នើមផងដែរ។

ជាងនេះទៅទៀត រាជបណ្ឌិតសភាកម្ពុជាយើងខ្ញុំបាននឹងកំពុងធ្វើដំណើរសឹងគ្រប់មុខជំនាញ នៃវិទ្យាសាស្ត្រនីមួយៗតាមបរិបទពិភពលោកផងដែរ ប៉ុន្តែសុទ្ធតែអ្វីៗនៅមានកម្រិត សូម្បីតែការងារជួយរាជរដ្ឋាភិបាលក៏នៅមានកម្រិតដែរ។

*អង្គពិធីទាំងមូល ជាទីគោរពសក្ការៈ និង គោរពរាប់អាន!*

មន្ត្រីសង្ឃជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជា ទាំង ៩ ព្រះអង្គ (សម្តេចអគ្គមហាសង្ឃរាជាធិបតី **ទេព វង្ស** សម្តេចព្រះអភិសិរីសុគន្ធាមហា សង្ឃរាជាធិបតី **បួរ គ្រី** និងសម្តេចព្រះមហាសុមេធាធិបតី **នន្ទ ង៉ែត** គោរមងារ កិត្តិសេដ្ឋាបណ្ឌិត ជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់**, និង កិត្តិបណ្ឌិត ថ្វាយសម្តេចព្រះធម្មលិខិត **លាស់ ឡាយ** ថ្វាយសម្តេចព្រះពោធិវង្ស **អ៊ំ លីមហេង**,សម្តេចព្រះវនរ័ត **ណយ ច្រឹក**, សម្តេច

ព្រះឧត្តមបញ្ញា **ជួង ផង់**, សម្តេច ឧត្តមវង្សា **មួង រ៉ា** និងព្រះមុនីកោសល **ហ៊ុល សុវណ្ណ** នាពេលនេះ) ជាអរិយសង្ឃជាន់ខ្ពស់បំផុតនៃព្រះរាជាណាចក្រកម្ពុជា ដែលបានបូជាព្រះកាយដើម្បីទ្រទ្រង់ក្នុងវិស័យព្រះពុទ្ធសាសនា តាំងពីដើមរៀងមកដោយឥតល្អៀងឡើយ [៣] ។ ដោយសារព្រះគុណធម៌ និងការប្រតិបត្តិធម៌វិន័យបានយ៉ាងខ្ជាប់ខ្ជួន ទើបបានជាពុទ្ធបរិស័ទ និងមហាជនទូទៅ បានចាត់ទុកសម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈនៃព្រះរាជាណាចក្រកម្ពុជា ព្រះសង្ឃនាយក ព្រះសង្ឃនាយករង និងមន្ត្រីសង្ឃជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជាទាំង៩ ព្រះអង្គ ព្រះអង្គជាព្រះសង្ឃគំរូដ៏ល្អនាពេលបច្ចុប្បន្ននេះ។

ក្រៅពីគុណសម្បត្តិខាងលើ សម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈនៃព្រះរាជាណាចក្រកម្ពុជា សម្តេចសង្ឃនាយក សម្តេចសង្ឃនាយករង និងមន្ត្រីសង្ឃជាន់ខ្ពស់នៃព្រះរាជាណាកម្ពុជា ទាំង៩ព្រះអង្គបានខិតខំរៀបរៀង និងតែងនិពន្ធក្បួនច្បាប់ធម៌វិន័យផ្សេងៗ ព្រមទាំងជួយត្រួតពិនិត្យ និងកែសម្រួលសៀវភៅក្បួនច្បាប់ សៀវភៅធម៌អាថ៌នានាបានយ៉ាងច្រើនទៀតផង។ ជាមួយគ្នានេះព្រះអង្គបានជួយ

[៣] **អរិយ អៈរ៉ិយ៉ះ** បា.; សំ ( គុ. ) (អរិយ; អាយ៌) ប្រសើរ; ត្រឹមត្រូវ; សុភាព; រៀបរយ; មានបែបបទល្អ; ស្លូតត្រង់; ដែលឥតទោស ។ ន. អ្នកប្រសើរ; អ្នកមានតម្លៃ, អ្នកដែលគួររាប់រក; អ្នកមានធម៌ឬទំនៀមទម្លាប់ល្អ (នាំឲ្យមានសេចក្តីចម្រើន); អ្នកមានសភាពស្លូតត្រង់; អ្នកដែលមានបែបបទរៀបរយ;... ។ ព. ពុ. អ្នកដែលបានសម្រេចលោកុត្តរធម៌ តាំងពីថ្នាក់សោតាបត្តិមគ្គរៀងទៅដល់អរហត្តផល (អរិយបុគ្គល) ។ មានន័យមួយផ្សេងក្នុងគម្ពីរពុទ្ធសាសនាថា អរិយៈ មាន ៤ ប្រភេទគឺ ១- អាចារអរិយៈ ឬ អាចារិយៈ អ្នកដែលមានមារយាទត្រឹមត្រូវ (សូម្បីសត្វតិរច្ឆាន បើមានមារយាទល្អត្រឹមត្រូវ ក៏ហៅថា អាចារអរិយៈ បានដែរ); ២- ទស្សនអរិយៈ ឬ ទស្សនារិយៈ អ្នកដែលមានរូបឆោមលោមព័ណ៌ល្អ មានឥរិយាបថស្រគត់ស្រគំសមរម្យ គួរឲ្យចង់ឃើញចង់មើល; ៣- លិង្គអរិយៈ ឬ លិង្គារិយៈ បព្វជិតដែលល្អតែភេទ គឺអ្នកបួសដែលផ្ចិតផ្ចង់ប្រុងប្រយ័ត្នតែត្រង់ការស្លៀកដណ្តប់ឲ្យត្រឹមត្រូវតាមបែបបទជាសមណសារូប ប៉ុន្តែជាមនុស្សទ្រុស្តសីល; ៤- បដិវេធអរិយៈ ឬ បដិវេធារិយៈ លោកអ្នកបានលុះលោកុត្តរធម៌ (ពុទ្ធាទិបណ្ឌិត) ។ ប្រើពាក្យ អាយ៌ សរសេរសម្រួលជា អារ្យ (អារ-យ៉ះ) ផ្លាស់ប្តូរគ្នាក៏បាន, ដូចជា អរិយជន ឬ អារ្យ-- ជនពួកអារ្យៈ គឺជនមានរបៀប បែបបទទំនៀមសណ្តាប់ល្អ នាំឲ្យមានសេចក្តីចម្រើន ។



កសាងសមិទ្ធផលនានា មាន ព្រះវិហារ កុដិ និងសាលារៀន។ល។ ពេលគឺមានទាំងក្នុងផ្នែកពុទ្ធចក្រ និងផ្នែកអាណាចក្របានយ៉ាងច្រើនសន្ធឹកសន្ធាប់ផងដែរ។

ដោយឡែក ឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺជាឥស្សរជនជាតិដ៏ឆ្នើមមួយរូបបានលះបង់កម្លាំងកាយ ប្រាជ្ញា ស្មារតី យ៉ាងច្រើនសន្ធឹកសន្ធាប់សម្រាប់ ប្រទេសជាតិ ជាពិសេសលើវិស័យសេដ្ឋកិច្ច ជាក់ស្តែងនៅឆ្នាំ១៩៩៣ ឯកឧត្តមបានគោរពជូនសម្តេច អគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នូវសារណាមួយស្តីពី ***"តួនាទីរបស់រដ្ឋនៅក្នុងសេដ្ឋកិច្ចទីផ្សារ"*** ហើយឯកឧត្តមបានដឹកនាំដោយផ្ទាល់នូវក្រុមការងារជំនាញជាតិ និងបរទេស ក្នុងការរៀបចំចាត់ចែងនូវឯកសារដ៏មានសារសំខាន់មួយទៀតគឺ ***"កម្មវិធីជាតិសម្រាប់នីតិសម្បទា និង អភិវឌ្ឍន៍"*** (NPRD- 1994)។ ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្តមបានចូលរួមដឹកនាំសកម្មភាពទាំងឡាយ ដែលប្រកាន់ទិសឆ្ពោះទៅកាន់សេដ្ឋកិច្ចទីផ្សារ ដោយឈរលើមូលដ្ឋានកំណែទម្រង់ គ្រប់ប្រភេទ និងគ្រប់ផ្នែក ដោយឈរលើសមិទ្ធផលនៃកំណែទម្រង់របស់អតីតរដ្ឋកម្ពុជា ដែលបានឈានដល់ដំណាក់កាលលែងថយក្រោយ នៅឆ្នាំ១៩៨៩ហើយបានបោះជំហានទៅមុខថែមទៀតពីឆ្នាំ១៩៩៣ មក។

ផ្អែកតាមលក្ខណៈវិនិច្ឆ័យ ដូចបានលើកឡើងដោយសង្ខេបខាងលើនេះ ក្រុមសមាជិកពេញសិទ្ធិនៃរាជបណ្ឌិត្យសភាកម្ពុជា បានសម្រេចជាឯកច្ឆ័ន្ទ ប្រគល់គោរមងារកិត្តិឧទ្ទេសបណ្ឌិតថ្វាយ សម្តេច

ព្រះអភិ សិរីសុគន្ធាមហាសង្ឃរាជាធិបតី **បួរ គ្រី**, គោរមងារកិត្តិសេដ្ឋាបណ្ឌិតជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់**, និងសញ្ញាបត្រកិត្តិបណ្ឌិតប្រគេនសម្តេច ព្រះពោធិវង្ស **អំ លីមហេង**, សម្តេចព្រះវនរ័ត **ណយ ច្រឹក**, សម្តេចព្រះឧត្តមបញ្ញា **ដួង ផង់**, សម្តេចឧត្តមវង្សា **មួង រ៉ា** និងព្រះមុនីកោសល **ហ៊ុល សុវណ្ណ** នាពេលនេះ។

ក្នុងនាមឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការ គណៈរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីអាណាព្យាបាលបច្ចេកទេស នៃរាជបណ្ឌិត្យសភាកម្ពុជា និងជាប្រធានក្រុមបណ្ឌិតសភាចារ្យ ថ្នាក់ដឹកនាំ និង មន្ត្រីរាជការរាជបណ្ឌិត្យសភាកម្ពុជាទាំងមូលខ្ញុំព្រះករុណានាងខ្ញុំសូមសម្តែងនូវអំណរសាទរបីតិសោមនស្សរីករាយយ៉ាងក្រៃលែងបំផុត ថ្វាយចំពោះសម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈនៃព្រះរាជាណាចក្រកម្ពុជា ព្រះសង្ឃនាយក ព្រះសង្ឃនាយករង និងមន្ត្រីសង្ឃជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជាទាំង ៩ ព្រះអង្គព្រម ទាំងឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់** និង សូមថ្វាយ និងប្រគេននូវព្រះពរសព្វសាធុការសូមព្រះអង្គមានព្រះជន្មាយុយឺនយូរជាងរយព្រះវយព្រះវស្សា ដើម្បីជួយទ្រទ្រង់ព្រះពុទ្ធសាសនា នៃយើងមានអត្ថិភាពជាភិយ្យោភាព និង សូមគោរពជូនពរដល់អគ្គមហាសេនា បតីតេជោបណ្ឌិតសភាចារ្យ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជានិងលោកជំទាវ កិត្តិព្រឹទ្ធបណ្ឌិត ព្រមទាំងឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី អនុរដ្ឋមន្ត្រី ព្រឹទ្ធសភា រដ្ឋសភា ឯកឧត្តម ឧកញ៉ា ឯកឧត្តមបណ្ឌិតសភាចារ្យ សាស្ត្រាចារ្យ បណ្ឌិត



អស់លោក លោកស្រី ភ្ញៀវ កិត្តិយសទាំងអស់ ដែលមានវត្តមានក្នុងពិធីនេះ សូមទទួលបាននូវព្រះ ពុទ្ធពរគ្រប់ប្រការកុំបី ឃ្លៀងឃ្លាតឡើយ។

*សូមអរព្រះគុណ និង សូមអរគុណ!*

## ហត្ថលេខា
## បណ្ឌិតសភាចារ្យ ខ្លូត ធីតា

- ប្រធានរាជបណ្ឌិត្យសភាកម្ពុជា
- ទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោបណ្ឌិតសភាចារ្យ **ហ៊ុន សែន** ទទួលបន្ទុកការងារធម្មការនិងសាសនា
- អនុប្រធានអចិន្ត្រៃយ៍នៃក្រុមបណ្ឌិសភាចារ្យនៃរាជបណ្ឌិត្យសភាកម្ពុជា
- អនុប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ
- សមាជិកគណៈកម្មការបណ្ឌិតសភាអនុម័តពាក្យច្បាប់
- ប្រធានសមាគមវប្បធម៌ខ្មែរ-ថៃ

# គុណកថា និងជីវប្រវត្តិសង្ខេប
# របស់ក្រុមជយលាភី ព្រះសង្ឃ ៩ អង្គ

### អានដោយឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ីវ ច័ន

- សូមក្រាបថ្វាយបង្គំសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី **ទេព វង្ស** សម្តេចព្រះមហាសង្ឃរាជ នៃគណៈមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់ !
- សូមក្រាបថ្វាយបង្គំសម្តេចព្រះអភិសិរីសុគន្ធា មហាសង្ឃរាជាធិបតី **បួរ គ្រី** សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយនៃព្រះរាជាណាចក្រកម្ពុជាជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់!
- សូមក្រាបថ្វាយបង្គំព្រះសង្ឃនាយក ព្រះសង្ឃនាយករង ព្រះថេរានុថេរៈគ្រប់ព្រះអង្គ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់ !
- សូមគោរពសម្តេចអគ្គមហាសេនាបតីតេជោបណ្ឌិតសភាចារ្យ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!
- ឯកឧត្តមបណ្ឌិតសភាចារ្យ សាស្ត្រាចារ្យ បណ្ឌិត ឯកឧត្តមលោកជំទាវ អស់លោក លោកស្រី ជាទីគោរពរាប់អាន!

ថ្ងៃនេះ ថ្នាក់ដឹកនាំ មន្ត្រីរាជការរាជនៃបណ្ឌិត្យសភាកម្ពុជាទាំងមូលមានកិត្តិយសនិងមោទនភាពយ៉ាងក្រៃលែង ដែលបានរៀបចំពិធីប្រគល់ គោរមងារកិត្តិឧទ្ទេសបណ្ឌិតថ្វាយ សម្តេចអគ្គមហាសង្ឃ រាជាធិបតី **ទេព វង្ស** សម្តេចព្រះអភិសិរីសុគន្ធា មហាសង្ឃរាជាធិបតី **បួរ គ្រី**



និងសម្តេចព្រះមហាសុមេធាធិបតី **នន្ទ ង៉ែត**, គោរមងារកិត្តិសេដ្ឋាបណ្ឌិតជូនឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, និងកិត្តិបណ្ឌិតប្រគេន សម្តេចព្រះធម្មលិខិត **លាស់ ឡាយ** ប្រធានថេរសភាព្រះពុទ្ធសាសនា , សម្តេចព្រះពោធិវង្ស **អ៊ំ លីមហេង**, សម្តេចព្រះវនរ័ត **ណយ ច្រឹក**, សម្តេចព្រះឧត្តមបញ្ញា **ដួង ផង់**, សម្តេចឧត្តមវង្សា **មួង រ៉ា** និងព្រះមុនី កោសល **ហ៊ុល សុវណ្ណ** នាពេលនេះ។ ជាបន្តខ្ញុំព្រះករុណា ខ្ញុំបាទសូមគោរពអនុញ្ញាតអាននូវជីវប្រវត្តិសង្ខេប និងគុណកថារបស់ជយលាភីខាងលើដូចតទៅ ៖

### ១- សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី ទេព វង្ស សម្តេច ព្រះមហាសង្ឃរាជ នៃគណៈមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា

សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី **ទេព វង្ស** សម្តេចព្រះមហាសង្ឃរាជ នៃគណៈមហានិកាយនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ប្រសូតក្នុងបច្ឆិមយាមទៀតភ្លឺ ថ្ងៃព្រហស្បតិ៍ ២រោច ខែបុស្ស ឆ្នាំវកចត្វាស័ក ព.ស២៤៦៦ . ត្រូវនឹងថ្ងៃទី១២ ខែមករា ឆ្នាំ១៩៣២ នៅភូមិត្រពាំងចក (បច្ចុប្បន្នហៅភូមិប្រឡាយ) ឃុំជ្រាវ ស្រុកសៀមរាប ខេត្តសៀមរាប ដែលមានមាតានាម **ម៉ិច អាត់** និងបិតានាម **ទេព ឈិត** ។

ក្នុងវ័យពី ៤-១០ វស្សា សម្តេចបានព្យាយាមសិក្សារៀនសូត្រនូវចំណេះវិជ្ជាមេផ្ទះយ៉ាងច្រើនដែលរាល់កូនអ្នកជនបទតែងតែព្យាយាមហ្វឹកហាត់ ធ្វើការបម្រើមាតាបិតា-ជីតា ប្រកបដោយកតញ្ញូតាធម៌។ ក្នុងជន្មាយុ១១ វស្សា សម្តេចត្រូវបានមាតាបិតានាំទៅប្រគេនព្រះគ្រូសមុហ៍គណ **ហ៊ីង ម៉ៅ** ដែលជាព្រះចៅអធិការវត្តរាជបូព៌ ដើម្បី

សិក្សាអក្សរខ្មែរ និងវិជ្ជាផ្លូវលោក-ផ្លូវធម៌និងបានសាងផ្នួសជាសមណេររយៈពេល ៩ ខែ។លុះដល់ឆ្នាំ១៩៥២ ក្នុងជន្មាយុ ២១ វស្សា សម្តេចបានសាងផ្នួសម្តងទៀតក្នុងសំណាក់ព្រះគ្រូ សមុហ៍គណ **ហ៊ីង ម៉ៅ** (ពុទ្ធសរ)ជាព្រះឧបជ្ឈាយ៍ក្នុងពទ្ធសីមាវត្តរាជបូព៌ទីរួមខេត្តសៀមរាប។

នៅក្នុងចន្លោះឆ្នាំ១៩៧០-១៩៧៩ សម្តេចក៏មិនខុសពីប្រជា-ពលរដ្ឋដទៃដែរ គឺទទួលរងឥទ្ធិពលនូវការប្រែប្រួលនយោបាយ របស់ប្រទេសជាតិយ៉ាងខ្លាំង។ ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានទៅនិមន្តព្រះសង្ឃពីកម្ពុជាក្រោមចំនួន ៩ អង្គ ដើម្បីមកបំបួសអតីតបព្វជិតចំនួន ៧ រូប ដែលក្នុងនោះមានសម្តេចផងដែរ នៅពុទ្ធសីមាវត្តឧណ្ណាលោមរាជធានីភ្នំពេញ នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៩ ដោយមានព្រះគ្រូ **ឋិត សី** សង្ឃនាយកកម្ពុជាក្រោម ជាព្រះឧបជ្ឈាយ៍។ ក្រោយការបំបួសចប់សព្វគ្រប់ ហើយព្រះគ្រូឧបជ្ឈាយ៍ បានប្រកាសក្នុងជំនុំសង្ឃថា ព្រះភិក្ខុ **ទេព វង្ស** ឱ្យឡើងឋានានុក្រម ឋានន្តរស័ក្តិ ជាព្រះវិន័យធរសង្ឃ និងជាព្រះឧបជ្ឈាយ៍សម្រាប់បំបួសភិក្ខុសាមណេរនៅកម្ពុជា។

ចាប់តាំងពីក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ មកសម្តេច បានបូជាព្រះកាយទាំងស្រុងក្នុងការស្តារនិងអភិវឌ្ឍន៍វិស័យព្រះពុទ្ធសាសនាឡើងវិញ។ អាស្រ័យដោយស្មារតីព្យាយាមយ៉ាងក្រៃលែងក្នុងការ បម្រើព្រះពុទ្ធសាសនានិងសង្គមជាតិ នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៦ ព្រះមហាក្សត្របានតែងតាំងសម្តេច ជាសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជនៃគណៈមហានិកាយនៃព្រះរាជាណាចក្រកម្ពុជា និងទទួលបាននូវគ្រឿងឥស្សរិយយសជាច្រើនគ្រឿង ក្នុងនោះមានគ្រឿងឥស្សរិយយស «ជាតូបការ» មួយគ្រឿងផងដែរ។



**២-សម្តេចព្រះអភិសិរីសុគន្ធា មហាសង្ឃរាជាធិបតី បួរ គ្រី សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា**

សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី ស្តេចទ្រង់ប្រសូតនៅថ្ងៃព្រហស្បតិ៍ ១៣ រោច ខែបុស្ស ឆ្នាំរកា ព.ស. ២៤៨៨ ត្រូវនឹងថ្ងៃទី១១ ខែមករា ឆ្នាំ១៩៤៥ នៅឃុំស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបង។ព្រះមាតាព្រះនាម **ជា ជួន** ព្រះបិតាព្រះនាម **បួរ ទ៉ាន**។ លុះព្រះអង្គមានព្រះជន្មបាន ៧ ព្រះវស្សា ស្តេចបានសិក្សាអក្សរ និងលេខនព្វន្ត នៅសាលាបឋមសិក្សា ឃុំស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបង។ នៅក្នុងឆ្នាំកុរ ឯកស័ក ព.ស. ២៥០៣ ត្រូវនឹងគ.ស. ១៩៥៩ ព្រះអង្គបានប្រឡងចូលសិក្សា នៅវិទ្យាល័យបាត់ដំបង ឃុំស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបង។

លុះដល់ឆ្នាំថោះ គ.ស១៩៦៣ ព្រះអង្គបានប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ (ឌីប្លូម)។ ទោះបីជាព្រះអង្គអាចនឹងបន្តការសិក្សាទៀតបាន ប៉ុន្តែ ទ្រង់ទតមើលឃើញភេទបព្វជ្ជា គឺជាភេទដ៏ឧត្តុង្គឧត្តម ជាផ្លូវលោកុត្តរៈ ដែលល្អប្រសើរថ្លៃថ្លា ជាងវិជ្ជាផ្លូវលោកណាៗទាំងអស់ ទើបព្រះអង្គសម្រេចព្រះរាជហឫទ័យ លាចាកព្រះមាតាបិតា និងក្រុមញាតិមកបំពេញភេទបព្វជ្ជា ជាសាមណេរនិងឧបសម្បទាជាភិក្ខុភាវៈនៅវត្តបុប្ផារាម ស្ថិតនៅក្នុងឃុំស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបង។ តាំងពីពេលនោះមក ទ្រង់បានបម្រើក្នុងវិស័យព្រះពុទ្ធសាសនាជាប់ជានិច្ច។

ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៧ ទ្រង់បានទទួលព្រះបរមងារជាសម្តេចព្រះអភិសិរីសុគន្ធា មហាសង្ឃរាជាធិបតីសម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា។ ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១០ ទ្រង់បានទទួលព្រះឋានៈបន្ថែមទៀតជាព្រះប្រធានគណៈសង្ឃនាយក គណៈធម្មយុត្តិកនិកាយនៃព្រះរាជាណាចក្រកម្ពុជា។ នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៧ សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតីសម្តេចព្រះមហាសង្ឃរាជ បានទទួលមេដាយជាន់ខ្ពស់ថ្នាក់ " ជាតូបការ។"

**៣-សម្តេចព្រះមហាសុមេធាធិបតី នន្ទ ង៉ែត សម្តេចព្រះសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា ព្រះអគ្គាធិការពុទ្ធិកសិក្សាជាតិជាសាកលវិទ្យាធិការ នៃពុទ្ធិកសាកលវិទ្យា-ល័យ ព្រះចៅអធិការវត្តបទុមវតី**

សម្តេច **នន្ទ ង៉ែត** ប្រសូតនៅថ្ងៃ៥ រោច ខែវិសាខ ឆ្នាំឆ្លូវ ព.ស២៤៦៧ ត្រូវនឹងថ្ងៃទី៥ ខែឧសភា គ.ស១៩២៦ នៅភូមិត្រពាំងវែង ឃុំលំចង់ ស្រុកសំរោង ខេត្តតាកែវ។ ព្រះអង្គជាបុត្រទី២ នៃលោកឧបាសក **នន្ទ នុត** និងលោកយាយ ឧបាសិកា **ម៉ឹង យឹម** ។ ក្នុងជន្មាយុ ១១ វស្សា មាតាបិតា បាននាំទៅសិក្សាចំណេះវិជ្ជា មានអក្សរសាស្ត្រ លេខនព្វន្ត និងរៀនធម៌វិន័យទៅតាមសម័យកាល នៅវត្តពោធិ៍ ឃុំពោធិ៍អង្គ្រង ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ក្នុងសំណាក់ព្រះគ្រូព្រះនាម **ស្នួស មាស** ជាព្រះចៅអធិការវត្ត។

លុះដល់ជន្មាយុ២១វស្សា សម្តេចបានសាងផ្នួសជាសាមណេរ ក្នុងសំណាក់ព្រះគ្រូព្រះនាម **ស្នួស មាស** ជាព្រះឧបជ្ឈាយ៍ ក្នុងពុទ្ធ



សីមាវត្ត ពោធិ៍អង្គ្រង ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។ នៅគ.ស.១៩៤៨ ព.ស.២៤៩២ សម្តេចបានសម្រេចព្រះទ័យ បំពេញឧបសម្បទាជាភិក្ខុភាវៈក្នុងពទ្ធសីមាវត្តពោធិ៍ ឃុំពោធិ៍អង្គ្រង ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដោយមានព្រះគ្រូសូត្រស្តាំ និងព្រះគ្រូនាម **រស់ មាស** ជាព្រះគ្រូសូត្រឆ្វេងបានទទួលនាមបញ្ញត្តិថា **នន្ទ ត្ថេរោ**។ ក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩បានសាងផ្នួសជាថ្មីម្តងទៀតនៅថ្ងៃពុធ ១១រោច ខែភទ្របទ ឆ្នាំមមែ ព.ស២៥២៣ ត្រូវនឹងថ្ងៃទី១៩ ខែកញ្ញា គស.១៩៧៩ នៅវត្តឧណ្ណាលោម រាជធានីភ្នំពេញ រហូតមកដល់បច្ចុប្បន្ន។

នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៧ សម្តេចត្រូវបានតែងតាំងជាសម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា។នៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០៧សម្តេចត្រូវបានព្រះមហាក្សត្រតែងតាំងជាព្រះអគ្គាធិការពុទ្ធិកសិក្សាជាតិ។ នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៧ សម្តេចត្រូវបានតែងតាំងជាព្រះសាកលវិទ្យាធិការនៃសាកលវិទ្យាល័យព្រះសីហនុរាជ។នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩ សម្តេចទទួលបាននូវមេដាយ ជាតូបការ ពីរាជរដ្ឋាភិបាលកម្ពុជា។

**៤-ព្រះរាជជីវប្រវត្តិ នៃសម្តេចព្រះធម្មលិខិត លាស់ឡាយ ប្រធានថេរសភានៃព្រះពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា**

**ជាតិភូមិ** ៖ ព្រះអង្គប្រសូតនៅថ្ងៃពុធ៧ កើត ខែភទ្របទ ឆ្នាំថោះ ពុទ្ធសករាជ ២៤៥៧ នៅក្នុងភូមិធ្យូង ឃុំធ្យូង ស្រុកពញាឮ ខេត្តកណ្តាល។

មាតា និងបិតារបស់សម្តេចមាននាមដូចតទៅ ៖

-មាតានាម **ស៊ូ អ៊ុច**

-បិតានាម **ល័ក្ខ លាស់** (ហៅអាចារ្យលាក់)

មាតានិងបិតារបស់សម្តេច គឺជាត្រកូលកសិករសុទ្ធសាធ។

សម្តេចមានបងប្អូនបង្កើតចំនួន១០ នាក់ គឺប្រុស ៧ នាក់ និង ស្រី ៣ នាក់ ក្នុងនោះសម្តេចជាបុត្រទី៥ ។

**៥-សម្តេចព្រះពោធិវ័ង្ស អ៊ំ លីមហេង ព្រះសង្ឃនាយករងទី២ ព្រះអគ្គាធិការរង ពុទ្ធិកសិក្សាជាតិ នៃព្រះរាជាណាចក្រកម្ពុជា និងជាព្រះចៅអធិការវត្តមុនីសុវណ្ណ (ចំពុះក្អែក)**

សម្តេច **អ៊ំ លីមហេង** ប្រសូតនៅថ្ងៃព្រហស្បតិ៍ ១១រោច ខែអស្សុជ ឆ្នាំម្សាញ់ ព.ស ២៥០៨ ត្រូវនឹងថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៦៥ នៅឃុំរកាកោង១ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមានមាតានាម **ទន់ ជាវលី** និងបិតានាម **អ៊ំ សុខ** ។

ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨១ សម្តេចបានចូលសិក្សានៅសាលាបឋមសិក្សា រកាកោង១។ ពីឆ្នាំ១៩៨១ ដល់ឆ្នាំ១៩៨៤ សម្តេចបានចូលសិក្សានៅអនុវិទ្យាល័យសិរីមង្គលរកាកោង២ និងពីឆ្នាំ១៩៨៤ ដល់ឆ្នាំ១៩៨៧ សម្តេចបានចូលសិក្សានៅវិទ្យាល័យ **ហ៊ុន សែន** តាខ្មៅ ហើយបានប្រឡងជាប់សញ្ញាបត្រ មធ្យមសិក្សាកម្រិតទី២ (បាក់ឌុប) ទទួលបាននិទ្ទេសល្អបង្គួរ។

ក្រោយពេលប្រឡងជាប់បាន៧ថ្ងៃ សម្តេច **អ៊ំ លីមហេង** ហេតុតែមានឧបនិស្ស័យក្នុងព្រះពុទ្ធសាសនា ក៏មានទឹកចិត្តសទ្ធាជ្រះថ្លាស្រឡាញ់ពេញចិត្តចង់សាងផ្នួស ក៏បានសម្រេចចិត្តសុំការ អនុញ្ញាតពីមាតា បិតា ទៅបំពេញឧបសម្បទាជាភិក្ខុភាវៈក្នុងសំណាក់ ព្រះអរិយ



មគ្គញាណព្រះនាម **អន ហ៊ឹម** ជាព្រះឧបជ្ឈាយ៍ ក្នុងពទ្ធសីមាវត្តជ្រោយអំពិល ឃុំក្បាលកោះ ស្រុកកៀនស្វាយ ខេត្តកណ្តាល នៅថ្ងៃសុក្រ ១៥កើត ខែអាសាធ ឆ្នាំថោះ ព.ស ២៥៣១ ត្រូវនឹងថ្ងៃទី១០ ខែកក្កដា ឆ្នាំ១៩៨៧ បានទទួលនាមបញ្ញត្តិថា លោកសង្គហត្ថពោ។ លុះបានបំពេញឧបសម្បទាជាភិក្ខុភាវៈរួច សម្តេច **អ៊ំ លីមហេង** ក៏បាននិមន្តមកគង់នៅវត្តមុនីសុវណ្ណ(ចំពុះក្អែក) ពេលនោះវត្តចំពុះក្អែក គ្រប់គ្រងដឹកនាំដោយព្រះគ្រូចៅអធិការព្រះនាម **កែ យ៉ាន់** ។

ចាប់តាំងពីពេលបានឧបសម្បទា ជាភិក្ខុភាវៈរួចមក សម្តេច **អ៊ំ លីមហេង** បានយកព្រះទ័យទុកដាក់ ខិតខំប្រឹងប្រែង ព្យាយាមរៀនសូត្រ ព្រះធម៌ និង ព្រះវិន័យ ទាំងផ្នែកគន្ថធុរៈ និងវិបស្សនាធុរៈក្នុងសំណាក់ព្រះគ្រូធម្មាចារ្យ **សេង ហេង** បានយ៉ាងល្អប្រសើរ។ ដោយមានឆន្ទៈ និងវិរិយភាពយ៉ាងមោះមុតក្នុងការសិក្សារៀនសូត្រ ព្រះភិក្ខុ **អ៊ំ លីមហេង** បានទទួលការកោតសរសើរយ៉ាងខ្លាំងពីសំណាក់លោកគ្រូធម្មាចារ្យរបស់ខ្លួន ក៏ដូចជាញាតិញោមពុទ្ធបរិស័ទជិតឆ្ងាយ និងត្រូវបានថ្វាយនូវព្រះឋានៈ និង តួនាទីជាបន្តបន្ទាប់ រហូតដល់ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៦ ត្រូវបានតែងតាំងជាសម្តេចព្រះពោធិវង្ស ព្រះសង្ឃនាយករងទី២ នៃព្រះរាជាណាចក្រកម្ពុជា ហើយនៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៦ ជាអនុប្រធានទី៣ នៃថេរសភាសង្ឃព្រះពុទ្ធសាសនា។ លើសពីនេះទៀត នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១០ សម្តេចបានទទួលមេដាយ "ជាតូបការ" ដែលជាមេដាយខ្ពស់បំផុតនៃព្រះរាជាណាចក្រកម្ពុជា។

### ៦- សម្តេចព្រះវនរ័ត ណយ ច្រឹក ព្រះសង្ឃនាយក រងទី៣ និងជាព្រះអគ្គាធិការរងពុទ្ធិកសិក្សាជាតិ នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងជាព្រះចៅអធិការវត្ត ចន្ទ បូរីវង្ស ឃុំសំរោង ស្រុកពញាឮ ខេត្តកណ្តាល

សម្តេចព្រះវនរ័តប្រសូតនៅថ្ងៃសុក្រ១១កើត ខែមិគសិរ ឆ្នាំថោះ ត្រូវនឹង ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៤៩ នៅក្នុងភូមិគ្រួស ឃុំសំរោង ស្រុកពញាឮ ខេត្តកណ្តាល មានមាតានាម **ណយ យឹន** និងបិតានាម **ឌឹក ឆូ**។ លុះដល់វ័យល្មមដល់ការសិក្សាហើយ សម្តេចត្រូវបានមាតាបិតានាំទៅសិក្សាវិជ្ជា មានអក្សរសាស្ត្រ លេខនិព្វន្ត និងសិល្បៈសិប្បកម្មផ្សេងៗជាដើម នៅក្នុងវត្តថ្មីឬហៅវត្តសង្កែបត់ដែល សព្វថ្ងៃជាវត្តទេពវង្សី ឃុំព្រែកតាទែន ស្រុកពញាឮ ខេត្តកណ្តាល ដោយស្ថិតនៅក្នុងសំណាក់ព្រះគ្រូ **ជួន ឥន្ទបញ្ញោ** ជាព្រះចៅអធិការវត្ត។

លុះសិក្សាចេះដឹងវិជ្ជាអក្សរសាស្ត្រ លេខនព្វន្ត ទាំងផ្លូវលោកផ្លូវធម៌ល្មមអាចប្រើការបាន មាតាបិតា ក៏បានអនុញ្ញាតសម្តេចបួសជាសាមណេរក្នុងសំណាក់ព្រះតេជព្រះគុណ **កុល ឡោចន្ទត្ថេរោ**។ អាយុកាលផ្នួសជាសាមណេរបាន៩វស្សា គម្រប់ជន្មាយុ២១វស្សា ពេញបរិបូណ៌ សម្តេចក៏ចង់បំពេញឧបសម្បទាជាភិក្ខុភាវៈជាបន្តទៀត តែជាអកុសលពេលនោះ ប្រទេសជាតិត្រូវមានវិបត្តិកើតសង្គ្រាមស្រុករីករ ព្រះរាជបំណងរបស់ព្រះអង្គក៏ត្រូវបានអាក់ខាន។

ដោយទឹកព្រះទ័យជ្រះថ្លា ស្រឡាញ់គោរពជឿជាក់ចំពោះព្រះពុទ្ធសាសនា និងមានបំណងចង់តបស្នងសងគុណ ចំពោះអ្នកដ៏មានគុណមាន មាតាបិតា ជីដូនជីតា និងគ្រូឧបជ្ឈាយាចារ្យជាដើម សម្តេចក៏បានសម្រេចចិត្តចូលឧបសម្បទាជាភិក្ខុភាវៈឡើងវិញ ក្នុងឆ្នាំ១៩៨៦ ក្នុង ព័ទ្ធសីមាវត្តតាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល ដោយមានព្រះគ្រូ **ហាន ហ៊ឹម** ជាព្រះឧបជ្ឈាយ៍។ ក្រោយពេលសាងផ្នួសហើយ សម្តេច **ណយ ច្រឹក** ក៏បានសម្រេចព្រះទ័យនិមន្តចេញទៅគង់នៅ វត្តចន្ទបុរីវង្ស ឃុំសំរោង ស្រុកពញាឮ ខេត្តកណ្តាល រហូតមកដល់សព្វថ្ងៃ។

តាំងពីឆ្នាំ១៩៨៦ សម្តេចត្រូវបានប្រជាពុទ្ធបរិស័ទទូទៅគោរពស្រឡាញ់ និងមានជំនឿយ៉ាងជ្រាលជ្រៅ។ ដោយសារស្នាព្រះហស្តដ៏ឆ្នើមរបស់សម្តេចបានធ្វើឱ្យសម្តេចទទួលបាននូវព្រះឋានានុក្រមតួនាទីព្រះឋានៈនិងភារកិច្ចជាបន្តបន្ទាប់រហូតបានទទួលព្រះឋានៈជាព្រះសង្ឃនាយករងទី៣ និង ជាព្រះអគ្គាធិការរងពុទ្ធិកសិក្សាជាតិ នៃព្រះរាជាណាចក្រកម្ពុជាព្រមទាំងទទួលបាននូវមេដាយមាសស្ថាបនាជាតិចំនួន ៥ គ្រឿងទៀតផង។

### ៧- សម្តេចព្រះឧត្តមបញ្ញា ជួន ផន់

សម្តេចព្រះឧត្តមបញ្ញា **ជួន ផន់** ប្រសូតនៅថ្ងៃព្រហស្បតិ៍ ៨ កើត ខែទុតិយាសាឍ ឆ្នាំមមែ សំរឹទ្ធិស័ក ព.ស ២៤៧៦ គ.ស១៩៣២ នៅភូមិខ្ពបក្រោម ឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម។សម្តេចជាបុត្ររបស់ លោកឧបាសក **ជួ ជួន** និងលោកយាយឧបាសិកា **ញ៉ែម នាង** ដែលជាត្រកូលសម្មាទិដ្ឋិកសិករសុទ្ធសាធ។ ជន្មាយុ ៧ វស្សា សម្តេចត្រូវបានមាតាបិតា នាំយកទៅប្រគេនលោកគ្រូជា ដែលជាគ្រូសូត្រស្តាំ វត្តបទុមវតី ភូមិខ្ពបក្រោម ឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ដើម្បីឱ្យសិក្សារៀនសូត្រអក្សរសាស្ត្រ លេខនព្វន្ត រៀងរហូតមកដល់ព្រះជន្ម១២ វស្សា ។

លុះដល់ព្រះជន្មាយុ១៧វស្សា ក៏សិក្សាបន្តទៀតនូវធម្មវិន័យនិងវិបស្សនាធុរកម្មក្នុងសំណាក់ ព្រះឧបជ្ឈាយ៍ដដែល។ រហូតដល់ព្រះជន្មាយុ២១ព្រះវស្សា សម្តចក៏បានឧបសម្បទាជាភិក្ខុភាវៈ នៅពទ្ធសីមាវត្តបទុមវតីភូមិឃុំ ស្រុក ខេត្តដដែលក្នុងសំណាក់ព្រះឧបជ្ឈាយ៍ដដែល និងលោកគ្រូឧបសម្បទាចារ្យ ព្រះនាម **ម៉ៅ គឹមស្រុន** ហើយព្រះឧបជ្ឈាយ៍បានឱ្យនាមបញ្ញត្តិថា **ធម្មក្ខោរោ** ។ បន្ទាប់ពីបំពេញឧបសម្បទាមក ព្រះភិក្ខុ **ជួន ផង់** បានសិក្សាបន្តទៀតនូវវិបស្សនាធុរៈរហូតបានធ្វើជាគ្រូប្រដៅព្រះធម៌ ឬហៅថា (ព្រះធម្មាចារ្យ) បង្ហាត់បង្រៀនព្រះធម៌ដល់លោកតាលោកយាយ ដែលមានបំណងចង់រៀននូវវិបស្សនាកម្មដ្ឋាន។ នៅឆ្នាំ១៩៧០ សង្គ្រាមក៏បានចូលមកដល់ ភិក្ខុ **ជួន ផង់** ទទួលការកៀបសង្កត់ចាកសិក្ខាបទនៅឆ្នាំ១៩៧៦ របបរបស់លោក ប៉ុល ពត ក៏បានធ្វើទារុណកម្ម ហើយជម្លៀសទៅនៅខេត្តព្រៃវែង ខេត្តកណ្តាល និងក្រុងភ្នំពេញ គីឡូម៉ែត្រលេខ៦ រោងចក្រដ២ (ផលិតម៉ាស៊ីនកិនស្រូវ)។

នៅខែមករា ឆ្នាំ១៩៧៩ ប្រទេសជាតិបានរំដោះចេញផុតពីរបបប្រល័យពូជសាសន៍ សម្តេច **ជួន ផង់** បានមកសាងផ្នួសបួសជាភិក្ខុភាវៈឡើងវិញនៅពទ្ធសីមាវត្តសន្សំកុសលរាជធានីភ្នំពេញក្នុងសំណាក់ព្រះឧបជ្ឈយ៍ព្រះធម្មលិខិត **និលមុនី** ព្រះឧបជ្ឈាយ៍បានឱ្យនាមបញ្ញត្តិថា **នន្ទិយោ** នាសម័យរណសិរ្សក្រោមមាគ៌ាលោក **ឡុង ស៊ីម** និងលោក **ជា ស៊ីម** នៃរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា។ នៅខែកក្កដា ឆ្នាំ១៩៨០ សម្តេច ក៏បានបួសម្តងទៀតក្រោមព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់របស់សម្តេចព្រះមហាសង្ឃរាជាធិបតី **ទេព វង្ស**។ តាំងពី



ពេលនោះមក សម្តេចបានបូជាព្រះកាយក្នុងព្រះពុទ្ធសាសនាដរាបរៀងមកដោយទទួលបាននូវការគោរពស្រឡាញ់ពី ពុទ្ធបរិស័ទជិត ឆ្ងាយ និងថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់។ នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០១ សម្តេចត្រូវបានព្រះមហាក្សត្រតែងតាំងជាសម្តេចព្រះឧត្តមបញ្ញា ហើយនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៧ ទទួលបាននូវគ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់មហាសេរីវឌ្ឍន៍។

**៨- សម្តេចព្រះឧត្តមវង្សា មួង រ៉ា លេខាធិការថេរសភានៃព្រះពុទ្ធសាសនានៃព្រះរាជាណាចក្រកម្ពុជា និង ជាព្រះអគ្គាធិការរងពុទ្ធិកសិក្សាជាតិ**

សម្តេចព្រះឧត្តមវង្សា **មួង រ៉ា** ប្រសូតនៅថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៦០ នៅភូមិឡកំបោរ ឃុំព្រែកញ្ចៅ ស្រុកពញាឮ ខេត្តកណ្តាល បិតាព្រះនាម **មួង ជូ** និងមាតាព្រះនាម **ហែម ឡៃ**។ នៅឆ្នាំ១៩៧៩ សម្តេចសិក្សាបានត្រឹមថ្នាក់ទី៧ចាស់ និងបានសាងផ្នួសជាព្រះសង្ឃនៃព្រះពុទ្ធសាសនា គណៈមហានិកាយតាំងពី ឆ្នាំ១៩៧៩ រហូតមកដល់បច្ចុប្បន្ន។ ពីឆ្នាំ១៩៩៤ ដល់ឆ្នាំ១៩៩៦ សម្តេចបានសិក្សាចប់ធម្មវិន័យថ្នាក់ត្រី ថ្នាក់ទោ ថ្នាក់ឯក និងបាលីភិក្ខុបាតិមោក្ខ ហើយនៅឆ្នាំ២០០៩ សម្តេចបានទទួលសញ្ញាបត្របណ្ឌិតកិត្តិយសផ្នែកទស្សនវិជ្ជាពុទ្ធសាសនា។

ចាប់ពីឆ្នាំ១៩៩៤ មក សម្តេចបានទទួលនូវការតែងតាំងជាបន្តបន្ទាប់។ ឆ្នាំ១៩៩៤ ជាព្រះសមុហ៍គណស្រុកពញាឮ ឆ្នាំ១៩៩៧ ជាព្រះចៅអធិការវត្តមុនីប្រសិទ្ធីវង្ស និងជាព្រះធម្មធរអនុគណ ស្រុកពញាឮ ឆ្នាំ១៩៩៩បានទទួលគោរមងារជាព្រះសសនវង្ស៊ី ព្រះរាជា-

គណៈថ្នាក់កិត្តិយស ទីប្រឹក្សាសម្តេចព្រះសង្ឃរាជគណៈមហានិកាយ ឆ្នាំ២០០១ បានទទួលគោរមងារជា ព្រះវិន័យសំវរព្រះរាជាគណៈថ្នាក់ចត្វា ឆ្នាំ២០០១ ជានាយកប្រតិបត្តិអភិបាលកិច្ចសង្ឃទូទាំងប្រទេស ឆ្នាំ២០០១-២០១០ ជាព្រះធម្មធរគណខេត្តកណ្តាល ឆ្នាំ២០១០ជាឧត្តមទីប្រឹក្សាផ្ទាល់សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី **នេព ខេង្ស** សម្តេចព្រះអគ្គមហាសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជាពីឆ្នាំ២០០២-បច្ចុប្បន្ន បានទទួលគោរមងារជាសម្តេចព្រះឧត្តមវង្សា ពីឆ្នាំ២០០៦-បច្ចុប្បន្នជាលេខាធិការរថេរសភានៃព្រះពុទ្ធសាសនានៃព្រះរាជាណាចក្រកម្ពុជា និងជាព្រះអគ្គាធិការរងពុទ្ធិកសិក្សាជាតិ។

ទន្ទឹមនឹងនេះដែរ សម្តេចបានទទួលនូវមេដាយជាច្រើនគ្រឿងដូចជា មេដាយស្ថាបនាជាតិថ្នាក់លេខ១ មេដាយមុនីសារភណ្ឌថ្នាក់ធិបឌិន, មេដាយព្រះរាជាណាចក្រកម្ពុជាថ្នាក់សេនា, មេដាយមុនីសារភណ្ឌ ថ្នាក់មហាសេរីវឌ្ឍន៍, និងមេដាយព្រះរាជាណាចក្រកម្ពុជាថ្នាក់មហាសិរីវឌ្ឍន៍។

**៩- ព្រះមុនីកោសល ហ៊ុល សុវណ្ណ រាជាគណៈថ្នាក់ទោ ជាអនុគណខណ្ឌឫស្សីកែវ, សមាជិកថេរសភាសង្ឃនៃព្រះរាជាណាចក្រកម្ពុជា និងជាព្រះចៅអធិការវត្តទួលសុវណ្ណារាម សន្ធាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ**

ព្រះមុនីកោសល **ហ៊ុល សុវណ្ណ** ប្រសូតនៅថ្ងៃទី០១ ខែមករា ឆ្នាំ១៩២៣ នៅភូមិជីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្តាល មានបិតាឈ្មោះ **ហ៊ុល ផាន** មាតាឈ្មោះ **សេក យ៉ង់** មានបងប្អូន ៦នាក់ ប្រុស៣នាក់ ស្រី៣នាក់។



នៅឆ្នាំ១៩២៩ ក្នុងជន្មាយុ៦វស្សា មាតា បិតា នាំឱ្យទៅសិក្សានៅសាលាបឋមសិក្សាជីឥដ្ឋ ហើយបានប្រឡងជាប់វិញ្ញាបនបត្របារាំងខ្មែរ (Certificat d'étude primaire complementaire) ក្នុងឆ្នាំ១៩៣៨ រួចប្រឡងចូលរៀននៅវិទ្យាល័យដេកាដ ក្រុងភ្នំពេញ។ នៅឆ្នាំ១៩៤២ ក្នុងជន្មាយុ ១៩ វស្សា ជីតាបង្កើតរបស់សម្តេចបានទទួលអនិច្ចកម្ម មាតាបិតាក៏បានឱ្យសម្តេចបួសសងគុណ។ បន្ទាប់ពីឈាបនកិច្ចសពជីតារួចរាល់ហើយ សម្តេចបាននិមន្តមកគង់នៅកុដិលេខ១១ វត្តសំពៅមាស។ ទោះបីមានមិត្តភក្តិបបួលឱ្យសឹកធ្វើការរដ្ឋជាមួយគេយ៉ាងណាក៏ដោយ ក៏សាមណេរមិនព្រមតាមមិត្តភក្តិសោះឡើយ ហើយព្យាយាមសិក្សារៀនធម៌អាថ៌វិន័យសិក្ខា ដរាបបានប្រឡងជាប់វិញ្ញាប័នបត្រពុទ្ធិកបឋមសិក្សា(ភាសាបាលីរង) និងវិញ្ញាបនបត្រធម្មវិន័យគ្រប់កម្រិតទៀតផង។ លុះជន្មាយុគម្រប់ ២០ចូល ២១វស្សា សម្តេចក៏បានឧបសម្បទាជាភិក្ខុ ក្នុងពទ្ធសីមាវត្តសំពៅមាស ក្រុងភ្នំពេញ ដែលមានព្រះគ្រូសម្មាធិធម្មព្រះនាម **ស្វាយ អ៊ឹម** ជាចៅអធិការវត្តជាព្រះឧបជ្ឈាយ៍ ព្រះគ្រូ **ជ័យ ម៉ៃ** គ្រូសូត្រស្តាំ និងគ្រូ **ទី គុជ** គ្រូសូត្រឆ្វេងជាឧបសម្បទានចារ្យ។

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ សម្តេចត្រូវពួកប៉ុលពត បង្ខំឱ្យចាកចេញ ព្រមទាំងបន្សឹក និងបង្ខំឱ្យធ្វើការងារជាទម្ងន់នៅភូមិរពាងវែង ឃុំរពាងវែង ស្រុកកំពង់ត្រាច ខេត្តកំពត ដូចជា ប្រជាពលរដ្ឋដទៃឯទៀតដែរ។

ក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ ដោយមានឧបនិស្ស័យនឹងព្រះពុទ្ធសាសនា បណ្ឌិត **ហ៊ុល សុវណ្ណ** បានសម្រេចចិត្តចូល

កាន់ព្រះផ្នួសម្ដងទៀត ក្នុងឆ្នាំ១៩៨១ នៅពុទ្ធសីមាវត្តឧណ្ណាលោម ដែលមានសម្ដេច **ទេព វង្ស** អគ្គមហាសង្ឃរាជាធិបតី ជាព្រះឧបជ្ឈាយ៍រាជគណៈមហានិកាយនៃ ព្រះរាជាណាចក្រកម្ពុជាជាព្រះឧបជ្ឈាយ៍ ព្រះសពសម្ដេចមង្គលទេពាចារ្យ **អ៊ុំ ស៊ុំ** និងព្រះតេជគុណ **អ៊ិត ស៊ុំ** ជាឧបសម្បទាចារ្យ។ បួសពេញសិទ្ធិជាភិក្ខុភាវៈ ក្នុងព្រះពុទ្ធសាសនា ហើយបានគង់នៅវត្តលង្កាកុសុមារាមក្រុងភ្នំពេញ។

ចាប់ពីឆ្នាំ១៩៩៤ មក សម្ដេចបានទទួលសមណស័ក្តិជាបន្តបន្ទាប់។ ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ១៩៩៤ បានទទួលឋានានុក្រមជាព្រះធម្មចរិយា គូនាទីជាព្រះចៅអធិការវត្តទួលសុវណ្ណារាម និងជាទីប្រឹក្សាសម្ដេចព្រះសង្ឃរាជ **ទេព វង្ស** នៅថ្ងៃទី០៨ ខែសីហា ឆ្នាំ១៩៩៥ ឋាននុក្រមបានទទួល ជាព្រះមុនីកោសលរាជាគណៈថ្នាក់ទោ ជាអនុគណខណ្ឌឬស្សីកែវ។ នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៥ ជាសមាជិកនៃគណៈកម្មាធិការកណ្ដាល នៃមជ្ឈមណ្ឌលពុទ្ធិកសង្គ្រោះព្រមទាំងបាន ទទួលមេដាយស្ថាបនាជាតិមាស១ និងមេដាយស្ថាបនាជាតិសំរឹទ្ធិ១។



## ព្រះរាជជីវប្រវត្តិពិស្ដារ
## សម្ដេចអគ្គមហាសង្ឃរាជទាំងពីរគណៈ
## សម្ដេចព្រះសង្ឃនាយក ព្រះសង្ឃនាយករង
## និងមន្ត្រីសង្ឃជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជា

# ព្រះរាជក្រឹត្យត្រាស់បង្គាប់ផ្តល់គោរមងារកិត្តិឧទ្ទេសបណ្ឌិត

ព្រះរាជក្រឹត្យ

នស/រកត/០៩១២/៩៣៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស ឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការ បង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការ កែសម្រួល មាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និង មាត្រា២០ នៃព្រះរាជ ក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

**មាត្រា១**៖ តែងតាំងសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី **ទេព វង្ស** សម្តេចព្រះមហាសង្ឃរាជ នៃគណៈមហានិកាយនៃព្រះរាជាណាចក្រកម្ពុជាជា **កិត្តិឧទ្ទេសបណ្ឌិត** នៃរាជបណ្ឌិត្យសភាកម្ពុជា។

**មាត្រា២**៖សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា៣**៖ ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខៈ៤០៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រីរាជរដ្ឋាភិបាល
សយ សុខា

៣៦០.១២០៥ ៩៤២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១២



# ១-ព្រះរាជជីវប្រវត្តិ
# សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី ទេព វង្ស
# សម្តេចព្រះមហាសង្ឃរាជនៃគណៈមហានិកាយ
# នៃព្រះរាជាណាចក្រកម្ពុជា



សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី **ទេព វង្ស** សម្តេចព្រះមហាសង្ឃរាជ នៃគណៈមហានិកាយព្រះរាជាណាចក្រកម្ពុជា ទ្រង់ប្រសូតក្នុងបច្ចិមយាមទៀបភ្លឺ ថ្ងៃព្រហស្បតិ៍ ២រោច ខែបុស្ស ឆ្នាំវក ចត្វាស័ក ព.ស២៤៦៦ ត្រូវនឹងថ្ងៃទី១២ ខែមករា ឆ្នាំ១៩៣២ នៅភូមិត្រពាំងចក (បច្ចុប្បន្នហៅភូមិប្រឡាយ) ឃុំជ្រាវ ស្រុកសៀមរាប ខេត្តសៀមរាប ដោយមានមាតានាម **មិុច អាត់** និងបិតានាម **ទេព ឈិត** (អតីតអ្នកបួសបាន១២ព្រះវស្សា) និងមានបងប្អូន ៣នាក់ ៖

១- **ទេព សាយ** ហៅប៉ុក, កូនប្រុសទី១

២- **ទេព សុវណ្ណ**, កូនប្រុសទី២ (ស្លាប់ក្នុងទារកភាពអាយុបាន៧ខែ)

៣- **ទេព វង្ស**, កូនប្រុសទី៣ ក្នុងត្រកូលកសិករ។

អាយុ ៣ឆ្នាំ ៖ ឪពុកម្តាយបានយកកុមារ **ទេព ខេមរ** ទៅផ្ញើជាមួយជីតាខណៈពេលដែលលោកទាំងពីរជាប់រវល់នឹងកិច្ចការកសិកម្ម។ ខណៈពេលដែលអាស្រ័យនៅជាមួយជីតា កុមារ **ទេព ខេមរ** មានការឧស្សាហ៍ព្យាយាម គោរពតាមដំបូន្មានរបស់ព្រឹទ្ធាចារ្យរូបនេះណាស់។ ចាប់ពីវ័យ៤-១០វស្សា, កុមារ **ទេព ខេមរ** ព្យាយាម សិក្សារៀនសូត្រចំណេះវិជ្ជាមេផ្ទះយ៉ាងច្រើនដែលរាល់កូនអ្នកជនបទ តែងតែព្យាយាមហ្វឹកហាត់ ធ្វើការបម្រើមាតាបិតា ជីតា ប្រកបដោយកតញ្ញូតាធម៌។

អាយុបាន១១វស្សា ៖ ឪពុកម្តាយបាននាំយកកុមារ **ទេព ខេមរ** ទៅប្រគេនព្រះគ្រូសមុហ៍គណ **ហ៊ីង ម៉ៅ** ដែលជាព្រះចៅអធិការវត្តរាជបូព៌ដើម្បីសិក្សាអក្សរខ្មែរនិងវិជ្ជាផ្លូវលោក-ផ្លូវធម៌។ ប៉ុន្តែជាអកុសលក្នុងសម័យនោះ, ស្ថាប័នពុទ្ធសាសនា មានភាពរង្គោះរង្គើយ៉ាងខ្លាំងដោយសារទស្សនៈធម៌ចាស់-ថ្មី (សម័យបុរាណ)។

អាយុបាន ១២ វស្សា ដោយបិតាមានជំងឺរ៉ាំរ៉ៃក្នុងខ្លួន មាតាក៏សុំកុមារ **ទេព ខេមរ** អំពីព្រះគ្រូ សមុហ៍គណ **ហ៊ីង ម៉ៅ** មកឱ្យជួយគ្រប់គ្រងកិច្ចការផ្ទះវិញ។

អាយុ១៥វស្សា ៖ បិតាក៏បានទទួលអនិច្ចកម្មទៅដោយរោគាពាធ។ក្នុងបន្ទុកគ្រួសារកុមារ **ទេព ខេមរ** មានសមាជិកតែបីនាក់គត់ គឺ ម្តាយនិងកូនប្រុសពីរនាក់ប៉ុណ្ណោះ។

នៅក្នុងឆ្នាំនោះព្រះករុណាសម្តេចព្រះបាទ **នរោត្តម សីហនុ** ជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ចេញព្រះរាជក្រឹត្យត្រាស់បង្គាប់ សូមឱ្យខេមរៈពុទ្ធសាសនិក សាងព្រះផ្នួសក្នុងព្រះពុទ្ធសាសនា ដោយសទ្ធាជ្រះថ្លារបស់ខ្លួន។ នៅក្នុងគ្រួសារកុមារ **ទេព**



**ខេមរ** មានសមាជិកតែបីនាក់ប៉ុណ្ណោះ រួមទាំងម្តាយផង ប៉ុន្តែ អ្នកស្រី **ម៉ិច អាត់** បានអនុញ្ញាតឱ្យកូនប្រុសសាងព្រះផ្នួសក្នុងព្រះពុទ្ធសាសនាដោយលោក **ទេព សាយ** (ហៅប៉ុក) ជាបង ត្រូវបានបំពេញឧបសម្បទាឱ្យឡើងជាភិក្ខុភាវៈ ចំណែកឯកុមារជាប្អូនបានបួសជាសាមណេរក្នុងសំណាក់ព្រះគ្រូសមុហ៍គណ **ហ៊ីង ម៉ៅ** ព្រះចៅអធិការវត្តរាជបូព៌ និងជាព្រះឧបជ្ឈាយ៍ក្នុងឆ្នាំ១៩៤៧។ ចំណែកឯកុមារ **ទេព ខេមរ** ក៏ត្រូវលាចាកសិក្ខាបទមកជាគ្រហស្ថវិញ ដើម្បីគ្រប់គ្រងការងារផ្ទះ និងចិញ្ចឹមរក្សាញោមស្រី ក្រោយពីសាងផ្នួសបានតែ ៩ខែ។

លុះដល់ឆ្នាំ១៩៥០, ភិក្ខុ **ទេព សាយ** (ហៅប៉ុក) ជាបងមានរោគាពាធជាទម្ងន់ ក៏លាចាកសិក្ខាបទមកកាន់ភេទជាគ្រហស្ថវិញមិនបានយូរប៉ុន្មានផង ក៏ទទួលមរណភាពទៅ។

លុះដល់ឆ្នាំ១៩៥២ ព្រះជន្មាយុ ២១ឆ្នាំ ក្នុងមជ្ឈិមវ័យ យុវជន **ទេព ខេមរ** ក៏សុំម្តាយទៅបួសម្តងទៀតក្នុងសំណាក់ព្រះគ្រូ សមុហ៍គណ **ហ៊ីង ម៉ៅ** (ពុទ្ធសរ) ជាព្រះឧបជ្ឈាយ៍ ដោយព្រះគ្រូ តន់ លុយ (ពុទ្ធត្ថេរ) ជាកម្មវាចា ព្រះគ្រូ **ថាត់ មិន** (ឥន្ទជោតិ) ជា អនុស្សវណ្ណាចារ្យឱ្យឡើងជាភិក្ខុភាវៈក្នុងពទ្ធសីមាវត្តរាជបូព៌ទីរួមខេត្តសៀមរាបនៅថ្ងៃសុក្រ ១៣រោច ខែជេស្ឋ ឆ្នាំរោង ចត្វាស័កពុទ្ធសករាជ២៤៩៥ ត្រូវនឹងថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៥២ នៅវេលាម៉ោង៨ និង ៥នាទី ដោយព្រះឧបជ្ឈាយ៍ឱ្យនាមបញ្ញត្តិថា បញ្ញាសិរី ព្រះភិក្ខុ **ទេព ខេមរ**។

ក្រោយពីបានទទួលឧបសម្បទាជាភិក្ខុភាវៈហើយ ភិក្ខុ **ទេព ខេមរ** ចាប់ផ្តើមសិក្សារៀនសូត្រទាំង វិបស្សនាធុរៈ សមថកម្មដ្ឋាន និង

គន្ធធុរៈពីសំណាក់ព្រះគ្រូសមុណ៍គណ **ហ៊ីង ម៉ៅ** យ៉ាងយកចិត្តទុកដាក់។

ក្នុងព្រះជន្មាយុ២៥ព្រះវស្សា ព្រះភិក្ខុ **ទេព វង្ស** បានក្លាយជាព្រះបាតិមោក្ខកោវិទអ្នកចេះសូត្រវិន័យបាតិមោក្ខយ៉ាងស្ទាត់ជំនាញ។

លោកគ្រូសូត្រ ស្តាំ-ឆ្វេង មានជរាពាធប្រចាំថ្ងៃ ទើបព្រះគ្រូ **ហ៊ីង ម៉ៅ** រកការព្រមព្រៀងជាឯកច្ឆ័ននិមន្តព្រះភិក្ខុ **ទេព វង្ស** មកតែងតាំងជាលោកគ្រូសូត្រជំនួយការ និងប្រគល់ភារកិច្ចការងារដឹកនាំភិក្ខុសាមណេរនិងកុមារក្នុងវត្តឱ្យរៀនសូត្រ និងសាងសង់ក្នុងវត្តរាជបូព៌ទាំងមូល។

នៅក្នុងចន្លោះឆ្នាំ១៩៧០-១៩៧៩, ព្រះភិក្ខុ **ទេព វង្ស** ក៏មិនខុសពីប្រជាពលរដ្ឋដទៃដែរ គឺ ទទួលនូវឥទ្ធិពលនៃការប្រែប្រួលនយោបាយរបស់ប្រទេសជាតិយ៉ាងខ្លាំង។ នៅក្នុងសម័យខ្មែរក្រហម ព្រះគ្រូធម្មាចារ្យ **ទេព វង្ស** បានទទួលរងនូវទារុណកម្មយ៉ាងធ្ងន់ធ្ងរពីសំណាក់ពួកខ្មែរក្រហម។ ព្រះគ្រូធម្មាចារ្យត្រូវបានគេដាក់ពន្ធនាគារអស់រយៈពេល៣ខែ និងធ្លាប់ត្រូវបានគេយកទៅសម្លាប់ ប៉ុន្តែជីពជន្មមិនអស់រហូតដល់ឆ្នាំ១៩៧៩ ក៏ត្រូវរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាដឹកនាំដោយសម្តេច **ហេង សំរិន** សម្តេច **ជា ស៊ីម** និង សម្តេច **ហ៊ុន សែន** សង្គ្រោះឱ្យរួចផុតពីការគ្រប់គ្រង ដែលមិនប្រកបដោយទសពិធរាជធម៌របស់អ្នកដឹកនាំនៃរបបខ្មែរក្រហម។

ក្រោមការឧបត្ថម្ភពីសម្តេច **ជា ស៊ីម** អនុប្រធានរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលបានទៅនិមន្តព្រះសង្ឃពីកម្ពុជាក្រោមចំនួន ៩អង្គ ដើម្បីមកបំបួសអតីតបព្វជិតចំនួន ៧រូប ដោយមានលោក



ធម្មាចារ្យ **ទេព វង្ស** ក្នុងចំណោមទាំងនោះផង នៅពទ្ធសីមាវត្តឧណ្ណាលោម រាជធានីភ្នំពេញ នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៩ ដោយមានព្រះគ្រូ **ឋិត សីលោ** សង្ឃនាយកកម្ពុជាក្រោមជាព្រះឧបជ្ឈាយ៍ ព្រះគ្រូ **ឧឡា រោ** ជាកម្មវាចារ្យ ព្រះគ្រូ **កុសល ចិន្តោ** ជាអនុស្សវណ្ណាចារ្យឧបស្សទាកម្ម ជាភិក្ខុភាវៈក្នុងពទ្ធសីមាវិហារវត្តឧណ្ណាលោម ចប់នៅម៉ោង៤ រសៀល។ ព្រះឧបជ្ឈាយ៍បានឱ្យនាមបញ្ញត្តិ ជាឧបេក្ខាសម្មោជ្ឈង្គិកោ។ សូមបញ្ជាក់ថា ការបំបួសចប់សព្វគ្រប់ហើយ ព្រះគ្រូឧបជ្ឈាយ៍បានប្រកាសក្នុងជំនុំសង្ឃថា ព្រះ ភិក្ខុ **ទេព វង្ស** ឱ្យឡើងឋានានុក្រម ឋានន្តរស័ក្តិ ជាព្រះវិន័យធរសង្ឃ និងជាព្រះឧបជ្ឈាយ៍សម្រាប់បំបួសភិក្ខុសាមណេរនៅកម្ពុជា។ បន្ទាប់មក ជាអនុប្រធានរណសិរ្សសាមគ្គីកសាង និងការពារមាតុភូមិកម្ពុជា និងជាប្រធានសង្ឃទូទាំងប្រទេស ក្នុងការស្តារព្រះពុទ្ធសាសនាឡើងវិញ ក្នុងបច្ឆិមវ័យក្នុងការព្យាយាមបដិបត្តិនូវវិបស្សនាធុរៈ គន្ធធុរៈ ព្រមទាំងទទួលបាននូវអនុក្រឹត្យពីសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៩ ដើម្បីអនុវត្តតាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។

អាស្រ័យដោយស្មារតីព្យាយាមយ៉ាងក្រៃលែង ក្នុងការបម្រើ ព្រះពុទ្ធសាសនា និងសង្គមជាតិ គិតពីឆ្នាំ២០០៩ សម្តេចព្រះមហាសង្ឃរាជបានទទួលឥស្សរិយយស សញ្ញាបត្រសមណស័ក្តិ និងគោរមងារ ដូចខាងក្រោម៖

## ឥស្សរិយយស

១-វឌ្ឍនការប្រាក់ ព្រះរាជទាន ដោយព្រះករុណាព្រះបាទ

**នរោត្តម សីហនុវរ្ម័ន** ទ្រង់គង់ជាប្រមុខរដ្ឋ

២-មុនីសារាភ័ណ្ឌ

៣-អស្សរឹទ្ធិមុនីសារាភ័ណ្ឌ ព្រះរាជទានដោយព្រះករុណា ព្រះ-បាទសម្តេចព្រះ **នរោត្តមព្រះសុរាម្រឹត**

៤-មេដាយស្ពានជ្រោយចង្វារ ព្រះរាជទាន ដោយព្រះករុណា ព្រះបាទសម្តេច **ព្រះនរោត្តម ព្រះសុរាម្រឹត**

៥-មេដាយកីឡាអូឡាំពិកព្រះរាជទានដោយ**ព្រះមហាក្សត្រិយានីស៊ីសុវត្ថិកុសុមនារីរ័ត្ន**

៦-គ្រឿតស្សរិយយស ជាតូបការ ថ្វាយដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** សមណស័ក្តិ។

## សមណស័ក្តិ

- ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៩ ជាព្រះឧបជ្ឈាយ៍ និងប្រធានសង្ឃទូទាំងប្រទេសដោយសម្តេច **ជា ស៊ីម**
- ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ១៩៩១ ជាព្រះមហាសុមេធាធិបតី **ទេព វង្ស** ព្រះសង្ឃនាយកនៃរដ្ឋកម្ពុជា
- ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៩១ ជាសម្តេចព្រះសង្ឃរាជ គណៈមហានិកាយ នៃកម្ពុជា ដោយព្រះករុណាព្រះបាទសម្តេច ព្រះ **នរោត្តម សីហនុ**
- ខែកញ្ញា ឆ្នាំ២០០៣ ជាឯកអគ្គរដ្ឋទូតសន្តិភាពដោយសហព័ន្ធអន្តរជំនឿអន្តរជាតិ



- ឆ្នាំ២០០៦ ជាសហប្រធានក្រុមប្រឹក្សាសាសនាពិភពលោកដើម្បីសន្តិភាព ដោយក្រុមប្រឹក្សាសាសនាពិភពលោក ដើម្បីសន្តិភាព ញូវយ៉ក សហរដ្ឋអាមេរិក
- ថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៦ ជាសម្តេចព្រះអគ្គមហាសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជាដោយសម្តេចព្រះបរមនាថព្រះបាទ **នរោត្តម សីហនុ**។

## សញ្ញាបត្រ

- សញ្ញាបត្រធម្មវិន័យ ធម្មកោសល្យ ត្រី ទោ ឯក និងបាតិមោក្ខកោវិទ
- ឆ្នាំ១៩៩១ អគ្គមហាសទ្ធម្មជោតិកធជៈ (១លេខលំដាប់ថ្នាក់សាសនាទូត) ដោយឧត្តមសេនីយ៍ផុតលេខ **ថាន់ ស្វេ** ប្រធានក្រុមប្រឹក្សារដ្ឋសហភាពមីយ៉ាន់ម៉ា ,
- ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០៤ សញ្ញាបត្របណ្ឌិតកិត្តិយសផ្នែកព្រះពុទ្ធសាសនាពីពុទ្ធិកសាកលវិទ្យាល័យ ចូឡាឡុងករប្រទេសថៃ ទទួលស្គាល់ពីស្នាព្រះហស្តក្នុងការស្តារព្រះពុទ្ធសាសនានៅកម្ពុជាឡើងវិញ បន្ទាប់ពីសម័យខ្មែរក្រហម
- ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៨ សញ្ញាបត្របណ្ឌិតកិត្តិយសផ្នែកព្រះពុទ្ធសាសនានៅកម្ពុជា។

## ស្នាព្រះហស្ត

សម្តេចព្រះមហាសង្ឃរាជ ទ្រង់បានចងក្រង និងនិពន្ធសៀវភៅចំនួន ៥ក្បាល ៖

១- សៀវភៅអក្ខរកម្ម

២- ច្បាប់ប្រុស ច្បាប់ស្រី

៣-នគរកាយ

៤- ក្រមច្បាប់

៥-តម្រាក្បួនខ្នាតព្រាហ្មណ៍សាសនា និងព្រះពុទ្ធសាសនា វិបស្សនាធុរៈ។

ចាប់តាំងពីឆ្នាំ១៩៧៩ មកសម្តេចព្រះមហាសង្ឃរាជបានបំពេញកាតព្វកិច្ចក្នុងព្រះពុទ្ធសាសនាដូចជា បំបួសអតីតបព្វជិតចាស់ៗឲ្យឡើងជាព្រះមេគណ អនុគណ គ្រប់ស្រុក ខណ្ឌ គ្រប់វត្តជាង២០០០វត្ត និងអប់រំមហាជនគ្រប់បណ្តាថ្នាក់ ដែលមានសមត្ថភាពកសាងវត្តបន្ថែមឡើងជាង បួន ពាន់វត្ត។ ជាពិសេស សំណូមពរព្រះមហាក្សត្រព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ដើម្បីកសាងព្រះសាក្យមុនីចេតិយតម្កល់ព្រះបរមសារីរិកធាតុ នៅលើកំពូលភ្នំព្រះរាជទ្រព្យ។

ដោយឡែកការកសាងប្រទេសជាតិមាតុភូមិមានកសាងសាលារៀនតាំងពីមត្តេយ្យសាលា និងបឋមសិក្សាជាដើម ដូចជាហេដ្ឋារចនាសម្ព័ន្ធស្ពាន ថ្នល់ ទំនប់ ប្រឡាយ ស្ពាន សុវត្ថិភាព (២៧ គីឡូម៉ែត) នៅក្រុងព្រះសីហនុ ព្រមទាំងជួយបណ្តុះបណ្តាលផ្នែកចំណេះដឹងវិបស្សនាធុរៈ បរិយត្តិធម៌ រហូតទល់បច្ចុប្បន្ន។











ពិធីថ្វាយព្រះគោរមងារកិត្តិឧទ្ទេសបណ្ឌិតចំពោះសម្តេច
ព្រះមហាសង្ឃរាជាធិបតី **ទេព វង្ស**
ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៣












ពិធីថ្វាយព្រះគោរមងារកិត្តិឧទ្ទេសបណ្ឌិតចំពោះសម្តេច
ព្រះមហាសង្ឃរាជាធិបតី **ទេព វង្ស**
ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៣



# ព្រះរាជក្រឹត្យត្រាស់បង្គាប់ផ្តល់គោរមងារកិត្តិឧទ្ទេសបណ្ឌិត



ព្រះរាជក្រឹត្យ

នស/រកត/០៩១២/៧៣៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រតនខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស ឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការ បង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការ កែសម្រួល មាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និង មាត្រា២០ នៃព្រះរាជ ក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា១**: តែងតាំងសម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី **ទេព វង្ស** សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកៈនិកាយនៃព្រះរាជាណាចក្រកម្ពុជា ជា**កិត្តិឧទ្ទេសបណ្ឌិត** នៃរាជបណ្ឌិត្យសភាកម្ពុជា។

**មាត្រា២**: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា៣**: ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១២

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១២
**អគ្គលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី**
**សយ សុខា**

## ២-ព្រះរាជជីវប្រវត្តិពិស្តារ
## សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
## សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ
## នៃព្រះរាជាណាចក្រកម្ពុជា



សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតីស្តេច ទ្រង់ប្រសូត នៅថ្ងៃព្រហស្បតិ៍ ១៣រោច ខែបុស្ស ឆ្នាំរកា ព.ស២៤៨៨ ត្រូវនឹង ថ្ងៃទី១១ ខែមករា ឆ្នាំ១៩៤៥ នៅឃុំស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបង។ ព្រះមាតាព្រះនាម **ជា ជួន** ព្រះបិតាព្រះនាម **បួរ ខ៉ាន**។

លុះព្រះអង្គមានព្រះជន្មបាន ៧ព្រះវស្សា សម្តេចបានសិក្សាអក្សរ និងលេខនព្វន្ត នៅសាលាបឋមសិក្សា ឃុំស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបង។ នៅក្នុងឆ្នាំកុរ ឯកស័ក ព.ស ២៥០៣ ត្រូវនឹង គ.ស ១៩៥៩ ព្រះអង្គបានប្រឡងចូលសិក្សានៅវិទ្យាល័យបាត់ដំបង ឃុំស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបង។

លុះដល់ឆ្នាំថោះ គ.ស១៩៦៣ ព្រះអង្គបានប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ (ឌីប្លូម)។ ទោះបីជាព្រះអង្គអាចនឹងបន្តការសិក្សាទៀតបានក៏ដោយ ប៉ុន្តែទ្រង់ទតមើលឃើញភេទបព្វជ្ជា គឺជា



ភេទដ៏ ឧត្តុង្គឧត្តមជាផ្លូវលោកុត្តរៈ ដែលល្អប្រសើរថ្លៃថ្លាជាងវិជ្ជាផ្លូវលោកណាៗទាំងអស់ ទើបព្រះអង្គសម្រេចព្រះរាជហឫទ័យ លាចាកព្រះមាតាបិតា និងក្រុមញាតិមកបំពេញភេទបព្វជ្ជាជាសាមណេរនិងឧបសម្បទាជាភិក្ខុភាវៈនៅវត្តបុប្ផារាម ស្ថិតនៅក្នុងឃុំស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបង។ បន្ទាប់ពីបានបព្វជ្ជារួចហើយ ព្រះអង្គបានខិតខំរៀនសូត្រព្រះធម៌ និងព្រះវិន័យរហូតក្លាយជាពហុសូត្រ ជាអ្នកចេះចាំព្រះធម៌-វិន័យ បានយ៉ាងស្ទាត់ជំនាញ។ បន្ទាប់មកព្រះអង្គបានគង់នៅក្នុងវត្តបុប្ផារាមនិងវត្តបទុមវតីរាជវរារាម ដើម្បីសិក្សារៀនសូត្រភាសាបាលី ប្រែគម្ពីរធម្មបទនិងមង្គលទីបនីចប់សព្វគ្រប់។ ក្រោយមកទៀតព្រះអង្គបានទទួលការតែងតាំងជា ព្រះលេខាធិការគណប្រចាំខេត្តបាត់ដំបង ព្រមទាំងបានទទួលនូវសេចក្តីគោរពស្រឡាញ់ និងកោតសរសើរពីព្រះសង្ឃនិងពុទ្ធបរិស័ទយ៉ាងច្រើនអនេក។ មិនយូរប៉ុន្មានព្រះអង្គត្រូវបានទទួលការតែងតាំង បន្ថែមលើមុខងារដែលព្រះអង្គកំពុងបំពេញជាអ្នកបដិបត្តិនាទីជួសព្រះមេគណគណៈធម្មយុត្តខេត្តបាត់ដំបង និងនិមន្តឡើងចុះមើលការខុសត្រូវក្នុងការកសាងវត្តគណៈធម្មយុត្ត នៅប៉ោយប៉ែត។

នៅក្នុងឆ្នាំថោះ សប្តស័ក ព.ស ២៥១៩ គ.ស ១៩៧៥ បន្ទាប់ពីមានរដ្ឋប្រហារទម្លាក់ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** និងក្នុងពេលដែលប្រទេសកម្ពុជាធ្លាក់ចូលក្នុងរបបខ្មែរក្រហមស្ថានភាពព្រះពុទ្ធសាសនាបានធ្លាក់ចុះដុនដាបយ៉ាងខ្លាំង ព្រះអង្គបានភៀសព្រះកាយយាង ទៅកាន់ប្រទេសបារាំង នៅក្នុងឆ្នាំ១៩៧៦។ នៅក្នុងកិច្ចសវនាការជាមួយសម្តេចសង្ឃ Pope Jean Paul II នៅទីក្រុង

Vatican ព្រះអង្គក៏បានស្នើសុំដល់ព្រះវិហារកាតូលិក ថ្កោលទោសជាផ្លូវការចំពោះគោលនយោបាយ សម្លាប់មនុស្សរង្គាលនៃរបបខ្មែរក្រហមប៉ុល ពត។

ក្រោយពីព្រះអង្គស្ដេចយាងដល់ប្រទេសបារាំង នាឆ្នាំ១៩៧៧ ព្រះអង្គបានបង្កើតសមាគមខ្មែរដំបូងបង្អស់មួយឈ្មោះថា សមាគមពុទ្ធិខ្មែរ ដែលមានលក្ខណៈផ្លូវច្បាប់ខាងសាសនាសុទ្ធសាធស្ថិតនៅទីក្រុងក្រេតីយ៍ ប្រទេសបារាំង។

នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៨០ ព្រះអង្គបានកសាងវត្តដំបូងបង្អស់មួយដែលមាននៅក្នុងទ្វីបអឺរ៉ុបឈ្មោះថា «វត្តខេមរារាម» ស្ថិតនៅក្រោមការដឹកនាំគ្រប់គ្រងរបស់ ព្រះអង្គផ្ទាល់ដោយមានពិធីបញ្ចុះសីមាជាវត្តត្រឹមត្រូវតាមលក្ខណៈព្រះពុទ្ធសាសនា។ នៅថ្ងៃទី ២ ខែកក្កដា ឆ្នាំ១៩៨១ ពេលនោះដែរ ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ស្ដេចនៅជាព្រះអង្គម្ចាស់ **នរោត្តម សីហមុនី** បានយាងចូលសាងព្រះផ្នួសឧបសម្បទាជាភិក្ខុភាវៈមាននាមបញ្ញត្តិថា «ពុទ្ធវឌ្ឍិតោ» នាវត្តខេមរារាម មានសម្ដេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី **បួរ គ្រី** សម្ដេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយនៃព្រះរាជាណាចក្រកម្ពុជា ពេលនោះជាលោកគ្រូម្ចាស់ **បួរ គ្រី** ស្ដេចជាព្រះរាជឧបជ្ឈាយ៍បំបួសផ្ទាល់។

នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៥ ព្រះអង្គបានរៀបចំធ្វើពិធីសម្ពោធឆ្លងវត្តខេមរារាម-ពុទ្ធិកសមាគមខ្មែរ ក្រោមព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ**



ព្រះមហាវីរក្សត្រ និងសម្ដេចព្រះមហាក្សត្រី **នរោត្តម មុនីនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរនៅពេលនោះដែរ ព្រះករុណាព្រះមហាវីរក្សត្រ បានដំឡើងព្រះកិត្តិយសថ្វាយចំពោះព្រះអង្គជា " ព្រះសុវរធម្មខេមរសាសនវង្សាចារ្យ " ព្រះចៅអធិការ វត្តខេមរារាម ។

អាស្រ័យនូវទឹកព្រះទ័យមេត្តាករុណា ព្រះអង្គបានបង្កើតអង្គការមនុស្សធម៌មួយ ដែលមានឈ្មោះថាសមាគមពុទ្ធិសង្គ្រោះអន្តរ ជាតិនាឆ្នាំ១៩៨២ ដែលមានលក្ខណៈផ្លូវច្បាប់ខុសពីការបង្កើតវត្ត ដើម្បីផ្ដល់ជំនួយមនុស្សធម៌ដល់ជនរងគ្រោះនិងទីទ័លក្រ។ខណៈពេលដែលព្រះអង្គអាស្រ័យនៅប្រទេសបារាំង ព្រះអង្គតែងតែយាងចុះសួរសុខទុក្ខប្រជារាស្ត្រនៅឯជំរំជនភៀសខ្លួន នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ក្នុងគោលបំណងចែកជូននូវសម្ភារៈនិងផ្ដល់ជំនួយស្មារតីដល់ជនភៀស ខ្លួនដែលរងការឈឺចាប់ផ្លូវចិត្ត ក្នុងការប្រាសចាកលំនៅដ្ឋាននិវាសចាកពីមាតុប្រទេសរបស់ខ្លួន។

ព្រះអង្គបានខិតខំកសាងវត្តអារាម និងពុទ្ធមណ្ឌលជាច្រើននៅក្នុងទ្វីបអឺរ៉ុប ដូចជាប្រទេសបារាំង (នៅទីក្រុង Créteil, Toul-Nancy, Lille)ប្រទេសប៊ែលហ្ស៊ីក(ទីក្រុងBrussels) ប្រទេសអាល្លឺម៉ង់(ទីក្រុង Stuttgart) និងនៅសហរដ្ឋអាមេរិក (នៅទីក្រុងOhio និង Washin gton)។ ដោយមានការសម្គាល់នូវរាល់កិច្ចខិតខំប្រឹងប្រែងឥតឈប់ឈររបស់ព្រះអង្គ ទើបព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ទ្រង់ប្រោសប្រទានថ្វាយគោរមងារជា គ្រូសម្ដេចព្រះ នៅថ្ងៃច័ន្ទ ៦រោច ខែអស្សុជ ឆ្នាំរោង ព.ស២៥៣២ ត្រូវនឹងថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៨៧។

បន្ទាប់ពីកិច្ចព្រមព្រៀង នៅទីក្រុងប៉ារីសរវាងគ្រប់ភាគីទាំងអស់ នាថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាវីរក្សត្រ និងសម្តេចព្រះមហាក្សត្រីយ៍ **នរោត្តម មុនីនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ បានស្នើសុំយាងព្រះអង្គនិវត្តមកកាន់មាតុភូមិកម្ពុជាវិញ។

នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩៩១ ក្រោមការស្នើសុំពីសំណាក់សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៅពេលនោះជា ឯកឧត្តម **ជា ស៊ីម** ប្រធានរដ្ឋសភានៃរដ្ឋកម្ពុជា ប្រធានរណសិរ្សសង្គ្រោះមាតុភូមិកម្ពុជា និងជាប្រធានគណបក្សប្រជាជនកម្ពុជា ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ពេលនោះព្រះអង្គជា ព្រះប្រធានក្រុមប្រឹក្សាជាន់ខ្ពស់ ទ្រង់បានថ្វាយព្រះឋានៈជាសម្តេចព្រះសុគន្ធាធិបតី សម្តេចព្រះសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយនៃកម្ពុជា។ ពេលនោះពុំទាន់មានវត្ត និងព្រះសង្ឃគណៈធម្មយុត្តនៅឡើយ សម្តេចព្រះសង្ឃរាជ ទ្រង់ប្រថាប់នៅក្នុងវត្តឧណ្ណាលោម អស់រយៈពេលបីខែ រហូតដល់ថ្ងៃទី១៥ ខែ កុម្ភៈ ឆ្នាំ១៩៩២ ទើបសម្តេចយាងមកគង់នៅវត្តបទុមវតីរាជវរារាម ប្រារព្ធពិធីក្រោមព្រះរាជាធិបតី ដ៏ខ្ពង់ខ្ពស់របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាវីរក្សត្រ និងសម្តេចព្រះមហាក្សត្រី **នរោត្តម មុនីនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ដោយមានការអញ្ជើញចូលរួមពី សម្តេចអគ្គមហាធម្មពោធិសាល កិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម** ប្រធានព្រឹទ្ធសភា សម្តេចអគ្គមហាពញាចក្រីកិត្តិព្រឹទ្ធបណ្ឌិត **ហេង សំរិន** ប្រធានរដ្ឋសភាជាតិ និងមន្ត្រីរាជការជាន់ខ្ពស់ដទៃទៀត



ជាច្រើនរូប។ ចំណែកឯខាងព្រះសង្ឃមាន សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី **ទេព វង្ស** និងមន្ត្រីសង្ឃព្រមទាំងពុទ្ធបរិស័ទយ៉ាង និងអញ្ជើញចូលរួមយ៉ាងច្រើនកុះករនាឱកាសនោះ។

នៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ១៩៩២ សម្តេចព្រះសង្ឃរាជទ្រង់បានបំបួសកុលបុត្រ ដែលមានសទ្ធាជ្រះថ្លាក្នុងព្រះបវរពុទ្ធសាសនា ជាសាមណេរភិក្ខុរាប់រយអង្គ ព្រមទាំងបានកែកុនជួសជុលអតីតវត្តធម្មយុត្តមួយចំនួនតូចបំផុត ហើយទ្រង់បានខិតខំកសាងវត្តធម្មយុត្តថ្មីៗ បន្ថែមទៀត ដោយប្រក់ស្លឹកខ្លះ ប្រក់ស្បូវខ្លះ ដែលពុទ្ធបរិស័ទអ្នកមានសទ្ធាជ្រះថ្លា បានថ្វាយដីកសាងវត្ត ហើយព្រះអង្គបានចំណាយព្រះរាជទ្រព្យផ្ទាល់ទិញដីសម្រាប់កសាងវត្តគណៈធម្មយុត្តឡើងវិញ។

នាពេលបច្ចុប្បន្ននេះ ក្រោមព្រះរាជកិច្ចដឹកនាំរបស់សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី **បួរ គ្រី** សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា វត្តគណៈធម្មយុត្តទូទាំងព្រះរាជាណាចក្រកម្ពុជា មានចំនួនសរុប ១៦១វត្ត និងមានព្រះសង្ឃចំនួន ២៥០០អង្គ គិតមកដល់ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១១។

នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៧ សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី **បួរ គ្រី** សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយនៃព្រះរាជាណាចក្រកម្ពុជា ស្តេចបានទទួលនូវមហាកិត្តិយសដ៏ធំធេង ដោយសម្តេចអគ្គមហាសេនាបតីតេជោបណ្ឌិតសភាចារ្យ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានថ្វាយនូវមេដាយជាន់ខ្ពស់ថ្នាក់ «ជាតូបការ» ដែលជាមេដាយថ្នាក់ខ្ពស់បំផុត

នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីតបស្នងព្រះរាជគុណដែលព្រះអង្គមានស្នាព្រះហស្តដ៏ធំធេង លះបង់ព្រះកាយពលក្នុងព្រះរាជកិច្ចដឹកនាំព្រះ ពុទ្ធសាសនា (គណៈធម្មយុត្ត) ជាសាសនារបស់រដ្ឋ ដែលមានចែងទុកក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ ២០០៧ សម្តេចព្រះមហាសង្ឃរាជជាអម្ចាស់ ព្រះអង្គបានទទួលការតែងតាំងដោយព្រះរាជក្រឹត្យជា " ព្រះសាកលវិទ្យាធិការ " នៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា ពីព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា។

នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៧ សម្តេចព្រះមហាសង្ឃរាជជាអម្ចាស់ព្រះអង្គបានទទួលការ ប្រោសព្រះរាជទានព្រះរាជក្រឹត្យថ្វាយព្រះបរមងារជា សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយនៃព្រះរាជាណាចក្រកម្ពុជា ពីព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ដោយមានព្រះរាជបញ្ញត្តិទូលតបជាភាសារាជស័ព្ទឲ្យព្រះអង្គមានសិទ្ធិប្រើផ្លិតយសពិសេស។

នៅថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១០សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី **បួរ គ្រី** សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយនៃព្រះរាជាណាចក្រកម្ពុជាព្រះអង្គបានទទួលការប្រោសព្រះរាជទានព្រះរាជក្រឹត្យតែងតាំងទទួលខុសត្រូវបន្ថែម ជាព្រះប្រធានគណៈសង្ឃនាយកនៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជាពីព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី**



ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។

នៅថ្ងៃទី២២-២៣ ខែមករា ឆ្នាំ២០១១ សម្តេចអគ្គមហាសេនាបតីតេជោបណ្ឌិតសភាចារ្យ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** បានប្រកបពិធីដ៏អធិកអធមថ្វាយ ព្រះសុគន្ធវារីស្រង់ស្រោចស្រពជម្រះអង្គចម្រើនព្រះជន្មវស្សា គម្រប់ ៦៦ យាងចូល ៦៧ ព្រះវស្សា ដែលព្រះរាជពិធីនេះប្រារព្ធ នៅវត្តស្វាយពពែ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ៕















ពិធីថ្វាយព្រះគោរមងារកិត្តិឧទ្ទេសបណ្ឌិតចំពោះសម្តេច
ព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី **បួរ គ្រី**
ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៣





ពីធីថ្វាយព្រះគោរមងារកិត្តិឧទ្ទេសបណ្ឌិតចំពោះសម្តេច
ព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី **បួរ គ្រី**
ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៣







ពីធីថ្វាយព្រះគោរមងារកិត្តិឧទ្ទេសបណ្ឌិតចំពោះសម្តេច
ព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី **បួរ គ្រី**
ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៣



ពិធីថ្វាយព្រះគោរមងារកិត្តិឧទ្ទេសបណ្ឌិតចំពោះសម្តេច
ព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី **បួរ គ្រី**
ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៣

# ព្រះរាជក្រឹត្យត្រាស់បង្គាប់ផ្តល់គោរមងារកិត្តិឧទ្ទេសបណ្ឌិត

**ព្រះរាជក្រឹត្យ**

នស/រកត/០៩១២/៧៣៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រត្ថខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស ឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការ បង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការ កែសម្រួល មាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និង មាត្រា២០ នៃព្រះរាជ ក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា១**: តែងតាំងសម្តេចព្រះមហាសុមេធាធិបតី **នន្ទ ង៉ែត** សម្តេចព្រះសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជាព្រះអគ្គាធិការពុទ្ធិកសិក្សាជាតិ ជា **កិត្តិឧទ្ទេសបណ្ឌិត** នៃរាជបណ្ឌិត្យសភាកម្ពុជា។

**មាត្រា២**: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា៣**: ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ចករ**
**នរោត្តម សីហមុនី**

៣១៧.១២០៩.៩៤៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១២

លេខៈ ៧ ០៣ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ២០១២
**អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី**
សយ សុខា

## ៣- ព្រះរាជប្រវត្តិរូបសង្ខេប
## សម្តេចព្រះមហាសុមេធាធិបតី នន្ទ ង៉ែត
## សម្តេចព្រះសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា
## ព្រះអគ្គាធិការពុទ្ធិកសិក្សាជាតិ ជាសាកលវិទ្យាធិការនៃ
## ពុទ្ធិកសាកលវិទ្យាល័យ ព្រះចៅអធិការវត្តបទុមវតី



### I. ជាតិភូមិ

សម្តេច **នន្ទ ង៉ែត** ប្រសូតនៅថ្ងៃ៥ រោច ខែវិសាខ ឆ្នាំឆ្លូ ព.ស២៤៦៧ ត្រូវនឹងថ្ងៃទី៥ ខែឧសភា គ.ស១៩២៦ នៅភូមិត្រពាំងវែង ឃុំលំចង់ ស្រុកសំរោង ខេត្តតាកែវ។ ព្រះអង្គជាបុត្រទី២ នៃលោកឧបាសក **នន្ទ នុត** និងលោកយាយ ឧបាសិកា **ម៉ឹង យឹម**។ ព្រះអង្គមានបងប្អូន៤នាក់ គឺ ប្រុស៣នាក់ ស្រី១នាក់ នៅក្នុងត្រកូលកសិករសុទ្ធសាធ ហើយជាគ្រួសារប្រកបដោយគន្លងធម៌។

### II. ការសិក្សា និងបព្វជ្ជា

កុមារ **នន្ទ ង៉ែត** មានវ័យវឌ្ឍនាចម្រើនអាយុបាន១១ឆ្នាំ មាតា បិតាបាននាំបុត្រជាទីស្រឡាញ់ឲ្យទៅសិក្សាចំណេះវិជ្ជាមាន អក្សរសាស្ត្រ លេខនព្វន្ត និងរៀនធម៌វិន័យជាដើម ទៅតាមសម័យកាលនៅ



វត្តពោធិ៍ ឃុំពោធិ៍អង្គ្រង ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ក្នុងសំណាក់ព្រះគ្រូព្រះនាម **សួស មាស** ជាព្រះចៅអធិការវត្ត។

កុមារ **នន្ទ ង៉ែត** មានអត្តចរិត ស្លូតបូត សុភាពរាបសាកាយវិការទន់ភ្លន់ មានប្រាជ្ញា ឧស្សាហ៍ព្យាយាមខុសប្លែកពីកុមារទាំងពួង។ តាំងពីបានទៅសំណាក់ក្នុងវត្តហើយកុមារ **នន្ទ ង៉ែត** បានយកចិត្តទុកដាក់ខិតខំសិក្សារៀនសូត្រ ព្រមទាំងមានការគោរពគ្រូបាធ្យាយ ជានិច្ចកាល មិនថាយប់ មិនថាថ្ងៃឡើយ។

លុះនៅសិក្សារៀនសូត្រក្នុងវត្តអស់រយៈកាល៥ឆ្នាំ កុមារ **នន្ទ ង៉ែត** បានទទួលចំណេះវិជ្ជាផ្នែកអក្សរសាស្ត្រ លេខនព្វន្ត ធម៌-វិន័យ អាចប្រើការបានយ៉ាងគាប់ប្រសើរ។ នៅពេលស្របគ្នានោះដែរ មាតារបស់កុមារ **នន្ទ ង៉ែត** មានជំងឺជាទម្ងន់ ហើយក៏បានទទួលអនិច្ចកម្មទៅកាន់បរលោកចោលកុមារ **នន្ទ ង៉ែត** ទាំងក្តីសោកសៅកន្លង។ កុមារ**នន្ទ ង៉ែត** ត្រូវកំព្រាឥតមាតាតាំងពីពេលនោះមកក៏បានសម្រេចចិត្តថ្វាយបង្គំលា ព្រះគ្រូចៅអធិការ ត្រឡប់ទៅនៅផ្ទះវិញ ដើម្បីបានរស់នៅជាមួយឪពុក ជួយបម្រើកិច្ចការផ្សេងៗ ដោយសេចក្តីគោរពនិងយកចិត្តទុកដាក់បំផុត។

#### ក-ការបួសជាសាមណេរ

លុះដល់ថ្ងៃក្រោយមក យុវជន **នន្ទ ង៉ែត** អាយុបាន២១ឆ្នាំ ក៏មានចិត្តជ្រះថ្លាក្នុងព្រះពុទ្ធសាសនាបានសុំអនុញ្ញាតពីបិតាដើម្បីសាងបព្វជ្ជាជាសាមណេរ ក្នុងសំណាក់ព្រះគ្រូព្រះនាម **សួស មាស** ជាព្រះឧបជ្ឈាយ៍ក្នុងពទ្ធសីមាវត្ត ពោធិ៍អង្គ្រង ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។

យុវជន **នន្ទ ខ៉ែត** បានសាងព្រះផ្នួសបួសជាសាមណេរ រួចហើយបានខិតខំប្រឹងប្រែងឧស្សាហ៍ព្យាយាមសិក្សាធម្មវិន័យ ព្រមទាំងរៀនមូលកច្ចាន:វេយ្យាករណ៍ ប្រែគម្ពីរធម្មបទដ្ឋកថា មង្គលត្ថទីបនីជាដើម មានការយល់ដឹង និងចេះចាំយ៉ាងជ្រៅជ្រះ នូវក្បួនច្បាប់ព្រះពុទ្ធសាសនា សមជាពហុស្សូតក្នុងព្រះពុទ្ធសាសនមណ្ឌលនាគ្រានោះ។

**ខ-ការបួសជាភិក្ខុលើកទី១**

នៅគ.ស ១៩៤៨ ព.ស ២៤៩២ សាមណេរ **នន្ទ ខ៉ែត** បួសជាសាមណេរបាន៤ ព្រះវស្សា ក៏មានបសាទសទ្ធាចង់បំពេញមហាកុសលជាភិក្ខុភាវ: ហើយបានសុំអនុញ្ញាតពីបិតានិងលោកគ្រូចៅអធិការវត្ត។ បិតានិងលោកគ្រូចៅអធិការបានអនុញ្ញាតឲ្យតាមសំណូមពរសាមណេរ **នន្ទ ខ៉ែត** បានឧបសម្បទាជាភិក្ខុភាវ:ដោយមិនចាំបាច់ សឹកជាគ្រហស្ថវិញឡើយ។

សាមណេរ **នន្ទ ខ៉ែត** បានសម្រេចព្រះទ័យបំពេញឧបសម្បទាជាភិក្ខុភាវ:ក្នុងពទ្ធសីមាវត្តពោធិ៍ ឃុំពោធិ៍អង្រ្កង ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដោយមានព្រះគ្រូសូត្រស្តាំនិងព្រះគ្រូនាម **រស់ មាស** ជាព្រះគ្រូសូត្រឆ្វេងបានទទួលនាមបញ្ញត្តិថា **នន្ទ ត្ថេរោ**។

ក្រោយពីពេលបួសជាភិក្ខុរួចហើយ ព្រះភិក្ខុ **នន្ទ ត្ថេរោ** ខិតខំព្យាយាមសិក្សាគន្ថធុរ:(ព្រះបរិយត្តិធម៌) បន្តទៅទៀតរហូតដល់ក្លាយជាធម្មាចារ្យ។ បន្ទាប់មកព្រះភិក្ខុ **នន្ទ ត្ថេរោ** បាននិមន្តពីវត្តពោធិ៍មកគង់នៅវត្តអម្ពវ័ន ហៅព្រៃជ្វរ ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ ។ ព្រះសង្ឃវត្តព្រៃជ្វរ និងគណ:កម្មការវត្តបានតែងតាំងភិក្ខុ **នន្ទ ត្ថេរោ** ជាអាចារ្យបង្រៀនព្រះបរិយត្តិធម៌ដល់ភិក្ខុសាមណេរវត្តព្រៃជ្វរ



ឲ្យទទួលបានចំណេះដឹងធម៌វិន័យផ្នែកព្រះពុទ្ធសាសនា។នៅឆ្នាំ១៩៦២ ដល់១៩៦៤ បាននិមន្តទៅរៀនសាលាបំពេញវិជ្ជា នៅវត្តឈើ ទាលជ្រុំ ឃុំកុមារពជា ស្រុកបាទី ខេត្តតាកែវ និងបានត្រឡប់មកវត្តវិញ រហូតដល់ឆ្នាំ១៩៧៥ ទើបត្រូវពួកបនប្រល័យពូជសាសន៍ដែលជាទមិឡឥតសាសនាបានបង្ខំឲ្យព្រះភិក្ខុ **នន្ទ ត្ថេរោ** សឹកទៅជាគ្រហស្ថ ដែលពុំមែនជាបំណងប្រាថ្នារបស់ព្រះភិក្ខុ **នន្ទ ត្ថេរោ** ឡើយ។

ក្នុងរបបប្រល័យពូជសាសន៍ រយ:ពេលបីឆ្នាំ ប្រាំបីខែនិងម្ភៃថ្ងៃ អន្និត **នន្ទ ខ៉ែត** ត្រូវបានពួកបាតដៃប្រឡាក់ឈាមបង្ខំឲ្យធ្វើការងារជាទម្ងន់ដូចជាប្រជាជនខ្មែរដទៃទៀតដែរ។ ទោះបីស្ថិតនៅក្នុងភាពជាគ្រហស្ថ និងមានការលំបាកខាងផ្លូវចិត្ត និងផ្លូវកាយយ៉ាងណាក្តី ក៏ទឹកចិត្តជិតនៅជាប់ជាមួយនឹងព្រះពុទ្ធសាសនា ស្មើនឹងពាក់កណ្តាលជីវិតហើយនោះ លោកបន្និតក៏នៅតែប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួននូវការនមស្ការគុណព្រះរតនត្រ័យនៅក្នុងមុងដោយការលាក់លៀមនឹងពួក កងឈ្លបដែលបំបិទសិទ្ធិសេរីភាពគ្រប់បែបយ៉ាង រួមទាំងជំនឿសាសនាជាដើម។ ទោះបីជាយុគ:ស្ថិតនៅក្នុងលង្វែកសាសនាយ៉ាងណាក្តី ប៉ុន្តែសន្តានចិត្តរបស់លោកអន្និត **នន្ទ ខ៉ែត** នៅតែគិតមមៃដោយក្តីសង្ឃឹមយ៉ាងកក់ក្តៅបំផុតថា គង់តែមានបុគ្គលជាអ្នកមានបុណ្យស្នេហាជាតិ ចូលមកជួយស្រោចស្រង់ប្រទេសជាតិ និងព្រះពុទ្ធសាសនាឲ្យរស់ឡើងវិញជាក់ជាមិនខានឡើយ។ ដោយមានជំនឿជឿជាក់ក្នុងសតិអារម្មណ៍ដូចនេះហើយបានជាក្នុងពេលបន ប៉ុល ពត ចាប់បង្ខំអន្និត**នន្ទ ខ៉ែត**រៀបចំផ្សំផ្គុំនឹងនារី ដែលមានរូបស្អាតម្នាក់ឲ្យជាគូស្វាមីភរិយាតែលោកបានប្រកែកពុំព្រមទទួលយកយ៉ាងដាច់អហង្ការ ដោយលោកចង់ថែរក្សា

ព្រហ្មចរិយាធម៌ឲ្យបរិសុទ្ធ ដូចជានៅជាភិក្ខុសង្ឃអ៊ីចឹងដែរ។ ពិសេសជាងនេះទៅទៀត ប្រទេសកម្ពុជាក៏បានរំដោះ បានពីកណ្តាប់ដៃពួកបនប្រល័យពូជសាសន៍ទាំងស្រុង នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ដោយរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាក៏លោកអន្ទិត **នន្ទ ម៉ែត** មិនរវីរវល់អើពើនឹកនារកគូស្រករប្រចាំជីវិតដូចជា គ្រហស្ថភាគច្រើនឡើយ ព្រោះលោកចង់ថែរក្សាសីលឲ្យបរិសុទ្ធ ដូចជានៅបួសជាភិក្ខុសង្ឃដែរ។ លោកអន្ទិត **នន្ទ ម៉ែត** រង់ចាំថ្ងៃណាមួយប្រទេសកម្ពុជាមានព្រះពុទ្ធសាសនា មានភិក្ខុសង្ឃនិងព្រះឧបជ្ឈាយ៍ឡើងវិញ លោកនឹងចូលសាងព្រះផ្នួសជាភិក្ខុភាវៈបន្តទៅទៀត។ ដោយគុណបុណ្យនៃការគោរពប្រតិបត្តិនូវព្រះពុទ្ធសាសនា ជាពិសេសដោយសារគុណរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលមានសម្តេចទាំងបី គឺសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បានរំដោះប្រទេសកម្ពុជាឲ្យរួចផុតពីរបបខ្មៅងងឹត។ លោកអន្ទិត **នន្ទ ម៉ែត** ក៏ដូចជាប្រជាជនកម្ពុជាដទៃទៀតដែរ ដែលមានភ័ព្វសំណាងមិនអាចកាត់ថ្លៃបានក្នុងឆាកជីវិតប្រព្រឹត្តទៅនៅលើវាលពិឃាត ដែលរស់នៅបានមួយថ្ងៃគិតថា ខ្លួនមានជីវិតម្តងទៀត ហើយមិនដឹងថា ថ្ងៃស្អែកត្រូវគេយកទៅសម្លាប់ ឬទុកឲ្យរស់សម្រាប់ខែក្រោយ ឬឆ្នាំក្រោយឡើយ។

### គ-ការបួសលើកទី ២

ដោយហេតុតែឧបនិស្ស័យនៃការសាងផ្នួស ជាឧត្តមភេទកាត់ថ្លៃមិនបានពុំទាន់អស់អំពីសន្តានចិត្តរបស់លោកអន្ទិត **នន្ទ ម៉ែត** ពីព្រោះការលាចាកសិក្ខាបទនៅខែមេសា ឆ្នាំ១៩៧៥ នោះជាការបង្ខិតបង្ខំពីបនប្រល័យពូជសាសន៍ **ប៉ុល ពត** ដែលមិនមែនជាបំណងរបស់



លោកបណ្ឌិតឡើយ។ នៅក្នុងទំព័រប្រវត្តិថ្មីនេះទីស្តីការគណៈកម្មាធិការមជ្ឈិមរណសិរ្សសង្គ្រោះជាតិកម្ពុជាលេខ២៤.រ៨១.ស ស្តីអំពីរបៀបរបបបំបួសកុលបុត្រក្នុងព្រះពុទ្ធសាសនា ដោយរដ្ឋបានចាត់ចែងឲ្យនិមន្តព្រះឧបជ្ឈាយ៍ និងការរកសង្ឃមួយចំនួនមកពីកម្ពុជាក្រោមដើម្បីបំបួសដល់អតីតបព្វជិតដែលមានសទ្ធាជ្រះថ្លាចង់បួស លោកអន្ទិត **នន្ទ ម៉ែត** បានទទួលដំណឹងដ៏ល្អនេះ ក៏មានចិត្តសោមនស្សត្រេកអរឥតឧបមាពីព្រោះត្រូវនឹងបំណងប្រាថ្នារបស់ខ្លួន ដោយលោកស្រឡាញ់ គោរពជឿជាក់ ចំពោះព្រះពុទ្ធសាសនាស្មើជីវិត។ ម្យ៉ាងទៀតដោយចង់បានបុណ្យកុសលផ្ទាល់ខ្លួនផង និងមានបំណងចង់បួសសងគុណគ្រូឧបជ្ឈាយាចារ្យមាតាបិតាផង ពិសេសដើម្បីជ្រោងទង់ព្រះពុទ្ធសាសនា ដែលធ្លាក់ដល់ចំណុចសូន្យអស់រយៈកាលបីឆ្នាំ ប្រាំបីខែ និងម្ភៃថ្ងៃ ក៏ដូចជាប្រជាជនកម្ពុជា ដែលនៅសល់តែសម្បកជីវិត ប្រកបដោយភាពស្គមស្គាំងស្បែកដណ្តប់ឆ្អឹង មនុស្សទាំងអស់គឺមានភាពជរាមើលពុំដឹងក្មេងឬចាស់ឡើយ។

នៅពេលនោះលោកអន្ទិត **នន្ទ ម៉ែត** និងលោកឧបាសក ៦ នាក់ទៀត ក្នុងសម័យរដ្ឋកម្ពុជាបានទទួលបព្វជ្ជាជំបូងបង្អស់ នៅថ្ងៃពុធ ១១រោច ខែភទ្របទ ឆ្នាំមមែ ព.ស ២៥២៣ ត្រូវនឹងថ្ងៃទី១៩ ខែកញ្ញា គ.ស១៩៧៩ នៅវត្តឧណ្ណាលោម រាជធានីភ្នំពេញ ក្រោមអធិបតីភាពនៃការកសង្ឃទាំង ៧ អង្គ ៖

១-ព្រះអង្គ **យឹម ទឹម** ជាព្រះឧបជ្ឈាយ៍

២-ព្រះអង្គ **ថាច់ ធៀងតុង** ជាគ្រូសូត្រស្តាំ

៣-ព្រះអង្គ **ធីច ទីត** ជាគ្រូសូត្រឆ្វេង ឯព្រះអង្គ៤ ព្រះអង្គទៀត មិនចាំព្រះនាមអតីតបព្វជិតទាំង៧ រូប ដែលត្រូវបំបួសនោះគឺ ៖

១-ភិក្ខុ **កើត ថ៉ាយ** ទទួលនាមបញ្ញត្តិថា សតិសម្ពោជ្ឈង្គោ និមន្តមកពី ខេត្តកំពង់ធំ (សុគត ២៥ មករា ១៩៩១)

២-ភិក្ខុ **ច្រាក់ ឌិត** ទទួលនាមបញ្ញត្តិថា ធម្មវិច្ចយសម្ពោជ្ឈង្គោ និមន្តមកពីខេត្តតាកែវ (សុគត)

៣-ភិក្ខុ **ឌិន សារុន** ទទួលនាមបញ្ញត្តិថា វិរិយសម្ពោជ្ឈង្គោ និមន្តមកពី ខេត្តកណ្តាល (សុគត)

៤-ភិក្ខុ **អ៊ុ ស៊ុម** ទទួលនាមបញ្ញត្តិថា បីតិសម្ពោជ្ឈង្គោ និមន្តមកពីខេត្តតាកែវ (សុគត ០១ កញ្ញា ១៩៩៨)

៥-ភិក្ខុ **នន្ទ ង៉ែត** ទទួលនាមបញ្ញត្តិថា បស្សទ្ធិសម្ពោជ្ឈង្គោ និមន្តមកពីខេត្តតាកែវ

៦-ភិក្ខុ **កែន វង្ស** ទទួលនាមបញ្ញត្តិថា សម្មាធិសម្ពោជ្ឈង្គោ និមន្តមកខេត្តព្រៃវែង (សុគត)

៧-ភិក្ខុ **ទេព វង្ស** ទទួលនាមបញ្ញត្តិថា ឧបេក្ខាសម្ពោជ្ឈង្គោ និមន្តមកពីខេត្តសៀមរាប។

បន្ទាប់មកព្រះភិក្ខុបស្សទ្ធិសម្ពោជ្ឈង្គោ **នន្ទ ង៉ែត** បាននិមន្តមកគង់នៅវត្តលង្កាព្រះកុសុមារាមនាថ្ងៃ៥រោច ខែពិសាខ ព.ស២៥២៣ គ.ស ១៩៨០ បានទទួលងារព្រះចៅអធិការវត្ត និងជាព្រះឧបជ្ឈាយ៍បំបួសកុលបុត្រគង់នៅវត្តលង្កាព្រះកុសុមារាម អស់រយៈកាល៩ព្រះវស្សា។ ចំណែកវត្តបទុមវតី ពុំទាន់មានព្រះចៅអធិការវត្តនៅឡើយទេត្រូវបានសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** សម្តេចអគ្គមហាពញាចក្រី



**ហេង សំរិន** និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និមន្តព្រះភិក្ខុបស្សទ្ធិសម្ពោជ្ឈង្គោ **នន្ទ ង៉ែត** មកគង់នៅវត្ត បទុមវតីក្នុង គ.ស ១៩៨៩ មានការជួបប្រទះឧបសគ្គ និងកង្វះខាត ជាច្រើន ក្នុងជីវិតអ្នកបួសតែងកើតមានដូចក្នុងសម័យពុទ្ធកាល ដូច្នោះ ដែរ ប៉ុន្តែអ្វីដែលល្អបំផុតគឺគុណធម៌មាន សច្ចៈ ខន្តី កតញ្ញូ និងវិរិយភាពជាមេធម៌នាំឲ្យសម្រេចនូវអ្វីៗ ទាំងអស់ដោយការប្រកាន់ខ្ជាប់ និងអនុវត្តន៍នូវគោលធម៌ទាំងអស់នោះ ហើយទើបសាមគ្គីធម៌កើតមាន ភាពងាយស្រួលក្នុងភេទជាបព្វជិត ទាំងការងារ ទាំងការគោរពប្រណិបតន៍ ធម៌វិន័យបានយ៉ាងល្អ។ ព្រះភិក្ខុបស្សទ្ធិសម្ពោជ្ឈង្គោ **នន្ទ ង៉ែត** អនុវត្តនូវនាយកធម៌ គឺធម៌សម្រាប់អ្នកដឹកនាំទាំង៦ បានយ៉ាងខ្ជាប់ខ្ជួនល្អប្រសើរ ហើយថែមទាំងប្រតិបត្តិនូវការគោរពធម៌ចំពោះព្រះថេរៈចាស់ៗបានយ៉ាងល្អ។

ព្រះកាយវិការដ៏ទន់ភ្លន់ សុភាពរាបសា ព្រះចរិយាថ្លៃថ្នូរ មិនរើសអើង មិនប្រកាន់ឋានៈ តួនាទីអ្វីៗទាំងអស់។ សម្តេចជាទីស្រឡាញ់គោរព រាប់អានដល់ពុទ្ធបរិស័ទទូទៅ ដែលធ្លាប់មានការប្រាស្រ័យទាក់ទងជាមួយនឹងព្រះអង្គ ទាំងមន្ត្រីរាជការ ទាំងពុទ្ធបរិស័ទ ដែលប្រជារាស្ត្រ និងបព្វជិត ព្រមទាំងសាស្ត្រាចារ្យ ព្រឹទ្ធសាស្ត្រាចារ្យនូវពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹតបានវាយតម្លៃថា ព្រះភិក្ខុបស្សទ្ធិសម្ពោជ្ឈង្គោ **នន្ទ ង៉ែត** ជាព្រះភិក្ខុសង្ឃមួយអង្គ មិនមានព្រះភិក្ខុសង្ឃណាមួយធ្វើដូចបាន។ សម្តេច **នន្ទ ង៉ែត** ជាព្រះភិក្ខុសង្ឃគំរូដ៏ឆ្នើមមួយព្រះអង្គសម្រាប់ព្រះភិក្ខុសង្ឃទូទៅគោរពប្រតិបត្តិរៀនតាមដូចជា ៖

- លេចធ្លោលើវិស័យកសាងទាំងពុទ្ធចក្រ និងអាណាចក្រ

- សមិទ្ធផលផ្សេងៗដែលព្រះអង្គបានកសាងឡើងគឺសុទ្ធតែមានផលប្រយោជន៍ចំពោះព្រះពុទ្ធសាសនា និងសង្គមជាតិ
- គោរពប្រតិបត្តិធម៌វិន័យបានល្អ និងឧស្សាហ៍ថ្វាយបង្គំនមស្ការព្រះរតនត្រ័យព្រឹកល្ងាច ពុំដែលខានឡើយ
- មានព្រហ្មវិហារធម៌ និងសង្គហធម៌ ជានិច្ចនៅក្នុងខន្ធសន្តាន
- គារវធម៌ និងអបចាយនធម៌របស់ព្រះអង្គតែងមានជាប្រចាំ
- ទឹកព្រះទ័យទូលាយមានកតញ្ញូតាធម៌ជាប់ជានិច្ច និងមានបដិសណ្ឋារកិច្ចដ៏ល្អ។
- ការរស់នៅជាសុខក្តី ជាទុក្ខក្តី ព្រះអង្គតែងនឹកដល់អនិច្ចតាធម៌ជានិច្ច
- សម្តេច **នន្ទ ង៉ែត** ព្រះអង្គរស់នៅក្នុងអប្បមាទធម៌គ្រប់កាលៈទេសៈ

សម្តេចមានសមត្ថភាពគ្រប់គ្រាន់ ឈ្លាសវៃប៉ិនប្រសប់ក្នុងការដឹកនាំអប់រំ គ្រប់គ្រងព្រះសង្ឃ គ្រហស្ថ អាចារ្យ គណៈកម្មការវត្ត និងពុទ្ធបរិស័ទចំណុះជើងវត្ត និងគ្រប់គ្រងព្រះសង្ឃទូទាំងប្រទេសបានល្អជាពិសេស ទំនាក់ទំនងជាមួយរដ្ឋអំណាចទូទាំងប្រទេសបានល្អប្រសើរ ព្រះកិត្តិនាមកេរ្តិ៍ឈ្មោះនិងព្រះកិត្តិយសដ៏ល្បីល្បាញទាំងអស់នេះហើយ បានជាសម្តេចត្រូវទទួលការគាំទ្រ អបអរសាទរស្រឡាញ់រាប់អានយ៉ាងស្មោះស្ម័គ្រជាទីបំផុតពីព្រះសង្ឃ និងប្រជាពុទ្ធបរិស័ទទូទាំងប្រទេស។

ចាប់ពីឆ្នាំ១៩៨០ មកទល់នឹងឆ្នាំ២០១០ សម្តេច **នន្ទ ង៉ែត** មានសកម្មភាពយ៉ាងខ្លាំងក្លាក្នុងការដឹកនាំ ណែនាំព្រះសង្ឃ ប្រជាពុទ្ធបរិស័ទ និងសប្បុរជនទូទៅក្នុងការកសាងសមិទ្ធផលនានា មាន



សាលារៀន ផ្លូវថ្នល់ ផ្លូវលំ ស្រះទឹក អណ្តូងស្នប់ ព្រះវិហារ កុដិ ឧបដ្ឋានសាលា ខ្លោងទ្វារ របងវត្ត អគារពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ តុ កៅអី សាឡុង ម៉ាស៊ីនភ្លើង មេក្រូ អំពូលភ្លើង និងជួយឧបត្ថម្ភនូវបច្ច័យផ្តល់ប្រគេនដល់វត្តមួយចំនួនឲ្យយកទៅកសាងវត្ត និងទិញសម្ភារៈមាន តុ កៅអី ជាដើម ជួយដល់ព្រះពុទ្ធសាសនា និងជួយដល់សង្គមជាតិ។

## III. អំពីស្នាព្រះហស្តលើវិស័យកសាងសមិទ្ធផលនានា

### ក-វិស័យកសាងខាងផ្នែកពុទ្ធចក្រ នៅឆ្នាំ ១៩៨០-១៩៨៩

សម្តេចគង់នៅវត្តលង្កាព្រះកុសុមារាមព្រះអង្គបានកសាងដូចជា ៖

- សាលាបឋមសិក្សា២ខ្នងស្មើនឹង១០បន្ទប់ នៅក្នុងវត្តលង្កា ព្រះកុសុមារាម ក្រោយមកត្រូវរើទៅសាលាអនុវត្តវិញ
- សាលាបាលីរង ១ខ្នង ២ជាន់ ៦បន្ទប់
- ជួសជុលព្រះវិហារ
- កសាង និងជួសជុលកុដិ
- កសាងឧបដ្ឋានសាលា
- ជួសជុលដងទង់
- ជួសជុលពុទ្ធិកបឋមសិក្សា និងរៀបចំឲ្យទៅជាពុទ្ធិកវិទ្យាល័យ
- រៀបចំទីធ្លាវត្ត និងចាក់សាបទីធ្លាវត្តនៅឆ្នាំ១៩៨៩-២០១០

បទុមវតី ព្រះអង្គបានកសាងសំណង់នានាក្នុងវត្តបទុមវតីនិងវត្តផ្សេងៗមាន ៖

- កសាងដងទង់ ១គូ

- ជួសជុលព្រះវិហារ
- សាងសង់ឧបដ្ឋានសាលាថ្មី
- ធ្វើរបងវត្ត និងក្លោងទ្វារ
- ធ្វើបណ្ណាល័យ
- សាងសង់ចេតិយ
- កសាងមហាកុដិមួយ សម្រាប់តម្កល់ទុកក្នុងព្រះពុទ្ធសាសនា
- កសាងអគារពុទ្ធិកមហាវិទ្យាល័យមួយខ្នងពីរជាន់ ៦បន្ទប់
- ជួសជុលអគាធិការដ្ឋានចាស់
- កសាងតុ កៅអី ក្ដារខៀន ការិយាល័យសម្រាប់សមណសិស្ស សមណនិស្សិត និងសម្រាប់សាស្ត្រាចារ្យនៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត
- ជួយឧបត្ថម្ភព្រឹទ្ធសាស្ត្រាចារ្យទាំង១១រូប រៀងរាល់ឆ្នាំនិងជួយឧបត្ថម្ភយុវសាស្ត្រាចារ្យផងដែរ។
- កសាងកុដិព្រះគ្រូសូត្រស្ដាំ១ខ្នង
- កសាងសាលាគណរាជធានីភ្នំពេញ១ខ្នង
- សួនច្បារខាងមុខសាលាគណ១
- កសាងព្រះវិហារថ្មីនៅវត្តព្រៃជួរ ( សាងសង់កំពុង )
- កុដិ៤ខ្នងនៅវត្តព្រៃជួរ
- ស្រះទឹក២នៅវត្តព្រៃជួរ

**ខ-វិស័យកសាងខាងផ្នែកអាណាចក្រមាន ៖**

- ជីកអណ្ដូងស្នប់ចំនួន៣៥
- ផ្លូវលំចំនួន៥គីឡូម៉ែត្រ



- កសាងសាលាបឋមសិក្សាព្រៃជួរ ២ខ្នង មាន១០បន្ទប់
- កសាងទីចាត់ការ ១ខ្នង នៅអនុវិទ្យាល័យព្រៃជួរ

ផ្នែកបោះពុម្ពផ្សព្វផ្សាយ

- ចងក្រងសៀវភៅកំណើត៤
- ចងក្រងសៀវភៅពុទ្ធទំនាយ និងឥន្ទទំនាយ
- ចូលរួមពិនិត្យ និងចងក្រងសៀវភៅមង្គលត្ថទីបនីប្រែភាគ១
- ចូលរួមពិនិត្យ និងចងក្រងសៀវភៅពុទ្ធិកសិក្សា

## IV. អំពីព្រះរាជសមណស័ក្តិគោរមងារទី និង គ្រឿងឥស្សរិយយស

ដោយការពិនិត្យឃើញនូវសមិទ្ធផលនានា និងព្រះសកម្មភាពរបស់សម្ដេចកន្លងមក ក្នុងការជួយឧបត្ថម្ភកសាងវិស័យពុទ្ធចក្រ និងការជួយឧបត្ថម្ភរួមចំណែកក្នុងការកសាងវិស័យអាណាចក្រនិងមូលដ្ឋានរបស់ព្រះអង្គយ៉ាងច្រើនសន្ធឹកសន្ធាប់ តាំងពីមូលដ្ឋាន ភូមិ ឃុំ ស្រុក ខេត្ត រាជធានី រហូតដល់ជួយកសាងមូលដ្ឋានខេត្តនានាមួយចំនួនទៀត។

ដោយសារព្រះគុណូបការៈដ៏ធំធេងទាំងអស់នេះហើយ បានជារដ្ឋអំណាចមូលដ្ឋានគ្រប់លំដាប់ថ្នាក់ និងមន្ត្រីសង្ឃគ្រប់ជាន់ថ្នាក់ បានពិភាក្សាពិចារណា ទទួលឯកភាពគ្នាលើកសំណើ សុំការសរសើរ និងការតែងតាំងតួនាទីឋានៈថ្វាយចំពោះសម្ដេច **នន្ទ ង៉ែត** ជាបន្តបន្ទាប់។

ដោយសារស្នាព្រះហស្ត ដែលសម្ដេចបានកសាងសមិទ្ធផលយ៉ាងច្រើនក្នុងវិស័យពុទ្ធចក្រផង ទាំងក្នុងវិស័យអាណាចក្រផង ទើបព្រះកិត្តិយសដ៏ល្បីល្បាញនិងព្រះឥទ្ធិពលដ៏ល្អនេះបានជួយដល់សម្ដេច សម្ដេចគិតអ្វី ធ្វើអ្វី ឬក៏មានទំនាក់ទំនងអ្វីមួយជាមួយរដ្ឋអំណាចគ្រប់

ថ្នាក់ជាមួយរាជរដ្ឋាភិបាល ពិសេសជាមួយសម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** និងលោកជំទាវបណ្ឌិត **ប៊ុនរ៉ានី ហ៊ុន សែន** លើកសំណើសំណូមពរអ្វីៗបានដូចបំណងប្រាថ្នា។

ក្រោយពីសម្តេចត្រូវបានក្រុមប្រឹក្សារណសិរ្ស មានសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និមន្តពីវត្តលង្កាព្រះកុសុមារាម បានទទួលព្រះរាជសមណស័ក្តិនិងគ្រឿងឥស្សរិយយសមានដូចតទៅ៖

១-នៅថ្ងៃទី១ ខែសីហា ឆ្នាំ១៩៩១ សម្តេចត្រូវបានតែងតាំងជាអនុប្រធានការរកសង្ឃដោយរដ្ឋកម្ពុជា។

២-នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩២ សម្តេចត្រូវបានតែងតាំងជាសម្តេចព្រះពោធិវង្សដោយសម្តេចព្រះបាទ **នរោត្តម សីហនុ** ។

៣-នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៣ សម្តេចត្រូវបានតែងតាំងជាព្រះមេគណរាជធានីភ្នំពេញដោយសម្តេចព្រះសង្ឃរាជាធិបតី **ទេព វង្ស** និងសម្តេចអគ្គមហាសេនាបតីតេជោបណ្ឌិតសភាចារ្យ **ហ៊ុន សែន**។

៤-នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៦ សម្តេចទទួលបាននូវសញ្ញាបត្រស្ថាបនាជាតិ ពីសហគមន៍មជ្ឈមណ្ឌលសង្ឃព្រះពុទ្ធសាសនាខ្មែរ។

៥-នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០១ សម្តេចបានទទួលមេដាយមុនីសារាភណ្ឌ អំពីសម្តេចព្រះបាទ **នរោត្តម សីហនុ**។

៦-នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០១ សម្តេចទទួលបានមេដាយមហាសេនាអំពីសម្តេចព្រះបាទ **នរោត្ត សីហនុ**។



៧-នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៨ សម្តេចទទួលបានមេដាយមុនីសារាភណ្ឌអំពីរាជរដ្ឋាភិបាលកម្ពុជា។

៨-នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៦ សម្តេចបានទទួលគ្រឿងឥស្សរិយសមុនីសារាភណ្ឌនិងមហាសិរីវឌ្ឍន៍អំពីរាជរដ្ឋាភិបាលកម្ពុជា។

៩-នៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៦ សម្តេចត្រូវបានតែងតាំងជាប្រធានគណៈកម្មការសង្ឃ នៃព្រះរាជាណាចក្រកម្ពុជាដោយសម្តេចព្រះ **នរោត្តម សីហមុនី**។

១០-នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៧សម្តេចត្រូវបានតែងតាំងជាសម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជាអំពីរាជរដ្ឋាភិបាលកម្ពុជា។

១១-នៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០៧សម្តេចត្រូវបានតែងតាំងជាព្រះអគ្គាធិការពុទ្ធិកសិក្សាជាតិ ដោយសម្តេចព្រះ **នរោត្តម សីហមុនី** ។

១២-នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៧ សម្តេចត្រូវបានតែងតាំងជាព្រះសាកលវិទ្យាធិការនៃសាកលវិទ្យាល័យព្រះសីហនុរាជ។

១៣-នៅថ្ងៃទី... ខែ... ឆ្នាំ២០០... សម្តេចត្រូវបានថ្វាយងារជាប្រធានកិត្តិយសនៃពុទ្ធិកសមាគមកម្ពុជរដ្ឋ។

១៤-នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩ សម្តេចទទួលបាននូវមេដាយជាតូបការអំពីរាជរដ្ឋាភិបាលកម្ពុជា។

## V. ព្រះរាជបេសកកម្មផ្សព្វផ្សាយសាសនានៅបរទេស

សម្តេចព្រះមហាសុមេធាធិបតី ក្រោយពីបានទទួលបព្វជ្ជាលើកទីពីរ ទ្រង់ធ្លាប់បានយាងបំពេញទស្សនកិច្ចទៅកាន់ប្រទេសនានា លើសកលលោកយើងនេះជាច្រើនប្រទេសដូចជា ៖

- សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ
- សាធារណរដ្ឋសង្គមនិយមវៀតណាម
- ព្រះរាជាណាចក្រថៃឡង់ដ៍
- សហភាពមីយ៉ាន់ម៉ា
- សាធារណរដ្ឋសិង្ហបុរី
- សហភាពម៉ាឡេស៊ី
- សាធារណរដ្ឋសង្គមនិយមប្រជាធិបតេយ្យស្រីលង្កា
- សាធារណរដ្ឋឥណ្ឌា
- ព្រះរាជាណាចក្រនេប៉ាល់
- សាធារណរដ្ឋប្រជាមានិតចិន
- អាណាចក្រម៉ុងហ្គោលី
- ព្រះរាជាណាចក្រជប៉ុន
- សាធារណរដ្ឋកូរ៉េខាងត្បូង
- ប្រទេសបារាំង
- ចក្រភពអង់គ្លេស
- ប្រទេសស្វីសាលែន
- ប្រទេសអូស្ត្រាលី។

## VI. សេចក្តីសន្និដ្ឋាន

ដោយព្រះសកម្មភាពដ៏ខ្លាំងក្លា និងសមិទ្ធផលយ៉ាងច្រើនសន្ធឹកសន្ធាប់ ព្រមទាំងបានទទួលនូវគោរមងារ និងគ្រឿងឥស្សរិយយសដ៏ច្រើន ដូចមានខាងលើស្រាប់ដែលធ្វើឲ្យសម្តេចព្រះមហាសុមេធាធិបតី **នន្ទ ង៉ែត** មានព្រះកិត្តិនាមល្បីល្បាញទាំងក្នុងប្រទេស និងក្រៅប្រទេស។ ខាងក្នុងប្រទេសចាប់តាំងពីរដ្ឋអំណាចមូលដ្ឋានរហូតដល់រាជរដ្ឋាភិបាល មានសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជាប្រមុខរាជរដ្ឋាភិបាលមានចំណាប់អារម្មណ៍ទទួលស្គាល់ស្រឡាញ់គោរពព្រះអង្គ ហើយចាត់ទុកព្រះអង្គជាព្រះសង្ឃគំរូ ក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងការជួយឧបត្ថម្ភ កសាងសមិទ្ធផលខាងពុទ្ធចក្រក៏ដូចជា ការកសាងសមិទ្ធផលខាងអាណាចក្រដែរ។

ដោយព្រះវិរិយភាពយ៉ាងសកម្មក្នុងការងារ និងគុណធម៌ដ៏ល្អប្រសើរ ដែលសម្តេចបានប្រតិបត្តិក្នុងព្រះពុទ្ធសាសនាកន្លងមក សូមតេជៈនៃគុណព្រះរតនត្រ័យ និងទសបារមីនៃព្រះពុទ្ធសាសនាព្រមទាំងបារមីនៃវត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោកជួយបីបាច់ថែរក្សា ការពារទ្រទ្រង់សម្តេចព្រះមហាសុមេធាធិបតី **នន្ទ ង៉ែត** សម្តេចព្រះសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា សូមសម្តេចមានព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ដើម្បីជួយដឹកនាំ និងបានជាបង្អែកដ៏រឹងមាំសម្រាប់ជួយទ្រទ្រង់ព្រះពុទ្ធសាសនាផង និងជួយដល់សង្គមជាតិមាតុភូមិផង។

យើងខ្ញុំទាំងអស់គ្នា សូមថ្វាយព្រះពរចំពោះសម្តេចព្រះមហាសុមេធាធិបតី **នន្ទ ង៉ែត** សម្តេចព្រះសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជាសូមព្រះអង្គបានប្រកបដោយព្រះពុទ្ធពរ ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕





ពិធីថ្វាយព្រះគោរមងារកិត្តិឧទ្ទេសបណ្ឌិតចំពោះសម្តេច
ព្រះមហាសុមេធាធិបតី **នន្ទ ង៉ែត**
ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៣







ពិធីថ្វាយព្រះគោរមងារកិត្តិឧទ្ទេសបណ្ឌិតចំពោះសម្តេច
ព្រះមហាសុមេធាធិបតី **នន្ទ ង៉ែត**
ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៣





ពិធីថ្វាយព្រះគោរមងារកិត្តិឧទ្ទេសបណ្ឌិតចំពោះសម្តេច
ព្រះមហាសុមេធាធិបតី **នន្ទ ង៉ែត**
ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៣







ពិធីថ្វាយព្រះគោរមងារកិត្តិឧទ្ទេសបណ្ឌិតចំពោះសម្តេច
ព្រះមហាសុមេធាធិបតី **នន្ទ ង៉ែត**
ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៣





ពីធីថ្វាយព្រះគោរមងារកិត្តិឧទ្ទេសបណ្ឌិតចំពោះសម្តេច
ព្រះមហាសុមេធាធិបតី **នន្ទ ង៉ែត**
ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៣





ពីធីថ្វាយព្រះគោរមងារកិត្តិឧទ្ទេសបណ្ឌិតចំពោះសម្តេច
ព្រះមហាសុមេធាធិបតី **នន្ទ ង៉ែត**
ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៣

## ៤-ព្រះរាជជីវប្រវត្តិ
## នៃសម្តេចព្រះធម្មលិខិត លាស់ ឡាយ
## ប្រធានថេរសភានៃព្រះពុទ្ធសាសនា
## នៅព្រះរាជាណាចក្រកម្ពុជា



**ជាតិភូមិ** ៖ ព្រះអង្គប្រសូតនៅថ្ងៃពុធ៧ កើត ខែភទ្របទ ឆ្នាំថោះ ពុទ្ធសករាជ ២៤៥៧ នៅក្នុងភូមិធ្យូង ឃុំធ្យូង ស្រុកពញាឮ ខេត្តកណ្តាល។

មាតា និងបិតារបស់សម្តេចមាននាមដូចតទៅ ៖

-មាតានាម **ស៊ូ អ៊ុច**

-បិតានាម **ល័ក្ខ លាស់** (ហៅអាចារ្យលាក់)

មាតានិងបិតារបស់សម្តេច គឺជាត្រកូលកសិករសុទ្ធសាធ។

សម្តេចមានបងប្អូនបង្កើតចំនួន១០ នាក់ គឺប្រុស ៧ នាក់ និង ស្រី ៣ នាក់ ក្នុងនោះសម្តេចជាបុត្រទី៥ ។

**អំពីកុមារភាព** ៖ កុមារ **លាស់ ឡាយ** មានអត្តចរិតស្លូតបូត សុភាពរាបសា ស្រគត់ស្រគំ សម្តីវាចាទន់ភ្លន់ ផ្អែមល្ហែម ហើយមាន អត្តចរិតជាកុមារឧស្សាហ៍ វៃឆ្លាត មានព្យាយាម មានទំនាក់ទំនងល្អជា



មួយនិងកុមារដទៃទៀត។ កុមារ **លាស់ ឡាយ** មានចរិតពិសេស ប្លែកពីកុមារនានានៅក្នុងស្រុកភូមិជាមួយគ្នា។ កុមារ **លាស់ ឡាយ** អាយុល្មមវ័យដល់ការសិក្សា មាតាបិតាក៏ បានគិតគូរពិភាក្សាគ្នាចង់ឱ្យ កូនបានរៀនសូត្រចេះដឹងនិងគេ។ កុមារ **លាស់ ឡាយ** ជាដំបូងបំផុត បានរៀនសូត្រអក្សរសាស្ត្រពីសំណាក់បិតារបស់ខ្លួន។ក្នុងការរៀនសូត្រ នេះកុមារ **លាស់ ឡាយ** បានខិតខំយក ចិត្តទុកដាក់ស្រឡាញ់ការ សិក្សានេះណាស់ អស់រយៈពេលជាច្រើនខែ រហូតបានចេះអាន និង មើលបានសរសេរកើត ទើបមាតានិងបិតាបាននាំកុមារ **លាស់ ឡាយ** ឱ្យទៅសិក្សា រៀនសូត្រអក្សរសាស្ត្រ លេខនព្វន្ត នៅវត្តស្បែង ក្នុង សំណាក់ព្រះគ្រូសុមេធង្គរ ព្រះនាម **ឯក គាំ** ជាព្រះចៅអធិការនៅ ក្នុងវត្តនោះ។

**អំពីបព្វជ្ជា** ៖ កុមារលាស់ **ឡាយ** អាយុបាន១២ ឆ្នាំមាតា និងបិតា ក៏សម្រេចឯកភាពគ្នាឱ្យទៅបួសជាសាមណេរ ក្នុងសំណាក់ ព្រះគ្រូសុមេធង្គរ **ឯក គាំ** ជាព្រះឧបជ្ឈាយ៍។ ដោយសាមណេរ **លាស់ ឡាយ** មាន ប្រាជ្ញាស្មារតី វៃឆ្លាត ឆាប់ចាប់បាន ឆាប់យល់ ព្រះគ្រូ **ឯក គាំ** ព្រមជា មួយមាតា និងបិតា ក៏បានចាត់ឱ្យទៅរៀនអត្ត ក្នុងសំណាក់លោកគ្រូ ព្រះនាម មហា **អ៊ឹម** នៅវត្ត ព្រះពុទ្ធមានបុណ្យ ចាស់ ក្រុងភ្នំពេញ។ ចំណេរក្រោយមកសាមណេរអង្គនេះ បានទៅសុំ កន្លែងស្នាក់នៅក្នុងវត្តឧណ្ណាលោម ក្រុងភ្នំពេញ ដើម្បីរៀនសូត្រព្រះ បរិយត្តិធម៌ បន្តឱ្យបានជ្រៅជ្រះខ្លាំងថែមទៀត រហូតដល់ព្រះជន្មាយុ បាន១៩ឆ្នាំ ទើបសាមណេរអង្គនេះសុំលាចាកសិក្ខាបទមកជាគ្រហស្ថ ទៅបម្រើមាតា បិតារបស់ខ្លួន។

**អំពីឧបសម្បទា ៖** លុះដល់ជន្មាយុបានគម្រប់ ២១ ឆ្នាំ មាតាបិតាក៏ បាននាំអន្ទិត **លាស់ ឡាយ** ឱ្យទៅបំពេញ ឧបសម្បទាជា ភិក្ខុ នៅក្នុងសំណាក់ ព្រះឧបជ្ឈាយ៍ព្រះនាម **អ៊ុក** នៅវត្តសំរោង ឃុំវាលពុក ស្រុកថ្ពង ខេត្តកំពង់ស្ពឺ (នៅខាងលិចផ្សារឧត្តុង្គ) ដែលជាស្រុកកំណើតរបស់ញោមស្រី។ នៅក្នុងឆ្នាំនេះ ភិក្ខុ **លាស់ ឡាយ** បាននិមន្តចេញពីវត្តដើមមកសុំស្នាក់នៅក្នុងវត្តមហាមន្ត្រី ក្រុងភ្នំពេញវិញ។

លុះចូលមកដល់ក្នុងឆ្នាំ១៩៤៨ ភិក្ខុអង្គនេះ ក៏បាននិមន្ត ចេញទៅគង់នៅវត្តកំពង់ឃ្លាំង ស្រុកជីក្រែង ខេត្តសៀមរាប ដើម្បីជួយបង្រៀនព្រះបរិយត្តិធម៌នៅទីនោះបានចំនួនមួយឆ្នាំ ក៏វិលត្រឡប់មកវត្តមហាមន្ត្រី ក្រុងភ្នំពេញវិញ។

តក្រោយមកទៀត ដោយពិនិត្យលើសមត្ថភាព និងលទ្ធភាពចំណេះចេះដឹង ព្រមទាំងភាពឈ្លាសវៃរបស់ភិក្ខុ **លាស់ ឡាយ** សម្តេចព្រះពោធិវង្ស **ហួតតាត** ព្រះអគ្គាធិការពុទ្ធិកសិក្សានិងសាសនសិក្សាធិការ ព្រះអង្គបានចេញប្រកាសនីយប័ត្រតែងតាំងភិក្ខុ **លាស់ ឡាយ** ឱ្យជាអាចារ្យបង្រៀនជាផ្លូវការ បង្រៀននៅសាលាពុទ្ធិក បឋមសិក្សាក្នុងវត្តមហាមន្ត្រី ក្រុង ភ្នំពេញ។

នៅឆ្នាំ ១៩៦៥ ក្រសួងធម្មការ និងសាសនាសិក្សាធិការបាននិមន្តព្រះភិក្ខុ **លាស់ ឡាយ** ឱ្យទៅសិក្សាអប់រំផ្នែកគរុកោសល្យ នៅក្នុងពុទ្ធិកវិទ្យាល័យ ព្រះសុរាម្រឹត ក្រុងភ្នំពេញ ចំនួនរយៈពេល ១ ខែ រួចក្រសួងធម្មការបានចេញសញ្ញាបត្រវិក្រឹត្យការគរុកោសល្យឱ្យ ហើយបានចាត់ឱ្យទៅបង្រៀន ភាសាបាលី ថ្នាក់ពិសេស នៅក្នុងវត្តមហាមន្ត្រីម្តងទៀត តក្រោយមកទៀត ក្រសួងធម្មការ បានចេញបសំសនិយប័ត្រ



ប្រគេនមួយទៀត ជាការលើកទឹកចិត្តឱ្យស័ក្តិសមនឹងការខិតខំប្រឹងប្រែងក្នុងការងារភារកិច្ចប្រគេនដល់ព្រះអង្គ ហើយក្នុងនោះដែរ សម្តេចព្រះមហាសុមេធាធិបតីសម្តេចព្រះសង្ឃរាជ **ជួន ណាត** ជោតញ្ញាណោបានតែងតាំងងារជាព្រះគ្រូ"ឃោសាភីរ័ត្ន" ជា ឋានានុក្រមថែមទៀត។

នៅឆ្នាំ១៩៧០គណៈសង្ឃនៅក្នុងវត្តមហាមន្ត្រីបានប្រជុំជ្រើសរើសព្រះភិក្ខុ **លាស់ ឡាយ** ជាប្រធាននៃគណៈសង្ឃ សម្រាប់វត្តមហាមន្ត្រី ក្រុងភ្នំពេញ។

លុះចូលមកដល់ឆ្នាំ ១៩៧៥ ត្រូវបនពួកប្រល័យពូជសាសន៍ ប៉ុល ពត បានបណ្តេញទាំងបង្ខំឱ្យភិក្ខុ **លាស់ ឡាយ** សឹកទៅជាគ្រហស្ថនៅ ក្នុងវត្តមណ្ឌប ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។

នៅឆ្នាំ១៩៧៨ ពួកទមិឡចោរអប្រិយ៍ឥតសាសនា ពួកផ្តាច់ការឃោរឃៅអមនុស្សធម៌បានយកបណ្ឌិត **លាស់ ឡាយ** ទៅសម្លាប់រហូតដល់ពីរ ដង ៖

លើកទី១ នៅព្រៃកតាបេស ពួកវាបានយករទេះសេះមកដាក់បណ្ឌិត**លាស់ ឡាយ** តែដោយគុណបុណ្យបារមីនៃព្រះពុទ្ធសាសនា និងដោយសារគុណធម៌ខ្លាំងក្លានិងល្អផូរផង់របស់បណ្ឌិត**លាស់ឡាយ** ដែលបានកសាងសន្សំមកអស់រយៈកាលច្រើនឆ្នាំ និងច្រើនជាតិផង បានធ្វើឱ្យបំណងរបស់ពួកវាត្រូវអាក់ខាន ត្រូវបរាជ័យដោយរទេះសេះអូសមិនរួចទៅមិនកើត ពួកវាក៏បានសម្រេចថាទុកចាំពេលក្រោយ។

លើកទី២មកយកទៅសម្លាប់ម្តងទៀតនៅឡពាងធារី តែដោយគុណធម៌ដ៏ជ្រះថ្លា និងល្អបរិសុទ្ធរបស់បណ្ឌិត **លាស់ ឡាយ** ដែលបានកសាងសន្សំមកយ៉ាងច្រើន លើកទី២ នេះ ពួកវាយកឡាន មក

ដឹកបណ្ឌិត **លាស់ ឡាយ** ទៅសម្លាប់ចោលដោយរង់ចាំយូរពេក មិនអាចទ្រាំចាំបាន ព្រោះពួកវាប្រញាប់យកទ្បានទៅដឹកទ័ពទៅសមរភូមិមុខ។ បំណងដ៏ខ្មៅងងឹតរបស់ពួកវាក្នុងលើកទី១ និងលើកទី២ នេះមិនបានសម្រេចបំណងទេ។ ដោគវាសនា និងបុណ្យ កុសល ដ៏អស្ចារ្យរបស់បណ្ឌិត **លាស់ ឡាយ** ត្រូវឆ្លងផុតអំពីជ្រោះមរណៈជីវិត ត្រូវបានរស់រានរួចផុតអំពីសេចក្ដីស្លាប់ រហូតមកទល់សព្វថ្ងៃនេះ។ ជីវិតដ៏សែនថ្លៃនេះ តើមានអ្វីមកជួយ? ហើយមានអ្វីជាមូលដ្ឋាន?

នេះហើយមហាគុណធម៌ធំធេង ! អំពើជាមហាកុសលនិងសន្ដានចិត្តស្អាតល្អបរិសុទ្ធ ប្រកបដោយមេត្តា ករុណា និងសង្គមធម៌របស់សម្ដេចៗត្រូវឆ្លងផុតពីជ្រោះមរណៈទាំងពីរលើកយ៉ាងអស្ចារ្យណាស់។

នរណាមួយមានសន្ដានចិត្តល្អបរិសុទ្ធ ស្មោះត្រង់ជឿជាក់ ស្លាប់រស់ជាមួយពុទ្ធសាសនាៗនឹងជួយអ្នកនោះវិញនេះហើយឥទ្ធិពលបុណ្យបារមី ដ៏ស័ក្តិសិទ្ធិជឿប្រាកដ ស្លាប់រស់ក្នុងព្រះពុទ្ធសាសនាៗ នឹងតាមជួយថែរក្សាការពារអ្នកវិញ ដោយមិនអាចខានបាន។

នៅឆ្នាំ១៩៧៩ បណ្ឌិត **លាស់ ឡាយ** បានចូលមករស់នៅទីក្រុង ភ្នំពេញវិញ ហើយបានបំពេញឧបសម្បទាជាភិក្ខុថ្មីម្តងទៀត នៅក្នុងវត្ត សន្សំកុសល សង្កាត់លេខ៤ ក្រុងភ្នំពេញ និងបានបំពេញជាភិក្ខុភាវៈពេញលក្ខណៈស្របច្បាប់ នៅក្នុងពទ្ធសីមា វត្តឧណ្ណាលោម ដោយមានព្រះវិន័យ ធរ **ទេព ខង្ស** ជាព្រះឧបជ្ឈាយ៍។

អំពីព្រះសកម្មភាពនិងស្នាព្រះហស្តរបស់សម្ដេច**លាស់ឡាយ** ចាប់ តាំងពីថ្ងៃដែលព្រះភិក្ខុ **លាស់ ឡាយ** បានបំពេញឧបសម្បទានជាភិក្ខុភាវៈក្នុងជីវិតផ្នួសជាលើកទី២ របស់ព្រះអង្គមកព្រះអង្គបានខិត



ខំប្រឹងប្រែងប្រតិបត្តិធម៌វិន័យ ក្នុងភាពជាបព្វជិតបានយ៉ាងល្អប្រសើរ។ ព្រះអង្គជាអ្នកបួស១ រូប ប្រកបដោយសេចក្ដីថ្លៃថ្នូរ មានចរិត ចរិយាសមស្របតាមពុទ្ធប្បញ្ញត្តិ ពុទ្ធានុញ្ញាត និងអភិសមាចារ បានយ៉ាងល្អប្រពៃ។

ដោយសារព្រះគុណធម៌ទាំងអស់នេះហើយ បានជាពួកពុទ្ធបរិស័ទទូទៅ ទាំងព្រះសង្ឃ និងគ្រហស្ថ មានសេចក្ដីជ្រះថ្លា ស្រឡាញ់គោរពសម្ដេច បានចាត់ទុកព្រះអង្គថាជាសង្ឃគំរូដ៏ល្អមួយអង្គនៅក្នុងសម័យកាលនេះ។ ទាំងសមត្ថភាពចំណេះដឹង ផ្នែកខាងព្រះធម៌ព្រះវិន័យ ព្រះបាលីពុទ្ធសាសនា ព្រះអង្គបាន ចេះដ៏ច្បាស់លាស់ យ៉ាងជ្រៅជ្រះពិតប្រាកដ។

**អំពីស្នាព្រះហស្ត និងសមណស័ក្តិបានទទួលកន្លងមក ៖**

ស្នាព្រះហស្តសម្រេចបានទាំងក្នុងអតីត និងទាំងក្នុងបច្ចុប្បន្នមានដូចខាងក្រោម ៖

ក-ផ្នែករៀបរៀងតែងនិពន្ធក្បួនច្បាប់សៀវភៅធម៌អាថ៌នានាមាន ៖

១-ប្រវត្តិពុទ្ធសាសនាក្រោយព្រះពុទ្ធបរិនិព្វាន ព.ស.២៥០៨ គ.ស១៩៦០

២-បញ្ហាអន្តរធានកថា

៣-កាយគតាសតិកម្មដ្ឋាន ព.ស.២៥១៨ គ.ស.១៩៧៥

៤-ប្រវត្តិព្រះកច្ចាយនត្ថេរនៅវត្តសន្សំកុសល ព.ស.២៥៤៨ គ.ស.២០០៣

៥-សីមាវណ្ណនា នៅវត្តសន្សំកុសល ព.ស.២៥៤៧ គ.ស.២០០៣

៦-គាថាធម៌ផ្សេងនៅវត្តសន្សំកុសលព.ស.២៥៤៨ គ.ស.២០០៤

៧-គាថាធម៌មាឃ និងវិសាខបូជា ព.ស.២៥៤៨ គ.ស.២០០៤

៨-រំលឹកគុណព្រះរស់នៅវត្តសន្សំកុសលពស.២៥៤៩គ.ស.២០០៥

៩-រឿងទហរភិក្ខុនៅវត្តសន្សំកុសល ព.ស.២៥៥១ គ.ស.២០០៧

១០-ដោតិកភិក្ខុ និងសម្ពហុលភិក្ខុ

១១-សង្គ្រាមអមនុស្សថ្មី-ចាស់

១២-បណាគាថា មូលកច្ចាយន

១៣-អច្ចរិយកថា

១៤-សៀវភៅសច្ចប្បបរិយាយ (វត្តមហាមន្ត្រី) ព.ស. ២៥១២ គ.ស.១៩៦៨

១៥-ទុល្លភកថា ឬ (ច្បាប់ល្អក្ររកបាន)

១៦-សៀវភៅសង្ខារប្បបរិយាយ ព.ស.២៥១៧ គ.ស.១៩៧៣

១៧- អាយុវឌ្ឍនកុមារ ព.ស.២៥៣២ គ.ស.១៩៨៩

**ខ-បានជួយត្រួតពិនិត្យនិងកែសម្រួលសៀវភៅធម៌អាថ៌នានាមាន ៖**

១-សៀវភៅទិដ្ឋធម្មិកត្ថ ៖ ប្រយោជន៍បច្ចុប្បន្ន រៀបរៀងដោយព្រះ មុនីកោសល្យ **ហ៊ុល សុវណ្ណា**

២-សៀវភៅសម្បរាយិកត្ថ ៖ ប្រយោជន៍បរលោករៀបរៀងដោយព្រះមុនីកោសល្យ **ហ៊ុល សុវណ្ណា**

៣-សៀវភៅបរមត្ថ ៖ ប្រយោជន៍ក្រៃលែង (ព្រះនិព្វាន) រៀបរៀង ដោយព្រះមុនីកោសល្យ **ហ៊ុល សុវណ្ណា**

៤-សៀវភៅកំណើត ៤ យ៉ាង រៀបរៀងដោយ សម្តេចព្រះមហាសុមេ ធាធិបតី **នន្ទ ង៉ែត**



៥-សៀវភៅព្រះពុទ្ធឱវាទសង្ខេប៣យ៉ាង រៀបរៀងដោយព្រឹទ្ធសាស្ត្រាចារ្យ **ទេព ផុន** ទីប្រឹក្សាផ្ទាល់សម្តេចព្រះមហាសុមេធាធិបតី សម្តេចព្រះ សង្ឃនាយក **នន្ទ ង៉ែត** នៃព្រះរាជាណាចក្រកម្ពុជា

៦-សៀវភៅឧត្តមជីវិតកថា រៀបរៀងដោយ សម្តេចព្រះវនរ័ត **ណាយ ច្រឹក** ព្រះអគ្គាធិការវេងពុទ្ធិកសិក្សាជាតិនៃព្រះរាជាណាចក្រកម្ពុជា

៧-ព្រះក្នុងផ្ទះ រៀបរៀងដោយភិក្ខុញាណចារី (**នែម ពេជ**)

៨-មេរៀនភាសាសំស្រ្កឹត រៀបរៀងដោយ ភិក្ខុ ឧត្តមវិរិយោ **ហ៊ុំ សទ្ធា** (បាត់ដំបង)។ល។

ក្នុងការជួយត្រួតពិនិត្យនិងការកែសម្រួល ខ្លឹមសារពាក្យពេចន៍នៅក្នុងសៀវភៅធម៌អាថ៌ផ្សេងៗមានចំនួនច្រើនទៀត(បាត់បង់) ដែលយើងមិនអាច លើកយកមករៀបរាប់ឱ្យបានអស់នៅពេលនេះបានទេ ព្រោះខ្លឹមសារខ្លះ បាត់ឯកសារស្រាវជ្រាវរកមិនឃើញ។

ដូច្នេះការលើកឡើងទាំងប៉ុន្មានខាងលើ គឺជាសក្ខីកម្ម និងជាសមិទ្ធផលជាក់ស្តែងមកបញ្ជាក់ជាភស្តុតាង ក្នុងការរួមចំណែកជួយពង្រឹង នៃការផ្សព្វផ្សាយព្រះពុទ្ធសាសនា ព្រះបរមគ្រូ សមណគោតម របស់យើង។

**គ-បានជួយកសាងសមិទ្ធផលនានាក្នុងផ្នែកពុទ្ធសាសនា និងក្នុងសង្គមជាតិ ៖**

- បានកសាងកុដិ១ ខ្នង នៅក្នុងវត្តមហាមន្ត្រីក្រុងភ្នំពេញ។
- នៅឆ្នាំ១៩៨៩កសាងការិយាល័យសាលាពុទ្ធិកបឋមសិក្សា ក្នុងវត្តសន្សំកុសល ក្រុងភ្នំពេញ។

– នៅឆ្នាំ១៩៨៧ បានកសាងព្រះវិហារនៅវត្តស្បែង...។
– នៅឆ្នាំ១៩៩០ បានកសាងសាលាបាលីជាន់ក្រោមនៅវត្តសន្សំកុសលក្រុងភ្នំពេញ។
– នៅឆ្នាំ១៩៩៣ បានកសាងបណ្ណកុដិមួយខ្នង នៅវត្តសន្សំកុសល ក្រុងភ្នំពេញ។
– នៅឆ្នាំ១៩៩៩ បានកសាងមហាកុដិពីរជាន់មួយខ្នង នៅវត្តសន្សំកុសល ក្រុងភ្នំពេញ។
– នៅឆ្នាំ២០០០-២០០១ បានកសាងកុដិពីរខ្នងនិងសាលាបាលីជាន់លើថែមទៀតនៅក្នុងវត្តសន្សំកុសល ក្រុងភ្នំពេញ។
– នៅឆ្នាំ២០០២ បានកសាងកុដិទីប៉ាធាមួយខ្នង មានពីរជាន់នៅវត្ត សន្សំកុសល។
– នៅឆ្នាំ២០០៤បានចាប់ផ្ដើមកសាងពុទ្ធិកវិទ្យាល័យ សម្ដេចធម្មលិខិត លាស់ ឡាយ នៅក្នុងវត្តសន្សំកុសល។
– នៅឆ្នាំ២០០៤ នេះទៀតបានកសាងទីចាត់ការ នៃពុទ្ធិកវិទ្យាល័យ មួយខ្នងនៅក្នុងវត្តសន្សំកុសល។
– គ.ស. ២០០៥ កសាងធម្មសភាមួយខ្នង នៅវត្តសន្សំកុសល
– នៅក្នុងឆ្នាំ២០០៦បានអំពាវនាវសប្បុរសជន និងពុទ្ធបរិស័ទទាំងជិតនិងឆ្ងាយ ឱ្យចូលរួមចាក់បំពេញដីបំពេញខាងក្រោយជិតរបងវត្តសន្សំ កុសលអស់ អាចម៍ដីចំនួន ៤០០ ឡាន។
– នៅឆ្នាំ២០០៧ បានកសាងកុដិមួយខ្នងមានពីរជាន់ ជាប់និងរបងវត្តខាងលិច និងធ្វើរបងប៉ែកខាងមុខព្រះវិហារមានប្រវែង ៣៥ ម៉ែត្រ។



– គ.ស.២០០៩បានសាងព្រះវិហាររួចជាស្ថាពរក្រោមការឧបត្ថម្ភរបស់សម្ដេច ហ៊ុន សែន និងលោកជំទាវ តាមរយៈឯកឧត្តមបណ្ឌិត ប៉ែន ស៊ីម៉ន និងលោកជំទាវ។

**សមណស័ក្តិ និងតួនាទីមុខតំណែងបានទទួល៖**

– នៅក្នុងទសវត្សរ៍ ឆ្នាំ១៩៦០ សម្ដេចបានទទួលប្រកាសនីយប័ត្រតែងតាំងជាអាចារ្យបង្រៀនពីសម្ដេចព្រះពោធិវង្ស **ហួត តាត** ព្រះអគ្គាធិការពុទ្ធិកសិក្សានៃក្រសួងធម្មការនិងសាសនសិក្សាធិការ។
– បានទទួលសញ្ញាបត្រវិក្រឹតការគរុកោសល្យ និងបសំសនីយប័ត្រ ចេញដោយក្រសួងធម្មការ និងសាសនា។
– បានទទួលងារជា ព្រះឃោសាភិវ័ត ប្រកាសតែងតាំងផ្ដល់ប្រគេន ពីសម្ដេចព្រះសង្ឃរាជ ជួន ណាត ជោតញ្ញាណោ។

១-ពីថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៨៥ ព្រះអង្គបានទទួលប័ណ្ណសរសើរ មួយច្បាប់ពីគណៈកម្មាធិការប្រជាជនបដិវត្តន៍រដ្ឋធានីភ្នំពេញ។

-នៅថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៨៦ ព្រះអង្គបានទទួលប័ណ្ណសរសើរពីមន្ទីរអប់រំរដ្ឋធានីភ្នំពេញមួយច្បាប់។

-នៅថ្ងៃទី១៣ ខែមករា ឆ្នាំ១៩៩១ ក្រុមប្រឹក្សារណសិរ្សកសាងការ ពារមាតុភូមិកម្ពុជា បានតែងតាំងសម្ដេចព្រះធម្មលិខិត **លាស់ ឡាយ** ជា អធិបតីក្រុមជំនុំព្រះត្រៃបិដក នៅទីក្រុងភ្នំពេញ។

-នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩២ សហប្រធាន World Buddhist Supreme TATHAGATA Follower (WBSTF) បានថ្វាយព្រះឋានន្តរស័ក្តិងារជា "មហាលោកិយ" លំដាប់ថ្នាក់ទី១ (ចំពោះ

សម្តេចព្រះធម្មលិខិត **លាស់ ឡាយ**) (First High Rank of the Moha Lokaya Order) ជាសមាជិករបស់ WBSTF នៅទីក្រុងកូឡំបូ ប្រទេសសិរីលង្កា។

-នៅថ្ងៃទី៣០ ខែមករា ឆ្នាំ១៩៩៥ ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តមសីហនុ ទ្រង់បានឡាយព្រះហស្តលេខាលើ ព្រះរាជក្រឹត្យលេខ នសរ កត ០១៩៥/០៨ តែងតាំងជាសម្តេចព្រះធម្មលិខិត។

-នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០១ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ទ្រង់បានឡាយព្រះហស្តលេខាលើ ព្រះរាជក្រឹត្យលេខនសរកត១០០១/៤០១ថ្វាយគ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជាថ្នាក់មហាសេនា។

-នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០២ លោកជំទាវ ប៊ុនរ៉ានីហ៊ុនសែន បានថ្វាយលិខិតថ្លែងអំណរព្រះគុណ លេខ ៧៨៩/០២ ថ្វាយសម្តេចដែលព្រះអង្គបានចូលរួមជួយឧបត្ថម្ភនូវបច្ច័យចំនួន ៤.២២៥.៣០០រៀល(បួនលានពីរសែនពីរម៉ឺនប្រាំពាន់បីរយរៀល)ដល់កាកបាទក្រហមកម្ពុជា។

-នៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០២ សម្តេចព្រះមហាសុមេធាធិបតី ទេព វង្ស សម្តេចព្រះសង្ឃរាជគណៈមហានិកាយ ព្រះអង្គបានចេញសញ្ញាប័ត្រ លេខ ៣៩៧៩ កសវ តែងតាំងសម្តេចព្រះធម្មលិខិត **លាស់ ឡាយ** ជាព្រះ អនុគណ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

-នៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៦ ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជាទ្រង់បានឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យ នស/រកត ០៥០៦/២០០៧ ថ្វាយងារសម្តេចជាព្រះសង្ឃនាយករងទី១ នៃព្រះរាជាណាចក្រកម្ពុជា។

-នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៦ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានតែងតាំងសម្តេច លាស់ ឡាយ ជាអគ្គាធិការរងពុទ្ធិកសិក្សាជាតិ នៃព្រះរាជាណាចក្រកម្ពុជា(តាមអនុក្រឹត្យលេខ៨៨ អនក្រ បក/០៦)។

-នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៦ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានតែងតាំងសម្តេចព្រះធម្មលិខិត លាស់ ឡាយ ជាប្រធាន ថេរសភានៃពុទ្ធសាសនា (តាមអនុក្រឹត្យលេខ ៥៧៦ អនក្រ បក/២០០៦)។

នៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៩ លោកជំទាវ **ប៊ុនរ៉ានី ហ៊ុនសែន** បានថ្វាយលិខិតថ្លែងអំណរគុណលេខ១១៩៣/០៩ កក្រក.ទទ ដែលសម្តេច បានជួយឧបត្ថម្ភនូវថវិកាចំនួន ៥០០០ដុល្លារ។

-នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១០ គណៈកម្មការសាខាកាកបាទ ក្រហមកម្ពុជារាជធានីភ្នំពេញ បានថ្វាយលិខិតថ្លែងអំណរគុណលេខ ០០១/១០ កក្រក.ភព ដែលសម្តេចបានជួយឧបត្ថម្ភនូវគ្រឿងឧបភោគបរិភោគ និង ថវិកា ១.៣៤៧.០៥២ រៀល។

-ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី សព្វ ព្រះរាជហឫទ័យ ប្រោសព្រះរាជទាន ព្រះឋានៈជាសម្តេច ព្រះសង្ឃនាយករងទី១ នៃព្រះរាជាណាចក្រកម្ពុជា និងមានសិទ្ធិប្រើរាជសព្វព្រមទាំង មានសិទ្ធិប្រើផ្លិតយសពិសេស តាមព្រះរាជក្រឹត្យលេខ នស/រកត/១០០៧/៥៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៧។

**សមត្ថភាព ចំណេះចេះដឹងអក្សរសាស្ត្រជាតិ និងភាសាបរទេស៖**

-ចំពោះអក្សរសាស្ត្រជាតិនិងភាសាខ្មែរសម្តេចចេះ យ៉ាងស្ទាត់ជំនាញ

-ភាសាបាលីនិងសំស្ក្រឹតសម្តេច ចេះអាចប្រើការបានដូចភាសាខ្មែរដែរ តែដោយឡែកផ្នែកភាសាបាលី សម្តេចអាចសរសេរតែងនិពន្ធបានយ៉ាងងាយច្បាស់លាស់ ដោយមិនច្រឡំគ្នាឡើយ។

-ភាសាសំស្ក្រឹតអាចមើលសរសេរបាន។

-អក្សរភាសាថៃ (សៀម) សម្តេចអាចសន្ទនា និងអានបានទាំងសម្រាយទាំងបាលី។

-ភាសាបារាំង សម្តេចអាចអាន សន្ទនាបានយ៉ាងល្អ។

-ផ្នែកព្រះធម៌និងព្រះវិន័យ សម្តេចមានឈ្មោះល្បីល្បាញយ៉ាងខ្ទរខ្ទារ ព្រះអង្គចេះវិន័យបាតិមោក្ខសូត្ររត់មាត់ចាំប្រាកដ ច្បាស់លាស់ណាស់ ហើយពូកែស៊ីជម្រៅយ៉ាងខ្លាំងខាងព្រះវិន័យពុទ្ធសាសនា។ ព្រះអង្គចេះគម្ពីរវុត្តោទ័យ ព្រមទាំងអដ្ឋកថាដីកាយោជនា យ៉ាងស្ទាត់ជំនាញពីសំណាក់ព្រះតេជព្រះគុណព្រះធម្មលិខិត **ម៉ឺន សែស** ប្រធានថេរសភាសង្ឃជាព្រះគ្រូដ៏ ផ្ទើមរបស់សម្តេច។

ចំពោះការគោរពប្រតិបត្តិព្រះពុទ្ធសាសនា ក្នុងផ្នែកព្រះធម៌ និងព្រះវិន័យសម្តេចអនុវត្តបានយ៉ាងល្អប្រសើរ គួរឱ្យគោរពស្រឡាញ់ និងជ្រះថ្លា។

ដោយសារព្រះគុណធម៌ និងសេចក្តីថ្លៃថ្នូរទាំងអស់នោះហើយ បានជាទាំងព្រះសង្ឃ និងទាំងប្រជាពុទ្ធបរិស័ទ តែងបានលើកឡើង



កោតសរសើរចំពោះសម្តេចថា ព្រះអង្គជាពហុស្សូតមួយអង្គយ៉ាងផ្ទើមក្នុងសម័យបច្ចុប្បន្ននេះក៏ដូចជាក្នុងសម័យកាលកន្លងមក។

ចំពោះសម័យបច្ចុប្បន្ននេះ សម្តេចជាមហាថេរមួយអង្គកម្រនឹងរកបានទាំងសមត្ថភាពនិងគុណធម៌ ព្រះអង្គបានជាព្រះសង្ឃគំរូដ៏ ល្អប្រសើរមួយអង្គក្នុងសង្គមខ្មែរ។

ក្នុងការសរសេរលើកឡើងនូវព្រះរាជជីវប្រវត្តិរបស់សម្តេចលាស់ឡាយ នាពេលនេះ សូមចប់ដោយសង្ខេបខ្លីត្រឹមប៉ុណ្ណឹង។

ជាអវសាននេះ ខ្ញុំព្រះករុណា ទូលព្រះបង្គំ យើងខ្ញុំទាំងអស់គ្នាសូម ប្រសិទ្ធពរជ័យ សិរីមង្គល វិបុលសុខ មហាប្រសើរ គ្រប់បែប យ៉ាងសូមថ្វាយ ប្រគេន ចំពោះអង្គសម្តេចផ្ទាល់ និងសម្តេចគ្រប់ព្រះអង្គសប្បុរសជន និងពុទ្ធមាមកជនទូទៅ ទាំងព្រះសង្ឃ និងគ្រហស្ថ ដែលព្រះអង្គ និងអស់លោក មានទឹក ព្រះទ័យ ទឹកចិត្តជ្រះថ្លាចូលរួមជួយឧបត្ថម្ភទាំងកម្លាំងកាយ-ចិត្តនិងបច្ច័យលុយកាក់សម្ភារៈផ្ទាល់ខ្លួនរៀងៗខ្លួនចេញថ្លៃក្នុងការបោះពុម្ព ព្រះរាជជីវប្រវត្តិរបស់សម្តេចនេះ សូមឱ្យបានជួបប្រទះតែនឹងសេចក្តីសុខចម្រើនជានិច្ចនិរន្តរ៍តែរៀងទៅ។ពិសេសជាងនេះទៀតសូមបានប្រកបដោយពុទ្ធពរ៤ប្រការគឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីអាក់ខានឡើយ។











ពីធីថ្វាយព្រះគោរមងារសញ្ញាបត្រកិត្តិបណ្ឌិតចំពោះសម្តេច
ព្រះធម្មលិខិត **លាស ឡាយ** ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១១





ពីធីថ្វាយព្រះគោរមងារសញ្ញាបត្រកិត្តិបណ្ឌិតចំពោះសម្តេច
ព្រះធម្មលិខិត **លាស ឡាយ** ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១១



# ៥-ព្រះរាជជីវប្រវត្តិ
# សម្តេចព្រះពោធិវង្ស អ៊ំ លីមហេង ព្រះសង្ឃនាយករងទី២ ព្រះអគ្គាធិការរង ពុទ្ធិកសិក្សាជាតិ នៃព្រះរាជាណាចក្រកម្ពុជានិងជាព្រះចៅអធិការវត្ត មុនីសុវណ្ណ (ចំពុះក្អែក)



## ១-អំពីជាតិភូមិ

សម្តេច **អ៊ំ លីមហេង** ប្រសូត្រនៅថ្ងៃព្រហស្បតិ៍ ១១រោច ខែអស្សុជ ឆ្នាំម្សាញ់ ព.ស ២៥០៨ ត្រូវនឹងថ្ងៃទី២១ ខែតុលា ឆ្នាំ ១៩៦៥ នៅក្នុង ភូមិរកាកោង ឃុំរកាកោង១ ស្រុកមុខកំពូល ខេត្ត កណ្តាល។

មាតា និងបិតារបស់សម្តេច មាននាមដូចខាងក្រោម ៖

- មាតានាម **ទន់ ជាវលី** កើតថ្ងៃសៅរ៍១២រោចខែចេត្រ ឆ្នាំរោង ត្រូវនឹងថ្ងៃទី៤ ខែឧសភា ឆ្នាំ១៩៤០ នៅភូមិទូរីកណ្តាល ឃុំព្រែកពោធិ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។

- បិតានាម **អ៊ំ សុខ** កើតថ្ងៃអង្គារ ១៤រោច ខែផល្គុន ឆ្នាំជូត ត្រូវនឹងថ្ងៃទី២ ខែមេសា ឆ្នាំ១៩៣៥នៅភូមិរកាកោង ឃុំរកាកោង១ ស្រុកមុខកំពូល ខេត្តកណ្ដាល។

## ២-អំពីកុមារភាព

- ចាប់ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨១ រៀននៅសាលាបឋមសិក្សារកាកោង១
- ពីឆ្នាំ១៩៨១ ដល់ឆ្នាំ១៩៨៤ រៀននៅអនុវិទ្យាល័យ សិរីមង្គល រកាកោង២
- ពីឆ្នាំ១៩៨៤ ដល់ឆ្នាំ១៩៨៧ រៀននៅវិទ្យាល័យ **ហ៊ុន សែន** តាខ្មៅហើយបានប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ទទួលបាន (បាក់ឌុប)និទ្ទេសល្អបង្គួរ។

## ៣-អំពីការសាងផ្នួស

លុះប្រឡងជាប់ហើយបាន៧ថ្ងៃ យុវជន **អ៊ំ លីមហេង** ហេតុតែមានឧបនិស្ស័យក្នុងព្រះពុទ្ធសាសនា ក៏មានទឹកចិត្តសទ្ធាជ្រះថ្លា ស្រឡាញ់ពេញចិត្តចង់សាងផ្នួស ក៏បានសម្រេចចិត្តសុំការអនុញ្ញាតពីមាតា បិតា ទៅបំពេញឧបសម្បទាជាភិក្ខុភាវៈក្នុងសំណាក់ព្រះអរិយមគ្គញាណព្រះនាម **អន ហ៊ឹម** ជាព្រះឧបជ្ឈាយ៍ ក្នុងពទ្ធសីមាវត្តជ្រោយអម្ពិល ឃុំក្បាលកោះ ស្រុកកៀនស្វាយ ខេត្តកណ្ដាលនៅថ្ងៃសុក្រ ១៥កើត ខែអាសាធ ឆ្នាំថោះព.ស ២៥៣១ ត្រូវនឹងថ្ងៃទី១០ ខែកក្កដា ឆ្នាំ១៩៨៧ បានទទួលនាមបញ្ញត្តិថា (លោកសង្ឃហត្ថរោ)។ លុះបានបំពេញ ឧបសម្បទាជាភិក្ខុភាវៈរួច ភិក្ខុ **អ៊ំ លីមហេង** ក៏បាន



និមន្តមកគង់នៅវត្តមុនីសុវណ្ណ (ចំពុះក្អែក) ពេលនោះវត្តចំពុះក្អែក គ្រប់គ្រងដឹកនាំដោយព្រះគ្រូចៅអធិការព្រះនាម **កែ យ៉ាន់**។

ចាប់តាំងពីពេលបានឧបសម្បទាជាភិក្ខុភាវៈរួចមកភិក្ខុ**អ៊ំ លីមហេង** បានយកព្រះទ័យទុកដាក់ ខិតខំ ប្រឹងប្រែង ព្យាយាមរៀនសូត្រព្រះធម៌និងព្រះវិន័យ ទាំងផ្នែកគន្ថធុរៈនិងវិបស្សនាធុរៈក្នុង សំណាក់ព្រះគ្រូធម្មាចារ្យ **សេង ហេង** បានយ៉ាងល្អប្រសើរ។ ដោយមានធន្ទៈនិងវិរិយភាពយ៉ាងមោះមុតក្នុងការសិក្សារៀនសូត្រ ព្រះភិក្ខុ **អ៊ំ លីមហេង** បានទទួលការកោតសរសើរយ៉ាងខ្លាំងពីសំណាក់លោកគ្រូធម្មាចារ្យរបស់ខ្លួន ដែលជាអ្នកបង្ហាត់បង្រៀនផ្ទាល់។

## ៤-អំពីឋានានុក្រមតួនាទី ឋានៈ និងការកិច្ចដែលសម្ដេចទទួលបាន

- នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៩៨ ជាព្រះគ្រូសូត្រស្ដាំវត្តមុនីសុវណ្ណ (ចំពុះក្អែក)
- នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៨ ជាលេខាគណខេត្តកណ្ដាល
- នៅថ្ងៃទី២ ខែឧសភា ឆ្នាំ១៩៩៩ ជាព្រះសាសនសំវររាជាគណៈថ្នាក់កិត្តិយស
- នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៩៩ បានទទួលតួនាទីជាព្រះឧបជ្ឈាយ៍
- នៅថ្ងៃទី១ ខែឧសភា ឆ្នាំ២០០០បានទទួលការតែងតាំងជាអធិបតីនៃមជ្ឈមណ្ឌលព្រះសមថកម្មដ្ឋានវត្តមុនីសុវណ្ណ(ចំពុះក្អែក)
- នៅថ្ងៃទី៥ ខែមីនា ឆ្នាំ២០០១ ជាព្រះសាក្យវង្ស រាជាគណៈថ្នាក់ត្រី

- នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៣ ជាព្រះចៅអធិការវត្ត មុនីសុវណ្ណ (ចំពុះក្អែក)
- នៅថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៦ ជាសម្តេចព្រះពោធិវង្ស ព្រះសង្ឃនាយករងទី២នៃព្រះរាជាណាចក្រកម្ពុជា
- នៅថ្ងៃទី៤ ខែសីហា ឆ្នាំ២០០៦ជាអនុប្រធានទី៣ នៃថេរសភាសង្ឃព្រះពុទ្ធសាសនា។

## ៥-អំពីគ្រឿងឥស្សរយសដែលសម្តេចទទួលបាន

- នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៩៨ មេដាយស្ថាបនាជាតិ ថ្នាក់លេខ១ (មេដាយមាស)
- នៅថ្ងៃទី១ ខែសីហា ឆ្នាំ២០០១ មេដាយសុវត្ថារា ថ្នាក់ធិបឌិន
- នៅថ្ងៃទី៩ ខែសីហា ឆ្នាំ២០០៣ មេដាយសុវត្ថារា
- នៅខែធ្នូ ឆ្នាំ២០០៤មេដាយស្ថាបនាជាតិថ្នាក់លេខ១(មេដាយមាស)
- នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៥ មេដាយស្ថាបនាជាតិ ថ្នាក់អស្សឫទ្ធិ
- នៅថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៦ មេដាយមុនីសារាភ័ណ្ឌ ថ្នាក់មហាសេនា
- នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៧មេដាយមុនីសារាភ័ណ្ឌ ថ្នាក់មហាសេរីវឌ្ឍន៍
- នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១០ មេដាយ ជាតូបការ។











ពិធីថ្វាយព្រះគោរមងារសម្តេចព្រះធម្មលិខិត **អ៊ំ លីមហេង**
ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៣



# ៦-ព្រះជីវប្រវត្តិ
# សម្តេចព្រះវនរ័ត ណយ ច្រឹក ព្រះសង្ឃនាយករងទី៣
# និងជាព្រះអគ្គាធិការរងពុទ្ធិកសិក្សាជាតិ
# នៃព្រះរាជាណាចក្រកម្ពុជា
# ព្រមទាំងជាព្រះចៅអធិការវត្ត ចន្ទ បូរីវង្ស
# ស្ថិតនៅក្នុងឃុំសំរោង ស្រុកពញាឮ  ខេត្តកណ្តាល



## ១-អំពីជាតិភូមិ

សម្តេចព្រះវនរ័ត ប្រសូតនៅថ្ងៃសុក្រ ១១កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រូវនឹង ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៤៩ នៅក្នុងភូមិគ្រួស ឃុំសំរោង ស្រុកពញាឮ ខេត្តកណ្តាល។ មាតានាម **ណយ យ៉ឹន** បិតានាម **ផឹក ផូ**។ ព្រះអង្គមានបងប្អូនបង្កើតចំនួន ៧នាក់ គឺ ប្រុស ៤នាក់ និងស្រី ៣នាក់។ ព្រះអង្គជាបុត្រទី២ នៅក្នុងគ្រួសារនេះស្ថិតក្នុងត្រកូលកសិករ សុទ្ធសាធ ហើយជាគ្រួសារមួយប្រកបដោយសម្មាទិដ្ឋិដ៏ប្រពៃ។

## ២-អំពីការសិក្សា  បព្វជ្ជា និងឧបសម្បទា

កុមារ **ណយ ច្រឹក** មានអត្តចរិតស្លូតបូត សុភាពរាបសា ចរិតជាអ្នកឧស្សាហ៍ព្យាយាម វៃឆ្លាត ប៊ិនប្រសប់ ហើយមានទំនាក់

ទំនងល្អ ស្រឡាញ់រាប់អានកុមារៗ ដូចគ្នាជាពិសេសចាស់ៗ ដែលរស់នៅក្នុងស្រុកភូមិ ក៏មានការស្រឡាញ់ពេញចិត្តច្រើន។ កុមាររូបនេះគឺជាបុត្រដ៏ល្អប្រសើររស់នៅក្នុងបន្ទុកគ្រួសាររបស់មាតាបិតាបាន យ៉ាងស្រួល។

លុះវ័យល្មមដល់ការសិក្សាហើយ មាតាបិតាបាននាំបុត្រជាទីស្រឡាញ់ឲ្យទៅនៅសិក្សាវិជ្ជា មានអក្សរសាស្ត្រ លេខនព្វន្ត និងសិល្បៈសិប្បកម្មផ្សេងៗជាដើម នៅក្នុងវត្តថ្មី ឬហៅវត្តសង្កែបត់ ដែលសព្វថ្ងៃជាវត្ត **ទេព រង្សី** ឃុំព្រែកតាទែន ស្រុកពញាឮ ខេត្តកណ្តាល។

កុមារ **ឈាយ ទ្រឹក** បានទៅស្នាក់នៅវត្ត ស្ថិតនៅក្នុងសំណាក់ព្រះគ្រូ **ជួន ឥន្ទបញ្ញា** ជាព្រះចៅអធិការវត្ត។

កុមារ **ឈាយ ទ្រឹក** មានចរិតឧស្សាហ៍ព្យាយាមក្នុងការងារ ក៏ដូចជាក្នុងការសិក្សា ជាកុមារមានកាយវិការទំនាក់ទំនងល្អចេះស្រឡាញ់កុមារគ្នាឯងបានយ៉ាងល្អ។ គំនិតល្អ ចរិតចរិយាល្អ មានលក្ខណៈខុសប្លែកពីកុមារដទៃ ពិសេសមានលក្ខណៈវៃឆ្លាត ប៉ិនប្រសប់ក្នុងកិច្ចការរបស់ខ្លួន។តាំងពីបានទៅសំណាក់នៅវត្តហើយកុមារនេះបានយក ចិត្តទុកដាក់ខិតខំរៀនសូត្រជាប្រចាំមិនថាយប់មិនថាថ្ងៃឡើយ។

លុះសិក្សាចេះដឹងវិជ្ជាអក្សរសាស្ត្រ លេខនព្វន្ត ទាំងផ្លូវលោកផ្លូវធម៌ល្មមអាចប្រើការបាន មាតាបិតា ក៏បានអនុញ្ញាតឲ្យកុមារ **ឈាយ ទ្រឹក** បព្វជ្ជាជាសាមណេរក្នុងសំណាក់ព្រះតេជព្រះគុណ **គុល ឡៅ ចន្ទត្ថេរោ**។ ដោយមានការសព្វព្រះហឫទ័យចំពោះកុមារ **ឈាយ ទ្រឹក** ព្រះតេជព្រះគុណ **គុលឡៅ** បានជួយបង្កលក្ខណៈឧបត្ថម្ភលើកទឹកចិត្តឲ្យកុមារ **ឈាយ ទ្រឹក** បានសាងផ្នួសជាសាមណេរដើម្បីជាកិច្ច



តបស្នងសងគុណចំពោះព្រះគ្រូ **ទែន ជួនឥន្ទបញ្ញា** គ្រូដើមរបស់កុមារ **ឈាយ ទ្រឹក** ដែលព្រះអង្គបានសុគតទៅ។

កុមារ **ឈាយ ទ្រឹក** បានសាងផ្នួសជាសាមណេរដោយបានខិតខំប្រឹងប្រែងឧស្សាហ៍ព្យាយាមសិក្សារៀនសូត្រធម៌វិន័យ ព្រមទាំងបានរៀនមូលវេយ្យាករណ៍ប្រែបាលីយ៉ាងខ្ជាប់ខ្ជួននាពេលនោះ។ចំណេះដឹង និងការយល់ដឹងក្នុងការសិក្សារៀនសូត្រ មានការចេះចាំយល់ដឹងយ៉ាងជ្រៅជ្រះអំពីច្បាប់ចំពោះព្រះពុទ្ធសាសនា ហើយថែមទាំងបានរៀននូវសមាធិវិបស្សនាកម្មដ្ឋានបានយ៉ាងជ្រៅជ្រះទៀតផង។

នៅឆ្នាំ១៩៧២-៧៣ អាយុកាលផ្នួសជាសាមណេរបាន៩ វស្សា គម្រប់ជន្មាយុ ២១ វស្សា ពេញបរិបូណ៌ក៏ចង់ឧបទាសម្បទាជាភិក្ខុភាវៈ តែជាអកុសលពេលនោះប្រទេសជាតិត្រូវមានវិបត្តិកើតសង្គ្រាម នៅក្នុងស្រុករឹករវមានការបាញ់ផ្លោង យន្តហោះទម្លាក់គ្រាប់បែកមិនឈប់ឈរ ធ្វើឲ្យប្រជាជនមានការភ័យខ្លាចរត់ចោលផ្ទះសម្បែង វត្តអារាមត្រូវបំផ្លាញខ្ទេចខ្ទីវិនាសអន្តរាយគ្មានសល់ ភិក្ខុ-សាមណេរ ត្រូវភៀសខ្លួនរត់ចោលវត្តអារាម ពេលនោះការបំពេញផ្នួសជាភិក្ខុត្រូវអាក់ខាន។

ប្រជាជន ប្រុស ស្រី ក្មេង ចាស់ ត្រូវរត់គេចពីសង្គ្រាម គ្រាប់ផ្លោងពីការទម្លាក់គ្រាប់បែក ខ្លះបានរស់រួចខ្លួន ខ្លះត្រូវស្លាប់បាត់បង់ជីវិតយ៉ាងអណោចអាធម្មជាទីបំផុត។

របប លន់ នល់ បានត្រូវរលំឈានចូលដល់របបមួយ ខ្មៅងងឹតសូន្យសុង នៅខែមេសា ឆ្នាំ១៩៧៥ ជ័យជំនះមហាលោតផ្លោះ មហាអស្ចារ្យអន្តរធាន ព្រះពុទ្ធសាសនា វត្តអារាម ភិក្ខុសាមណេរ និងប្រជាជន ប្រុស ស្រី គ្រប់វ័យ ត្រូវពួកបនប្រល័យពូជសាសន៍ ប៉ុល ពត

បង្ខិតបង្ខំប្រជាជន ប្រុស ស្រីទាំងអស់ឲ្យធ្វើការយ៉ាងធ្ងន់ធ្ងរជាទីបំផុត ធ្វើខ្លាំងបង្អត់បាយកាន់តែខ្លាំង ហើយពួកវាបានបង្ខំព្រះសង្ឃខ្មែរឲ្យសឹក ទាំងអស់ក្នុងទូទាំងប្រទេស ក្នុងនោះក៏មានព្រះសង្ឃ **ណាយ ច្រឹក** មួយអង្គដែរ។

នៅក្នុងយុគសម័យដ៏ខ្មៅងងឹត រយៈពេល៣ឆ្នាំ ៨ ខែ និង ២០ ថ្ងៃ ការរស់នៅដូចសត្វធាតុប្រៀបបាននិងឋាននរកអវិចី វេទនាទុក្ខវេទនា វេទនាកម្មពោរពេញទៅដោយទារុណកម្មខ្លោចផ្សា ក្តុកក្តួលក្នុងចិត្ត ពោរពេញទៅដោយទឹកភ្នែក គ្រាំគ្រាក្នុងចិត្តឥតឧបមា ឈឺចាប់ខ្លោចផ្សា វេទនា លំបាក និរាសព្រាត់ប្រាសឪពុកម្តាយ ឃ្លាតឆ្ងាយពីកូន ប្រុស ស្រី ប្តីព្រាត់ប្រពន្ធគ្មានពេលជួប ស្លាប់បាត់សូន្យឈឹង នេះហើយ ក្នុងរបប ប៉ុល ពត ដែលប្រវត្តិសាស្ត្រពិភពលោកមិនដែលជួបប្រទះសោះឡើយ។

ប្រជាជន ប្រុស ស្រី ក្មេង ចាស់ គ្រប់ៗរូប កំពុងវេទនាកម្ម កំពុងឈឺចុកចាប់ កំពុងលំបាកវេទនា កំពុងខ្លោចផ្សាផ្លូវចិត្ត ស្ថិតនៅក្នុងភក់ជ្រាំយ៉ាងសែនទារុណកម្មខ្លោចផ្សាចិត្តធ្ងន់ធ្ងររកទីបំផុតគ្មាន។

ជាភ័ព្វសំណាងល្អ ទំព័រថ្មីនៃប្រវត្តិសាស្ត្រ ថ្ងៃជ័យជំនះជា ប្រវត្តិសាស្ត្រ ៧មករា ១៩៧៩ ប្រទេសជាតិមាតុភូមិត្រូវបានរំដោះទាំងស្រុងពីនឹមដែកអំរែកថ្ម គុកឥតជញ្ជាំង ក្នុងរបបប្រល័យពូជសាសន៍ ប៉ុល ពត ដ៏សែនឃោរឃៅអមនុស្សធម៌។

ក្រោមមាគ៌ារណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដឹកនាំដោយ សម្តេច**ជា ស៊ីម** សម្តេច **ហេង សំរិន** និងសម្តេច **ហ៊ុន សែន**ទឹកដីមាតុភូមិកម្ពុជាបានរំដោះទាំងស្រុង ហើយអ្វីៗទាំងអស់សវិញ្ញាណកៈ



និងអវិញ្ញាណកៈក៏បានរស់រានមានជីវិតឡើងវិញ ព្រមគ្នាទាំងអាយុជីវិត ទាំងជំនឿសាសនា ទាំងសិទ្ធិសេរីភាព។ល។ ក៏ត្រូវបាន រស់ឡើងវិញទាំងអស់ ក្នុងនោះព្រះអង្គ **ណាយ ច្រឹក** នឹង ប្រជាជនទូទាំងប្រទេស ត្រូវបានរស់មានទឹកមុខស្រស់ស្រាយសប្បាយ រីករាយក្នុងចិត្តគ្រប់ៗគ្នាហើយក៏បាននាំគ្នាខិតខំប្រឹងប្រែងស្តារហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងសេដ្ឋកិច្ច និងបានរៀបចំសង្គម មានការជួសជុលវត្តអារាមឡើងវិញ ទៅតាមជំនឿទឹកចិត្តសទ្ធាជ្រះថ្លាចំពោះព្រះពុទ្ធសាសនា តាមគោលការណ៍របស់មជ្ឈិមរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា នាពេលនោះគ្រប់ៗគ្នា។

ដោយទឹកព្រះទ័យជ្រះថ្លា ស្រឡាញ់គោរពជឿជាក់ចំពោះ ព្រះពុទ្ធសាសនា និងមានបំណងចង់តបស្នងសងគុណចំពោះអ្នកដ៏មានគុណមាន មាតាបិតា ជីដូនជីតា និងគ្រូឧបជ្ឈាយាចារ្យជាដើម ក៏បានសម្រេចចិត្តចូលឧបសម្បទាជាភិក្ខុភាវៈឡើងវិញ ក្នុងឆ្នាំ១៩៨៦ ក្នុងពុទ្ធសីមាវត្តតាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល ដោយមានព្រះគ្រូ **ហាន ហ៊ឹម** ជាព្រះឧបជ្ឈាយ៍ ព្រមទាំងបានការជួយឧបត្ថម្ភគាំទ្រពីលោក **លឹម ចិន** អ្នកស្រី **ម៉ាលី** លោកអាចារ្យ **ម៉េង** អ្នកស្រី **មុទ្ធា** និងលោកស្រី **អ៊ុំ ស្រី** បានជួយឧបត្ថម្ភទាំងកម្លាំងកាយចិត្ត និងសម្ភារៈព្រមទាំងទេយ្យវត្ថុផ្សេងៗក្នុងពេលសាងព្រះផ្នួសនោះបានយ៉ាងអធិកអធម។

ក្រោយពេលសាងផ្នួសហើយ ព្រះភិក្ខុ **ណាយ ច្រឹក** ក៏បានសម្រេចព្រះទ័យនិមន្តចេញទៅគង់នៅវត្តចន្ទបុរីវង្ស ឃុំសំពៅង ស្រុកពញាឮ ខេត្តកណ្តាល រហូតមកទល់នឹងសព្វថ្ងៃ គឺ ឆ្នាំ១៩៨៦ ជាដំបូងការលំបាកការខ្វះខាតក្នុងជីវិតជាសង្ឃ តែងតែមានដូចក្នុងសម័យ

ពុទ្ធកាលអញ្ចឹងដែរ។ តែអ្វីដែលល្អនោះ គឺខន្តីធម៌ សច្ចធម៌ និងធម៌វីរិយភាព គឺការព្យាយាមខិតខំប្រឹងប្រែងទាំងក្នុងការរៀនសូត្រ ការរៀបចំកសាងចាត់ចែង ហើយធ្វើជាមេដឹកនាំរាល់ការងារឲ្យបានសម្រេចនូវអ្វីៗគ្រប់បែបយ៉ាងមានកុដិ ព្រះវិហារ សាលារៀន មន្ទីរពេទ្យ និងអ្វីៗជាច្រើនទៀត។ល។ ដោយមានការប្រកាន់ខ្ជាប់ជាប់ជាប្រចាំនៅក្នុងព្រះសន្តានអនុវត្តនូវគោលធម៌ទាំងអស់នោះហើយ ទើបធម៌សាមគ្គីកើតមានឡើង ភាពងាយស្រួលនិងការសប្បាយក្នុងភេទជាបព្វជិត ក៏ចេះតែមានការអភិវឌ្ឍឥតឈប់ឈរ ទាំងការអនុវត្តការងារ ការគោរពប្រតិបត្តិធម៌ ធម៌វិន័យបានយ៉ាងល្អប្រសើរ។ ចំណែកនាយកធម៌ទាំង៦បានប្រកាន់យ៉ាងខ្ជាប់ខ្ជួនល្អ ហើយថែមទាំងប្រណិបតន៍នូវគារវធម៌អបចាយធម៌និងសង្គហធម៌ចំពោះមហាថេរចាស់ៗបានយ៉ាងល្អប្រពៃ។

ព្រះកាយវិការដ៏ទន់ភ្លន់ ព្រះចរិយាសុភាពរាបសា ថ្លៃថ្នូរ និងពិធីបដិសណ្ឋារកិច្ចចំពោះភ្ញៀវទូទៅ មិនថាគ្រហស្ថ ឬបព្វជិតឡើយ ព្រះអង្គអនុវត្តក្នុងពិធីបដិសណ្ឋារកិច្ចបានយ៉ាងល្អស្មើដូចៗគ្នា។ ដោយការមិនប្រកាន់តួនាទី ឋានៈ បុណ្យស័ក្តិ យ៉ាងសាមញ្ញទាំងអស់នេះ ហើយបានធ្វើឲ្យពុទ្ធបរិស័ទទូទៅ គោរពស្រឡាញ់សម្តេចយ៉ាងស្មោះត្រង់ និងជ្រះថ្លាជាមួយសម្តេចជានិច្ចគ្មានពេលបំភ្លេចបាន។

ព្រះកាយវិការ ព្រះសកម្មភាព និងព្រះវីរិយភាពដ៏សកម្មខ្លាំងក្លាលេចធ្លោ ឆ្នើមបំផុតលើវិស័យកសាងសមិទ្ធផលនានា ដែលមានយ៉ាងច្រើនជាអនេកទាំងក្នុងពុទ្ធចក្រ និងក្នុងអាណាចក្រ។

អ្វីៗដែលសម្តេចបានកសាងឡើង សុទ្ធតែមានផលប្រយោជន៍យ៉ាងធំធេងដល់ពុទ្ធសាសនា និងដល់សង្គមជាតិទាំងមូល។



សម្តេចមានសមត្ថភាព និងទេពកោសល្យគ្រប់គ្រាន់ ឈ្លាសវៃប៉ិនប្រសប់ មានបច្ចេកទេសខ្ពស់ក្នុងការដឹកនាំ ណែនាំអប់រំ គ្រប់គ្រងព្រះសង្ឃ គ្រហស្ថ អាចារ្យ គណៈកម្មការ និងពុទ្ធបរិស័ទទូទៅជាពិសេសជាមួយព្រះសង្ឃគ្រប់លំដាប់ថ្នាក់បានយ៉ាងល្អប្រសើរ មិនតែប៉ុណ្ណោះសូម្បីជាមួយមន្ត្រីរាជការ តូច ធំ គ្រប់លំដាប់ថ្នាក់មានការប្រាស្រ័យទាក់ទងគ្នាបានយ៉ាងល្អ ព្រោះសម្តេចបានអនុវត្តនូវទិសស្លោកមួយឃ្លាថា៖"បើកាលណាកាន់តែធំ ឲ្យកាន់តែទាបចុះ" ។ ទឹកព្រះទ័យនិងសកម្មភាពដ៏ល្អនេះហើយ បានធ្វើឲ្យព្រះកិត្តិសព្ទកេរ្តិ៍ឈ្មោះព្រះកិត្តិយសល្បីល្បាញ ខ្ចរខ្ចាយទៅសព្វទិសានុទិសទាំងក្នុងនិងក្រៅប្រទេសត្រូវបានទទួលការគាំទ្រ អបអរសាទរ ស្រឡាញ់ រាប់អានយ៉ាងច្រើនជាពិសេសមានការស្រឡាញ់ស្មោះស្ម័គ្រជាមួយ នឹងព្រះអង្គជានិច្ច។

ក្រោយពីបានឃើញនូវរាល់ស្នាព្រះហស្ត ក្នុងការកសាងសមិទ្ធផលនានា ដ៏ច្រើនសន្ធឹកសន្ធាប់ចាប់តាំងពីអាយុកាលសាងផ្នួស គឺ នៅឆ្នាំ១៩៨៦ មកទល់នឹងបច្ចុប្បន្ននេះ សម្តេចព្រះវនរ័ត មានព្រះសកម្មភាពយ៉ាងខ្លាំងក្លាក្នុងការដឹកនាំណែនាំព្រះសង្ឃ ពុទ្ធបរិស័ទ និងសប្បុរសជនទាំងក្នុងស្រុក ក្រៅស្រុក ជាពិសេស អ្នកក្រុងភ្នំពេញដោយព្រះអង្គ ចលនាឲ្យចូលរួមក្នុងការកសាងសមិទ្ធផលនានា មានសាលារៀន ផ្លូវថ្នល់ ស្រះទឹក អណ្តូងស្នប់ ព្រះវិហារ ឧបដ្ឋានសាលាបុណ្យ កុដិ ក្លោងទ្វារ របងវត្ត ម៉ាស៊ីនភ្លើង មេក្រូ អំពូលភ្លើង ដងទង់ផ្ទះកងទ័ព។ល ។ ព្រមទាំងបានជួយឧបត្ថម្ភនូវបច្ច័យផ្តល់ឲ្យចំពោះវត្តនានាបានមួយចំនួននៅតាមបណ្តាលខេត្ត-ក្រុងខ្លះ នៅក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា។

នៅក្នុងការជួយឧត្តម្ភនោះ ក៏មានជាសម្ភារៈបម្រើឲ្យនៅតាមការិយាល័យមាន ៖ តុ ទូ កៅអី ទូដាក់ឯកសារ ទូតម្កល់ព្រះត្រៃបិដក តុវែងសម្រាប់បម្រើឲ្យការប្រជុំ កម្រាលព្រំសម្រាប់តុបតែងក្រាលនៅក្នុងការិយាល័យជាដើម។ល។ និងសម្ភារៈផ្សេងៗជាច្រើនមុខទៀត ដូចជា ដងទង់ ទង់ជាតិ បង្គោលភ្លើង អំពូលភ្លើង បានជួយផ្តល់ចំពោះពុទ្ធសាសនា និងចំពោះសង្គមជាតិមាតុភូមិ។

## ៣-អំពីស្នាព្រះហស្តក្នុងវិស័យកសាងសមិទ្ធផលនានា

### ក -/វិស័យកសាងសមិទ្ធផលនានា

នៅវត្តចន្ទបូរីវង្សទាំងមូលក្នុងឃុំសំរោង ស្រុកពញាឮ ខេត្តកណ្តាល (ចាប់ពីឆ្នាំ១៩៨៦រហូតមកដល់ឆ្នាំ២០១០) មានដូចខាងក្រោម ៖

- បានកសាងព្រះវិហារកំពូលត្រីសូល៍ប្រាំពីរ អស់បច្ច័យ ១២៥,០០០ ដុល្លារ
- កសាងឧបដ្ឋានសាលាធ្វើពីស៊ីម៉ង់ត៍មួយខ្នង អស់បច្ច័យ ៨,៣០០ ដុល្លារ
- កសាងកុដិថ្មប្រក់ក្បឿងមួយខ្នង អស់បច្ច័យ ៥,៣០០ ដុល្លារ
- កសាងបណ្ណាល័យមួយខ្នង អស់បច្ច័យ ៥,៣០០ ដុល្លារ
- បានកសាងរបងសាលារៀន **ហ៊ុន សែន** នៅសំរោង មានប្រវែងបណ្តោយ ២៤០ម កំពស់ ២,៧០ម និងបានកសាងក្លោងទ្វារសាលាបានចំនួន៣សរុបបច្ច័យអស់១៦,១៩៧ដុល្លារ
- បានកសាងរបងវត្តព័ទ្ធជុំវិញប្រវែង ៦៥១ម កំពស់ ២.៧០ម អស់បច្ច័យចំនួន ២៥,៦៣០ ដុល្លារ



- បានកសាងក្លោងទ្វារវត្តចំនួន៥ ធ្វើអំពីថ្មមានក្បូរក្បាច់រចនាយ៉ាងទំនើបអស់បច្ច័យសរុបចំនួន ១២៥,០០០ ដុល្លារ
- បានកសាងរោងបាយមួយខ្នងអស់បច្ច័យចំនួន១៥,០០០ដុល្លារ
- កសាងវច្ចកុដិ(បង្គន់អនាម័យ)ចំនួន៣បន្ទប់ អស់បច្ច័យចំនួន ១០,៥០០ ដុល្លារ
- បានខិតខំកសាងទូក-ងចំនួន ៥ គ្រឿងអស់ បច្ច័យចំនួន ២៥,០០០ ដុល្លារ
- បានកសាងអាងតម្កល់ទឹកចំនួន ៣ចំណុះ ចំនួន ៣៦ម$^{៣}$ អស់បច្ច័យចំនួន ៣,៦០០ ដុល្លារ
- បានខិតខំចាក់ដីបំពេញក្នុងទីវត្តចំនួន១២,០០០ ដុល្លារ
- បានចាក់ផ្លូវក្រាលក្រួសក្រហម អស់បច្ច័យចំនួន ៦០,០០០ ដុល្លារ អស់បច្ច័យសរុបចំនួន ១៨,០០០ ដុល្លារ
- បានកសាងសាលារៀនមួយខ្នងមាន ៣ បន្ទប់ អស់បច្ច័យ ៨,៧៧២ ដុល្លារ
- បានធ្វើខឿនអំពីបេតុងអារមេទប់ដីផ្លូវចេញពីវត្តចន្ទបូរីវង្សរហូតដល់ថ្នល់ជាតិចំនួនប្រវែង១២០០មអស់បច្ច័យ២,៦០០ដុល្លារ
- បានចូលរួមកសាងបង្គោលភ្លើងធ្វើអំពីស៊ីម៉ង់ត៍មានក្បូរក្បាច់បានចំនួន ៤៨ដើម អស់បច្ច័យ ៤,០០០ដុល្លារ។

❖ ចំណុចពិសេសលេចធ្លោ ៖ កម្រមានអ្នកចាប់អារម្មណ៍កសាងក្នុងការងារនេះ សម្តេចបានកសាងក្តារម្ឈូសមានក្បូរក្បាច់សម្រាប់ដាក់តម្កល់សព ចំនួន ៥គ្រឿង អស់បច្ច័យ ៧,៥០០ ដុល្លារ

- ក្នុងការកសាងសមិទ្ធផលនានា សម្តេចមិនភ្លេចទេចំពោះជីវភាពអ្នកក្រីក្រ អ្នកជួបការលំបាកខ្វះខាតជាងគេ លំបាកវេទនា តោកយ៉ាកខ្លាំង ព្រះអង្គតែងបានគិតគូរចាប់អារម្មណ៍ចែកជាអំណោយចំនួន ៧ លើកដល់អ្នកក្រីក្រទាំងអស់នោះ អស់បច្ច័យចំនួន ២៨,០០០ដុល្លារ

❖ ពិសេសម្យ៉ាងទៀត ៖ ក្នុងការផ្សព្វផ្សាយ បោះពុម្ពសៀវភៅធម៌នានាមាន ៖១- សៀវភៅ វិសាខបូជា មាឃបូជា, ២- កប្បកថា, ៣- ព្រះពុទ្ធ ៤-ឱវាទសង្ខេប ៣យ៉ាង និងសៀវភៅឧត្តមជីវិតកថា ផ្ទាល់ព្រះហស្តរបស់ព្រះអង្គ អស់បច្ច័យសរុប ៦,០០០ ដុល្លារ + ២,០០០ដុល្លារ = ៨,០០០ដុល្លារ

❖ បានជួយឧបត្ថម្ភក្នុងការបោះពុម្ពសៀវភៅធម៌នានាមាន ៖

១- ប្រវត្តិពុទ្ធសាសនា ក្រោយព្រះពុទ្ធបរិនិព្វាន រៀបរៀងដោយសម្តេចព្រះលិខិត **លាស់ ឡាយ** លើកទី៣ បច្ច័យ.............

២- សៀវភៅធម៌កំណើត ៤ រៀបរៀងដោយសម្តេចព្រះមហាសុមេធាធិបតី **នន្ទ ង៉ែត** លើកទី៣ បច្ច័យ.........................

៣- សៀវភៅព្រះពុទ្ធឱវាទសង្ខេប ៣ យ៉ាង ស្រាវជ្រាវរៀបរៀងដោយព្រឹទ្ធសាស្ត្រាចារ្យ**ឆេព ផុន**បោះពុម្ពលើកទី២អស់បច្ច័យចំនួន...............

៤- សៀវភៅមាគ៌ានាំទៅរកសុខ រៀបរៀងដោយព្រឹទ្ធសាស្ត្រាចារ្យមួយក្រុមបោះពុម្ពលើកទី១ចំនួន២០០០ច្បាប់អស់បច្ច័យ

- រាល់សកម្មភាពជាសង្គហធម៌ និងប្រកបដោយមេត្តាធម៌សម្តេចតែងបានជួយឧបត្ថម្ភគាំទ្រជាបច្ច័យ និងសម្ភារៈផ្សេងៗចំពោះ



អ្នកដែលបានធ្វើទំនាក់ទំនងក្នុងការងារ ទាំងការងារពុទ្ធសាសនានិងការងារសង្គមកិច្ចតែងបានជួយឧបត្ថម្ភជានិច្ចកាលអស់ប៉ាន់ប្រមាណចំនួនរាប់ម៉ឺនដុល្លារ នេះនិយាយក្នុងការចំណាយទូទៅទាំងព្រះសង្ឃនិងគ្រហស្ថ ព្រោះថារាល់ការជួបក្នុងការលើកទឹកចិត្តនោះទេ។

**ខ/-ការជួយឧបត្ថម្ភក្នុងការសាងសង់តាមបណ្តាវត្ត** នៅខេត្ត ក្រុង ក្នុងទូទាំងប្រទេស ៖

- ជួយឧបត្ថម្ភកសាងវត្តអង្គសិរីសួស្តី ឃុំសំរោង ស្រុកពញាឮ ខេត្តកណ្តាល អស់បច្ច័យ ៥,៩៥០ដុល្លារ
- បានជួយឧបត្ថម្ភកសាងវត្តសំរោង ខេត្តកណ្តាល............. អស់បច្ច័យ ១៣,៨៩៥ដុល្លារ
- បានជួយឧបត្ថម្ភកសាងវត្តជេដ្ឋាឧត្តម ឃុំសំរោង ស្រុកពញាឮ ខេត្តកណ្តាល អស់បច្ច័យ ២,០០០ដុល្លារ
- បានជួយឧបត្ថម្ភកសាងវត្តពពៃលើ ឃុំជ្រៃលាស់ ស្រុកពញាឮ ខេត្តកណ្តាល អស់បច្ច័យ ១៥,៣៥០ដុល្លារ
- បានជួយឧបត្ថម្ភកសាងផ្លូវលំនៅសំរោងជើង ឃុំសំរោង ស្រុកពញាឮ ខេត្តកណ្តាល អស់បច្ច័យ ១៥,៨៥៣ ដុល្លារ
- បានជួយឧបត្ថម្ភកសាងវត្តពោធិព្រឹក្សនៅខេត្តកំពត អស់បច្ច័យ ១០,២០០ដុល្លារ
- បានឧបត្ថម្ភកសាងវត្តឈូកនៅ ខេត្តកំពតអស់បច្ច័យ១១,២៧៥ ដុល្លារ សរុបរួមទាំង ៨កន្លែង អស់បច្ច័យ ៨៥,០៧៣ដុល្លារ

- បានជួយឧបត្ថម្ភកសាងវត្តសិរីមង្គល ហៅវត្តក្បេរ ស្ថិតនៅក្នុងវត្តក្បេរ ឃុំព្រែករំដេង ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម រួមមាន ៖
  ១- ដំបូលព្រះវិហារ
  ២- ក្លោងទ្វារជុំវិញព្រះវិហារ
  ៣- សាលារៀនមួយខ្នង មាន៣បន្ទប់
  ៤- បង្គន់អនាម័យចំនួន ២បន្ទប់
  ៥- របងវត្តធ្វើអំពីបេតុងអាមេ និងបានចាក់ដី អស់ជា ច្រើនរយម៉ែត្រគូប អស់បច្ច័យចំនួន ៤៣,៦៩០ដុល្លារ (ក្នុងឆ្នាំ២០០៧)។
- បានជួយឧបត្ថម្ភកសាងផ្លូវលំចាក់ក្រួសក្រហមពីវត្តអង្គរ ដល់វត្តធ្លា ស្ថិតនៅក្នុងភូមិបន្ទាយថ្ម ឃុំអម្ពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម អស់បច្ច័យ ១១,០០០ដុល្លារ
- បានជួយឧបត្ថម្ភកសាងដំបូលកុដិវត្តធ្លាស្ថិតនៅក្នុងភូមិបន្ទាយថ្មី ឃុំអម្ពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម អស់បច្ច័យ ២,០០០,០០០រៀល (ឆ្នាំ២០០៩)
- បានជួយឧបត្ថម្ភកសាងផ្លូវថ្នល់ ចាក់ដីខ្មៅអស់ចំនួន ១,០០០ឡាន បណ្ដោយមានប្រវែង៧០២ម និងទទឹង ៧ម អស់បច្ច័យចំនួន ២៨,២០០ដុល្លារ (ឆ្នាំ២០០៧)
- បានជួយឧបត្ថម្ភរបងខឿនទប់រលកទឹកបោក មានប្រវែង ៧២ម ទទឹងផ្លូវប្រវែង៥ម អស់បច្ច័យ២០១៧ដុល្លារ និងលុយខ្មែរចំនួន ៧៥ម៉ឺន (ឆ្នាំ២០០៧)



- បានចូលរួមជួយកសាងជួសជុលផ្លូវលំចាក់ដី និងក្រាលក្រួសក្រហម មានប្រវែងបណ្ដោយ៥៥៥ម និងទទឹង ៥ម អស់បច្ច័យចំនួន ៣៩៨០ ដុល្លារ ស្ថិតនៅក្នុងភូមិគ្រួសខាងជើង (ឆ្នាំ២០០៧)
- នៅក្នុងឆ្នាំនោះដែរ បានចាក់ដីនៅវត្តចន្ទបូរីវង្ស អស់អាចម៍ដីចំនួន៥០០ឡាន អស់បច្ច័យចំនួន ៥,០០០ដុល្លារ
- បានជួយឧបត្ថម្ភលូតាមផងផ្លូវសំរោងជើង មានចំនួន២២៨លូកង់ អស់បច្ច័យចំនួន ២,២៨០,០០០រៀល (ឆ្នាំ២០០៧)
- បានកសាងរៀបឥដ្ឋធ្វើប្រឡាយទឹកនៅ ភូមិសំរោងជើង អស់បច្ច័យ ១,៦០០,០០០រៀល
- បានជួយឧបត្ថម្ភជួសជុលផ្លូវនៅ វត្តសំរោង នៅក្នុងភូមិសំរោងខាងជើងឃុំសំរោង ស្រុកពញាឮអស់បច្ច័យចំនួន២២៥ ដុល្លារ
- បានជួយឧបត្ថម្ភបច្ច័យសម្រាប់ទិញដងទង់ជាតិចំនួន ៤១ដើមអស់បច្ច័យចំនួន ២៥៦ដុល្លារ សម្រាប់ឃុំសំរោង
- បានជួយឧបត្ថម្ភរៀបចំដាក់លូ ចំនួន២កន្លែង អស់ចំនួនលូ២០កង់ អស់បច្ច័យចំនួន ២៥០,០០០រៀល នៅសំរោងជើង
- បានជួយឧបត្ថម្ភទិញទង់ជាតិចំនួន ២០០ដុល្លារ សម្រាប់ផ្ដល់ឲ្យឃុំសំរោង អស់បច្ច័យចំនួន ២៥០ដុល្លារ
- បានជួយឧបត្ថម្ភបច្ច័យក្នុងថ្ងៃទិវាសិទ្ធិនារី ១៨មីនា អស់បច្ច័យចំនួន ១,៧០០,០០០រៀល (ឆ្នាំ២០០៩)

- បានជួយឧបត្ថម្ភកសាងវិទ្យាល័យ **ហ៊ុន សែន** សំពោង ចំនួន ២ខ្នង មាន១០បន្ទប់ អស់បច្ច័យចំនួន ៩៧,១៤២ដុល្លារ (ឆ្នាំ២០០៧)
- បានជួយឧបត្ថម្ភកសាងក្រាលឥដ្ឋការ៉ូ (ការ៉ូឡា) ក្នុងវិទ្យាល័យ **ហ៊ុន សែន**សំពោងអស់បច្ច័យចំនួន ៥,៦០០ដុល្លារ
- បានជួយឧបត្ថម្ភ ក្នុងការកសាងកន្លែងសុវត្ថិភាព ដាក់ក្នុងវិទ្យាល័យ **ហ៊ុន សែន** សំពោងអស់បច្ច័យចំនួន ៥០០ដុល្លារ
- បានជួយឧបត្ថម្ភកសាងកន្លែងធ្វើទីបាត់ការ នៅក្នុងវិទ្យាល័យ **ហ៊ុន សែន** សំពោង អស់បច្ច័យចំនួន ៤០០ដុល្លារ
- បានជួយឧបត្ថម្ភកសាងប្រាង្គតម្កល់រូប ព្រះបាទជ័យវរ្ម័នទី៧ អស់បច្ច័យចំនួន ៥,០០០ដុល្លារ
- បានជួយឧបត្ថម្ភចូលជាស៊ីម៉ង់ត៍ សម្រាប់កសាងសាលាបុណ្យ (ឧបដ្ឋានសាលា) នៅវត្តអង្គក្រពើសង្កាត់គោករកា ខណ្ឌដង្កោ រាជធានីភ្នំពេញ ស៊ីម៉ង់ត៍ ចំនួន ៤០០បាវ (ឆ្នាំ២០០៨)
- បានជួយឧបត្ថម្ភកសាងផ្លូវថ្នល់ធ្វើអំពីបេតុងអាមេ មានចំនួន ១ខ្សែ មានប្រវែងចំនួន ៨៤៤ម ទទឹង ៨ម អស់បច្ច័យ ១៣,៥០០ដុល្លារ (ឆ្នាំ២០០៨)
- បានជួយឧបត្ថម្ភចូលរួមកសាងពិដានព្រះវិហារនៅវត្តពោធិលឹង ភូមិស្រះពឹង ឃុំបាធាយ ស្រុកបាធាយ ខេត្តកំពង់ចាម អស់ស៊ីម៉ង់ត៍ចំនួន ៦០០បាវ (ឆ្នាំ២០០៩)
- បានជួយឧបត្ថម្ភកសាងវត្តអង្គពពាយ ស្រុកអង្គស្នួល ខេត្តកណ្ដាល អស់បច្ច័យចំនួន ៣០០ដុល្លារ (ឆ្នាំ២០១០)



- បានចូលរួមជួយឧបត្ថម្ភកសាងផ្លូវលំ ដែលស្ថិតនៅក្នុងភូមិព្រៃកពោធិ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម អស់បច្ច័យចំនួន ២លានរៀល (ឆ្នាំ២០១០)
- បានចូលរួមកសាងក្លោងទ្វារវត្តទាន់ អស់បច្ច័យចំនួន ៥០០ ដុល្លារ (ឆ្នាំ២០១០)
- បានចូលរួមជួយឧបត្ថម្ភចំពោះអ្នករងគ្រោះដោយខ្យល់ព្យុះដួលរលំផ្ទះនៅក្នុងភូមិគ្រួស ឃុំសំពោង ស្រុកពញាឮ ខេត្តកណ្ដាល អស់បច្ច័យចំនួន ១០០ដុល្លារ (ឆ្នាំ២០១០)
- ជាលើកទី២ទៀតបានជួយឧបត្ថម្ភចំពោះប្រជាជនរងគ្រោះ នៅក្នុងភូមិឃុំ ស្រុក ខេត្ត ដដែល អស់បច្ច័យចំនួន ៥០០ដុល្លារ (ឆ្នាំ២០១០)
- បានចូលរួមជួយឧបត្ថម្ភក្នុងកសាងឧបដ្ឋានសាលា (សាលាបុណ្យ) នៅក្នុងវត្តប្រាសាទ ភូមិត្រពាំងសំរិទ្ធ ឃុំកងណយ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល អស់បច្ច័យចំនួន ១០០ ដុល្លារ (ឆ្នាំ២០១០)
- បានជួយឧបត្ថម្ភបង្គោលភ្លើងមួយចំនួននៅក្នុងភូមិសំពោងជើង អស់បច្ច័យចំនួន ១,៥០០ដុល្លារ (ឆ្នាំ២០១០)
- បានជួយឧបត្ថម្ភកសាងប្រាសាទនាងអស់បច្ច័យចំនួន៧,២០០ ដុល្លារ (ឆ្នាំ២០១០)
- បានជួសជុលកែលម្អដងទង់១គូ ឲ្យមានសោភណភាពល្អឡើង អស់បច្ច័យចំនួន ៣,២០០ដុល្លារ (ឆ្នាំ២០១០)

- បានជួយឧបត្ថម្ភកសាងប្រាសាទមួយអស់បច្ច័យចំនួន១,៨០០ ដុល្លារ
- បានជួយឧបត្ថម្ភកសាងបល្ល័ង្កមួយអស់បច្ច័យចំនួន៥០០ដុល្លារ
- បានកសាងក្លោងទ្វារធំមួយមានក្បូរក្បាច់រចនាយ៉ាងទំនើបអស់បច្ច័យចំនួន ១៦,០០០ដុល្លារ (ឆ្នាំ២០១០)
- បានចូលរួមជួយឧតប្ថម្ភកសាងបង្គោលភ្លើងចំនួន ១១៧ ដើម អស់បច្ច័យចំនួន ១៣,៥១៤ដុល្លារ (ឆ្នាំ២០១០)
- បានកសាងចេតិយមួយ អស់បច្ច័យចំនួន ៦,៥៤៧ដុល្លារ
- បានកសាងប៉ាណូមួយផ្ទាំង អស់បច្ច័យចំនួន ៥០០ដុល្លារ
- សម្តេចព្រះវនរ័ត **ណយ ច្រឹក** ព្រះអង្គសព្វព្រះហឫទ័យជួយ សម្រាលបន្ទុកចំពោះប្រជាជនក្រីក្រ ដែលជួបការលំបាក នៅក្នុងភូមិបន្ទាយថ្ម ឃុំអម្ពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម ជាសម្ភារៈគ្រឿងឧបភោគបរិភោគ អស់បច្ច័យចំនួន ៥០០ ដុល្លារ (ឆ្នាំ២០១០)
- បានកសាងមហាកុដិមួយខ្នង មានពីរជាន់ធ្វើអំពីបេតុងអារមេ អស់បច្ច័យចំនួន ៧៥៦,០១៦ ដុល្លារ

**គ/- ចំពោះសមរភូមិមុខ (ខេត្តព្រះវិហារ)៖**

សម្តេចព្រះវនរ័ត **ណយ ច្រឹក** ព្រះអង្គតែងតែមានព្រះទ័យចាប់អារម្មណ៍គិតគូរដល់សមរភូមិទាំងពីរ គឺ ទាំងសមរភូមិខាងក្រោយ និងទាំងសមរភូមិខាងមុខ ជាក់ស្តែងចំពោះទឹកព្រះទ័យនិងព្រះសន្តានចិត្តរបស់ព្រះអង្គ សព្វថ្ងៃព្រះអង្គកំពុងបានសុខស្រួល និងមានសុវត្ថិភាពជាស្ថាពរនេះ គឺប្រាកដជាបានមកដោយសារកងកម្លាំងប្រដាប់អាវុធ



ឈរជើង នៅសមរភូមិតាមព្រំដែន ពិសេស គឺ ខេត្តព្រះវិហារ។ ពេលសម្តេចបាននិមន្តទៅផ្ទាល់ហើយបានឃើញជាក់ស្តែង ធ្វើឲ្យទឹកព្រះទ័យការរំជួលទឹកចិត្តអាណិតអាសូរកាន់តែខ្លាំងឡើង ហើយសម្តេចបានចូលរួមជួយឧបត្ថម្ភក្នុងការកសាងផ្ទះផ្តល់ឲ្យកងទ័ពចំនួន ៥ ខ្នង ចំពោះកងទ័ពដែលបានឈរជើងនៅតាមព្រំដែនខេត្តព្រះវិហារ អស់បច្ច័យ (៣,៧០០ដុល្លារ ៥) = ១៨,៥០០ដុល្លារ។

ចំពោះកងទ័ពជាតិ ដែលបានឈរជើងនៅសមរភូមិមុខ (នៅប្រាសាទព្រះវិហារ) បានទទួលសម្ភារៈប្រើប្រាស់ជាគ្រឿងឧបភោគបរិភោគយ៉ាងច្រើនព្រមទាំងបច្ច័យចំនួន ២០,០០០,០០០រៀល (ក្នុងឆ្នាំ២០១០)។

ក្នុងពេលនោះដែរ សម្តេចព្រះវនរ័តព្រះអង្គមានព្រះទ័យជ្រះថ្លាដឹងគុណចំពោះកងទ័ពជាតិដែលមានស្មារតីលះបង់ខ្ពស់ចំពោះប្រទេសជាតិមាតុភូមិ និងព្រះពុទ្ធសាសនារបស់ខ្លួន ព្រះអង្គបានជួយឧបត្ថម្ភជាម៉ាស៊ីនភ្លើងចំនួន២ គ្រឿងអស់បច្ច័យចំនួន ៣,០០០ដុល្លារនិងបានជួយឧបត្ថម្ភជាអំពូលភ្លើងមួយចំនួនធំទៀត អស់បច្ច័យចំនួន ៣,៥០០ ដុល្លារ (ឆ្នាំ២០១០)។

យើងដឹងហើយថា សម្ភារៈ និងបច្ច័យលុយកាក់ដ៏ច្រើនសន្ធឹកសន្ធាប់ដែលសម្តេចព្រះវនរ័ត បានខិតខំចំណាយពេលវេលាយ៉ាងច្រើនក្នុងកិច្ចការបម្រើប្រយោជន៍រួមនោះ គឺបានមកពីទឹកព្រះទ័យលះបង់ខ្ពស់របស់ព្រះអង្គ ដោយបានយកបច្ច័យមកចូលរួមជួយឧបត្ថម្ភក្នុងការកសាងសង្គមពុទ្ធសាសនា និងសង្គមជាតិ ដើម្បីឲ្យទង់ទាំងពីរ គឺ ទង់ពុទ្ធចក្រ និងទង់អាណាចក្របានវិលស្មើគ្នា លឿនដូចគ្នា នោះទើបពុទ្ធ

សាសនានិងសង្គមជាតិរីកចម្រើនជឿនលឿនទៅមុខបានយ៉ាងល្អ។ព្រះសកម្មភាពនិងព្រះវិរិយភាពព្រមទាំងការលះបង់ចំណាយនូវបច្ច័យ ក្នុងវិស័យកសាងចំពោះពុទ្ធសាសនា និងចំពោះសង្គមជាតិមាតុភូមិបានធ្វើឲ្យព្រះកិត្តិសព្ទព្រះកិត្តិនាម របស់ព្រះអង្គល្បីល្បាញខ្ទរខ្ទារហើយថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ មានការចាប់អារម្មណ៍ពេញចិត្តពេញថ្លើម និងទទួលស្គាល់សម្តេចព្រះវនរ័តថា ជាព្រះសង្ឃគំរូឆ្នើមមួយព្រះអង្គក្នុងសង្គមបច្ចុប្បន្ននេះ និងទៅអនាគត។ ដោយសារស្នាព្រះហស្ថដ៏ឆ្នើមទាំងអស់នោះ ហើយបានធ្វើឲ្យសម្តេចទទួលបាននូវព្រះឋានានុក្រមតួនាទីព្រះឋានៈនិងភារកិច្ចបានជាបន្តបន្ទាប់រហូតមកទល់បច្ចុប្បន្ននេះ។

❖ អំពីឋានានុក្រមតួនាទីឋានៈនិងភារកិច្ចដែលសម្តេចទទួលបាន៖

- នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៩៤ បានឡើងជាព្រះវិន័យធរ ស្រុកពញាឮ
- នៅថ្ងៃទី៣ ខែសីហា ឆ្នាំ១៩៩៥ បានឡើងជាព្រះឧបជ្ឈាយ៍ ស្រុកពញាឮ
- នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៩៥ បានឡើងជាព្រះចៅអធិការ វត្តចន្ទបូរីវង្ស ស្រុកពញាឮ
- នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ១៩៩៧ បានឡើងជាព្រះគ្រូចរិយាកោសល អនុគណស្រុកពញាឮ
- នៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ១៩៩៩ បានឡើងជាព្រះគ្រូទេពសត្ថារាជាគណៈថ្នាក់ចត្វា
- នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០២ ឡើងជាព្រះសុមេធវង្សរាជាគណៈថ្នាក់ត្រី



- នៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០៤ ឡើងជានាយករងទី១ ខុទ្ទកាល័យសម្តេចព្រះសង្ឃរាជ **ទេព វង្ស**
- នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៤ ឡើងជាព្រះឃោសធម្មរាជាគណៈថ្នាក់ទោ
- នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៦ អនុប្រធានទី២ ថេរសភានៃព្រះពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា
- នៅថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៦ ឡើងជាអគ្គាធិការរងពុទ្ធិកសិក្សាជាតិនៃព្រះរាជាណាចក្រកម្ពុជា

❖ បានឡើងជា ៖

- ឧត្តមទីប្រឹក្សាសម្តេចអគ្គមហាសង្ឃរាជាធិបតី **ទេព វង្ស** មហាសង្ឃរាជ នៃព្រះរាជាណាចក្រកម្ពុជា
- ឧត្តមទីប្រឹក្សាសម្តេចព្រះពោធិវង្ស **នន្ទ ង៉ែត**
- ឧត្តមទីប្រឹក្សាសម្តេចព្រះធម្មលិខិត **លាស់ ឡាយ**
- ឧត្តមទីប្រឹក្សាព្រះមេគណខេត្តកណ្តាល **ឃឿន យ៉ាត់**
- នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១០ ឧត្តមប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជាទទួលបន្ទុកផ្នែកមនុស្សធម៌ សង្គមកិច្ច និងសេដ្ឋកិច្ច

❖ អំពីគ្រឿងឥស្សរិយយសដែលសម្តេចទទួលបានជាបន្តបន្ទាប់ ៖

- មេដាយគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជាថ្នាក់អស្សឫទ្ធិ
- មេដាយមុនីសារាភណ្ឌ ថ្នាក់មហាសិរីវឌ្ឍន៍
- មេដាយមុនីសារាភណ្ឌ ធិបឌិន

- មេដាយមាសស្ថាបនាជាតិ ចំនួន៥គ្រឿង

❖ បេសកកម្មនៅក្នុងប្រទេស និងក្រៅប្រទេស ៖

ក- ទស្សនកិច្ចជាផ្លូវការនៅក្នុងប្រទេស ៖

នៅពេល ដែលសម្តេចទ្រង់បានទទួលព្រះឋានៈតួនាទី និងភារកិច្ចថ្មី គឺសម្តេចព្រះវនរ័ត តែងតែមានការមមាញឹកយ៉ាងខ្លាំង ក្នុងការងារភារកិច្ចស្នួលរបស់ព្រះអង្គយ៉ាង សកម្ម។ ក្នុងចំណោមខេត្ត-ក្រុងទាំង២៤ខេត្ត-ក្រុងខ្លះ ព្រះអង្គបានចុះទៅច្រើនដង តាមសំណូមពរការងារចាំបាច់ដែលមូលដ្ឋានខេត្ត ក្រុង ស្នើ និមន្ត ដូចជាបវេសនកាលនៅតាមពុទ្ធិកវិទ្យាល័យរបស់ខេត្ត-ក្រុង និងក្នុងពិធីបើកសម្ពោធសមិទ្ធផលនានានៅតាមខេត្ត ក្រុង ដែលមានសំណូម ពរស្នើនិមន្ត។ ពេលសម្តេចនិមន្តចុះទៅគឺត្រូវចំណាយយ៉ាងតិចកន្លែងខ្លះរហូតដល់ពី១លានប្លាយរហូតដល់២លានរៀល។

ខ- ទស្សនកិច្ចជាផ្លូវការនៅក្រៅប្រទេស ៖

ចំពោះការធ្វើទស្សនកិច្ចជាផ្លូវការទៅក្រៅប្រទេស សម្តេចព្រះវនរ័តព្រះអង្គបាននិមន្តធ្វើទស្សនកិច្ច ជាផ្លូវការតាមបណ្តាប្រទេសមួយចំនួនដូចខាងក្រោម ៖

១- និមន្តទៅប្រទេសលាវ

២- និមន្តទៅប្រទេសថៃ

៣- និមន្តទៅប្រទេសវៀតណាម

៤- និមន្តទៅប្រទេសស្រីលង្កា

៥- និមន្តទៅប្រទេសឥណ្ឌា

៦- និមន្តទៅប្រទេសសឹង្ហបុរី



៧- និមន្តទៅប្រទេសអាមេរិក

៨- និមន្តទៅប្រទេសចិន។

## សេចក្តីសន្និដ្ឋាន

សម្តេចព្រះវនរ័ត **ណាយ ច្រឹក** ព្រះអង្គមានសកម្មភាព និងព្រះវិរិយភាពយ៉ាងខ្លាំងក្លានិងមោះមុតបំផុត។ ទាំងក្នុងការងារពុទ្ធសាសនា និងការងារកសាងជាតិមាតុភូមិ (ការងារសង្គមកិច្ច) ពិសេសការងារក្នុងវិស័យជួយឧបត្ថម្ភកសាងសមិទ្ធផលនានា មានយ៉ាងច្រើនជាអនេកក្នុងសង្គមជាតិទាំងមូល។

នៅក្នុងវត្តចន្ទបូរីវង្ស ដែលជាវត្តផ្ទាល់របស់ព្រះអង្គ កាលដើមឡើយវត្តនេះមានតែកុដិចាស់ៗចំនួនពីរបីហើយផ្ទៃដីវត្តក្រហេងក្រហូងមិនល្អ មិនរាបស្មើទាល់តែសោះ។ តែបច្ចុប្បន្ននេះ វត្តចន្ទបូរីវង្ស មានសមិទ្ធផលនានាយ៉ាងច្រើន ហើយសុទ្ធតែទំនើបៗ ដូចជា ព្រះវិហារ ឧបដ្ឋានសាលា (សាលាបុណ្យ) មហាកុដិ កុដិថ្ម កុដិឈើយ៉ាងល្អសមរម្យ ផ្លូវខ្វាត់ខ្វែង នៅក្នុងវត្តបានក្រាលកៅស៊ូយ៉ាងស្អាតពេញផ្ទៃវត្តទាំងមូល។ មិនតែប៉ុណ្ណោះ នៅមានសមិទ្ធផលយ៉ាងច្រើនទៀតនៅក្នុងវត្ត ដែលយើងខ្ញុំមិនអាចលើកឡើងបានអស់។ ចំពោះតាមបណ្តាខេត្ត ក្រុងនានាក្នុងទូទាំងប្រទេស សម្តេចបានជួយឧបត្ថម្ភចូលរួមក្នុងការកសាង មានការកសាងវត្តអារាម, កុដិ, សាលារៀន, ព្រះវិហារ, ស្រះទឹក អណ្តូងទឹក, អណ្តូងស្នប់, របងវត្ត, ក្លោងទ្វារវត្ត ផ្លូវថ្នល់ ។ល។យ៉ាងច្រើនសន្ធឹកសន្ធាប់អស់បច្ច័យរាប់ម៉ឺនដុល្លារ។

ក្នុងរយៈពេលជាង ១០ ឆ្នាំ ចាប់តាំងពីឆ្នាំ១៩៨៦ មកទល់នឹងឆ្នាំ២០១០ នេះ សម្តេចមានស្នាព្រះហស្តយ៉ាងច្រើនសន្ធឹកសន្ធាប់

ណាស់ទាំងនៅក្នុងវិស័យកសាងព្រះពុទ្ធសាសនាក៏ដូចជាវិស័យកសាងសង្គមជាតិទាំងមូល។ដោយសារស្នាដៃព្រះហស្ដដ៏ធំធេងទាំងអស់នោះហើយ ដែលធ្វើឲ្យអង្គសម្ដេចបានទទួលនូវព្រះឋានានុក្រម តួនាទីឋានៈ និគោរមងារ ព្រមទាំងគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ជាបន្តបន្ទាប់ទាំងក្នុងផ្នែកពុទ្ធចក្រ និងការងារអាណាចក្រ។

ព្រះកិត្តិនាម ព្រះកិត្តិសព្ទដ៏ល្បីល្បាញ ផ្សព្វផ្សាយទៅគ្រប់ទិសទីទាំងក្នុងនិងក្រៅប្រទេសបានធ្វើឲ្យអស់លោកទាំងអស់នោះ ទទួលស្គាល់ហើយស្រឡាញ់គោរពរាប់អានសម្ដេចបានយ៉ាងច្រើន។

ព្រះគុណធម៌ ចរិយាធម៌ និងអបចាយនធម៌ ដ៏ល្អប្រសើររបស់សម្ដេចធ្វើឲ្យមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ តាំងពីថ្នាក់កំពូល រហូតមកដល់ថ្នាក់មូលដ្ឋាន មន្ត្រីសង្ឃ និងព្រះសង្ឃទូទៅ តែងតែមានទឹកព្រះទ័យទឹកចិត្តកោតស្ញប់ស្ញែង កោតសរសើរនូវ ព្រះគុណធម៌ ចរិយាធម៌ មេត្តាធម៌ ព្រមទាំងសង្គហធម៌របស់ព្រះអង្គជានិច្ច។

គំរូវីរភាពនិងព្រះសកម្មភាពដ៏ឆ្នើមៗទាំងអស់នោះហើយ ដែលធ្វើឲ្យពុទ្ធបរិស័ទទូទៅស្រឡាញ់ គោរពរាប់អានយ៉ាងអស់ពីចិត្តពីថ្លើម។ ការស្រឡាញ់ ការគោរព គឺជាព្រះគុណធម៌មួយដែលមិនអាចបំភ្លេចបានរហូតដល់អាយុកាលជាអវសាន។

សូមតេជៈគុណបុណ្យព្រះបារមីព្រះរតនត្រ័យនៃព្រះពុទ្ធសាសនា ព្រមទាំងវត្ថុស័ក្តិសិទ្ធិមានមហិទ្ធិឫទ្ធិខ្លាំងក្លា សូមជួយបីបាច់ ថែរក្សាការពារ និងអភិបាលតាមជួយប្រោះពរជ័យសិរីមង្គល សូមឲ្យបានសុខចម្រើនគ្រប់ទិវារាត្រីកុំបីអាក់ខាន។



សូមសម្ដេចទ្រង់បានជួបប្រទះតែនឹងព្រះសុខមាលភាពល្អ បរិបូណ៌ ព្រះជន្មាទីឃាយុយឺនយូរដល់រយព្រះវស្សាដើម្បីបានជាបង្អែកដ៏រឹងមាំនិងយ៉ាងកក់ក្ដៅចំពោះពុទ្ធបរិស័ទទូទៅនៅក្នុងព្រះពុទ្ធសាសនា។

សូមព្រះសកម្មភាពដ៏ខ្លាំងក្លានិងព្រះបញ្ញាញាណដ៏ភ្លឺថ្លាមុតស្រួច ព្រមទាំងទេពកោសល្យខ្ពស់រស់រវើក និងគំរូដ៏ល្អឆ្នើមឲ្យកាន់តែឆ្នើមប្រសើរ តទៅទៀត នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

សូមព្រះអង្គសម្ដេច បានប្រកបដោយពុទ្ធពរទាំង ៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។









ពីធីថ្វាយព្រះគោរមងារសម្តេចព្រះវនរ័ត **ណយ ច្រឹក**
ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៣

## ៧-ព្រះជីវប្រវត្តិសង្ខេប
## សម្តេចព្រះឧត្តមបញ្ញា ជួង ផង់ នន្ទិយោ



សម្តេចព្រះឧត្តមបញ្ញា **ជួង ផង់** ប្រសូត្រនៅថ្ងៃព្រហស្បតិ៍ ៨ កើត ខែទុតិយាសាឍ ឆ្នាំមមែ សំរិទ្ធិស័ក ព.ស ២៤៧៦ គ.ស ១៩៣២ នៅភូមិខ្ពបក្រោម ឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម។ ជាបុត្ររបស់លោកឧបាសក **ជូ ជួង** និងលោកយាយឧបាសិកា **ញ៉ែម នាង** ដែលជាត្រកូលសម្មាទិដ្ឋិកសិករសុទ្ធសាធ។ ព្រះអង្គមានបងប្អូនបង្កើត៧នាក់ (ប្រុស៤ ស្រី៣ ហើយព្រះអង្គជាកូនទី១។

### អំពីកុមារភាព

កាលពីកុមារភាព កុមារ **ជួង ផង់** មានលក្ខណសម្បត្តិមកពីធម្មជាតិគួបផ្សំនឹងការអប់រំពីសំណាក់មាតាបិតាផងនោះ កុមារ **ជួង ផង់**គឺជាកុមារមួយរូបដែលមានអត្តចរិតនិងអាកប្បកិរិយាថ្លៃថ្នូរ ទន់ភ្លន់ សុភាពរាបសា ចេះជួយទុក្ខធុរៈអ្នកដទៃ និងចេះគោរពឪពុកម្តាយចាស់ ព្រឹទ្ធាចារ្យគួរជាទីស្រឡាញ់រាប់អាន។ លុះមានវ័យបាន៧ឆ្នាំ ល្មមដល់ការសិក្សាហើយ មាតាបិតាបាននាំយកទៅប្រគេនលោកគ្រូ **ជា**



ដែលជាគ្រូសូត្រស្តាំវត្ត បទុមវតី ភូមិខ្ពបក្រោម ឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ដើម្បីឲ្យសិក្សារៀនសូត្រអក្សរសាស្រ្ត លេខនព្វន្ត រៀងរហូតមកដល់អាយុ១២ឆ្នាំ។

### អំពីជីវិតផ្នួស និងការសិក្សា

កុមារ **ជួង ផង់** មាននិស្ស័យ និងសុឆន្ទៈចំពោះព្រះពុទ្ធសាសនាស្រាប់នោះ ក៏បានចូលសាងព្រះផ្នួសជាសាមណេរនៅក្នុងពទ្ធសីមាវត្តបទុមបតី ភូមិខ្ពបក្រោម ឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ក្នុងសំណាក់ព្រះឧបជ្ឈាយ៍ព្រះនាម **ហៀង មោគ** ហើយបានសិក្សារៀនសូត្រធម៌អាចំសិក្ខាវិន័យចេះស្ទាត់ រហូតដល់ព្រះជន្មាយុ ១៧វស្សា ក៏នៅតែសិក្សាបន្តទៀតនូវធម្មន័យ និងវិបស្សនាធុរកម្មក្នុងសំណាក់ព្រះឧបជ្ឈាយ៍ដដែល។ លុះដល់ព្រះជន្មាយុ២១ព្រះវស្សាក៏បានឧបសម្បទាជាភិក្ខុភាវៈនៅពទ្ធសីមាវត្តបទុមវតី ភូមិឃុំស្រុកខេត្តដដែល ក្នុងសំណាក់ព្រះឧបជ្ឈយ៍ដដែល និងលោកគ្រូឧបសម្បទាចារ្យ ព្រះនាម **ម៉ៅ គឹមស្រុន** ហើយព្រះឧបជ្ឈយ៍បានឲ្យនាមបញ្ញត្តថា **ធម្មត្ថេរោ**។ បន្ទាប់ពីបំពេញឧបសម្បទាមក ព្រះភិក្ខុ **ជួង ផង់** បានសិក្សាបន្តទៀតនូវវិបស្សនាធុរៈ រហូតបានធ្វើជាគ្រូប្រដៅព្រះធម៌ ឬហៅថា (ព្រះធម្មាចារ្យ) បង្ហាត់បង្រៀនព្រះធម៌ដល់លោកតាលោកយាយ ដែលមានបំណងចង់រៀននូវវិបស្សនាកម្មដ្ឋាន។

នៅឆ្នាំ១៩៧០ សង្គ្រាមក៏បានចូលមកដល់ ភិក្ខុ **ជួង ផង់** ទទួលការគាបសង្កត់ចាកសិក្ខាបទ នៅឆ្នាំ១៩៧៦ របបរបស់លោកប៉ុល ពត ក៏បានធ្វើទារុណកម្ម ហើយជម្លៀសទៅនៅ ខេត្តព្រៃវែង ខេត្ត

កណ្តាល និងក្រុងភ្នំពេញ គីឡូម៉ែត្រលេខ៦ រោងចក្រដ២ (ផលិតម៉ាស៊ីនកិនស្រូវ)។

### **អំពីផ្នួសលើកទីពីរ**

នៅខែមករា ឆ្នាំ១៩៧៩ ប្រទេសជាតិបានរំដោះចេញផុតពីរបបប្រល័យពូជសាសន៍ (អន្ទិត) **ដួង ផង់** បានមកសាងផ្នួសបួសជាភិក្ខុភាវៈឡើងវិញនៅ ពទ្ធសីមាវត្តសន្សំកុសល រាជធានីភ្នំពេញក្នុងសំណាក់ព្រះឧបជ្ឈាយ៍ព្រះធម្មលិខិត **និល មុនី** ព្រះឧបជ្ឈាយ៍បានឲ្យនាមបញ្ញត្តិថា **នន្ទិយោ** នាសម័យរណសិរ្សក្រោមមាគ៌ាលោក **ឡុង ស៊ឹម** និងលោក **ជា ស៊ីម** នៃរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា។

នៅខែកក្កដា ឆ្នាំ១៩៨០ ភិក្ខុ **ដួង ផង់** ក៏បានបួសម្តងទៀតក្រោមព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់របស់សម្តេចព្រះមហាសង្ឃរាជាធិបតី **ទេព វង្ស** សម្តេចព្រះមហាសង្ឃរាជានៃព្រះរាជាណាចក្រកម្ពុជា កាលសម្តេចនៅជាព្រះវិន័យធរ មានការជួយឧបត្ថម្ភឡើងដោយសម្តេចតេជោ **ហ៊ុន សែន** កាលនោះលោកនៅជារដ្ឋមន្ត្រីក្រសួងការបរទេស។ ហើយបាននិមន្តទៅគង់នៅធ្វើជាចៅអធិការវត្តចេតិយថ្មី ដើម្បីជួយកសាងវត្តមាន ព្រះវិហារ កុដិ សាលា និងជួយកសាងវត្តដទៃទៀតជាច្រើនដែលនៅក្បែរនោះ ដូចវត្តសង្វរ វត្តកោះចិន និងវត្តព្រៃប្រប។ល។ ក្រោយមកព្រះភិក្ខុ **ដួង ផង់** ក៏ត្រូវបានទទួលតំណែងជាប្រធានសង្ឃស្រុក (អនុគណ) ស្រុកពញាឮ ខេត្តកណ្តាល។

នៅឆ្នាំ១៩៨៤ សម្តេចតេជោ **ហ៊ុន សែន** កាលលោកនៅជារដ្ឋមន្ត្រីក្រសួងការបរទេសព្រមជាមួយពុទ្ធបរិស័ទស្រុកក្រូចឆ្មារសុំនិមន្តលោកគ្រូ **ដួង ផង់** ឲ្យមកគង់នៅវត្តវេឡុវតនារាម (ហៅវត្តដើមជ្រៃ)



ឃុំក្រូចឆ្មារ ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម។ ក្នុងព្រះឋានៈជាប្រធានសង្ឃស្រុក (អនុគណ)។ ហើយមានព្រះគោរមងារជា ព្រះគ្រូធម្មាចារ្យនន្ទិយោ។ បន្ទាប់ពីទទួលបានព្រះគោរមងារនោះមក ព្រះគ្រូបានយកចិត្តទុកដាក់បង្ហាត់បង្រៀនព្រះវិបស្សនាកម្មដ្ឋានដល់ឧបាសក ឧបាសិកាជារៀងរាល់ឆ្នាំមិនដែលខានឡើយ។

លុះដល់ឆ្នាំ១៩៨៩ ព្រះអង្គបាននិមន្តទៅគង់នៅវត្តហ្លួងរកាខ្នុរកណ្តាល ឃុំរកាខ្នុរ ស្រុកខេត្តដដែល ដើម្បីកសាងព្រះវិហារនៅទីនោះបន្តទៀត ហើយព្រះគ្រូក៏មិនព្រងើយកន្តើយ ក៏បានបង្ហាត់បង្រៀននូវវិបស្សនាកម្មដ្ឋានដល់ឧបាសកឧបាសិកានៅទីនោះបន្តទៀត។

បន្ទាប់មកនៅឆ្នាំ១៩៩៣ ព្រះអង្គបាននិមន្តមកគង់នៅវត្តខ្សាច់ប្រឆេះក្រោម ឃុំក្រូចឆ្មារ ស្រុកខេត្តដដែល ដើម្បីកសាងព្រះវិហារ កុដិសាលានៅទីនោះបន្តទៀត។

នៅឆ្នាំ១៩៩៦ ឯកឧត្តម **គន់ គីម** អភិបាលខេត្តកណ្តាល បាននិមន្តសម្តេចមកគង់នៅវត្តមហានន្ទិយនេរញ្ជរារាមនិវេន (ហៅព្រែកប្រាំង) ឃុំកំពង់ហ្លួង ស្រុកពញាឮ ខេត្តកណ្តាល ដើម្បីជួយកសាងវត្តនៅទីនោះបន្តទៀត។

### **សមិទ្ធផលនានាដែលសម្តេចដឹកនាំកសាង**

ទន្ទឹមនឹងការងារដឹកនាំអប់រំបង្រៀនព្រះធម៌ដល់ពុទ្ធបរិស័ទ សម្តេចបានដឹកនាំកសាងសមិទ្ធផលផ្សេងៗជាច្រើន ដើម្បីទុកជាប្រយោជន៍សម្រាប់ព្រះពុទ្ធសាសនា និងជាប្រយោជន៍សម្រាប់សង្គមជាតិផង។ សមិទ្ធផលទាំងឡាយដែលសម្តេចបានកសាងមានដូចតទៅ ៖

- ១៩៦៧-១៩៧៣ វត្តសន្ធរង្សីខ្លបតាងួន ដីបាក់វត្តអស់បីដង ការកសាងក៏មានបីដងដែរ ឃុំខ្លបតាងួន ស្រុកស្ទឹងត្រែង ខេត្តកំពង់ចាម។
- ១៩៦៧-១៩៧៥ កសាងវត្តបទុមវតីខ្លបតាងួន ដីបាក់វត្តអស់បីដង ការកសាងក៏មានបីដងដែរ ឃុំខ្លបតាងួន ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។
- ១៩៨០-១៩៨៤ វត្តចេតិយថ្មី ជួយជួសជុលព្រះវិហារ កសាងធម្មត្រៃ កុដិ សាលាជួយជួសជុលវត្តព្រែកជីក, វត្តប្រាំបីឆោម, វត្តសង្វរ, វត្តព្រែកប្រាប, វត្តអង្គខ្នារ, វត្តតាមាស, អនុវិទ្យាល័យទេពប្រណម្យ មន្ទីរពេទ្យក្រាំងពន្លី ស្រុកពញាឮ ខេត្តកណ្តាល ជួយកសាងវិមានសពតាខ្មៅ អនុវិទ្យាល័យតាខ្មៅ វិក្រិតការតាខ្មៅ និងជួយជួសជុលព្រះវិហារវត្តតាខ្មៅខេត្តកណ្តាល។
- ១៩៨៤-១៩៨៦ ជួសជុលព្រះវិហារវត្តដើមជ្រៃ កសាងសាលាបឋមសិក្សាដើមជ្រៃ កសាងព្រះពុទ្ធរូបលោហធាតុ២អង្គ ដែលមានទម្ងន់ ២ តោនក្នុងព្រះមួយអង្គ មានទំហំភ្លែន ១.៥ម ព្រះអង្គថ្មប្រក់នាគទំហំភ្លែន១.៥ម កោដ្ឋធ្វើអំពីលោហធាតុ មានកម្ពស់ ២ម និងព្រះពុទ្ធរូបតូចៗជាច្រើនទៀត កសាងរបងវត្តក្លោងទ្វារ កុដិ សាលា ក្នុងឃុំក្រូចឆ្មារ ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម។
- ១៩៨៦-១៩៨៩ កសាងសាលារៀនអនុវិទ្យាល័យរកាខ្នុរ មាន ២អាគារ ២ជាន់ ១៦បន្ទប់ អំពីបេតុងអារមេ ឃុំរកាខ្នុរ ស្រុកខេត្តដដែល។



- ១៩៨៩-១៩៩៣ កសាងព្រះវិហារវត្តហ្លួង រកាខ្នុរអំពីបេតុងអារមេមានទំហំ១៥មx៣០ម ព្រះពុទ្ធរូបថ្មទំហំភ្លែន៣មព្រះពុទ្ធរូបលោហធាតុ២អង្គមានទំហំភ្លែន ១.៥ម និងទំហំភ្លែន១.២ម កុដិសាលារបង ខ្លោងទ្វារឃុំរកាខ្នុរស្រុកខេត្តដដែល។
- ១៩៩៣-១៩៩៦ កសាងព្រះវិហារវត្តខ្សាច់ប្រឆេះក្រោមអំពីបេតុងអារមេទំហំ ១០មx២០ម ព្រះបរមចេតិយកម្ពស់ ២១ម ព្រះពុទ្ធរូបលោហ ធាតុ៥អង្គទំហំ១.៥ម ២អង្គ និងទំហំភ្លែន ១.២ម ៣អង្គប៉មអាងទឹកចំណុះ១៥០០០ល កុដិ សាលារបងខ្លោងទ្វារសាលាបឋមសិក្សាវត្តខ្សាច់ប្រឆេះក្រោមក្នុងឃុំក្រូចឆ្មារ ស្រុកខេត្តដដែល។
- ពីឆ្នាំ១៩៩៦ ដល់បច្ចុប្បន្ន ៖ កសាងព្រះវិហារ វត្តមហាននិ្ទយនេរញ្ជរារាមនិវេនអំពីបេតុងអារមេទំហំ១៤ម x ២៨ម ព្រះពុទ្ធរូបថ្មអភ័យសត្វកម្ពស់៧.៥ម ព្រះពុទ្ធរូប(ថ្ម)ត្រាសជើង២ អង្គទំហំភ្លែន៥ម និងទំហំភ្លែន៣ម ព្រះពុទ្ធរូប(ថ្ម) កែវពោធិ៍សាត់ត្រាសជើង ២ អង្គទំហំភ្លែន៤ម និងទំហំភ្លែន១.២ម ព្រះពុទ្ធរូបថ្មបរិនិព្វាន ប្រវែង៧ម ព្រះសិអារមេត្រិយថ្មទំហំភ្លែន៤.៥ម ព្រះពុទ្ធរូបលោហធាតុ ៩ អង្គ ទំហំ២ម ៥អង្គទំហំ១.៥ម២អង្គ និងទំហំភ្លែន ១.២ម២អង្គ គ្រែទេសនាលោហធាតុ១ គ្រឿង គ្រែទេសនារាងជាបល្ល័ង្ក ២ គ្រឿងថ្មកែវពោធិ៍សាត់ ១ គ្រឿង ថ្មភ្នំសន្ទុក១គ្រឿង គ្រែទេសសត្វរាជសីហ៍៦គ្រឿងធ្វើ អំពីឈើ ២គ្រឿង ធ្វើអំពីថ្មភ្នំសន្ទុក២គ្រឿង ធ្វើអំពីថ្មព្រះវិហារ ២គ្រឿង គ្រែថ្ម៣គ្រឿង ទូថ្ម១ គ្រឿង ចេតិយ៦ថ្មភ្នំសន្ទុក ២ គ្រឿង

មាត្រដ្ឋាន ១.២ម និងកម្ពស់៣ម ព្រះវេស្សន្តរដាក់ទានដំរីដល់ព្រាហ្មណ៍ទាំង៨នាក់ រូបព្រះអង្គប្រសូត្រ (ថ្មព្រះវិហារ) កុដិថ្ម២ ទំហំ ៩មx១២ម ១ធ្វើអំពីថ្មភ្នំព្រះនេត្រព្រះ ១ធ្វើអំពីថ្មម៉ាបភូមាប៉មអាងទឹកមានទឹកមានចំណុះ៥០,000លីត្រសាលា កុដិ របងខ្លោងទ្វារនិងសមិទ្ធផលជាច្រើនទៀត ឃុំកំពង់ហ្លួង ស្រុកពញាឮ ខេត្តកណ្តាល។

- ឆ្នាំ២០០១ សម្តេចបាននិមន្តទៅបង្កើតវត្តថ្មីមួយទៀតនៅ ឃុំបឹងព្រាវ ស្រុកស្រែអំបិល ខេត្តកោះកុងមានទំហំដី ១០០មx ១០០០ម។ បានចាប់ផ្តើមកសាងព្រះវិហារនៅឆ្នាំ ២០០៨ ដែលមានទំហំ ១២មx ២៨ម ព្រះពុទ្ធរូបត្រាស់ដឹងភ្នែនថ្មី ២ម សាលា កុដិ របង ខ្លោងទ្វារ គ្រែទេសនាសត្វរាជសីហ៍ធ្វើអំពីថ្មព្រះវិហារ២គ្រឿងនិងសមិទ្ធផលផ្សេងៗទៀត។
- ឆ្នាំ២០០២ សម្តេចបាននិមន្តទៅជួយកសាងបង្ហើយនូវព្រះវិហារវត្តបទុមវតីខ្ពបក្រោម ឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម។
- ឆ្នាំ២០០៨-២០១០ សម្តេចបានរៀបចម្លង គម្ពីរព្រះត្រៃបិដកសាស្ត្រាស្លឹករឹតភាសាបាលីច្បាប់ដើម(នៅក្នុងព្រះបរមរាជវាំង) មួយចប់ និងគម្ពីរផ្សេងៗជាច្រើនទៀត។

## **សមណសក្តិ**

- ឆ្នាំ១៩៨០-១៩៨៤ បានទទួលឋានៈជាប្រធានសង្ឃស្រុក (អនុគណស្រុក) ស្រុកពញាឮ ខេត្តកណ្តាល។



- ឆ្នាំ១៩៨៩-១៩៩៦ បានទទួលឋានៈជាប្រធានសង្ឃស្រុក (អនុគណស្រុក) ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម។
- ឆ្នាំ១៩៩៦ បានទទួលឋានៈជាប្រធានសង្ឃវត្ត មហានន្ទិយនេរញ្ជរារាមនិវេទ ហៅវត្ត ព្រែកប្រាំង ឃុំកំពង់ហ្លួង ស្រុកពញាឮ ខេត្តកណ្តាល ជាចៅអធិការវត្ត។
- ឆ្នាំ១៩៩៩ បានទទួលព្រះរាជក្រឹត្យ នស/រកត/២៩៩/២៧ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ១៩៩៩ តែងតាំងជា ព្រះបិដកធម្មរាជាគណៈថ្នាក់ចត្វាគណៈមហានិកាយនៃព្រះរាជាណាចក្រកម្ពុជា។
- ឆ្នាំ២០០១ បានទទួលព្រះរាជក្រឹត្យ នស/រកត/០៩០១/៣២៩/ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០១ តែងតាំងឲ្យឡើងជាសម្តេចព្រះឧត្តមបញ្ញា។
- ឆ្នាំ២០០៦ បានទទួលអនុក្រឹត្យលេខ៥៧៦ អនក្រ.តត ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៦ តែងតាំងសមាជិកថេរសភាសង្ឃនៃព្រះរាជាណាចក្រកម្ពុជា។
- ឆ្នាំ២០១០ បានទទួលប្រកាសនីយបត្រលេខ ០៨/០១០មសរ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១០ តែងតាំងជា ឧត្តមប្រឹក្សាផ្ទាល់សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី **ទេព វង្ស** សម្តេចព្រះមហាសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជា។
- ឆ្នាំ២០០៦ ទទួលបានសញ្ញាបត្របណ្ឌិតកិត្តិយស ទស្សនវិជ្ជាផ្នែកវប្បធម៌ និងសាសនា ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៦ ពីសាកលវិទ្យាល័យចំរើនពហុច្ចេកវិទ្យា។

## គ្រឿងឥស្សរិយយស

- ឆ្នាំ២០០១ បានទទួលព្រះរាជក្រឹត្យ នស/រកត/០២០១/០២៨ ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០០១ទទួលបានគ្រឿងឥស្សរិយយស

**មេដាយសុវត្ថារា ថ្នាក់ ធិបឌិន្ទ**

- ឆ្នាំ២០០១ បានទទួលព្រះរាជក្រឹត្យ នស/រកត/១០០១/៣៩៩ ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០១ បានទទួលគ្រឿងឥស្សរិយយស

**ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ**

- ឆ្នាំ២០០៧ បានទទួលព្រះរាជក្រឹត្យនស/រកត/០៤០៧/១៤៨ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៧ បានទទួលគ្រឿងឥស្សរិយ-យស **មុនីសារាភ័ណ្ឌថ្នាក់ មហាសេរីវឌ្ឍន៍**
- ឆ្នាំ២០០៧ បានទទួលព្រះរាជក្រឹត្យ នស/រកត/០៧០៧/៣១១ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៧ ទទួលបាននូវគ្រឿងឥស្សរិយសយព្រះរាជាណាចក្រកម្ពុជា ថ្នាក់មាហាសេរីវឌ្ឍន៍។












ពីធីថ្វាយព្រះគោរមងារសម្តេចព្រះឧត្តមបញ្ញា **ដួង ផង់ នន្ទិយោ**
ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៣



# ៨- សម្តេចព្រះឧត្តមវង្សា មួង រ៉ា ព្រះចៅអធិការវត្តមុនីប្រសិទ្ធីវង្ស និង ជា លេខាធិការថេរសភានៃព្រះពុទ្ធសាសនា នៃព្រះរាជាណាចក្រកម្ពុជា



## ១-ព័ត៌មានផ្ទាល់ខ្លួន

-គោត្តនាម និងនាម ៖ **មួង រ៉ា** ជាអក្សរឡាតាំង MOUNG RA
ជនជាតិខ្មែរ សញ្ជាតិខ្មែរ
-ឆ្នាំកំណើត.ខែ.ថ្ងៃ ៖ ២៩ មករា ១៩៦០
-ទីកន្លែងកំណើត ៖ ភូមិឡកំបោរ ឃុំព្រែកញ្ចៅ ស្រុកពញាឮ
ខេត្តកណ្តាល
-អាសយដ្ឋានបច្ចុប្បន្ន ៖ វត្តមុនីប្រសិទ្ធីវង្ស សង្កាត់ព្រែកញ្ចៅ
ខណ្ឌសែនសុខ រាជធានីភ្នំពេញ
-ឪពុកឈ្មោះ ៖ **មួង ជួ** ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរកសិករ
(ឆ្នាំ ១៩៧៨ ស្លាប់)
-ម្តាយឈ្មោះ ៖ **ហែម ខ្នៃ** ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរមេផ្ទះ

(ចាស់ជរា) នៅភូមិឡកំបោរ សង្កាត់ស្វាយប៉ាក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

**២-អំពីការសិក្សា**

-១៩៧៩ ៖ សិក្សាបានត្រឹមថ្នាក់ទី៧ ចាស់

-១៩៩៤-១៩៩៦ ៖ សិក្សាចប់ធម្មវិន័យថ្នាក់ត្រី ថ្នាក់ទោ ថ្នាក់ឯក និងបាលីភិក្ខុបាតិមោក្ខ

-២០០៩ ៖ ទទួលសញ្ញាបត្របណ្ឌិតកិត្តិយស ផ្នែកទស្សនវិជ្ជាពុទ្ធសាសនា

**៣-អំពីការងារ**

-១៩៧៩-បច្ចុប្បន្ន ៖ សាងផ្នួសជាព្រះសង្ឃនៃព្រះពុទ្ធសាសនាគណៈមហានិកាយ

-១៩៩៤ ៖ ជាព្រះសមុហ៍គណស្រុកពញាឮ

-១៩៩៧ ៖ ជាព្រះចៅអធិការវត្តមុនីប្រសិទ្ធីវង្ស និងជាព្រះធម្មធរអនុគណស្រុកពញាឮ

-១៩៩៩ ៖ ទទួលគោរមងារជាព្រះសសនរង្សី ព្រះរាជាគណៈថ្នាក់កិត្តិយស ទីប្រឹក្សាសម្តេចព្រះសង្ឃរាជគណៈមហានិកាយ

-២០០១ ៖ ទទួលគោរមងារជាព្រះវិន័យសំវរ ព្រះរាជាគណៈថ្នាក់ចត្វា

-២០០១ ជានាយកប្រតិបត្តិអភិបាលកិច្ចសង្ឃទូទាំងប្រទេស

-២០០១-២០១០ ៖ ជាព្រះធម្មធរគណខេត្តកណ្តាល

-២០១០ ៖ ជាឧត្តមទីប្រឹក្សាផ្ទាល់ សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី **ទេព វង្ស** សម្តេចព្រះអគ្គមហាសង្ឃរាជ នៃព្រះរាជាណាចក្រកម្ពុជា

-២០០២-បច្ចុប្បន្ន ៖ ទទួលគោរមងាជា សម្តេចព្រះឧត្តមវង្សា

-២០០៦-បច្ចុប្បន្ន ៖ ជាលេខាធិការរងរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា

-២០០៦-បច្ចុប្បន្ន ៖ ជាព្រះអគ្គាធិការរងពុទ្ធិកសិក្សាជាតិ

**I. គ្រឿងឥស្សរិយយស**

មេដាយ ស្ថាបនាជាតិ ថ្នាក់លេខ

មេដាយ មុនីសារភណ្ឌ ថ្នាក់ធិបឌិន

មេដាយ ព្រះរាជាណាចក្រកម្ពុជា ថ្នាក់មហាសេនា

មេដាយ ព្រះរាជាណាចក្រកម្ពុជា ថ្នាក់មហាសេរីវឌ្ឍន៍











ពិធីថ្វាយព្រះគោរមងារសម្តេចព្រះឧត្តមវង្សា **ម្ហូង រ៉ា**
ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៣

## ៩-ព្រះរាជជីវប្រវត្តិសង្ខេប
## ព្រះមុនីកោសល ហ៊ុល សុវណ្ណ រាជាគណៈថ្នាក់ទោ
## ជាអនុគណខណ្ឌឬស្សីកែវ ជាសមាជិកថេរសភាសង្ឃ
## នៃព្រះរាជាណាចក្រកម្ពុជា
## និងព្រះចៅអធិការវត្ត ទួលសុវណ្ណារាម
## សង្កាត់ទួលសង្កែ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ



### ១-កុមារភាព

កុមារ **ហ៊ុល សុវណ្ណ** កើតនៅថ្ងៃទី០១ ខែមករា ឆ្នាំ១៩២៣ នៅភូមិជីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្ដាល។

- បិតាឈ្មោះ **ហ៊ុល ផាន**(ស្លាប់)
- មាតាឈ្មោះ **សេក យ៉ង់**(ស្លាប់)
- មានបងប្អូន ៦នាក់ ប្រុស៣នាក់ ស្រី៣នាក់
- ទី១ ៖ ឈ្មោះ **ហ៊ុល ហាឡ្យ** ភេទស្រី អាយុ ៦៨ឆ្នាំ (ស្លាប់)
- ទី២ ៖ ឈ្មោះ **ហ៊ុល ផេន** ភេទស្រី អាយុ ៦០ឆ្នាំ (ស្លាប់)
- ទី៣ ៖ ឈ្មោះ **ហ៊ុល ហុខ** ភេទប្រុស អាយុ ៥៩ឆ្នាំ (ស្លាប់)
- ទី៤ ៖ ឈ្មោះ **ហ៊ុល សុវណ្ណ** ភេទប្រុស គឺ រូបអត្មាភាព



- ទី៥ ៖ ឈ្មោះ **ហ៊ុល សាន់** ភេទស្រី អាយុ ៥០ឆ្នាំ (ស្លាប់)
- ទី៦ ៖ ឈ្មោះ **ហ៊ុល មុនីស៊ីផាន** ភេទប្រុស អាយុ ៤៨ឆ្នាំ ស្លាប់ក្នុងរបប ប៉ុលពត ។

កុមារ **ហ៊ុល សុវណ្ណ** ជាបុត្រទី៤។ (ឆ្នាំ១៩២៩) អាយុបាន ៦ឆ្នាំ មាតាបិតានាំឲ្យទៅសិក្សានៅសាលាបឋមសិក្សាជីឥដ្ឋ ហើយបានប្រឡងជាប់វិញ្ញាបនបត្របារាំងខ្មែរ (Certificat d'Etude Primaire Complementaire) ក្នុងឆ្នាំ១៩៣៨ រួចប្រឡងចូលរៀននៅវិទ្យាល័យដេកាដក្រុងភ្នំពេញ។

ឆ្នាំ១៩៤២ អាយុ១៩ឆ្នាំ ជីតាបង្កើតរបស់ខ្លួនបានទទួលអនិច្ចកម្ម មាតាបិតា ក៏បង្ខំឲ្យបួសសងគុណ។ កុមារ **ហ៊ុល សុវណ្ណ** ក៏ផ្អាកការសិក្សាហើយចូលមកបួសជាសាមណេរដើម្បីសងគុណជីតា។ បន្ទាប់ពីឈាបនកិច្ចសពជីតារួចរាល់ហើយក៏និមន្តមកគង់នៅកុដិលេខ ១១ វត្តសំពៅមាស។ ទោះបីមានមិត្តភក្តិបបួលឲ្យសឹកធ្វើការរដ្ឋជាមួយគេយ៉ាងណាក៏ដោយ ក៏សាមណេរមិនព្រមតាមមិត្តភក្តិសោះឡើយ ហើយព្យាយាមសិក្សារៀនធម៌អាថ៌វិន័យសិក្ខា ដរាបបានប្រឡងជាប់វិញ្ញាបនបត្រពុទ្ធិកបឋមសិក្សា (ភាសាបាលីរង) និងវិញ្ញាបនបត្រធម្មវិន័យគ្រប់កម្រិតទៀតផង។លុះជន្មាយុគម្រប់២០ចូល២១ឆ្នាំសាមណេរ **ហ៊ុល សុវណ្ណ** ក៏បានឧបសម្បទាជាភិក្ខុ ភាវៈក្នុងពទ្ធសីមាវត្តសំពៅមាសក្រុងភ្នំពេញដែលមានព្រះគ្រូសម្មាធិធម្មព្រះនាម **ស្វាយ អឹម** ចៅអធិការវត្តជាព្រះឧបជ្ឈាយ៍ ព្រះគ្រូ **ជ័យ ម៉ៃ** គ្រូ សូត្រស្ដាំ និងគ្រូ **ទី គុជ** គ្រូសូត្រឆ្វេងជាឧបសម្បទាចារ្យ។

ព្រះថេរៈចាស់ៗ ក្នុងកុដិលេខ១១ បានចាកសិក្ខាបទខ្លះ ខ្លះទៀតនិមន្តត្រឡប់ទៅស្រុកកំណើតវិញ ព្រះគ្រូ **ស្វាយ អឹម** ជាចៅអធិការវត្តបានចាត់តាំងភិក្ខុ **ហ៊ុល សុវណ្ណ** ឲ្យធ្វើមេកុដិនេះតទៅ។ ដោយកុដិលេខ១១នេះ ធ្វើអំពីឈើជាយូរឆ្នាំណាស់មកហើយ មានសភាពទ្រុឌទ្រោមថមថយ ព្រមទាំងមានទឹកដក់នៅខាងក្រោមកុដិខ្ទប ប្រាំងខ្ទបវស្សាផង ភិក្ខុ **ហ៊ុល សុវណ្ណ** បានរុះរើកុដិចាស់ចេញ។

**២-របបប៉ុលពត**

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ អង្គការរបស់ខ្មែរក្រហមបានជម្លៀសប្រជាជនទាំងបុព្វជិត ទាំងគ្រហស្ថ ទាំងមន្ត្រីរាជការ ទាំងកម្មករឲ្យចាកចេញពីទីក្រុងភ្នំពេញទាំងអស់គ្មានសល់នរណាម្នាក់ឡើយ។

ភិក្ខុ **ហ៊ុល សុវណ្ណ** ក៏ត្រូវពួកប៉ុលពត បង្ខំឲ្យចាកចេញ ព្រមទាំងបន្សឹក និងបង្ខំឲ្យធ្វើការងារជាទម្ងន់នៅភូមិរពាងវែង ឃុំរពាងវែង ស្រុកកំពង់ត្រាច ខេត្តកំពត ដូចប្រជាពលរដ្ឋដទៃឯទៀតដែរ។ ពិតមែនតែខ្មែរក្រហម បានផ្សឹកពីសង្ឃ ប៉ុន្តែ បណ្ឌិត **ហ៊ុល សុវណ្ណ** នៅតែរក្សាឧបោសថសីលនិងមិនទទួលទានបាយល្ងាច មិនព្រមយកគ្រួសារ បើទោះបីពួក ប៉ុល ពត បង្ខិតបង្ខំ ធ្វើទុក្ខបុកម្នេញយ៉ាងណាក៏ដោយ។

**៣-អំពីការសាងផ្នួស**

ក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលមានសម្តេច **ជា ស៊ីម** សម្តេច **ហេង សំរិន** សម្តេច **ហ៊ុន សែន** ហើយនិងឥស្សរជនខ្មែរអ្នកស្នេហាជាតិ បានវាយរំដោះប្រជាជនខ្មែរឲ្យរួចផុតពីរបបប្រល័យពូជសាសន៍ ប៉ុល ពត ហើយខិតខំ



ប្រឹងប្រែងស្តារឡើងវិញពីបាតដៃទទេនូវគ្រប់ហេដ្ឋារចនាសម្ព័ន្ធជាតិមានវិស័យព្រះពុទ្ធសាសនាជាដើមឲ្យរស់រានមានជីវិតឡើងវិញ។

បណ្ឌិត **ហ៊ុល សុវណ្ណ** ក៏បានរួចផុតពីរណ្តៅមរណៈដោយសារតែគុណបុណ្យរបស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា។ ដោយមានឧបនិស្ស័យនឹងព្រះពុទ្ធសាសនា បណ្ឌិត **ហ៊ុល សុវណ្ណ** មិនព្រងើយកន្តើយក៏សម្រេចចិត្តចូលកាន់ព្រះផ្នួសម្តងទៀតក្នុងឆ្នាំ១៩៨១ នៅពទ្ធសីមាវត្តឧណ្ណាលោម ដែលមានសម្តេច **ទេព វង្ស** អគ្គមហាសង្ឃាធិបតី ជាព្រះឧបជ្ឈាយ៍រាជគណៈមហានិកាយនៃព្រះរាជាណាចក្រកម្ពុជាជាព្រះឧបជ្ឈាយ៍ ព្រះសពសម្តេចមង្គលទេពាចារ្យ **អ៊ុំ ស៊ុំ** និងព្រះតេជគុណ **អ៊ិត ស៊ុំ** ជាឧបសម្បទាចារ្យ។ បួសពេញសិទ្ធិជាភិក្ខុភាវៈក្នុងព្រះពុទ្ធសាសនា ហើយបានគង់នៅវត្តលង្កាកុសុមារាម ក្រុងភ្នំពេញ ការបួសលើកនេះបានឯកឧត្តម **ចាន់ វ៉ែន** ជួយធ្វើអន្តរាគមន៍។

**៤-អំពីព្រះសមណស័ក្តិ**

- ថ្ងៃទី១៩ ទទួលឋានានុក្រមជា ព្រះធម្មចរិយា ១៩៩៤/០៦/តួនាទីជាព្រះចៅអធិការវត្តទួលសុវណ្ណារាម និងជាទីប្រឹក្សាសម្តេចព្រះសង្ឃរាជ **ទេព វង្ស**។
- ថ្ងៃទី០៨/០៨/១៩៩៥ ទទួលឋានានុក្រមជាព្រះមុនីកោសលរាជាគណៈថ្នាក់ទោល ជាអនុគណខណ្ឌឫស្សីកែវ។
- ថ្ងៃទី២៥/០៧/១៩៩៥ជាសមាជិកនៃគណៈកម្មាធិការកណ្តាលនៃមជ្ឈមណ្ឌលពុទ្ធិកសង្គ្រោះ។
- ថ្ងៃទី០៩/០២/២០០៤ ទីប្រឹក្សាអមគណៈកម្មាធិការនាយក ព.ស.ក អាណត្តិទី២ ។ សមាជិករណសិរ្សសាមគ្គីអភិវឌ្ឍន៍

មាតុភូមិកម្ពុជា អនុសាខាកិត្តិយសកាកបាទក្រហមខណ្ឌឫស្សី
កែវ សមាជិកថេរសភាសង្ឃនៃព្រះរាជាណាចក្រកម្ពុជា។

- មេដាយស្ថាបនាជាតិមាស១
- មេដាយស្ថាបនាជាតិសំរឹទ្ធិ១

## ៥-អំពីទស្សនកិច្ចក្រៅប្រទេសផ្លូវរដ្ឋ និងឯកជន

- ឆ្នាំ១៩៨៥ ទៅប្រទេសវៀតណាម (ផ្លូវរដ្ឋ)
- ឆ្នាំ១៩៨៥ ទៅប្រទេសអូស្ត្រាលី (ឯកជន)
- ឆ្នាំ១៩៩៣ ទៅប្រទេសអូស្ត្រាលី (ឯកជន)
- ឆ្នាំ១៩៩៣ ទៅប្រទេសអូស្ត្រាលី (ឯកជន)
- ឆ្នាំ១៩៩៨ទៅប្រទេសជប៉ុន(ប្រជុំព្រះពុទ្ធសាសនាពិភពលោក)
- ឆ្នាំ១៩៩៨ ទៅប្រទេសភូមា (តំណាងសម្ដេច ទេព វង្ស)

## ៦-ស្នាព្រះហស្ត

- ឧបោសថកថាសង្ខេប សម្បរាយិកត្ថប្រយោជន៍
- ទិដ្ឋធម្មិកត្ថប្រយោជន៍ បរមត្ថប្រយោជន៍ និងសកម្មភាពមនុស្ស
  ធម៌ជាច្រើនមានសម្ភារៈ ថវិកាជាដើម។











ពិធីថ្វាយព្រះគោរមងារព្រះមុនីកោសល **ហ៊ុល សុវណ្ណ**
ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៣



# សុន្ទរកថា
# ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត គាត ឈន់
# តំណាងជយលាភីដែលបានទទួលគោរម្យងារ
# និងសញ្ញាបត្រកិត្តិបណ្ឌិតនៃរាជបណ្ឌិត្យសភាកម្ពុជា

***សូមគោរពសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់*** !

ថ្ងៃនេះ ខ្ញុំមានកិត្តិយសនិងបុព្វសិទ្ធិគ្មានពីរដោយខ្ញុំបានទទួលនូវព្រះរាជសង្ឃដីកាដ៏ខ្ពង់ខ្ពស់ឱ្យខ្ញុំតាងព្រះបរមរាជនាម និងបរមនាម

.សម្តេចព្រះមហាសង្ឃរាជាធិបតី **ទេព វង្ស** សម្តេចព្រះមហាសង្ឃរាជនៃគណៈមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា,

.សម្តេចព្រះអភិសេរីសុគន្ធាមហាសង្ឃរាជាធិបតី **បួរ គ្រី** សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា,

.សម្តេចព្រះមហាសុមេធាធិបតី **នន្ទ ង៉ែត** សម្តេចព្រះសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា,

.សម្តេចព្រះធម្មលិខិត **លាស់ ឡាយ** សម្តេចព្រះសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា,

.សម្តេចព្រះពោធិវង្ស **អ៊ំ លឹមហេង** សម្តេចព្រះសង្ឃ នាយករងទី២ នៃព្រះរាជាណាចក្រកម្ពុជា,

.សម្តេចព្រះវនរ័ត **ឈាយ ច្រឹក** សម្តេចព្រះសង្ឃ នាយករងទី៣ នៃព្រះរាជាណាចក្រកម្ពុជា,

.សម្តេចព្រះឧត្តមបញ្ញា **ជួន ផង់** សមាជិកថេរសភា ព្រះពុទ្ធសាសនានៃព្រះរាជាណាចក្រ កម្ពុជា,

.សម្តេចឧត្តមវង្សា **មួង រ៉ា** លេខាថេរសភាព្រះពុទ្ធសាសនានៃព្រះរាជាណាចក្រកម្ពុជា,

.ព្រះមុនីកោសល **ហ៊ុល សុវណ្ណ** សមាជិកថេរសភា ព្រះពុទ្ធសាសនានៃព្រះរាជាណាចក្រកម្ពុជា

ដើម្បីសម្តែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅ ជាមួយនឹង គារវកិច្ចដ៏ខ្ពង់ខ្ពស់បំផុតចំពោះ **សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានឆ្លៀតពេលវេលាដ៏មមាញឹក និង ដ៏កម្របំផុត ដើម្បីអញ្ជើញ ចូលរួមជាអធិបតី និងផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់បំផុតក្នុងពិធីថ្វាយប្រគេន និង ប្រគល់គោរមងារ “**កិត្តិឧទ្ទេសបណ្ឌិត**” គោរមងារ “**កិត្តិសេដ្ឋាបណ្ឌិត**” និង សញ្ញាបត្រ “**កិត្តិបណ្ឌិត**” នាឱកាសដ៏ វិសេសវិសាលនេះ នៅចំពោះមុខលោកជំទាវបណ្ឌិតសភាចារ្យ **ខ្លូត ធីតា** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា និងឯកឧត្តម លោកជំទាវ បណ្ឌិតសភាចារ្យ បណ្ឌិតសាស្ត្រាចារ្យព្រមទាំងចំពោះមុខលោកជំទាវ ឯកឧត្តម សមាជិកសមាជិកានៃព្រឹទ្ធសភា រដ្ឋសភា និង រាជរដ្ឋាភិបាល ឯកឧត្តម លោក លោកស្រីនិងអង្គពិធីទាំងមូល ។

ក្នុងព្រះបរមរាជនាម និងបរមនាមសម្តេចព្រះជយលាភីទាំង ៩ អង្គ និង ក្នុងនាមទូលព្រះបង្គំខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវកតវេទិតា ដោយក្តីរំភើបបំផុតចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានសម្រេចទូលថ្វាយ **ព្រះករុណាព្រះបាទ សម្តេចព្រះ បរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** សូមព្រះអង្គព្រះរាជប្រទានថ្វាយ សម្តេចព្រះមហាសង្ឃរាជាធិបតី **នន្ទ ង៉ែត** (see note) សម្តេចព្រះអភិសេរីសុគន្ធា មហាសង្ឃរាជាធិបតី **បួរ គ្រី** និង សម្តេចព្រះមហាសុមេធាធិបតី **នន្ទ ង៉ែត** នូវគោរមងារ “**កិត្តិឧទ្ទេសបណ្ឌិត**”, និង រូបខ្ញុំផ្ទាល់នូវគោរមងារ “**កិត្តិសេដ្ឋាបណ្ឌិត**” ព្រមទាំងការសម្រេចដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោនាយករដ្ឋមន្ត្រី ក្នុងការថ្វាយសម្តេចព្រះធម្មលិខិត **លាស់ ឡាយ** សម្តេចព្រះពោធិវង្ស **អ៊ំ លឹម ហេង**, សម្តេចព្រះវនរ័ត **ឈាយ ច្រឹក**, សម្តេចព្រះឧត្តមបញ្ញា **ជួន ផង់**, សម្តេចឧត្តមវង្សា **មួង រ៉ា** និង ព្រះមុនីកោសល **ហ៊ុល សុវណ្ណ** នូវសញ្ញាបត្រ “**កិត្តិបណ្ឌិត**” ។ គោរមងារ និងសញ្ញាបត្រកិត្តិយស ដ៏ឧត្តុង្គឧត្តមទាំងនេះ មានលក្ខណៈជាស្ថាប័ន និងមានឋានានុក្រម ចេញពីស្ថាប័ន **រាជបណ្ឌិត្យសភាកម្ពុជា** ដែលមានលក្ខណៈវិទ្យាសាស្ត្រយ៉ាងពិតប្រាកដ។

ជាមួយគ្នានេះដែរ ក្នុងព្រះបរមរាជនាម និង បរមនាមសម្តេច ដែលជាព្រះជយលាភីទាំង ៩ អង្គ និង ក្នុងនាមទូលព្រះបង្គំខ្ញុំ ខ្ញុំសូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **រាជបណ្ឌិត្យសភាកម្ពុជា** ជាពិសេស ក្រុមសមាជិកពេញសិទ្ធិនៃ **រាជបណ្ឌិត្យសភាកម្ពុជា** ដែលបានសម្រេចលើកសំណើជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី និង ព្រះមហាក្សត្រ** ដើម្បីថ្វាយ និងផ្តល់នូវគោរមងារ «**កិត្តិឧទ្ទេសបណ្ឌិត**», គោរមងារ «**កិត្តិសេដ្ឋាបណ្ឌិត**» និង សញ្ញាបត្រ «**កិត្តិបណ្ឌិត**» ក្នុងក្របខ័ណ្ឌរាជបណ្ឌិត្យសភាកម្ពុជា។

***អង្គពិធីទាំងមូល ជាទីគោរពសក្ការៈ !***

បន្ទាប់ពីឆ្នាំ ១៩៨៥ រហូតមកដល់បច្ចុប្បន្ននេះ ដោយមានការដឹកនាំដ៏វៃឈ្លាសប្រកបដោយគតិបណ្ឌិត ហើយពោរពេញដោយបញ្ញាញាណដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានផ្លាស់ប្តូរពីបរិមាណទៅគុណភាព ពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត ជាបន្តបន្ទាប់ ពិសេសក្នុងពេលបច្ចុប្បន្ននេះ ព្រះរាជាណាចក្រកម្ពុជា កំពុងផ្លាស់ប្តូរពីចំណាត់ថ្នាក់នៃប្រទេសមានចំណូលទាប (Low Income Status- LIS) ឆ្លងកាត់ទៅចំណាត់ថ្នាក់ជាប្រទេសមានចំណូលមធ្យម (Middle-Income Status-MIS) ។ ឈរនៅលើមូលដ្ឋាននេះ និង តាមចលនាការនៃការអភិវឌ្ឍ និង កំណែទម្រង់លើគ្រប់វិស័យ និង កាន់តែស៊ីជម្រៅកាន់តែទូលំទូលាយ និងកាន់តែគ្រប់ជ្រុងជ្រោយ ដែល **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដឹកនាំដោយផ្ទាល់ ទូលព្រះ



បង្គំខ្ញុំខ្ញុំយល់ថា ក្នុងឆ្នាំ ២០៣០ ព្រះរាជាណាចក្រកម្ពុជា នឹងឈានដល់ចំណាត់ថ្នាក់ប្រទេសមានចំណូលមធ្យមខ្ពស់ (High Middle-Income Status- HMIS)។ ឱ្យតែព្រះរាជាណាចក្រកម្ពុជាបន្តអភិវឌ្ឍ និងធ្វើកំណែទម្រង់ហើយប្រកាន់ខ្ជាប់នូវទិសស្លោកដ៏ថ្លៃថ្លារបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដែលមានប្រសាសន៍ថា *«កំណែទម្រង់គឺជាការស្លាប់រស់របស់រាជរដ្ឋាភិបាលកម្ពុជា ហើយត្រូវចាត់ទុកថា កំណែទម្រង់គឺជាការងារប្រចាំថ្ងៃរបស់យើង ដើម្បីបន្តកែលម្អពង្រឹងបង្កើន និងពង្រីកសមត្ថភាព លទ្ធភាព និងសក្តានុពលភាព របស់យើង ក្នុងគោលដៅរក្សាឱ្យបានជាមួយនឹងការវិវត្តនៃសង្គម-សេដ្ឋកិច្ច និងនយោបាយក្នុងប្រទេសក្នុងតំបន់ និងពិភពលោក»* នោះនៅឆ្នាំ២០៥០ កម្ពុជានឹងមិនធ្លាក់ក្នុងអន្ទាក់នៃប្រទេសមានចំណូលមធ្យម (Middle Income Countries Trap) ដូចបណ្តាប្រទេសមួយចំនួន ដែលកំពុងជាប់ និងរើខ្លួនពីអន្ទាក់នេះពុំទាន់រួចហើយកម្ពុជា ប្រាកដជា នឹងប្រែក្លាយទៅជាប្រទេសអភិវឌ្ឍន៍ (Developed Countries) មួយក្នុងចំណោមប្រទេសអភិវឌ្ឍន៍ដទៃទៀតជាក់ជាពុំខាន។

ជាមួយគ្នានេះ យើងទាំងអស់គ្នាពិតជាមិនអាចប្រកែកបានទេថា សមិទ្ធផលទាំងអស់ រួមទាំងពិធីថ្ងៃនេះ ដែលកម្ពុជាសម្រេចបានក៏ដោយសារយើងមាន **ថ្ងៃមហាជ័យជំនះ ៧ មករា** ជាថ្ងៃប្រវត្តិសាស្ត្រដែលបានរំដោះប្រទេសជាតិ ឱ្យរួចផុតពីរបបប្រល័យពូជ-សាសន៍0hui ដ៏ព្រៃផ្សៃ ដែលពុំធ្លាប់កើតមាននៅលើមាតុភូមិអង្គរដ៏បវររបស់យើង ។ ហើយ **មហាជ័យជំនះ** នេះ គឺជាមូលដ្ឋានដំបូងនៃការនាំមកជូនកម្ពុជាឈានដល់ចំណុចឥតថយក្រោយនៅឆ្នាំ ១៩៨៩

ដែលជាបុរេលក្ខណៈ នាំឱ្យកម្ពុជាឈានទៅសម្រេចបាននូវកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស នាថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ១៩៩១ ដែល **ព្រះករុណា ព្រះមហាវីរក្សត្រ នរោត្តម សីហនុ**និង**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាតួអង្គសំខាន់ជាច់ណាត់ ។ កិច្ចព្រមព្រៀងនេះ បានផ្តល់កាលានុវត្តភាពសម្រាប់ឆ្លងទៅរកការផ្សះផ្សាជាតិ សន្តិភាព លទ្ធិប្រជាធិបតេយ្យ ការកសាង និង ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ។

ប៉ុន្តែ ហើយរឹតតែគ្មានការសង្ស័យទៀតថា សមិទ្ធផលធំៗដែលយើងសម្រេចបាននេះ គឺកើតចេញពីផ្លែផ្កាដ៏ស្រស់បំព្រង នៃការអនុវត្តគោលនយោបាយ **ឈ្នះ-ឈ្នះ** របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ហើយជោគជ័យនៃបូជនីយកិច្ចដ៏ពិសិដ្ឋរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ក្នុងការអនុវត្តគោលនយោបាយ **ឈ្នះ-ឈ្នះ** បាននាំមកចាប់តាំងពីចុងឆ្នាំ ១៩៩៨ ឱ្យកម្ពុជាជាស្ថាពរនូវសន្តិភាពពេញលេញ ឯកភាពទឹកដី ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សង្គម ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងស្ថិរភាពហិរញ្ញវត្ថុ ព្រមទាំងរក្សា បានទាំងស្រុងនូវអធិបតេយ្យ និងបូរណភាពទឹកដី ដូចអ្វីៗដែលយើង មានសព្វថ្ងៃនេះ។

ទូលព្រះបង្គំខ្ញុំ និង ភរិយា **ឡាយ នារី** ជាមួយនឹងសហការីមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុមានកិត្តិយស និង សេចក្តីរីករាយដោយបានរួមគ្នាកសាង ៊ស្រះម្លិះ៍ នៅឆ្នាំ ២០១១ ស្ថិតនៅឃុំទឹកក្រហម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ និង បានកសាងសិលាចារឹកហើយបានឧទ្ទិសនូវសមិទ្ធផលនៃស្រះម្លិះនេះ ចំពោះស្នាដៃអមតៈរបស់



**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលបានដាក់ចេញនូវនយោបាយ **ឈ្នះ-ឈ្នះ** ហើយសម្រេចបាននូវសុខសន្តិភាព ពេញលេញទូទាំងប្រទេស ឯកភាពទឹកដី ឯកភាពជាតិ ដែលញ៉ាំងឱ្យ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដឹកនាំប្រទេសជាតិទាំងមូលរក្សាបានទាំងស្រុងនូវអធិបតេយ្យ និង បូរណភាពទឹកដី ។ នៅឆ្នាំ ២០០០ ទូល ព្រះបង្គំយើងខ្ញុំបានកសាងនូវសិលាចារឹក នៅជើងភ្នំសុពណ៌កាលី នៅ ខេត្តក្រចេះ ឧទ្ទិសដល់សន្តិភាព និងឯកភាពនៃមាតុប្រទេស ដែល **សម្តេចតេជោនាយករដ្ឋមន្ត្រី** សម្រេចបាននៅចុងឆ្នាំ ១៩៩៨ ដោយភ្ជាប់អារម្មណ៍ទៅនឹងស្មារតីនៃសិលាចារឹក **ភ្នំសុពណ៌កាលី** Ka **84** ដែលបញ្ជាក់នូវស្នាព្រះហស្តបង្រួបបង្រួមប្រទេសនៃព្រះបាទ **មហេន្ទ្រវរ្ម័ន** និង ព្រះបាទ **ភវវរ្ម័នទី ១** ក្នុងចន្លោះឆ្នាំ ៥៥០ និង ឆ្នាំ៦០០ ហើយសូមឱ្យស្មារតីនៃសិលាចារឹកចេះតែបន្តរំជួលអារម្មណ៍របស់ជនជាតិកម្ពុជាគ្រប់រូបជារៀងរហូត។

***អគ្គពិធីនាំទម្លុល ជាទីគោរពសក្ការៈ !***

ទូលព្រះបង្គំជាខ្ញុំជឿជាក់ថា **សម្តេចព្រះមហាសង្ឃរាជ**, **សម្តេចព្រះសង្ឃនាយក**, **សម្តេចព្រះសង្ឃនាយករង**, **សម្តេច** និង **មន្ត្រីសង្ឃជាន់ខ្ពស់** ដែលជាព្រះជ័យលាភី ពិតជាឯកភាពជាមួយទូលព្រះបង្គំខ្ញុំថា ការផ្តល់គោរមងារនេះ កត្តាសំខាន់ គឺផ្អែកលើ3n8ăäរបស់ព្រះអង្គទាំង ៩ អង្គ និង លើ3n8ăäរបស់ទូលព្រះបង្គំខ្ញុំក៏ពិតមែន ប៉ុន្តែ កត្តាសត្យានុម័តដើរតួរឹតតែសំខាន់ជាង

នេះទៅទៀត ពីព្រោះ ការបំពេញភារកិច្ចដែលបានទទួលលទ្ធផលប្រកបដោយផ្លែផ្កាជូនប្រទេសជាតិក្នុងរយៈពេលកន្លងមក គឺបានមកដោយសារគុណបំណាច់ដ៏ថ្លៃថ្លានៃការដឹកនាំដ៏ឈ្លាសវៃ ប្រកបដោយគតិបណ្ឌិត និង ពោរពេញដោយបញ្ញាញាណដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្រោមព្រះរាជឱវាទដ៏ឧត្តុង្គឧត្តមរបស់ **ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ** និង **សម្តេចព្រះរាជអគ្គមហេសី នរោត្តម មុនីនាថ សីហនុ** ហើយបន្ទាប់មករបស់ **ព្រះករុណា ព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** និង តាមពុទ្ធិដែលទទួលបានពី **សាលាមនសិការជាតិ ព្រះនរោត្តម សីហនុ** ។

ដោយឡែក សម្រាប់ទូលព្រះបង្គំខ្ញុំក្នុងរយៈពេល ២០ ឆ្នាំ កន្លងមកនេះ ការបំពេញភារកិច្ច ដែលបានទទួលលទ្ធផលប្រកបដោយផ្លែផ្កាជូនប្រទេសជាតិ គឺបានមកដោយសារការផ្តល់ការគាំទ្រ និង ការផ្តល់ការទុកចិត្តពីសំណាក់គណបក្សប្រជាជនកម្ពុជា ជាពិសេស ការចង្អុលបង្ហាញដោយផ្ទាល់ និង ជាប្រចាំដល់រូបទូលព្រះបង្គំខ្ញុំពីសំណាក់ **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** ដែលក្នុងនាមខ្ញុំជាសេនាធិការរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដែលជាអគ្គមេបញ្ជាការតែមួយក្នុងការគ្រប់គ្រងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ដែលតែងតែផ្តល់ និង លើកឡើងនូវគោលនយោបាយកំណត់នូវយុទ្ធសាស្ត្រនិងផែនការសកម្មភាព ព្រមទាំងជំរុញការដាក់ចេញឱ្យ



អនុវត្តជាបន្តបន្ទាប់នូវគោលនយោបាយ និង យុទ្ធសាស្ត្រទាំងនោះ ។ ប្រាកដណាស់ថា ប្រសិនបើគ្មានការដឹកនាំដ៏វៃឈ្លៀសប្រកបដោយគតិបណ្ឌិតនិងញៀរពេញដោយបញ្ញាញាណដ៏ឧត្តុង្គឧត្តមរបស់ **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** ទេនោះ ហើយបើសិនជាគ្មានបរិការណ៍សន្តិភាពនិងស្ថិរភាពនយោបាយដែលបានប្រសូត្រចេញពីនយោបាយ **ឈ្នះ-ឈ្នះ** របស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ទេនោះ ខ្ញុំក៏មិនអាចបំពេញលក្ខខណ្ឌវិនិច្ឆ័យ សម្រាប់ការប្រទានគោរមងារពី **ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា** បានឡើយ។ទូលព្រះបង្គំខ្ញុំ ខ្ញុំជឿជាក់ថា **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** នឹងបន្តដឹកនាំរាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភាខាងមុខនេះ និងរាជរដ្ឋាភិបាលនីតិកាលបន្តបន្ទាប់ទៀត។

ក្នុងស្មារតីនេះ ទូលព្រះបង្គំជាខ្ញុំសូមព្រះរាជានុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **សម្តេចព្រះមហាសង្ឃរាជ**, **សម្តេចព្រះសង្ឃនាយក**, **សម្តេចព្រះសង្ឃនាយករង**, **សម្តេច** និង **មន្ត្រីសង្ឃជាន់ខ្ពស់** និងសូមការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី**សម្តេចតេជោនាយក រដ្ឋមន្ត្រី** ដើម្បីឧទ្ទិសនូវ មហាកិត្តិយសនៃការទទួលបាននូវគោរមងារ និងសញ្ញាបត្រកិត្តិយសនេះ ជូនដល់វិញ្ញាណក្ខន្ធបុព្វបុរសខ្មែរទាំងអស់ដែល បានបូជាជីវិតដើម្បីជាតិមាតុភូមិនាពេលកន្លងទៅ។ ទូលព្រះបង្គំជាខ្ញុំក៏សូមព្រះរាជានុញ្ញាត និងការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ បែករំលែកនូវផ្លែផ្កាដែលគួរជាទីមោទនៈនេះ ជូនដល់ភរិយា **ឡាយ នារី** ជាទី

ស្រឡាញ់ និងក្រុមគ្រួសារ ដែលជានិច្ចកាលតែងតែលើកទឹកចិត្ត និងគាំទ្រដល់រូបខ្ញុំគ្រប់កាលៈទេសៈ ហើយពិសេសជូនដល់គណបក្សប្រជាជនកម្ពុជា ចំពោះសហសេវិកក្នុងជួរនៃរាជរដ្ឋាភិបាល និង *ថ្នាក់ដឹកនាំ* មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រុមប្រឹក្សាអភិវឌ្ឍន៍ កម្ពុជា ដែលតែងតែចូលរួមបំពេញការងារបម្រើជាតិ មាតុភូមិយ៉ាង សកម្ម ព្រមទាំងតួអង្គពាក់ព័ន្ធទាំងអស់ នៃវិស័យឯកជន ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិលនិងមន្ត្រីរាជការ ដែលស្ថិតក្នុងចលនាការនៃប្រព័ន្ធតួអង្គ (Dynamique des systèmes d’acteurs) ដែលបានជ្រោមជ្រែង ដល់ កាតព្វកិច្ចការងាររបស់ទូលព្រះបង្គំជាខ្ញុំ ដើម្បីទូលព្រះបង្គំខ្ញុំខ្ញុំទទួល ខុសត្រូវ និងមានគណនេយ្យភាពពេញលេញចំពោះប្រមុខរាជរដ្ឋា- ភិបាល និងស្ថាប័ននីតិប្បញ្ញត្តិ ។

ជាទីបញ្ចប់ ក្នុងព្រះបរមនាមសម្តេចដែលជាព្រះជយលាភីទាំង ៩ អង្គ និងក្នុងនាមទូលព្រះបង្គំខ្ញុំផ្ទាល់ក្នុងឱកាសដែលប្រជាជនកម្ពុជាទូទាំងប្រទេស ទើបនឹងបានចូលរួមអបអរសាទរពិធីបុណ្យ ចូលឆ្នាំប្រពៃណីជាតិ កន្លងទៅថ្មីៗនេះ និង ក្នុងឱកាសខួបកំណើតរបស់សម្តេចតេជោនាយករដ្ឋមន្ត្រីគម្រប់ ៦២ឈានចូល៦៣ ឆ្នាំក្នុងនាមទូលព្រះបង្គំខ្ញុំខ្ញុំសូមគោរពជូនពរ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា លោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** បុត្រា បុត្រី ចៅប្រុស ចៅស្រី និង ក្រុមគ្រួសារ សូមប្រកបដោយពុទ្ធពរទាំង ៤ ប្រការ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។ ទូលព្រះបង្គំខ្ញុំ ខ្ញុំសូមគោរពជូនពរស្ថាប័ន រាជបណ្ឌិត្យសភាកម្ពុជា សូមទទួល



បានជោគជ័យថ្មីៗថែមទៀត ក្នុងបុព្វហេតុចូលរួមចំណែកកសាងសង្គមកម្ពុជាឱ្យមានការអភិវឌ្ឍ មានប្រជាពលរដ្ឋប្រកបដោយចំណេះដឹងបច្ចេកទេសនិងវិទ្យាសាស្ត្រ មានវប្បធម៌ជ្រៅជ្រះ មានសីលធម៌សង្គមផ្ទួរផង់មានជីវភាពសម្បូរសប្បាយប្រកបដោយសុខសន្តិភាពសុភមង្គល និងសេចក្តីថ្លៃថ្នូរ ។

*សូមអរព្រះគុណ សូមអរគុណ !*

## គណៈកម្មការរៀបរៀងនិងចងក្រងឯកសារ

គណៈកម្មាធិការប្រតិបត្តិរាជបណ្ឌិត្យសភាកម្ពុជា

ដឹកនាំនិងកែសម្រួលដោយលោកជំទាវបណ្ឌិតសភាចារ្យ **ខ្លួត ធីតា**

**ថវិកាបោះពុម្ព**

ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **គាត ឈន់**

**អគ្គាធិរុទ្ធ**

ឯកឧត្តម **មន់ សម្បត្តិ**

**អត្ថបទខ្លឹមសារក្បាច់អាច**

ឯកឧត្តមបណ្ឌិត **នូ ច័ន្ទ សុភី**

**សម្របសម្រួលការងារទូទៅ**

ឯកឧត្តម **លី សុធីរត្ន**

**រោងពុម្ព**

ឯកឧត្តមបណ្ឌិត **ហ៊ាន សាហ៊ីប**

លោកស្រី **កែវ ខេមរា**

**រៀបរៀងនិងរចនាជាសៀវភៅ**

លោក **សូត្រ សំណាង**

កញ្ញា **ខ្លួត វល័ក្ខណ៍**



## សម្បុរសជនឧបត្ថមបោះពុម្ព

ជួសមុខ ថ្វាយព្រះអរិយសង្ឃទាំង ៩ អង្គ ក្រុមបណ្ឌិតសភាចារ្យនៃរាជបណ្ឌិត្យសភាកម្ពុជា មានសម្តេចអគ្គមហាសេនាបតីតេជោបណ្ឌិតសភាចារ្យ **ហ៊ុន សែន** ជាប្រធានកិត្តិយសក្រុមបណ្ឌិតសភាចារ្យ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ជាប្រធានក្រុមបណ្ឌិតសភាចារ្យនិងនាង ខ្ញុំជាអនុប្រធានអចិន្ត្រៃយ៍ នៃក្រុមបណ្ឌិតសភាចារ្យ និងជាទីប្រឹក្សាផ្ទាល់ សម្តេចអគ្គមហាសេនាបតីតេជោបណ្ឌិតសភាចារ្យ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ទទួលបន្ទុកការងារធម្មការ និងសាសនា ព្រមទាំងក្រុមបណ្ឌិតសភាចារ្យនៃរាជបណ្ឌិត្យសភាកម្ពុជា យើងខ្ញុំទាំងអស់គ្នាសូមថ្លែងអំណរគុណ ដល់ឯកឧត្តមកិត្តិ សេដ្ឋាបណ្ឌិត **គាត ឈន់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលោកជំទាវ **ឡាយ នារី** ចំពោះការផ្តល់ថវិកា បោះពុម្ពសៀវភៅ "អបអរសាទរពិធីថ្វាយ និងប្រគេនគោរមងារកិត្តិ ឧទ្ទេសបណ្ឌិត និងសញ្ញាបត្រកិត្តិបណ្ឌិតនៃរាជបណ្ឌិត្យសភាកម្ពុជា" ចំនួន៥.០០០ក្បាល ដែលជាឯកសារអបអរសាទរ ពិធីដ៏មានអត្ថន័យ ជាប្រវត្តិសាស្ត្រ និងប្រកបដោយលក្ខណៈវិទ្យាសាស្ត្រគ្រប់ពេលវេលា។

ខ្ញុំសូមប្រសិទ្ធពរជ័យបវរមហាប្រសើរជូនឯកឧត្តម និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារ សូមប្រកបតែនឹងសុខភាពល្អ អាយុយឺនយូរ ជោគជ័យរាល់ការងារសង្គមគ្រួសារ និងជាតិមាតុភូមិ ព្រមទាំងពុទ្ធពរទាំង ៥ ប្រការកុំបីឃ្លៀងឃ្លាតឡើយ។

រាជបណ្ឌិត្យសភាកម្ពុជាថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៣

**ហត្ថលេខា**

**តំណាងក្រុមបណ្ឌិតសភាចារ្យ**
**អនុប្រធានអចិន្ត្រៃយ៍**

( ក្របក្រោយ )

**ឧបត្ថម្ភបោះពុម្ពដោយ**

**ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត គាត ឈន់**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងលោកជំទាវ ឡាយ នារី**

**( បោះពុម្ពលើកទី២ ចំនួន ៥.000 ក្បាល )**

**រាជបណ្ឌិត្យសភាកម្ពុជា ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៣**